# វិជ្ជាព្រាំបីប្រការ

## VIJJA PRAMBEI PRAKAR

ភ្នំពេញ

ការផ្សាយរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

ព.ស.២៥៤៥ គ.ស.២០០១

www.elibraryofcambodia.org

# វិជ្ជាប្រាំបីប្រការ

ឧកញ៉ា **បុណ្ណចន្ទ្រ-មន្តល**
ប្រែនិងរៀបរៀង

ទាំងលោយតៅ លោក ខៅ មួនសើរ
ដល់ការសាលាខ្មែរ ដើម្បីទុកដាក់ក្នុង
elibrary of Cambodia
ឧសភា ២០១៥

ភ្នំពេញ
ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ
គ.ស. ២០០១

# VIJJA PRAMBEI PRAKAR

par

S.E. LUONG VICIPRAVADAKAR KIM LIENG

VATHANAPREYDA

TRADUIT EN CAMBODGIEN AVEC L'AUTORISATION DE L'AUTEUR

par

L' OKNHA BUNCHAN-MONGKHONN

Troizième Edition

PHNOM PENH

Published by Buddhist Institute

2001

www.elibrarycambodia.org

Printed for free distribution by
**The Corporate Body of the Buddha Educational Foundation**
11F., 55 Hang Chow South Road Sec 1, Taipei, Taiwan, R.O.C.
Tel: 886-2-23951198 , Fax: 886-2-23913415
Email: overseas@budaedu.org.tw
Website:http://www.budaedu.org.tw
**This book is strictly for free distribution, it is not for sale.**



www.elibraryofcambodia.org

# បញ្ជីរឿង


ទំព័រ

អារម្ភកថា . . . . . . . . . . . . . . . . . . . . . ក. ខ. គ. ឃ.

សេចក្ដីផ្ដើមរបស់អ្នករៀបរៀង . . . . . . . . . . . . . . ង. ច. ឆ. ជ.

សេចក្ដីផ្ដើមអំពីវិជ្ជា ៨ ប្រការ . . . . . . . . . . . . . . . . ១

សាខារបស់វិជ្ជា ៨ ប្រការ . . . . . . . . . . . . . . . . ១០

គោលការរបស់យោគី . . . . . . . . . . . . . . . . . ១៤

គោលការកសិណនឹងឈាន . . . . . . . . . . . . . . . ២១

វិធីតាំងកសិណ . . . . . . . . . . . . . . . . . . . ២៥

ឈាន . . . . . . . . . . . . . . . . . . . . . . . ៣៤

អធិប្បាយពីរូបជ្ឈាន . . . . . . . . . . . . . . . . . ៣៥

អធិប្បាយពីអរូបជ្ឈាន . . . . . . . . . . . . . . . . ៤០

វិជ្ជាប្រការទី ១ វិបស្សនាញាណ ៩ . . . . . . . . . . . . . ៤២

វិជ្ជាប្រការទី ២ មនោមយិទ្ធិ . . . . . . . . . . . . . . ៤៣

វិជ្ជាប្រការទី ៣ ឥទ្ធិវិធិ . . . . . . . . . . . . . . . . ៧៦

វិជ្ជាប្រការទី ៤ ទិព្វសោត . . . . . . . . . . . . . . . ៩២

វិជ្ជាប្រការទី ៥ ចេតោបរិយញ្ញាណ . . . . . . . . . . . . ១០៣

វិជ្ជាប្រការទី ៦ បុព្វេនិវាសានុស្សតិញ្ញាណ . . . . . . . . . ១១១

វិជ្ជាប្រការទី ៧ ទិព្វចក្ខុ . . . . . . . . . . . . . . . ១៣១

វិជ្ជាប្រការទី ៨ អាសវក្ខយញ្ញាណ . . . . . . . . . . . . . ១៥៩


www.elibraryofcambodia.org

# អារម្ភកថា

សៀវភៅវិជ្ជា ៨ ប្រការនេះ ដែលទើបកើតឡើង ដោយមានមួយថ្ងៃ ខ្ញុំបានទៅសិក្សាសួរធម៌លោកគ្រូព្រះឧត្តមមុនី អ៊ុំ-ស៊ូ អធិបតីនៃក្រុមជំនុំប្រែព្រះត្រៃបិដក អំពីរឿងវិបស្សនាធុរៈ លោកក៏បានពន្យល់ខ្ញុំរួចហើយលោកមានពុទ្ធដីកាថា សៀវភៅវិជ្ជា ៨ ប្រការ ដែលហ្នឹង បើត្រូវការផ្ដិតសៀវភៅបានតែងនោះ ជាសៀវភៅមានប្រយោជន៍ច្រើនក្នុងពួកវិបស្សនាធុរៈ បើបានប្រែមកជាខ្មែរ ក៏ជាការល្អ ទើបបានជាសៀវភៅជួយគាំទ្រវិជ្ជាសមាធិក្នុងផ្លូវវិបស្សនា ។ លុះខ្ញុំត្រឡប់មកផ្ទះវិញ បានពិនិត្យមើលសៀវភៅនោះទៅ ឃើញមានសេចក្ដីអធិប្បាយពន្យល់ពីវិធីធ្វើវិជ្ជា ៨ ប្រការឲ្យកើតមានឡើង ក្នុងសៀវភៅនោះមានចាំរឿងហេតុដែលកើតមានឡើងក្នុងប្រទេសឯទៀតៗ ហើយត្រូវគ្នានឹងវិជ្ជា ៨ ប្រការនេះ មកបញ្ជាក់ឲ្យឃើញពិតប្រាកដថែមទៀត ។ វិជ្ជា ៨ប្រការនេះជាសេចក្ដីប្រដៅដល់អ្នករៀនកម្មដ្ឋាន កុំឲ្យប្រព្រឹត្តអាក្រក់ដោយចិត្តទុច្ចរិត គឺកុំឲ្យអ្នកជាខ្លួនមានបុណ្យមានឫទ្ធិ ធ្វើឲ្យមនុស្សជឿទាំងនាំបំបះបំបោរឲ្យកើតចលាចល ដូចដែលធ្លាប់មានក្នុងប្រទេសយើងរឿយៗមកហើយនោះបានឡើយ ព្រោះវិជ្ជានេះសម្រាប់តែមនុស្សសុចរិតប្រព្រឹត្ត

ទៅតែផ្ទៃស្ងប់ ផ្ទៃព្រះទ័យឧត្តមទោះទៀបសម ៗ កាលបើយើងពិនិត្យឃើញរបៀបដែលតែងសៀវភៅជា ៨ ប្រការនេះ លុះតែមនុស្សប្រកបដោយព្យា-យាមណាស់ ហើយចេះបាលីនឹងភាសាឯទៀតច្រើន ទើបអាចមើលសៀវ-ភៅនឹងដំណើរតាមការសេតដែលមានក្នុងភាសានោះ ៗ ទើបតែងបាន ៗ ម្យ៉ាងទៀត ឯការប្រែភាសាក្នុងថ្ងៃសៀវភៅនេះ ខ្ញុំបានប្រែរៀបរៀងតាមច្បាប់ដើម តែបើត្រង់កន្លែងណាដែលមានសេចក្ដីសាវវែង ៗ នោះ ខ្ញុំមានកាត់ចេញខ្លះហើយសម្រួលសេចក្ដីឲ្យស្រួលស្ដាប់ទៅវិញ ។

លុះខ្ញុំបានពិនិត្យរួចហើយ ក៏ទៅពឹងលោកគ្រូព្រះឧត្តមមុនី ជាទីទទួលប្រែល្បងមើល ព្រោះក្នុងសៀវភៅនោះនឹងមានសេចក្ដីហាមឃាត់ថាមិនឲ្យប្រែជាភាសាអ្វី ៗ ក៏ទេដែរ ។ ខ្ញុំបានសូមឲ្យលោកជួយផ្ទៀងផ្ទាត់ផ្ទឹមសេចក្ដីប្រែព្រមទាំងបាលី លោកក៏ទទួលជួយហើយលោកបានឲ្យភិក្ខុសង្ឃជួយសរសេរជាថ្មី ថែមទាំងដាក់ឲ្យព្រះមហាប៉ែននឹងអ្នកអាចារ្យសេនជាគ្រូដំនុំព្រះត្រៃបិដកជួយផ្ទៀងផ្ទាត់ម្ដងទៀត រួចហើយខ្ញុំក៏បានជូនសៀវភៅនេះ ឲ្យជាប់ទៅជាសម្បត្តិរបស់ព្រះរាជបណ្ណា-ល័យកម្ពុជា សម្រាប់បោះពុម្ពផ្សាយ ។

សូមផ្សាយកុសលដែលកើតមកអំពីការប្រែសៀវភៅនេះ ជូនដល់



www.elibraryofcambodia.org

លោកអ្នកផង ទាំងលោកដែលផ្តើមឲ្យខ្ញុំប្រែ ព្រមទាំងលោកសង្ឃដែលជួយក្នុងការនេះ សូមឲ្យបានសម្រេចដល់ព្រះនិព្វាន ។ ម្យ៉ាងទៀតកាលបើខ្ញុំមិនទាន់ដល់ព្រះនិព្វាន នៅអន្ទោលជាតិទៅមកក្នុងវដ្តសង្សារនៅឡើយ ហើយទៅកើតក្នុងជាតិណា ៗ នោះ សូមឲ្យខ្ញុំបានជួបតែនឹងលោកសប្បុរស ហើយឲ្យបានចេះគ្រប់ភាសាក្នុងលោក កុំបីឃ្លាតឡើយ ។

ឧកញ៉ាបុណ្ណចន្ទមង្គល

ឧត្តមមន្ត្រីត្រែត

www.elibraryofcambodia.org

# សេចក្ដីផ្ដើមរបស់អ្នករៀបរៀង

អំពីហេតុដែលជឿក្នុងការហោះហើរដើរឯអាកាសបាននោះ មកពីសេចក្ដីខ្នះខ្នែងសង្វាតព្យាយាមរបស់មនុស្សជាមូល ៗ កាលមុនមួយរយឆ្នាំមកនេះ អ្នកណាមួយជឿថា មនុស្សអាចធ្វើយន្តហោះបាន? ដែលធ្វើបាននោះមកពីមនុស្សព្រមយកជីវិតប្ដូរក្នុងវិធីធ្វើ ទាល់តែសម្រេចបាន ឲ្យឃើញប្រាកដនឹងភ្នែកយើងសព្វថ្ងៃនេះ ក្នុងសម័យនេះមនុស្សព្យាយាមពិនិត្យពិច្រោះស្វែងរកវិជ្ជាធ្វើគ្រឿងចក្រម៉ាស៊ីនអម្បាលម៉ាណ ក្នុងសម័យបុរាណគេក៏ព្យាយាមរកវិជ្ជាបង្ហាត់ផ្ចង់ចិត្តដូច្នេះដែរ ផ្ចង់ចិត្តមនុស្សមានឫទ្ធិអំណាចយ៉ាងណា ក្នុងសម័យនេះយើងមើលមិនឃើញ តែក្នុងសម័យពុទ្ធកាលគេចេះដឹងថាចិត្តដែលបានបង្ហាត់ទប់ហ្វឹកហ្វឺនយ៉ាងល្អជាប់ស៊ប់ទៅហើយ ក៏អាចនឹងប្រើធ្វើអ្វី ៗ បានតាមប្រាថ្នា ដូចមានប្រាកដក្នុងគម្ពីរវិសុទ្ធិមគ្គ ដែលពោលពុទ្ធដីកាថា ‶ម្នាលភិក្ខុទាំងឡាយ តថាគតមិនឃើញធម៌ណាមួយ ដែលបុគ្គលប្រើទៅផ្ចង់បានដោយល្អដូចជាចិត្តនេះទេ″ ។

អំពីរឿងព្រេងផ្សេង ៗ ដែលមានទាក់ទងនឹងព្រះពុទ្ធសាសនានោះ រឿងទាំងនេះមិនត្រូវសង្ស័យឡើយ គ្រាន់តែជារឿងប្រៀបប្រដូច គង់មានពិតខ្លះ មិនពិតខ្លះ ព្រោះអ្នកតែងរឿងគម្ពីរទាំងនោះ គង់មានអ្នកតែងខ្លះលុះដោយអំណាចអគតិធម៌ ជាសត្រូវនៃព្រះពុទ្ធសាសនា ព្យាយាម

www.elibraryofcambodia.org

ជាតិបាននោះ មានសេចក្តីសន្និដ្ឋានបានតែប្រការ គឺកាលក្នុងវេលា ព្រះអង្គបានសម្រេចព្រះសព្វញ្ញុតញ្ញាណហើយនោះ ព្រះអង្គមាន ព្រះហឫទ័យផូរផង់ដូចជាព្រះច័ន្ទក្នុងថ្ងៃពេញបូណ៌មី ប្រការមួយទៀត មុនព្រះអង្គនឹងបានត្រាស់ជាព្រះពុទ្ធនោះ ក្នុងជាតិនីមួយ ៗ ដែលព្រះអង្គ កំពុងសាងបារមី ព្រះអង្គប្រតិបត្តិធ្វើតែសេចក្តីល្អមកជារៀងជាតិ គ្មាន អ្វីនឹងធ្វើព្រះទ័យឲ្យល្អក់សៅហ្មងបានក្នុងវេលាដែលព្រះអង្គលើកចិត្ត ពី ជាតិមួយទៅជាតិមួយជាប់នោះ មុនដែលព្រះអង្គបានត្រាស់ជាព្រះពុទ្ធ ។

សេចក្តីនេះនឹងអធិប្បាយតាមអត្តនោមតិថា ធម្មតាមនុស្សយើងបើ ចាំអ្វីបាន ឬបានឃើញអ្វីមួយផងហើយដល់កន្លងយូរទៅ ក៏អាចភ្លេចទៅ វិញបាន បើនឹងព្យាយាមរំឭកនឹកចង់ឲ្យឃើញមកវិញនោះជារបស់ពិ- បាក តែមានថ្ងៃណាឬវេលាណាមួយ ចិត្តយើងថ្លាផូរផង់គ្មានអ្វីមកធ្វើ ឲ្យរំខានចិត្តសោះនោះ ក៏អាចនឹកឃើញឯង ៗ ដោយមិនបានព្យាយាមនឹក គេផង ឬមនុស្សដែលកំពុងព្យាយាមធ្វើការនីមួយ ៗ ចង់ឲ្យបានសម្រេច ម្យ៉ាង ៗ តែកាលកំពុងធ្វើនោះ ពុំទាន់គិតឃើញដល់ការរបស់ខ្លួនធ្វើបាន យ៉ាងណាខ្លះហើយនោះទេ លុះតែការដែលធ្វើនោះសម្រេចហើយបាន មើលទៅឃើញពេញចិត្ត ដោយផលនៃខ្លួនព្យាយាម ដួងចិត្តនោះក៏ថ្លា រឭកនឹកឃើញចាំនូវការផ្សេង ៗ ទាំងប៉ុន្មានដែលខ្លួនបានធ្វើមកហើយនោះ



www.elibraryofcambodia.org

ដូចជាអ្នករៀនវិជ្ជាផ្សេង ៗ ដែលកើបប្រឡងបានសម្រេចផល ៗ នឹងចាំទុក វិជ្ជាបានប្រសើរលើសជាងកាលកំពុងប្រឡងឬមុននឹងចូលប្រឡង ។ ព្រះពុទ្ធជាម្ចាស់របស់យើង ក៏ដូច្នេះដែរ សេចក្ដីសម្រេចរបស់ព្រះអង្គ ធ្វើឲ្យព្រះអង្គពេញព្រះទ័យក្នុងសន្តិសុខ ជាងសេចក្ដីសម្រេចពីការអ្វីៗ ទាំងអស់ ក៏អាស្រ័យនូវព្រះទ័យជ្រះថ្លាផូរផង់ ប្រាសចាកកិលេស នោះឯងបានជាសេចក្ដីចាំទាំងប៉ុន្មាន ៗ ត្រឡប់មកកាន់ព្រះអង្គ បានវិញ ។

មនុស្សយើងនឹងនៅគ្មានរបស់ដែលធ្លាប់បានប្រទះឃើញ ឬចាំបានមកហើយ ច្រើនមកពីចិត្តមិនទៀង ដូចចិត្តល្អក់សៅហ្មងក្នុងវេលាកំពុងធ្វើការ ។ ឯមនុស្សដែលគ្មានហេតុអ្វី មកធ្វើឲ្យខ្វល់ក្នុងដួងចិត្តបាននោះ មានសេចក្ដីចាំបានជាច្រើនបំផុត ។ មកពីហេតុនេះបានជាក្នុងវិសាស-នារបស់យើង ប្រកាន់ខ្ជាប់ឲ្យប្រដៅមនុស្សជិតស្លាប់ ឲ្យមានស្មារតីព្យាយាមរឭកនឹកតែពីសេចក្ដីល្អផ្សេងៗ ដែលខ្លួនបានធ្វើនោះសម្រាប់ធ្វើឲ្យវិញ្ញាណរឭកជាប់ទៅជាមួយ ក្នុងលោកខាងមុខ មនុស្សដែលគ្មានសេចក្ដីល្អ សម្រាប់នឹងនឹករឭក ឬមនុស្សដែលមានចិត្តបាបកក្រក់ប្រ-ព្រឹត្តធ្វើតែសេចក្ដីក្ដៅក្រហាយ ឲ្យមនុស្សទាំងពួងក្ដៅក្រហាយជានិច្ចនោះ ក៏មិនអាចនឹករឭកដល់ សេចក្ដីល្អរបស់ខ្លួនបានឡើយ បានជាមនុស្ស



www.elibraryofcambodia.org

រៀបរៀងរឿងដែលមិនពិតមកដាក់ក្នុងព្រះពុទ្ធសាសនា ធ្វើឲ្យបង្ខូច
តម្លៃរបស់ព្រះពុទ្ធសាសនាធ្លាក់ថយជាងសាសនាឯទៀត ហេតុនេះត្រូវ
យើងយកធម្មាធិដ្ឋានមកពិនិត្យមើល ដើម្បីឲ្យយល់ពីសេចក្ដីពិតដែល
ជាខ្លឹមរបស់គម្ពីរនោះៗ ព្រោះគម្ពីរទាំងនោះមានរឿងខុះ ពោលយក
សេចក្ដីបុគ្គលាធិដ្ឋានខ្លះមករៀបធៀបបំផ្លើសផង បើយកធម្មាធិដ្ឋានតែ
មួយមកពិនិត្យកាត់គម្ពីរទាំងនោះអស់ មុខជាគម្ពីររបស់ព្រះពុទ្ធសាសនា
មិនព្រំនៅយូរប៉ុន្មាន ព្រះត្រៃបិដក ៨៤.០០០ ព្រះធម្មក្ខន្ធ ដែលយើង
មានចិត្តជឿទាំងអស់ទុកមកនឹងសល់នៅត្រឹមតែធម្មក្ខន្ធមួយ បើនិយាយដល់
ប្រស្នាដែលជាសំខាន់ដូចជារឿងឥទ្ធិបាដិហារិយ៍នេះ គួរជឿជាក់របស់
មានពិតប្រាកដមែន ព្រោះសេចក្ដីយល់ឃើញរបស់ព្រះគ្រូអាចារ្យ
ទាំងប៉ុន្មានត្រូវគ្នាជាច្រើន ហើយពួកពុទ្ធសាសនិកជនក៏បានសេចក្ដីជឿ
ជាក់មកជាងពីរពាន់ឆ្នាំហើយ ។

(១) គម្ពីរធម្មបទនោះបានពណ៌នាសេចក្ដីសំខាន់ផ្សេងៗទុកជា
ច្រើន ហើយបាននាំយកសេចក្ដីរបស់អ្នកប្រាជ្ញសណ្ដៅពីរនាក់ ម្នាក់ឈ្មោះ
ឃោសកមហាថេរៈ ម្នាក់ទៀតឈ្មោះស្វាមិភក្តិសិតៈ ដែលបានសរសេរ
រៀបរៀងទុកក្នុងគម្ពីរវិជ្ជាវេទមន្តនិងរឿងក្បួនកេតដោយអំណាចផងចិត្ត
មកប្រែដាក់ផែកប្រៀតចូលគម្ពីរដែលពោលអំពីមោឃវិជ្ជផង ដើម្បីប្រ-



www.elibraryofcambodia.org

ជាប់សតិបញ្ញារបស់អ្នកមើលសៀវភៅនេះ ឲ្យដឹងជាមានសេចក្ដីពិតឬមិនពិតត្រឹមណា ហើយនឹងបានដឹងថាអ្នកដែលគេជឿក្នុងលទ្ធិទាំងនេះ មានឫទ្ធិធ្វើបែបយ៉ាងណា ៗ យើងគួរជឿឬមិនគួរជឿត្រឹមណា ។

(២) គោលក្នុងព្រះពុទ្ធសាសនា ដែលមានពាក់ព័ន្ធនឹងវិជ្ជា ៨ ប្រការនេះក៏បាននាំយកមកពណ៌នាដោយល្អិតដែរ គោលទាំងនេះបានស្រង់យកមកពីគម្ពីរវិសុទ្ធិមគ្គ តែការនឹងនាំយកគោលក្នុងគម្ពីរនេះមកបរិយាយនោះ មិនបានយកពាក្យខ្ពស់ ៗ មកពោលទេ បានព្យាយាមរើសតែពាក្យដែលងាយ ៗ មកពោល ទុកជាអ្នកមិនចេះភាសាបាលីឬអ្នកមិនដែលរៀនធម៌វិន័យមកក្ដី ក៏អាចមើលចូលចិត្តបាន ។

ឯគម្ពីរវិសុទ្ធិមគ្គនេះ ជាគម្ពីរយ៉ាងឯករបស់ព្រះពុទ្ធឃោសាចារ្យដែលល្បីខ្ទរលោក មិនបានប្រែពីច្បាប់លក្ខដូចគម្ពីរផ្សេង ៗ ទេ គម្ពីរវិសុទ្ធិ-មគ្គនេះអ្នកប្រាជ្ញច្បាប់កេរប្រើទាំងអ្នកកាន់ព្រះពុទ្ធសាសនាទាំងអ្នកក្រៅព្រះពុទ្ធសាសនា ហើយជាគម្ពីរសម្រាប់ទុកជាគោលរបស់អ្នកសិក្សាដល់ប្រ-យោគទី ៨ ទី ៩ នៃស្យាមប្រទេស ហេតុដូច្នេះបានជាហ៊ាននាំយកមកបរិយាយក្នុងសៀវភៅនេះ ។ សេចក្ដីអធិប្បាយទាំងប៉ុន្មានដែលមានបំពេញលើសពីគម្ពីរវិសុទ្ធិមគ្គនោះ ច្រើនយកតាមសេចក្ដីរបស់អ្នកប្រាជ្ញដែលមានមកពីជាន់មុន ហើយនឹងសេចក្ដីយល់ឃើញរបស់អ្នកតែងសៀវ-

www.elibraryofcambodia.org

សៀវភៅនេះ  ហេតុដូច្នេះបើអ្នកមើលទៅបានប្រទះសេចក្ដីណាមួយគឺ អធិប្បាយរបស់អ្នកដទៃជាពាក្យ ពីកាព្យ ឬអ្នកប្រាជ្ញណាក្ដី ក៏គួរប្រាប់ថា សេចក្ដីនោះជាសេចក្ដីយល់ឃើញរបស់អ្នកនោះ ឯសេចក្ដីនេះមិនមែនការ យល់ឃើញខុសពីគ្នាជាពីរផ្លូវ មនុស្សយើងខុសជាធម្មតា ហើយ នឹងទុកដាក់ថាជាមនុស្សនោះគ្មានយល់ឃើញអ្វីសោះក៏ថាពុំបាន ការដែល បុគ្គលសំដែងសេចក្ដីយល់ឃើញរបស់ខ្លួនដោយសុចរិតនោះ ទុកជាយល់ ឃើញខុសពីសេចក្ដីរបស់អ្នកដទៃក្ដី មិនត្រូវតិះដៀលថាគ្មានសេចក្ដី គោរពដល់អ្នកនោះឡើយ ។

( ៣ ) ហេតុដែលនាំយកគោលលទ្ធិរបស់លោកជាច្រើនមកពោល ទុកក្នុងសៀវភៅនេះ បានជ្រើសរើសតែសេចក្ដីសំខាន់ៗមកអធិប្បាយទុក ជាដើម ដើម្បីឲ្យអ្នកមើលចាប់នូវគោលដ៏សំខាន់ជាមេបានសិន រួចទៅ សារៈរបស់គោលនោះនឹងបានធ្វើឲ្យចូលចិត្តសេចក្ដីម៉ាំមួនឡើង ឯសេច-ក្ដីបរិយាយវាងនឹងប៉ុន្មានបានយកពីតម្រារបស់លោកកបបេក: ដែលជាច្បាប់ ល្អបំផុតជាងសៀវភៅលទ្ធិលោកឯទៀត ។

សេចក្ដីបំផុតនេះ  អ្នកតែងសៀវភៅសូមអរគុណដល់អ្នកដែលយក ចិត្តទុកដាក់នឹងសៀវភៅនេះ  ឯការតិះដៀលឬសរសើរនោះក្នុងផលប្រ-យោជន៍អ្វីប្លែកពីគ្នាទេ ។



www.elibraryofcambodia.org

# សេចក្តីផ្តើម អំពីវិជ្ជា ៨ ប្រការ

បើយើងពិចារណារបៀបរៀបប្រវត្តិរបស់លោកអ្នកបង្កើតសាសនាផ្សេងៗ គួរជឿថាវិជ្ជា ៨ ប្រការនេះ អគ្គមហាបុរសដែលតាំងសាសនាទាំងប៉ុន្មានៗ សុទ្ធតែបានលុះហើយទាំងអស់ឬក៏បានលុះដោយប្រការខ្លះមិនដែលខាន បានសេចក្តីថាប្លែកណាស់ថា វិជ្ជា ៨ យ៉ាងនេះមានអ្នកយកមកទុកដាក់រៀនសូត្រ នេះដឹងស្គាល់ច្បាស់ដែលគន្ធទ្វីបអាស៊ីចំណែកខាងលិច គឺពីប្រទេសឥណ្ឌាទៅទល់នឹងប្រទេសអាហ្វ្រិក ចំណែកឯស្រុកចិននិងអេស៊ីបក្តី ដែលចំរើនបន្ទាន់ៗគ្នានោះ ឬមុនឥណ្ឌាទៅទៀត ក៏មិនឃើញច្បាស់ថា រុងរឿងដោយវិជ្ជាទាំងនេះ តាមសេចក្តីពិនិត្យដែលមិនបាច់ផ្ដែកប្រកែកគ្នាបាននោះ គឺអ្នកតាំងបង្កើតសាសនាផ្សេងៗ ដូចជាសម្តេចព្រះសម្មាសម្ពុទ្ធជាម្ចាស់យើង ១ ព្រះយេស៊ូគ្រិស្ត ១ ព្រះមហាម៉ាត់ ១ ទាំង ៣ នេះបានមកចាប់កំណើតនឹងសម្រេចបានជាសាស្តាចារ្យក្នុងក្តស់ សុទ្ធតែនៅក្នុងទ្វីបអាស៊ីទាំងអស់ ។

វិជ្ជា ៨ ប្រការនេះ ព្រះពុទ្ធជាម្ចាស់បានលុះគ្រប់ប្រការ កន្លងលោកត្រៃក្រោមម្លប់មហាពោធិព្រឹក្សលើរតនបល្ល័ង្កជាពិតប្រាកដ ទើបមានប្រស្នាចោទសួរថា "វិជ្ជាទាំង ៨ នេះសំដៅសេចក្តីត្រឹមណា? អភិនិហាររបស់ព្រះសម្ពុទ្ធជាម្ចាស់នោះមានប្រការដូចម្តេចខ្លះ"? ប្រស្នា

www.elibraryofcambodia.org

តាំងពីនេះ អ្នកប្រាជ្ញដែលកាន់សាសនាព្រះពុទ្ធ និងអ្នកដែលមិនកាន់ យល់ឃើញជា ២ ផ្លូវគឺ:

១ — សេចក្ដីយល់ឃើញរបស់អ្នកដែលជឿឥទ្ធានុភាពថា មនុស្ស អាចមានអំណាចបណ្ដាលឲ្យរបស់ផ្សេងៗ ដែលមនុស្សធម្មតាមិនអាចធ្វើបាននោះ ឲ្យប្រែប្រួលឬកើតបានតាមចិត្ត បានជាអ្នកដែលជឿឥទ្ធិបាដិហារិយ៍ទាំងនោះក៏ជឿថា ព្រះពុទ្ធជាម្ចាស់ទ្រង់អាចធ្វើបានជាប្រាកដ ។

២ — សេចក្ដីយល់ឃើញរបស់អ្នកដែលជឿចំពោះរបស់ដែលបានឃើញនិងស្គាល់ដោយអាយតនខាងក្នុងទាំង ៥ គឺ ភ្នែក, ត្រចៀក, ច្រមុះ, អណ្ដាត, កាយ មិនព្រមជឿហួសពីនេះ ក៏ប្រកាន់ថាឥទ្ធិបាដិហារិយ៍ផ្សេងៗជារបស់មិនពិតទេ គ្រាន់តែជាសេចក្ដីប្រៀបប្រដូចប៉ុណ្ណោះ ។

ឯប្រស្នានេះជាសំខាន់ណាស់ នឹងឲ្យត្រូវទាំងសងខាងមិនបានទេ ព្រោះម្ខាងស ម្ខាងខ្មៅ គង់ខុសម្ខាងៗ បើវាជាក្រហមវិញគង់ខុសទាំងសងខាង ប៉ុន្តែនឹងឲ្យត្រូវទាំងពីរមិនបានទេ បើនឹងឲ្យឃើញពិតជាខាងណាត្រូវខាងណាខុសសិនមានចំណែកដោយឡែក គឺថាបើពិនិត្យតាមសេចក្ដីយល់ឃើញទី ១ ជាពិតប្រាកដថា ព្រះពុទ្ធជាម្ចាស់របស់

លើកទុកជាព្រះម្ចាស់សួគ៌ (Dieu) មានឋានៈខ្ពស់ជាងទេវតា ឥន្ទ្រ ព្រហ្មទាំងឡាយ ដូចយ៉ាងអ្នកកាន់សាសនាផ្សេងៗ ទុកដាក់ឲ្យអ្នកតាំង បង្កើតសាសនាគេនោះជា (Dieu) ព្រះម្ចាស់សួគ៌ដូច្នោះ ។ បើប្រ-សិនជាវិនិច្ឆ័យជាសេចក្ដីយល់ឃើញទី ២ ជាត្រឹមត្រូវវិញ ព្រះពុទ្ធជាម្ចាស់ក៏គ្រាន់តែជាអ្នកចេះដឹងសីលធម៌ (Philosophe) ដូចខុងជឺដែលជាសាស្ដារបស់ចិន ឬសោក្រាតទីងសូក្រាតដែលជាសាស្ដារបស់ក្រិកប៉ុណ្ណោះ មិនខ្ពង់ខ្ពស់ប្រសើរអ្វីជាងអ្នកទាំងនេះឡើយ ។

មុននឹងវិនិច្ឆ័យរកហេតុឲ្យឃើញ គួរលើកតាំងប្រស្នាសួរខ្លួនឯងបាន ២ ឬ ៣ ខសិនគឺ:

ព្រះពុទ្ធជាម្ចាស់ ទ្រង់បានសិក្សាក្នុងសំណាក់លទ្ធិផ្សេងៗ ដែលមនុស្សកាប់កេនមុនព្រះអង្គត្រាស់ដឹង ហើយព្រះអង្គបានធ្វើទុក្ករកិរិយាដល់ ៦ ឆ្នាំទើបបានសម្រេច, សេចក្ដីសម្រេចដែលបានមកដោយព្យា-យាមយ៉ាងធំក្រៃលែងដូច្នេះ មិនមានអ្វីជាទីធ្វើឲ្យព្រះអង្គមានគុណសម្បត្តិវិសេសយ៉ាងខ្ពង់ខ្ពស់លើសមនុស្សធម្មតាទេឬអ្វី ? ។

បើព្រះអង្គគ្រាន់តែជាអ្នកចេះសីលធម៌តែប៉ុណ្ណោះទេ ហេតុអ្វីក៏ព្រះអង្គកេចផ្សាយសាសនារបស់ព្រះអង្គបានឆាប់ហើសព្រៀនជាងសាស-នាឯទៀតៗ ហើយស្ថិតស្ថេរអាយុវែងមកជាងសាសនាឯទៀតៗ ប្រស្នានេះ



www.elibraryofcambodia.org

មានពាក្យដោះស្រាយជា ២ ប្រការគឺ: ១) ជាធម៌របស់ព្រះអង្គទៀងត្រង់ ជាសុខុមនាំទៅកាន់សេចក្ដីពិត ច្រើនជាងធម៌ដទៃក្នុងសាសនាផ្សេងៗ ២) ជាកាលព្រះអង្គត្រាស់ដឹងហើយ ។ បានទេសនាប្រោសព្រះបាទពិម្ពិសារ ដែលមានអំណាចដ៏ធំក្រៃលែងក្នុងស្រុកឥណ្ឌាក្នុងគ្រានោះ បានជាមនុស្សទាំងឡាយជឿកាន់តាមដោយបានអំណាចរបស់ព្រះបាទពិម្ពិសារជាអ្នកទំនុកបម្រុង ។

ខដោះស្រាយទាំង ២ ប្រការនេះ នឹងទុកជាជាប់ប្រាកដពុំបាន ព្រោះមនុស្សតែងតែយល់ឃើញថា "សាសនារបស់ខ្លួនល្អ" ការដែលគិតជឿសាសនានេះមានជាដកបមកជាងពាន់ឆ្នាំហើយក៏គ្មានអ្នកណាវិនិច្ឆ័យឲ្យដាច់ខាត ថាសាសនាណាល្អជាបំផុតជាងគេ ដែលជាប្រាកដនោះ លោកដែលតាំងបង្កើតសាសនាគ្រប់រូប បានដាក់គោលចារិកបែបផែនជាសំខាន់ទុកសឹងប្រហែលៗគ្នា ផ្សេងគ្នាតែសេចក្ដី ឯជឿសាសនានេះមិនគួរនឹងអួតអាងថា "សាសនារបស់ខ្លួនវិសេសជាងសាសនាឯទៀតៗ ហើយបន្ទុះបន្ទាប់សាសនាឯទៀតៗ ជាសោម្យជាកហាបជាងរបស់ខ្លួន" ឯការដែលប្រកាន់ដូច្នេះ មិនមែនចរិយារបស់អ្នកចេះឡើយ បាក់ដែលជាមនុស្សល្អមែនៗ ជាអ្នកប្រដៅសាសនាគ្រិស្ដ មិនដែលត្មះតិះដៀលសាសនាព្រះពុទ្ធយើងទេ ។

ត្រង់ទី ៤ ដែលថាព្រះពុទ្ធជាម្ចាស់បានអំណាចពីព្រះបាទពិម្ពិសារ ជាគ្រឿងជោបផែនធ្វើឲ្យព្រះអង្គផ្សាយសាសនាបានឆាប់រហ័សនោះជាការខុសពិត ព្រោះថាការស្ដីជាកេចារ្យរបស់ព្រះបាទអាលេកសង់ដ៏រមហារាជដែលមានឈ្មោះក្នុងពង្សាវតារខុសប្រទុកជាស្ដេចចក្រពត្តិ មានអំណាចក្នុងទ្វីបខុប្រហែលដល់មកស្រណោះ សម័យជាងអំណាចព្រះបាទពិម្ពិសារទៅទៀត ក៏មិនប្រាកដថាការស្ដីយកអំណាចព្រះបាទអាលេក-សង់ដ៏រជាគ្រឿងផ្សាយលទ្ធិរបស់ខ្លួនបានឡើយ ។

ប្រស្នាមួយទៀត គឺរឿងអង្គុលិមាលចោរ មានសេចក្ដីដំណាលមកថាជាចោរសម្លាប់មនុស្សមកហើយ ៩៩៩ នាក់ កាត់យកម្រាមដៃដោតជាបណ្ដោប ទៅខ្វះតែម្នាក់ទៀតទើបបានគ្រប់ជា ១.០០០ នាក់តាមបង្គាប់របស់អាចារ្យ គេបកបានជួបប្រទះនឹងព្រះពុទ្ធ បានដេញតាមព្រះអង្គមិនទាន់ ព្រះអង្គមានព្រះបន្ទូលតែមួយព្រះឱស្ឋ អង្គុលិមាលចោរក៏ឈប់គិតបំពានប្រទូស្តនឹងព្រះអង្គទៅទៀត ត្រឡប់ជាស្ដាប់ធម៌ទេសនារបស់ព្រះអង្គបានសម្រេចបួសបព្វជាជាឯហិភិក្ខុ ជាព្រះអរហន្តក្នុងព្រះពុទ្ធសា-សនាមួយព្រះអង្គ ។ រឿងនេះគួរគិតពិចារណាជា ២ ផ្នែកគឺ ១ ព្រះពុទ្ធជាម្ចាស់ទ្រង់សម្ដែងព្រះឥរិយាបថជាទីបំផុត ព្រះអង្គគង់ជាមិនបានរត់ទេ

www.elibraryofcambodia.org

ចុះហេតុអ្វីក៏ព្រះអង្គុលិមាលដេញតាមមិនទាន់(១) ? ប្រសិនបើព្រះអង្គមិនមានឥទ្ធិបាដិហារិយ៍ទេ ពាក្យដែលព្រះអង្គមានព្រះបន្ទូលតែមួយព្រះឱស្ឋ អាចធ្វើឲ្យចោរចិត្តទមិឡសម្លាប់មនុស្សជាង ៩០០ នាក់មកហើយឲ្យព្រមឈប់ស្តាប់ព្រះធម្មទេសនាបានឬ ? ប្រសិនបើជាខ្លួនយើងវិញចូលទៅក្នុងព្រៃប្រទះនឹងចោរដែលកាប់ប្រមឺមកសម្លាប់យើង យើងនិយាយតាមព្រះពុទ្ធវចនៈនោះឲ្យចោរស្តាប់ មុខជាវាមិនព្រមឈប់ស្តាប់យើងទេ សមាទេ កំសម្លាប់យើងមុនទេសនាមិនទាន ។

ប្រការមួយវិញទៀត យើងសន្និដ្ឋានថា ឥទ្ធិបាដិហារិយ៍នៃព្រះពុទ្ធ-លាជិដ្ឋានមិនបានហើយ ។ ថាព្រះពុទ្ធជាម្ចាស់មិនមានឥទ្ធិបាដិហារិយ៍វិសេសជាងមនុស្សសាមញ្ញទេ ក៏គួរសង្ស័យណាស់ ហេតុអ្វីបានជាអ្នកប្រាជ្ញដែលសរសេរគម្ពីរទុកមកជាច្រើន ពីរឿងឥទ្ធិបាដិហារិយ៍របស់ព្រះពុទ្ធជាម្ចាស់ តើអ្នកប្រាជ្ញទាំងនោះយកមកពីណា ? មនុស្សយើងមានធម្មជាតិមួយជាប្រាកដដែលហៅថាមនោគតិ (Imagination) មានតួកាលធ្វើឲ្យមនុស្សគិតគេឃើញរបស់ ដែលហួសវិស័យមនុស្សទៅបាន

(១) អ្នកតែងសៀវភៅនេះមិនចង់ឲ្យអ្នកណាសន្និដ្ឋានថា «ពីព្រោះព្រះពុទ្ធយាងស្រាលៗទ្រង់ស្គាល់ស្ទាត់ផ្លូវណាស់ ទ្រង់យាងកាត់តែតាមចៀសបត់បែនទៅបានគ្រប់ច្រក បើចេញអង្គុលិមាលដេញតាមទាន់» ដូច្នេះឡើយ ព្រោះថាបើយើងស្តាប់ពាក្យសន្និដ្ឋានដូច្នេះហើយ មុខតួរឲ្យគេគិតថា អញ្ចឹងប្រៀបដូចជាព្រះពុទ្ធកំពុងទ្រង់ព្រួសលបស្លុងបិទពួនជៀសពីអង្គុលិមាល ។

តែជាមនោគតិមនុស្ស មានតែត្រឹមគេឃើញធ្វើរបស់ដែលបានឃើញ ពិតនៅក្នុងលោកខ្លះតែប៉ុណ្ណោះ ទើបមានមនោគតិក្នុងរឿងដ៏ប្រាសចាក សេចក្តីពិតប្រាកដនោះពុំបានឡើយ ដូចជាការជឿយន្តហោះឬកប៉ាល់មុជ ទឹកនិងរទេះដើរក្នុងដីទាំងនេះ សុទ្ធមានមកពីមនោគតិមួយៗ ហើយ សព្វថ្ងៃនេះក៏ក្លាយទៅជារបស់ពិតទាំងអស់ ប្រការមួយទៀត បើឥទ្ធិបាដិ-ហារិយ៍របស់ព្រះពុទ្ធជាម្ចាស់មិនពិតទេ អ្នកប្រាជ្ញដែលតែងសាស្ត្រាតម្រា ទុកមកជាច្រើនពីរឿងឥទ្ធិបាដិហារិយ៍នោះ ដល់ជាប្រាសចាកហិរិឱត្តប្បៈ យកសេចក្តីមិនពិតមកពោលកុហកបញ្ឆោតមហាជនបានដល់ម្ល៉េះឬ ? លោកអ្នកប្រាជ្ញទាំងនោះសុទ្ធតែជាអ្នកមានសីលធម៌ បរិសុទ្ធខ្ពង់ខ្ពស់, មើលទៅលោកមិនគេចយកសេចក្តីកុហកបញ្ឆោតមកតែងទុកទេ មានពុទ្ធ-ភាសិត ១ បទថា "សច្ចំ វេ អមតា វាចា" ពាក្យពិតជាពាក្យមិន ស្លាប់ បើប្រសិនជាតម្រាឥទ្ធិបាដិហារិយ៍របស់ព្រះពុទ្ធមិនពិតប្រាកដទេ ប្រហែលជាបាត់យូរណាស់ទៅហើយ មុខជាគ្មានអ្នកណាសង្វាតចម្លងទុក តៗមកដល់ពេលបច្ចុប្បន្ននេះទេ សេចក្តីនេះគួរទុកជាពាក្យមិនស្លាប់ គួរប្រកាន់យកជាការពិតបានឬមិនបាន ? ។

បើប្រសិនជារិះគិតពិចារណា តាមសេចក្តីដែលពោលមកហើយនេះ អ្នកទាំងឡាយស្គាល់ជាក់ថា ព្រះពុទ្ធជាម្ចាស់របស់យើង មានឥទ្ធិបាដិហារិយ៍



www.elibraryofcambodia.org

ដ៏សក្តិសិទ្ធិខ្ពង់ខ្ពស់ជាងមនុស្សធម្មតា តែឫទ្ធិបាដិហារិយ៍ទាំងនេះ ទើបទុកដាក់ជាធម្មតាដូចទាំងអស់ក៏ពុំបាន ព្រោះទុកជាបុគ្គលដទៃខ្លះ ៗ ដែលជា ព្រះពុទ្ធជាម្ចាស់របស់យើងទ្រង់មានឫទ្ធិបាដិហារិយ៍ខ្ពង់ខ្ពស់ជាងមនុស្សធម្មតានោះ តើយើងនឹងអធិប្បាយឫទ្ធិបាដិហារិយ៍នោះដោយរបៀបណា? សេចក្តីនេះមនុស្សយល់ឃើញជា ២ ផ្លូវគឺ ១ ជាមានរបស់អ្វីមួយ ហួសអំណាចខ្ពស់លើសអំណាចធម្មជាតិ (Surnaturel) ៗ ២ ជារបស់ដោះនៅក្នុងវិធីធម្មជាតិដោះឯង គឺអំណាចផ្លូវចិត្តដែលបានបណ្តុះទុកស្រេចយ៉ាងល្អហើយ ៗ ពួកទី ១ ជាពួកដែលជឿថាមានអំណាចអ្វីខ្ពស់បំផុតនៅខាងលើដែលអាចធ្វើឲ្យអ្នកណាទៅជាអ្វីក៏បាន បើអ្នកណាប្រាថ្នាដូចចិត្តបានហើយ ។ ក៏អាចនឹងធ្វើការជាប់គន្លងអំណាចនៅខាងលើ គឺទេវតាបាន - អាចសុំឫទ្ធិតេជះពីទេវតាបាន (សទ្ធៃ) អាចនឹងចរចានិយាយសួររឿងផ្សេង ៗ នឹងអ្នកសក្តិសិទ្ធិនៅខាងលើបាន (ទិព្វលោក) អធិប្បាយមកនេះទុកជាខុសទាំងស្រុងក៏ពុំបាន គួរជឿខ្លះដែរ ៗ ប៉ុន្តែគួរជ្រះថ្លាក្នុងពួកទី ២ ដែលជាឫទ្ធិតេជះរបស់ព្រះពុទ្ធឬព្រះសាវក ទើបអ្នកណាដែលអាចធ្វើបាន សឹងនៅក្នុងវិធីនៃធម្មជាតិទាំងអស់ពោលគឺដោយអំណាចផ្លូវចិត្តដែលបានហាត់ហ្វឹកហ្វឺនទម្លាប់ហើយ មិនមែនជារបស់លើសធម្មជាតិ ឬហួសវិស័យមនុស្សទេ ព្រោះធម្មជាតិមានវិធីទូលាយ

ក្រីបណា ដែលមនុស្សមានលក្ខណៈកំណត់ត្រឹមណានោះ យើងចេះដឹង បំពេញទាំងពួងល្អប្រសើរទាំងនោះទៀត ហេតុនេះមុនយើងនឹងវិនិច្ឆ័យ គួរគិត ជាមុនសិនថា "របស់នេះរបស់នោះជារបស់លើសធម្មជាតិវិស័យ ឬហួស វិស័យមនុស្សពើងធ្វើបាន" ដូច្នេះកុំអាលប្រញាប់វិនិច្ឆ័យហើសពេក. បើ វិនិច្ឆ័យតាមតែងណាស់ទៅ បើដូចជាមនុស្សខ្វាក់ស្ទាបដំរី បើស្ទាបពាមទៅ លើកឧបមាថាដំរីនោះមានខ្លួនដូចសត្វពស់ ។

ប្រស្នាផ្សេងៗ ដែលបានពណ៌នាមកខាងដើមនេះ ជាមូលហេតុ នៃការគិតសរសេរវិជ្ជា ៨ ប្រការតាមគំនិតគិតឃើញ អ្នកតែងរឿងនេះ ជឿថាព្រះពុទ្ធជាម្ចាស់របស់យើង មានឥទ្ធាភិនិហារ្យលើសលប់មនុស្ស ធម្មតាផង ហើយព្រះអង្គអាចធ្វើការអ្វីៗ ដែលមនុស្សធម្មតាមិនអាចធ្វើ បានទាំងអស់ផង ។ ឯឥទ្ធិបាដិហារ្យដែលទ្រង់បានទាំងអម្បាលនេះ ក៏ជាផលនៃអំណាចដួងចិត្តរបស់ព្រះអង្គ ដូចមានសេចក្តីពិស្តារក្នុងរឿង. ទៅនេះស្រាប់ ដើម្បីឲ្យអ្នកមើលងាយចូលចិត្ត នោះបានញែកវិជ្ជាទាំង ៨ ចេញ ហើយនាំយកទៅកន្លែងឯទៀតៗ ដែលមានទាក់ទងគ្នា មក ប្រមូលទុកជាមួយគ្នា ដើម្បីឲ្យអ្នកមើលបានដឹងថា វិជ្ជាទាំង ៨ ប្រការនេះ ជាធម៌ដ៏សំខាន់របស់ព្រះពុទ្ធជាម្ចាស់ត្របដណ្តប់លើធម៌ឯទៀតជាច្រើន មួយវិញទៀត ការរៀនវិជ្ជា ៨ ប្រការនេះនឹងជួយឲ្យបានចូលចិត្តក្តីដល់ គម្ពីរឯទៀតៗជាច្រើនផង ។

www.elibraryofcambodia.org

សាខារបស់វិជ្ជាទាំង ៨ នោះដូចមានខាងក្រោយនេះ

១ — វិបស្សនាញាណ ញាណដែលកប់បញ្ចូលក្នុងវិបស្សនា

២ — មនោមយិទ្ធិ ឫទ្ធិតាមផ្លូវចិត្ត

៣ — ឥទ្ធិវិធិ សំដែងឫទ្ធិបាន

៤ — ទិព្វសោត ត្រចៀកទិព្វ

៥ — ចេតោបរិយញ្ញាណ ចេះកំណត់ចិត្តអ្នកដទៃ

៦ — បុព្វេនិវាសានុស្សតិញ្ញាណ រឭកជាតិបាន

៧ — ទិព្វចក្ខុ ភ្នែកទិព្វ

៨ — អាសវក្ខយញ្ញាណ ចេះធ្វើឲ្យអស់កិលេស ។

វិជ្ជា ៨ នេះផ្ទុយនឹងអវិជ្ជា ៨ គឺ:

១ — មិនស្គាល់ទុក្ខ

២ — មិនស្គាល់ហេតុដែលជាទីកើតនៃទុក្ខ

៣ — មិនស្គាល់សេចក្ដីរលត់ទុក្ខ

៤ — មិនស្គាល់ផ្លូវដែលជាឧបាយរលត់ទុក្ខ

៥ — មិនស្គាល់ហេតុក្នុងអតីត

៦ — មិនស្គាល់ហេតុក្នុងអនាគត

៧ — មិនស្គាល់ហេតុទាំងក្នុងអតីតទាំងក្នុងអនាគត



www.elibraryofcambodia.org

៥ — ទិព្វចក្ខុ ភ្នែកទិព្វ

៦ — អាសវក្ខយញ្ញាណ ប្រាជ្ញាកំណត់ដឹងនូវការបំបាត់អស់ទៅនៃអាសវៈ ។

គ — គ្របដណ្តប់ទសពលញ្ញាណ ៣ គឺ:

១ — បុព្វេនិវាសានុស្សតិញ្ញាណ ប្រាជ្ញាកំណត់រឭកជាតិកន្លងមកហើយបាន

២ — ចុតូបបាតញ្ញាណ ប្រាជ្ញាកំណត់ដឹងច្យុតិបដិសន្ធិរបស់សត្វទាំងឡាយ ដែលកើតមកផ្សេងៗ ពីព្រោះផលកម្ម

៣ — អាសវក្ខយញ្ញាណ ប្រាជ្ញាកំណត់ដឹងនូវការបំបាត់អស់ទៅនៃអាសវៈ ។

បើពោលឲ្យល្អិតញែកសាខារបស់វិជ្ជាទាំង ៨ ចេញហើយ នឹងពួកនេះទៅគ្រប់ធម៌ពួកឯទៀតៗ ទុកជាច្រើនពួកគឺ:

១ — វិបស្សនាញ្ញាណ ក្នុងពួកវិជ្ជា គ្របវិបស្សនាញ្ញាណ ៩

២ — ឥទ្ធិវិធ គ្របឥទ្ធិបាដិហារិយៈ

៣ — ទិព្វចក្ខុ គ្របញ្ញាណ ៣ គឺ ១ — អតីតង្សញ្ញាណ ញាណក្នុងចំណែកអតីត ២ — អនាគតង្សញ្ញាណ ញាណក្នុងចំណែកអនាគត ៣ - បច្ចុប្បន្នង្សញ្ញាណ ញាណក្នុងចំណែកបច្ចុប្បន្ន ។

២ — មិនស្គាល់ក្នុងទុក្ខសមុទយ

៣ — មិនស្គាល់ក្នុងទុក្ខនិរោធ

៤ — មិនស្គាល់ក្នុងទុក្ខនិរោធគាមិនីបដិបទា ។

ហេតុដែលកាន់យកលទ្ធិយោគីមកពោលក្នុងប្រីននៃក្នុងសៀវ-ភៅនេះហើយបាននាំយកគោលការណ៍ព្រះពុទ្ធសាសនា ក្នុងរឿងវិជ្ជា ៨ ប្រការមកបរិយាយក្នុងផង ដើម្បីឲ្យគេដឹងស្គាល់ខុសខាង ៗ របស់លទ្ធិយោគី ឯកសិណទាំងឈានទាំងស្មុះក្នុងសិន ទាំងនាំពោលទាំង ៣ ប្រការនេះមកអធិប្បាយដោយខ្លីៗ ដូចមានតទៅនេះ ការណ៍ណា បើអ្នកមើលពិសិក្សាដោយច្បាស់លាស់តាំងពីដើមរហូតដល់ចុងហើយនឹងធ្វើឲ្យយល់ចិត្តសេចក្តីត្រង់ទៀតសេចក្តីអធិប្បាយអំពីវិជ្ជា ៨ ប្រការដោយងាយត្រូវខាងឡើងបាន ។

ក — គោលការណ៍របស់យោគី

លទ្ធិរបស់យោគីនោះ ប្រកាន់ថាមនុស្សយើងមានកាយដែលចែកចេញបានជា ៧ ភាគគឺ:

៧ — វិញ្ញាណ

៦ — ដួងចិត្ត

៥ — បញ្ញា

៤ — សញ្ញា

## ២ — ខេតកូត

ខេតកូតគេក៏ប្រកាន់ថាជាកាយមួយដែរ សឹងតាមលក្ខណៈល្អិតជាងកាយធម្មតា ព្រោះតាមប្រក្រតីយើងមើលឃើញនឹងភ្នែកពុំបាន ប៉ុន្តែនៅត្រូវត្រាតជាធម្មជាតិទាំង ៥ ប្រការខាងលើនោះទៀត ព្រោះខេតកូតនេះអាចឃើញដោយភ្នែកបានដោយកាលខ្លះៗ ក្នុងសម័យបុរាណគេស្គាល់ច្បាស់ណាស់ ទើងជាដើមកំណើតនៃការប្រកាន់ខ្មោចព្រាយប្រផ្លូវ ឬកាន់ខ្មោចបិសាចឬហេតុស្វាត់កំបាំងផ្សេងៗ ។ តែបើពោលតាមលទ្ធិរបស់យោគីនោះ ខេតកូតជាភាគមួយរបស់កាយនេះឯង ហើយចេញចេញពីកាយបានដោយកាលខ្លះៗ វេលាដេកលក់ ដែលចេញចេញទៅនោះ ក៏នៅមានទាក់ទងនឹងកាយ ដូចមានខ្សែចងភ្ជាប់នឹងកាយ កាលណាបាញ់ចេញទៅហើយ វេលាត្រូវការត្រឡប់មកកាន់កាយវិញបាន ដូចកាលត្រឡប់មកហើសពេក ខេតកូតក៏មកប៉ះនឹងកាយជាខ្លាំងពាល់តែជ័នខ្លួនឲ្យខ្ញាប់ពេក ដូចយើងកំពុងដេកលក់យ៉ាងស្រួលសប្បាយខេតកូតចេញពីកាយទៅហើយ កំពុងដើរត្រាច់ណាសប្បាយ ម្ដងនោះរបស់អ្វីធ្លាក់ឬឮសូរគរអ្វីជាខ្លាំងខាងខ្លួន ធ្វើឲ្យយើងភ្ញាក់ភ្ញើយទៀងដោយហើសខ្ទត់ញ័រក្នុងចិត្តជាខ្លាំង នេះមកពីខេតកូតត្រឡប់មកប៉ះកាយយើងយ៉ាងខ្លាំង ។



www.elibraryofcambodia.org

ដោយគេសម្លាប់ឬស្លាប់ដោយរោគាផ្សេងៗ ដែលធ្លាប់កើតមាននោះ ចេត-កូតមិនទាន់ដឹងខ្លួនចេញទៅកើតកាយថ្មីមិនទាន់ មិនដឹងជាទៅកន្លែងណា ក៏ត្រាច់ទៅៗ ពីនោះឬក៏ទៅរកញាតិដែលស្គាល់ក្នុងកាលនៅក្នុងកាយមិនទាន់ស្លាប់នោះ ជួនកាលក៏ធ្វើឲ្យឃើញរូបទីពីរដែលលាក់ស្តែងចំពោះអ្នកណាមួយដែលយើងហៅថា "បិសាច" ព្រោះហេតុនេះមនុស្សដែលមានជម្ងឺឈឺយូរ ស្លាប់ទៅមិនសូវឃើញ (បិសាច) ឯមនុស្សស្លាប់ក្នុងបច្ចុប្បន្នទាន់ហន់ដែលហៅថាស្លាប់តាយហោងនោះច្រើនឃើញ "បិសាច" បកយាយវៀយៗ ដែលចុកជាក់ជាជាខ្មោចកាច ៗ បើយើងរៀបតាមលទ្ធិយោគីអធិប្បាយមកនេះ មិនគួរយើងខ្លាចខ្មោចសោះ ព្រោះជាភាគមួយរបស់កាយយើងនេះដែរ ៗ

តាមសេចក្ដីពន្យល់ក្នុងសៀវភៅរបស់យោគីឈ្មោះ កបៈចាកៈ មានសេចក្ដីបរិយាយថា ក្នុងវេលាយើងមានជីវិតរស់នៅ ក៏អាចប្រើចេតកូតជាប្រយោជន៍បាន បើយើងចេះទម្លាប់បានល្អហើយអាចបង្គាប់ចេតកូតរបស់យើងឲ្យទៅប្រាកដឃើញនៅទីណា ក៏បាន តែវិទ្យាពេទ្យពិសោធធ្វើការអ្វីបានឬមិនបាននោះ មិនឃើញមាននិយាយក្នុងសៀវភៅការរបត្រាន់តែថាអាចស៊ើបការឬឲ្យដឹងការអ្វីជាមុនបានទៅវេលាយើងដេកលក់ចេតកូតខ្ញុំនាំពណ៌ដែលមានមកយកការផ្ដល់យើង ឲ្យដឹងឃើញក្នុងពេល

នាំគប៉ាល់ទៅដើរឲ្យលិចខូចខាត ម្ចាស់គប៉ាល់ (វិញ្ញាណ) ក៏ត្រូវទទួល
គ្រោះថ្នាក់ទាំងអស់ ហេតុនេះបានជាថាដួងចិត្តជាសំខាន់បំផុត ព្រោះធ្វើ
ល្អឬអាក្រក់ស្រេចនូវដួងចិត្ត ឯវិញ្ញាណត្រាន់តែជាអ្នកទទួលផល បញ្ញា
និងសញ្ញាប្រៀបដូចគ្រឿងប្រដាប់សម្រាប់គប៉ាល់ ដូចជាកែវយីនិងត្រីវិ-
ស័យសម្រាប់ចង្អុលទិស ព្រាណប្រៀបដូចម៉ាស៊ីនដែលធ្វើឲ្យគប៉ាល់ដើរ
បាន ចេតសិកប្រៀបដូចជាកៃវេរយ៏តឬវិទ្យុព្រោះសព្វស្រែប់ឃើញរលើនដើរ
ឲ្យដំណើរជាមុនដែលនឹងមានហេតុមកដល់ ឯកាយគឺសំបកគប៉ាល់ឬតួ
គប៉ាល់នោះឯង ។

ដោយហេតុនេះបានជាលោកយោគីប្រកាន់ថា ក្នុងខ្លួនមនុស្សយើង
កាយជារបស់គ្រោតគ្រាតបំផុត ហើយមានសេចក្ដីសំខាន់ទីងមួយយ៉ាង
តិចបំផុតជាងធម្មជាតិឯទៀត អ្នកមិនដែលរិះគិតឲ្យជ្រាលជ្រៅក៏ឃើញ
ត្រឹមតែថា មនុស្សមានតែកងកាយជារបស់សំខាន់ទំនុកបំរុងតែសេច-
ក្ដីសុខឲ្យកងកាយប៉ុណ្ណោះក៏ល្មមសមគួរហើយ បើប្រសិនជាគិតផ្ចឹងឲ្យ
ជ្រៅទៅកាយត្រាន់តែជាភាគ ១ ក្នុងភាគ ៧ របស់មនុស្សប៉ុណ្ណោះ នៅ
មាន ៦ ភាគទៀត ដែលយើងត្រូវយកចិត្តទុកដាក់ទំនុកបំរុងរក្សាធ្វើឲ្យ
ល្អឡើងទើបបានប្រើជាប្រយោជន៍បានបើចេះប្រើ ។

ឯសេចក្ដីទាំងប៉ុន្មានដែលពោលមកហើយក្នុងលោកិយនេះ អ្ន



www.elibraryofcambodia.org

ផ្នែកកសិណនិងឈានជាមុន ទៅចាប់រៀនវិជ្ជា ៨ ប្រការតែក្នុងនោះប្រៀបដូចយើងរៀនភាសាតាងប្រទេស មិនទាន់បានរៀនវេយ្យាករណ៍ជាមុន ស្រាប់តែយកសៀវភៅរឿងទីមួយៗ ទៅឲ្យគ្រូបង្ហាត់ប្រែតែម្តងយើងក៏ពិតមានសេចក្តីលំបាកជាដរាប ហេតុនេះឃើញជាត្រូវចាប់ផ្តើមពន្យល់ពោលតាំងពីប្រការនេះសិន មុននឹងបកវិជ្ជា ៨ ប្រការជាៗ តទៅ បើយើងចូលចិត្តក្នុងផ្នែកកសិណហើយក៏នឹងបានជួយឲ្យយើងអាចដោះស្រាយប្រស្នាផ្សេងៗ អំពីឥទ្ធិបាដិហារ្យរបស់ព្រះពុទ្ធជាម្ចាស់ដូចមានពោលទុកក្នុងសៀវភៅពុទ្ធានុភាពនោះ(១) បានងាយស្រួលឡើងជាច្រើន ។

ឯសៀវភៅទាំងឡាយ ដែលអធិប្បាយអំពីកសិណនិងឈានដោយអ្នកប្រាជ្ញលោកតែងទុកសម្រាប់ពួកអ្នកប្រាជ្ញគ្នាលោកមើលនោះ ប្រើសុទ្ធតែពាក្យឬប្រយោគដែលសាមញ្ញជនមិនងាយចូលចិត្តបាន ។ ជាពួកយើងមិនសូវយកចិត្តទុកដាក់រៀនឲ្យចូលចិត្តមក តែការដែលពោលអំពីកសិណនិងឈានក្នុងសៀវភៅនេះ បានព្យាយាមរកពាក្យដែលងាយយល់មកដាក់ សូមអ្នកមើលសៀវភៅនេះ កុំអាលបោះបង់ចោល ចូរមើលតរៀងទៅ អាចនឹងនាំឲ្យអ្នកមើលចេះដឹងជាក់ច្បាស់ ។

---

១ នេះជាឈ្មោះសៀវភៅមួយរបស់អ្នកតែងវិជ្ជា ៨ ប្រការនេះដែរ ឯសៀវភៅនោះពោលអំពីអានុភាពរបស់ព្រះពុទ្ធជាម្ចាស់ ដែលទ្រង់ប្រតិស្ឋានព្រះពុទ្ធសាសនាជាអស្ចារ្យចំឡែកណាស់ ហើយមានសេចក្តីចំរើនគឺស្ថិតស្ថេរជាងសាសនាឯទៀត ៗ ។

៥— នីលកសិណ យកពណ៌ខៀវជាអារម្មណ៍ បើចំរើនបានសម្រេច អាចនិម្មិតរូបឲ្យខៀវធ្វើឲ្យងងឹតឈប់ក៏បាន ។

៦ – បីតកសិណ យកពណ៌លឿងជាអារម្មណ៍ បើចំរើនបានសម្រេច អាចនិម្មិតរូបឲ្យលឿង អធិដ្ឋានរបស់អ្វីៗឲ្យទៅជាមាសក៏បាន ។

៧ – លោហិតកសិណ យកពណ៌ក្រហមជាអារម្មណ៍ បើចំរើនបានសម្រេច អាចនិម្មិតរូបឲ្យក្រហមឬចង់ធ្វើពណ៌ណាៗឲ្យទៅជាក្រហមក៏បាន ។

៨— ឱទាតកសិណ យកពណ៌សជាអារម្មណ៍ បើចំរើនបានសម្រេច អាចធ្វើពណ៌ណាៗឲ្យទៅជាពណ៌សបាន ធ្វើខ្លួនឯងមិនឲ្យងងុយដេក ដាស់មនុស្សដេកឲ្យក្រោកពីលក់ កំចាត់ងងឹតឲ្យភ្លឺ ឲ្យមានចក្ខុទិព្វឃើញរូបបាន ។

៩— អាលោកកសិណ យកពន្លឺជាអារម្មណ៍ បើចំរើនបានសម្រេច អាចធ្វើបានដូចគ្នានឹងឱទាតកសិណ ។

១០— បរិច្ឆិន្នាកាសកសិណ យកចន្លោះប្រហោងជាអារម្មណ៍ បើចំរើនបានសម្រេច អាចធ្វើផែនដីនឹងភ្នំរបស់អ្វីផ្សេងៗដូចជាជញ្ជាំងកំផែងឲ្យទៅជាអាកាសរួចដើរចេញចូលបាន ។

ផលនៃកសិណទាំង ១០ នេះ យើងនឹងជឿឬមិនជឿក៏បាន តែគួរ

ជាសង្ខេប ព្រោះកសិណទាំង ១០ នេះ មានគោលដូចគ្នា ខុសគ្នាបន្តិចបន្តួច ៗ

## ១– បឋវីកសិណ

ការចំរើនបឋវីកសិណ តាំងពីដើមដល់ចប់នោះមាន ៦ ប្រការ

១– រៀបចំរបៀបនិងវិធីសំឡឹងមើល

២– កើតឧគ្គហនិមិត្ត

៣– កើតបដិភាគនិមិត្ត

៤– កើតឧបចារសមាធិ

៥– កើតអប្បនាសមាធិ

៦– វិធីបម្រុងរក្សាអប្បនាសមាធិឲ្យហំប្អួន ទាល់តែកើតឈាន ៗ

## ១– របៀបរៀបចំនិងវិធីសំឡឹង

របៀបចំរើនបឋវីកសិណនោះ ហាមមិនឲ្យយកដីពណ៌ខៀវ, លឿង, ក្រហម, ស ឲ្យរើសគេយកតែដីពណ៌អរុណ (គឺជាពណ៌ក្រហមលាយលឿង) ក្នុងគម្ពីរវិសុទ្ធិមគ្គ ឲ្យយកដីដូចដីក្នុងទន្លេគង្គា នៅក្នុងប្រទេសឥណ្ឌា យើងនឹងរកឲ្យបានដីយ៉ាងនោះដូចម្តេចបាន ព្រោះនៅឆ្ងាយផុតវិស័យទៅគេមកធ្វើជាគំរូបាន ដីដែលនឹងយកមកប្រើនោះ ត្រូវរើស



www.elibraryofcambodia.org

ធ្មេចភ្នែកក៏នៅឃើញវង់ដីដូចបើកភ្នែក ដូចឃើញសំឡឹងមើលព្រះកេចិក្ស រួចបិទភ្នែកទៅ នៅឃើញផ្សែងក្តីជាប់នឹងភ្នែកបានមួយស្របក់ តែឧគ្គ-ហនិមិត្តនោះ ត្រូវតែក្សាឲ្យឃើញជាប់នៅភ្នែកឲ្យបានយូរតាមយើងត្រូវការ បើបាត់ទៅកាលណា យើងត្រូវការនឹងនឹកយកមកឲ្យឃើញនៅនឹងភ្នែក យើងវិញបាន កាលណាឧគ្គហនិមិត្តកើតឡើងហើយ លោកឲ្យក្រោក ចេញពីទីនោះ ទៅអង្គុយនៅទីដែលរៀបចំទុកនោះ នាំយកឧគ្គហនិ-មិត្តឲ្យជាប់នឹងភ្នែកទៅអង្គុយធ្មេចភ្នែកឲ្យឃើញដូចកាលអង្គុយនៅកន្លែង មុន កិច្ចនេះមិនមែនជារបស់ងាយទេ តាមគម្ពីរវិសុទ្ធិមគ្គប្រាប់ឲ្យគេ ស្បែកជើងទុក បើបានឧគ្គហនិមិត្តហើយក្រោកទៅពាក់ស្បែកជើង ដើរ ទៅអង្គុយនៅទីដែលខ្លួនបំរុងទុកឯកន្លែងទៀត បានជាឲ្យពាក់ស្បែកជើង ព្រោះកុំឲ្យវិលលានជើងនាំឲ្យខូចពេល ក្រែងតំរើងឧគ្គហនិមិត្តរលុះបាត់ តែកើតបដិភាគនិមិត្ត ។

## ៣ — កើតបដិភាគនិមិត្ត

បដិភាគនិមិត្តនោះ តាមគម្ពីរវិសុទ្ធិមគ្គអធិប្បាយថា: ឃើញរូបដី ដែលជាប់នឹងភ្នែកអណ្តែតឡើង មូលដូចដួងព្រះចន្ទដែលផុះចេញពីស្រ-ពាប់មេឃ ឃើញច្បាស់ជាងឧគ្គហនិមិត្តតាំងមួយរយភាគ តាមសេចក្តី អធិប្បាយ របស់សម្តេចព្រះមហាសមណវិញ្ញាណវករសថា "កាល

យ៉ាងណា នោះចូរមើល (គន់និយាយអំពីផ្លូវ ៨ (បការគេទៅចុះ) ឯអប្បនា-សមាធិជាធម្មជាតិពិបាកក្រៃ អ្នកដែលចំរើនបានហើយគេនឹងព្យាយាម រក្សាឲ្យមាំមួន ដូចក្នុងគម្ពីរវិសុទ្ធិមគ្គប្រៀបធៀបថា ឲ្យរក្សាដូចស្ត្រីដែល រក្សាគភ៌ដែលមានស្តេចចក្រពត្តិមកបដិសន្ធិ ពោលគឺត្រូវចំរើនអប្បនា-សមាធិនេះជានិច្ច ក្នុងវេលាមិនបានចំរើន ក៏ត្រូវរក្សាខ្លួនឲ្យល្អ ប្រយ័ត្នកុំ ឲ្យមានរអ៊ូទាំងឡាយដែលនាំមកធ្វើឲ្យចិត្តកង្វល់រញ៉េរញ៉ៃឲ្យកើតសេចក្ដីប្រហែស ក្នុង ការធ្វើសមាធិ ឲ្យសាយបាត់ទៅនោះ ការនឹងរក្សាខ្លួន ក្នុងគម្ពីរវិសុទ្ធិមគ្គ អធិប្បាយថា

១ — ឲ្យរកទីកន្លែងនៅជាសប្បាយ

២ — រក្សាកុំឲ្យគន្ធីព្រះកេចិត្តតាំងផ្អែក

៣ — ចៀសវាងពីពាក្យមិនពិរោះ

៤ — បរិភោគអាហារដែលមិនឲ្យទោសដល់រូបកាយ

៥ — ឲ្យចេះបន្ទំចិត្តដំកល់ចិត្តទីនីល្អនិងលោមចិត្តឲ្យស្រស់ថ្លាស្មើជា ដរាប

៦ — ចៀសវាងពីមនុស្សមានលក្ខណៈចិត្តទន់ខ្សោយ រើសគប់តែ មនុស្សដែលមានលក្ខណៈចិត្តរឹងមាំមួន

៧ — កុំនឹកឲ្យចិត្តហើរសព្វខ្លីលច្រអូស ។



www.elibraryofcambodia.org

កន្ទេលចាស់ស្បែកឬកំសំពត់មកបោះកណ្តាលដាប្រហែលប្រមាណ ១ ចំអាម ៤ ធ្នាប់ ធ្វើរបៀបដូចបរិកសិណ ស្រេចហើយអ្នកសំឡឹងការតា ពាល់តែឧគ្គហនិមិត្តកើតឃើញអណ្តាតភ្លើងកំពុងញាប់ញ័រ, ឯបដិភាគនិ-មិត្តនោះតែឃើញអណ្តាតភ្លើងនៅនឹងថ្កល់មិនញាប់ញ័រ លោកប្រៀប ប្រដូចឃើញកំណាត់សំពត់ក្រហមដាក់នៅកណ្តាលអាកាស គឺនេះ ធ្វើឲ្យដូចបរិកសិណ ។

## ៤ — វាយោកសិណ

ការចំរើនយកខ្យល់ជាអារម្មណ៍ លោកបញ្ញត្តទុក ២ យ៉ាង យ៉ាងយក ខ្យល់ដែលបក់មកប៉ះកាយ, យ៉ាងទៀតឃើញខ្យល់ដែលបក់ត្រូវស្លឹកឈើ ល្ងិច ៗ ឧគ្គហនិមិត្តកើតឡើងឃើញខ្យល់ញាប់ញ័រ ដូចចំហាយបាយពុះ ទើបដាក់ពីចង្ក្រាន ឯបដិភាគនិមិត្ត ឃើញនៅនឹងថ្កល់មិនញាប់ញ័រ ។

## ៥ - នីលកសិណ

លោកអធិប្បាយថា នឹងយកផ្កាលំចង់ខៀវ ឬផ្កាអញ្ចាន់ ឬកំសំ-ពត់ពណ៌ខៀវមកពាសពីលើមាត់ប្រអប់ឬតែអ្វីមួយដូចជាស្គរក៏បាន ឧគ្គ-ហនិមិត្តកើតឡើងឃើញទាំងព្រមនឹងផ្កា ឬរបស់អ្វីៗ ដែលយកមកប្រើជាកសិណនោះផង ឯបដិភាគនិមិត្តមិនឃើញអ្វីក្រៅពីពណ៌ខៀវនោះឡើយ ឃើញច្បាស់តែពណ៌ខៀវម៉្យាង ។



www.elibraryofcambodia.org

៦ — បីតកសិណ

៧ — លោហិតកសិណ

៨ — ឱទាតកសិណ

ទាំង ៣ នេះមានន័យដូចគ្នានឹងនីលកសិណ គ្រាន់តែផ្លាស់ពណ៌ជាលឿង, ក្រហម, ស វិញប៉ុណ្ណោះ ។

៩ — អាលោកកសិណ

លោកបញ្ញត្តថា យកពន្លឺតាមចន្លោះជញ្ជាំង, បង្អួច ឬដុតភ្លើងរួចនោះប្រហោងយកពន្លឺភ្លើងដែលធ្លុះមកជាប់នៅទីណា ៗ ជាអារម្មណ៍ក៏បាន ឧគ្គហនិមិត្តកើតឡើង ឃើញពន្លឺនឹងរបស់ផ្សេង ៗ ដែលជាប់នៅទីនោះ ឯបដិភាគនិមិត្ត ឃើញចំពោះតែពន្លឺប៉ុណ្ណោះ ។

១០ — បរិច្ឆិន្នាកាសកសិណ

កសិណនេះ មើលទៅពិបាកជាងកសិណឯទៀត លោកបញ្ញត្តថា ឲ្យយកចន្លោះពេលណាមួយ ដូចជាចន្លោះបង្អួច, ទ្វារ, ជញ្ជាំង, ឲ្យនឹកតែត្រឹមចន្លោះប៉ុណ្ណោះ មិនឲ្យគិតនឹកដល់ពន្លឺឬខ្យល់ឲ្យសោះ ឧគ្គហនិមិត្តកើតឡើងឃើញចន្លោះព្រមទាំងក្របបង្អួច, ទ្វារ, ឬជញ្ជាំង ឯបដិភាគនិមិត្ត ឃើញតែចន្លោះពេលមួយមុខ មិនឃើញរបស់អ្វីជាប់ជាមួយផងឡើយ ។

www.elibraryofcambodia.org

## ២ — ឈាន

កាលណាចិត្តលុះអប្បនាសមាធិហើយ សេចក្ដីសប្បាយក្នុងកាមគុណទាំងអកុសលចិត្តទាំងឡាយក៏អស់ទៅ ពោលគឺអស់សេចក្ដីវល់ខ្វាយក្នុងកាមតណ្ហា ហើយមិនមានចិត្តប្រែប្រួលភ័យនឹងអ្នកណា ចិត្តស្ងប់ស្ងាត់បាន ទើបហៅថាបានឈាន ឈាននេះចែកជាពីរប្រភេទ គឺ

ក — រូបជ្ឈាន (ឈានមានរូប) ចែកជា ៤ គឺ

១ — បឋមជ្ឈាន ឈានទី ១

២ — ទុតិយជ្ឈាន ឈានទី ២

៣ — តតិយជ្ឈាន ឈានទី ៣

៤ — ចតុត្ថជ្ឈាន ឈានទី ៤ ។

ខ — អរូបជ្ឈាន (ឈានគ្មានរូប) ចែកជា ៤ ដូចគ្នាគឺៈ

១ — អាកាសានញ្ចាយតនជ្ឈាន ពិចារណាឃើញបដិភាគនិមិត្ត របស់កសិណទាំងនោះ ទាល់តែឃើញអាកាសទទេគ្មានអ្វីសោះ

២ — វិញ្ញាណញ្ចាយតនជ្ឈាន យកវិញ្ញាណជាអារម្មណ៍

៣ — អាកិញ្ចញ្ញាយតនជ្ឈាន គ្មានអ្វីជាអារម្មណ៍ឡើយ

៤ — នេវសញ្ញានាសញ្ញាយតនជ្ឈាន គ្មានអារម្មណ៍អ្វីឡើយ បុគ្គលដែលលុះដល់ទីនេះ នឹងថាដឹងខ្លួន ឬថាមិនដឹងខ្លួនក៏ពុំបាន ។



www.elibraryofcambodia.org

អ្នកដែលបានឃើញឈ្មោះឈានទាំង ៨ នេះហើយ គង់មានចិត្តធុញថប់ព្រួយពេក ដោយឃើញថាជារបស់ពិបាកចូលចិត្ត ហេតុដូច្នេះសូមអ្នកមើលកុំអាលលះបង់នូវសេចក្ដីឧស្សាហ៍ ចូរទុកចិត្តថាសៀវភៅវិជ្ជា ៨ ប្រការនេះនឹងចុះសុទ្ធតែសេចក្ដីធ្វើឲ្យអ្នកមើល បានយល់ចូលចិត្ត មិនយកសេចក្ដីដែលមិនយល់មកចុះទុកក្នុងនេះឡើយ ។

## ក៣ — អធិប្បាយពីរូបផ្កាឆ

មុនដែលយើងនឹងពិហារណាដល់រូបផ្កាឆ យើងត្រូវឲ្យយល់ចូលចិត្តពីចិត្តរបស់មនុស្សសិន ព្រោះចិត្តមនុស្សតែងតែមានធម្មជាតិច្រើនយ៉ាង ទាំងល្អទាំងអាក្រក់ច្របល់គ្នា ដូចជាពាក្យបុរាណថា កិលេសមួយពាន់ប្រាំរយ តណ្ហាមួយរយប្រាំបី តែយើងមិនបាច់យកចំនួននោះមកចែកអធិប្បាយឡើយ ទុកជូនលោកអ្នកប្រាជ្ញជាន់ខ្ពស់លោកពណ៌នាចុះ សម្រាប់ពួកយើងត្រូវការយកតែសេចក្ដី ដែលចូលចិត្តយល់ដ៏ល្មមសមគួរ យើងនាំយកតែត្រឹម ១០ ទាំងកិលេសនឹងតណ្ហា រួមនឹងធម្មជាតិដែលល្អផង ក្នុង ១០ ប្រការនេះ យើងយកមករៀបជាផ្លូវទុក ល្អ ១ ពួក អាក្រក់ ១ ពួក ដូច្នេះ


www.elibraryofcambodia.org

| ពួកល្អ | ពួកអាក្រក់ |
|---|---|
| ១– សមាធិ | ៦– កាមច្ឆន្ទ |
| ២– បីតិ | ៧– ព្យាបាទ |
| ៣– វិតក្ក | ៨– ថីនមិទ្ធ |
| ៤– សុខ | ៩– ឧទ្ធច្ចកុក្កុច្ច |
| ៥– វិចារ | ១០– វិចិកិច្ឆា ។ |

ចរិតទាំងនេះជាលក្ខណៈរបស់ចិត្តមនុស្សគ្រប់គ្នា ចំណែកចិត្តមនុស្សយើង មានចរិតទាំងដប់នេះ: នៅកាលណាបើចិត្តយើងកើតសេចក្ដីស្រឡាញ់ខ្លាំងនូវរបស់អ្វីមួយ កាមច្ឆន្ទកើតឡើងវេលានោះសមាធិក៏ខូច ចិត្តក៏អណ្ដែតអណ្ដូងមួយរំពេច ៗ តាមប្រក្រតី ចិត្តយើងមាន បីតិ តែកាល តែកាលណាបើចិត្តនឹកដល់របស់ដែលគេធ្វើឲ្យតាស់ចិត្តយើង បីតិក៏លោយក្លាយទៅជាព្យាបាទវិញ ៗ យើងមានចិត្តសម្រាប់នឹកគិតដល់របស់អ្វី ៗ មួយ ហៅថា វិតក្ក តែមានកាលយើងហាក់មិននឹកឃើញ ព្រោះចិត្តយើងស្ពឹកដោយងងុយដេក ថីនមិទ្ធក៏កើតឡើង ៗ ធម្មជាតិសាងយើងឲ្យមានសេចក្ដីសុខ យើងត្រូវការសេចក្ដីសុខគ្រប់គ្នា តែបើកាលចិត្តយើងរាយមាយជា ឧទ្ធច្ច នាំចិត្តជាកុក្កុច្ច មកកាត់សេចក្ដីសុខចេញ ៗ យើងមានសតិបញ្ញាសម្រាប់ត្រិះរិះ (វិចារ) រកផ្លូវដែលជាប្រយោជន៍របស់



www.elibraryofcambodia.org

ឃើញ តែកាលណាបើភិក្ខុសេចក្ដីសង្ស័យ ( វិចិកិច្ឆា ) មិនដាច់ស្រេចនៅឡើយណា ត្រិះរិះគិតអ្វីក៏មិនសម្រេច ។

កាលណាឃើញច្បាស់ចិត្តយល់សេចក្ដីទាំងនេះល្អហើយ ការដែលនឹងចូលចិត្តយល់ឋានឈានក៏ងាយទៀតជាអនេកគឺ:

១ — អ្នកដែលបានសម្រេចបឋមជ្ឈាន ( ឈានទី ១ ) អាចកាត់ប-ង់សេចក្ដីកក្រក់ទាំង ៥ ប្រការនោះចេញបាន នៅសល់តែគុណល្អទាំង ៥ គឺ: សមាធិ, បីតិ, វិតក្ក, សុខ, វិចារ ។

២ — គុណធម្មជាតិល្អទាំង ៥ ប្រការនេះ វិតក្កនិងវិចារ ក៏ជារបស់គ្រោតគ្រាតជាហេតុនាំធ្វើឲ្យចិត្តវិលវល់បាន ត្រូវព្យាយាមរំលត់វិតក្កនិងវិចារចេញ ឲ្យនៅសល់តែសមាធិ បីតិ និងសុខ ធ្វើបានសម្រេចដូច្នេះហៅថាបានលុះទុតិយជ្ឈាន ( ឈានទី ២ ) ។

៣ — យ៉ាងណាក៏ដោយ បីតិសេចក្ដីពេញចិត្តនោះ ក៏នៅជាធម្ម-ជាតិមិនទាន់ប្រាកដនៅឡើយ ខ្លាចក្រែងនាំយកធម្មជាតិអាក្រក់ចូលមកជាប់ទៀត ហេតុនេះត្រូវតែព្យាយាមលះបង់ចោលបីតិមួយនេះចេញទៀត ឲ្យសល់នៅតែសមាធិនិងសុខ អ្នកដែលធ្វើបានសម្រេចគុណថ្នាក់នេះ ឈ្មោះថាបានលុះតតិយជ្ឈាន ( ឈានទី ៣ ) ។

៤ — ទុកជាដល់ថ្នាក់នេះហើយ សេចក្ដីសុខក៏នៅជារបស់គ្រោត-

www.elibraryofcambodia.org

ត្រាតទៀត ព្រោះថាបើសុខនៅមាន ទុក្ខក៏គង់មានមកមួយថ្ងៃមិនខាន ព្រោះថាទុក្ខនឹងសុខជាគូនឹងគ្នា បានជាត្រូវលះបោលសេចក្ដីសុខចេញទៀត ឲ្យនៅតែសមាធិនឹងឧបេក្ខា គឺនៅព្រងើយមិនរវល់រវល់ឡើងទាំងអស់ នៅមានជួនចិត្តតែមួយដក់លំនឹង ហៅថា "ឯកគ្គតា" នេះហៅថាបានព្រះចតុត្ថជ្ឈាន (ឈានទី ៤) ។

តាមន័យនេះឃើញថា ពាក្យដែលហៅថា ឈាន នោះ ទុកជាធ្វើពិបាកយ៉ាងណាក្ដី ការដែលចូលចិត្តលក្ខណៈរបស់ឈានហើយ មិនពិបាកជួបឃើញតិចតួចមកនោះទេ ព្រោះសេចក្ដីអធិប្បាយទាំងប៉ុន្មានខាងលើ ជួយឲ្យអ្នកមើលចូលចិត្តលក្ខណៈរបស់រូបជ្ឈាន ដោយមិនពិបាកឡើយ ទីនេះរៀបជារបៀបលក្ខណៈឈានទាំង ៤ នេះឲ្យច្បាស់ ដើម្បីឲ្យអ្នកមើលមានគតិព្រួតថា ឈាននោះ គឺជួនចិត្តជាថ្នាក់ ៗ ពាល់តែសល់នៅបណ្ដាលដែលជារបស់ល្អបំផុតនោះឯង ។

## បិដ្ឋមនុស្សធម្មតា

| | |
|---|---|
| ១ — សមាធិ . . . . | ៦ — កាមច្ឆន្ទ |
| ២ — បីតិ . . . . . | ៧ — ព្យាបាទ |
| ៣ — វិតក្ក . . . . . | ៨ — ថីនមិទ្ធ |
| ៤ — សុខ . . . . . | ៩ — ឧទ្ធច្ចកុក្កុច្ច |
| ៥ — វិចារ . . . . . | ១០ — វិចិកិច្ឆា ។ |

## ចិត្តអ្នកលុះបឋមជ្ឈាន

១ — សហគត — ៦ — . . . . . . . .
២ — បីតិ — ៧ — . . . . . . . .
៣ — វិតក្ក — ៨ — . . . . . . . .
៤ — សុខ — ៩ — . . . . . . . .
៥ — វិចារ — ១០ — . . . . . . . ។

## ចិត្តអ្នកលុះទុតិយជ្ឈាន

១ — សហគត — ៦ — . . . . . . . .
២ — បីតិ — ៧ — . . . . . . . .
៣ — . . . . . . . . — ៨ — . . . . . . . .
៤ — សុខ — ៩ — . . . . . . . .
៥ — . . . . . . . . — ១០ — . . . . . . . ។

## ចិត្តអ្នកលុះតតិយជ្ឈាន

១ — សហគត — ៦ — . . . . . . . .
២ — . . . . . . . . — ៧ — . . . . . . . .
៣ — . . . . . . . . — ៨ — . . . . . . . .
៤ — សុខ — ៩ — . . . . . . . .
៥ — . . . . . . . . — ១០ — . . . . . . . ។

www.elibraryofcambodia.org

# ចិត្តអ្នកលុះចតុត្ថជ្ឈាន

១ — សមាធិ ៦ — . . . . . . . .

២ — . . . . . . . . ៧ — . . . . . . . .

៣ — . . . . . . . . ៨ — . . . . . . . .

៤ — . . . . . . . . ៩ — . . . . . . . .

៥ — . . . . . . . . ១០— . . . . . . . . ។

## ១- អធិប្បាយពីអរូបជ្ឈាន

ឈានទាំង៤ដែលពោលមកខាងដើមនោះ ហៅថារូបជ្ឈាន ព្រោះអាស្រ័យនូវវត្ថុដែលមានរូប គឺកសិណជាគ្រឿងជួយ បើអ្នកធ្វើធ្លាប់ចំរើនឈានទាំង ៤ ទាល់តែថ្នឹកវេលាណា បើត្រូវការធ្វើនឹងធ្វើបាន សម្រេចមួយរំពេច ត្រូវហាត់ចំរើនរបស់ដែលពិបាកនឹងល្អិតតទៀងទៅទៀត គឺលើកកសិណចោលចេញ ចូលឈានមិនបាច់ប្រើកសិណក៏បាន ហៅថា អរូបជ្ឈាន។ មាន៤ ប្រការគឺ:

១- យកអាកាសជាអារម្មណ៍ គឺផ្ចង់នឹកថា អាកាសៗ ជាពហុ-ជាតម៉ងហានអ្វីជាទីបំផុត កុំឲ្យនឹកដល់បដិភាគនិមិត្ត នឹងរូបជាអារម្មណ៍ឡើយ ហៅថា អាកាសានញ្ចាយតនជ្ឈាន ។

២- ឈប់លើកការផ្ចង់នឹកដល់អាកាសចេញ ត្រូវផ្ចង់នឹកដល់

វិញ្ញាណតែមួយៗថា វិញ្ញាណ ៗ ជាធម្មជាតគ្មានទីបំផុត ហៅថា វិញ្ញាណញ្ចាយតនជ្ឈាន ។

៣ – ឈប់លើកការដេញវិញ្ញាណចេញ កុំទុកដល់អ្វីឲ្យនោះ ព្រួងចិត្តដំកល់ឲ្យទន់ កុំឲ្យមានអ្វីមកប៉ះពាល់ ហៅថា អា-កិញ្ចញ្ញាយតនជ្ឈាន ។

៤ – កាលណាដួងចិត្ត ដំកល់ទីនៅក្នុងឈានយ៉ាងល្អិតបំផុត ដូច្នេះហើយបុគ្គលដែលចំរើនឈាននោះ ក៏បាននៅក្នុងភាពដែលកប់ចូលជាពិសេសមួយ ពោលគឺមានសេចក្ដីដឹងខ្លួនយ៉ាងតិចបំផុត ហាក់ដូចជាបាត់ដឹងខ្លួនអស់ហើយ ។ អ្នកណាទៅវាយដំដូចម្ដេចក៏មិនដឹងខ្លួនដែរ តែជីវិតគង់មាននៅហើយ ឈានក្នុងទីជាន់ខ្ពស់បំផុតនេះហៅថា នេវ-សញ្ញានាសញ្ញាយតនជ្ឈាន គឺជាទីមានសញ្ញា (conscient) ក៏ជាបាត់បង់ជាគ្មានសញ្ញា (inconscient) ក៏មិនមែន សូមអ្នកដែលមើលសៀវភៅនេះយល់ថា វិធីផ្សេង ៗ តាំងពីកសិណទៅដល់ឈាន នោះសុទ្ធតែជាវិធីហ្វឹកហ្វឺនដួងចិត្តជាថ្នាក់ ៗ តទៅ អ្នកដែលហ្វឹកហ្វឺនចិត្តដូច្នេះហើយ ដួងចិត្តតែងតែមានអំណាចជាទីបំផុត ចង់ប្រើអធិដ្ឋានធ្វើអ្វីក៏បាន ដូចហេតុពណ៌នាតទៅ ក្នុងចំណែកទី ៨ ប្រការ វេលាណាមិនត្រូវការប្រើអំណាចដួងចិត្ត ក៏ជាមនុស្សធម្មតា តែបើត្រូវការប្រើក៏ចូលឈានមួយរំពេចបាន មិនថាថ្នាក់ណា ហេតុនេះបានជាកប់ថាមានគ្រឿង

www.elibraryofcambodia.org

ប្រដាប់យ៉ាងប្រសើរ សម្រាប់ធ្វើការដែលមនុស្សធម្មតាធ្វើពុំបាន ព្រោះហេតុនេះបានជាហៅកសិណ ទីនឈាន ជាកាំជណ្ដើរដំបូងរបស់វិជ្ជា ៨ ប្រការ ។

សេចក្ដីបរិយាយពីលទ្ធយោគ គឺទីនកសិណ ហើយទីនឈាន ដូចខាងមកហើយនោះក៏ល្មមសមគួរហើយ តពីនេះនឹងបានបរិយាយចំណែកវិជ្ជា ៨ ប្រការផ្សេងៗ សម្រាប់ប្រដាប់សតិបញ្ញាបារមីរបស់អ្នកមើលតទៅ ។

## វិជ្ជាប្រការទី ១

### វិបស្សនាញាណ

វិបស្សនាញាណ មានចំណែកចែកចេញជា ៩ យ៉ាងគឺ:

១ — ឧទយព្វយានុបស្សនាញាណ ប្រាជ្ញាកំណត់ឃើញសេចក្ដីកើតនិងរលត់នៃសង្ខារ

២ — ភង្គានុបស្សនាញាណ ប្រាជ្ញាកំណត់ឃើញសេចក្ដីរលត់នៃសង្ខារ

៣ — ភយតុបដ្ឋានញាណ ប្រាជ្ញាកំណត់ឃើញសង្ខារជាគួរខ្លាច

៤ — អាទីនវានុបស្សនាញាណ ប្រាជ្ញាកំណត់ឃើញទោសនៃសង្ខារ

៥ — និព្វិទានុបស្សនាញាណ ប្រាជ្ញាពិចារឃើញរូបសង្ខារជាគួរនឿយណាយផងធ្ងន់

៦ — មុញ្ចិតុកម្យតាញាណ ប្រាជ្ញាពិចារដោយមានប្រាថ្នានឹងចង់ចេញឲ្យផុតទៅ

៧ — បដិសង្ខានុបស្សនាញាណ ប្រាជ្ញាពិចារតិតរកផ្លូវរតចាយ

៨ — សង្ខារុបេក្ខាញាណ ប្រាជ្ញាពិចារដោយសេចក្ដីព្រងើយកន្តើយក្នុងសង្ខារ

៩ — សច្ចានុលោមិកញាណ ប្រាជ្ញាប្រព្រឹត្តទៅដោយសមគួរដល់ការកំណត់ដឹងនូវអរិយសច្ច ។

តាមសេចក្ដីអធិប្បាយ របស់សម្ដេចព្រះមហាសមណវរញ្ញាណ-វិសេស ទ្រង់ធ្វើអត្ថាធិប្បាយទុកថា ញាណទី ១ ពិចារឃើញសេចក្ដីកើតនិងសេចក្ដីរលត់នៃសង្ខារ ។ ញាណទី ២ លើកលែងពិចារដល់សេចក្ដីកើត ពិចារយកជាអារម្មណ៍ចំពោះតែសេចក្ដីរលត់នៃសង្ខារនោះវិញ ។ ញាណទី ៣ ពិចារឃើញសង្ខារនោះមានសេចក្ដីរលត់ជាប្រាកដ គួរឲ្យខ្លាច ដូចខ្លាចសត្វសាហាវមានសីហៈជាដើម ។ ញាណទី ៤ ពិចារឃើញទោសនៃសង្ខារនោះដូចជាផ្ទះដែលភ្លើងឆេះហើយ ។ ញាណទី ៥ ពិចារដល់សង្ខារដែលនាំឲ្យមានទោសក៏នឿយណាយផងធ្ងន់ ។ ញាណ

www.elibraryofcambodia.org

ទី ៦ គឺចង់ចេញចាកពីសង្ខារ ដែលបានឃើញភ័យហើយនោះ ដូចជាសត្វត្រីដែលជាប់អន្ទាក់ចង់តែឲ្យរួចចេញពីអន្ទាក់ ។ ញាណទី ៧ គឺដោយពិចារណាត្រិះរិះរកផ្លូវចេញឲ្យផុតពីសង្ខារ ដូចជាសត្វដែលហៅថាសមុទ្រ-សកុណចុះលេងក្នុងសមុទ្រ ។ ញាណទី ៨ គឺដោយសេចក្តីព្រងើយកន្តើយក្នុងសង្ខារ ដូចជាបុរសដែលមិនអើពើនឹងភរិយាដែលបានលែងគ្នាហើយនោះ ។ ញាណទី ៩ គឺនៅដោយខណៈនៃចិត្តដែលកើតជាអនុលោមកើតឡើង ក្នុងលំដាប់នៃមគ្គវិថី កាត់ផ្លូវចិត្តដែលកើតឡើងក្នុងខណៈដែលអរិយមគ្គនឹងកើតជាទីបំផុតនៃសង្ខារុបេក្ខាញាណ ។

សេចក្តីអធិប្បាយរបស់សម្តេចព្រះមហាសមណអស់តែប៉ុណ្ណេះ ។

បើយើងពិចារណាមើលឲ្យល្អ នឹងឃើញជាធម៌ទាំងឡាយរបស់ព្រះពុទ្ធជាម្ចាស់គ្រប់ៗ ក្រៅពីធម៌ឯទៀតដែលគួរសរសើរហើយនោះ នៅមានធម៌ដែលគួរសរសើរជាទីបំផុត គឺវិជ្ជា ៨ ប្រការនេះ គួរសរសើរណាស់ ព្រោះរៀបរៀងជាលំដាប់ចុះល្អណាស់ គឺមានវិបស្សនាញាណជាខាងដើម ហើយមានអាសវក្ខយញាណជាទីបំផុត ញាណទាំង ២ នេះ បើត្រិះរិះគិតឲ្យល្អិតនៅឃើញជាញាណទាំង ២ ប្រការនេះ ជាគោលសំខាន់បំផុតក្នុងវិជ្ជា ៨ ប្រការ បើខ្វះញាណទាំង ២ នេះហើយ វិជ្ជាទាំង ៦ ប្រការនោះ មិនប្រព្រឹត្តទៅតាមធម៌បានឡើយ ត្រឡប់ជាគ្រឿងប្រដាប់ សម្រាប់ធ្វើការទុច្ចរិតទៅវិញ ។

អ្នកមើលគន់យល់ថា ការតែងសៀវភៅនេះ រៀបរៀងគន្លងផ្លូវបុគ្គលាធិដ្ឋាន ពោលគឺទីងពិសោធឲ្យឃើញថា ព្រះពុទ្ធជាម្ចាស់មានបុទ្ធិពិតមែន ហើយសំដែងបាដិហារិយ៍បានទៅក្រៃលែងជាងមនុស្សធម្មតា ទ្រង់ហានចិត្តលោក ទ្រង់ត្រេកជាតិបានហើយ ទ្រង់មានទិព្វចក្ខុឃើញធម៌ ដែនដី ចំងាយកៀកពិតមែន សាវករបស់ព្រះអង្គដែលលុះវិជ្ជាទាំង ៨ នេះ ក៏អាចធ្វើបានប្រាកដពិត រូបសេចក្តីថាមនុស្សយើងបើបានហ្វឹកហ្វឺនប្រ-ពៃចិត្ត (développer) តាមគោលវិជ្ជា ៨ ប្រការនេះហើយ បើមានឫទ្ធិតេជៈយ៉ាងតិច ក៏អាចមើលធ្លុះកំផែងបានឬក៏ឮសំឡេងពីឆ្ងាយលើសវិស័យក្រៅពីមនុស្សធម្មតាដែលទាំងឮបាននោះ (មិនបាច់ប្រើតេលេស្កូ) ។

គ្រានេះនឹងគេមានពាក្យសើកសៀតមកថា បើមនុស្សយើងអាចធ្វើបានដល់ទីនេះហើយ ហេតុអ្វីមនុស្សក្នុងលោកក៏ទៅយកចិត្តទុកដាក់រៀនវិជ្ជាផ្សេងៗទៅវិញ មិនរៀនវិជ្ជាទាំង ៨ ប្រការនេះឲ្យសម្រេចទៅនឹងបានទិព្វចក្ខុមើលល្បែងលេងស៊ីសងជាប្រាក់ យកឈ្នះឲ្យបានប្រាក់មកធ្វើជាសេដ្ឋី បើមានប៉ូលិសឬសង់ដាមមកចាប់ ក៏សំដែងឫទ្ធិហោះឬមុជផែនដីទៅ ឬទៅស្រុកមួណាកូ លេងល្បែងនៅទីមង់តេកាឡូឲ្យឈ្នះ ហើយយកប្រាក់ទាំងលានទាំងកោដិមកធ្វើជាមហាសេដ្ឋី ពួកបាក់ងដែលមិនជឿក្នុងវិជ្ជានេះ ក៏សួរថាដូចជាប្រទេសឥណ្ឌា មានយោគី



www.elibraryofcambodia.org

ពាសពេញទៅតាមភ្នំហិមាល័យ សុទ្ធតែអ្នកខ្លួនថា តើយ៉ាងណា ព្រោះយ៉ាងនេះ បាន ហេតុអ្វីក៏មិនធ្វើឲ្យស្រុកឥណ្ឌារួចពីអំណាចអង់គ្លេសទៅជាឯករាជ្យ ជាមហាប្រទេសជាធំក្នុងលោកទៅ ? ពាក្យស៊កសៀតឯទៀតៗ ក្រៅពីនេះនៅមានជាច្រើន តែយើងអាចតបដោះស្រាយដោយងាយ គឺថា មនោមយិទ្ធិ ឥទ្ធិវិធិ ទិព្វសោត ទាំងធម៌ប្រការឯទៀតដែលមានក្នុងវិជ្ជាទាំង ៨ នោះ បើមិនបានសម្រេចវិជ្ជាដំបូងគឺវិបស្សនាញាណទេ ក៏ពុំអាចចំរើនឲ្យវិជ្ជាទាំងនេះកើតបានឡើយ ។

យើងគួរសង្កេតម្យ៉ាងទៀត ថាធម៌របស់ព្រះពុទ្ធជាម្ចាស់ទ្រង់ រៀបដូចជាដែលមក អាចយកទៅប្រើការក្នុងផ្លូវល្អឬផ្លូវខូចក៏បាន តែជាធម៌របស់ព្រះពុទ្ធជាម្ចាស់ មិនបានសម្រាប់ទុកឲ្យប្រើក្នុងផ្លូវខុសទេ បានជាមានល័ក្ខណ៍បញ្ញត្តិទុក ដូចជាវិជ្ជា ៨ ប្រការនេះ មនុស្សដែលនឹងចំរើនបាន ចំពោះតែមនុស្សដែលមានប្រាជ្ញា រំពឹងឃើញសេចក្តីកើត សេចក្តីស្លាប់ ឃើញសង្សារគួរឲ្យខ្លាច ឃើញទោសជំទន់ចង់តែចៀសចេញឲ្យផុតពីសង្សារ ពិចារណារកផ្លូវនឹងធ្វើត្រើយកន្ទ្រើយ ក្នុងទីបំផុតមានប្រាជ្ញាកំណត់ដឹងអរិយសច្ច អ្នកដែលមានប្រាជ្ញាដូចពោលមកនេះជាអ្នកមានចិត្តប្រាថ្នាតែបន្ទាយពីកាមតណ្ហា ប្រាកដជាមិនប្រើឥទ្ធិវិធិទិព្វ-សោត ទិព្វចក្ខុ ក្នុងផ្លូវស្វែងរកប្រយោជន៍របស់ខ្លួន ហើយធ្វើឲ្យខូចខាត



www.elibraryofcambodia.org

អន្តរាយរបស់អ្នកដទៃនោះឡើយ ហេតុដូច្នេះមនុស្សយើងនឹងរៀនឥទ្ធិវិធិ, ទិព្វសោត ទិព្វចក្ខុ, ឲ្យសម្រេចបាន ដើម្បីយកទៅប្រើក្នុងការអាក្រក់ដូចមានពោលមកនេះ ពុំអាចចំរើនបានឡើយ ព្រោះមនុស្សដែលមានសេចក្តីគិតដូច្នោះ ហៅថាព្រាសចាកវិបស្សនាញាណដែលជាគ្រឿងឧបករណ៍របស់វិជ្ជាឯទៀតៗ

ដូចជារដ្ឋការក្នុងស្រុក មិនអនុញ្ញាតឲ្យអ្នកណាមានកាំភ្លើងកាន់ កាប់ លុះតែឈ្មោះនោះមានលក្ខណ៍ ជាមនុស្សមានកេរ្តិ៍ឈ្មោះល្អពិត មិនបានយកទៅប្រើខុសច្បាប់ ទើបរដ្ឋការអនុញ្ញាតឲ្យកាន់កាប់កាំភ្លើងបាន យ៉ាងដូចម្តេចមិញ ខាងធម៌ក៏ដូច្នោះ ព្រះពុទ្ធជាម្ចាស់ទ្រង់មិនអនុញ្ញាតឲ្យអ្នកណាមានឥទ្ធិវិធិ ទិព្វសោតនិងទិព្វចក្ខុបាន ព្រោះតែទ្រង់យកវិជ្ជាបីប្រការនេះ ទៅប្រើក្នុងផ្លូវដែលធ្វើឲ្យគេខូចប្រយោជន៍ លុះតែមនុស្សនោះមានវិបស្សនាញាណជាមុន បានចំរើនវិជ្ជាទាំងនេះបាន ព្រោះវិបស្សនាញាណប្រដូចនឹងកេរ្តិ៍ឈ្មោះដែលល្អពិតជាមិនយកទៅប្រើក្នុងការដែលធ្វើឲ្យអន្តរាយដល់អ្នកទាំងពួង ។

រួមសេចក្តីថា ការរៀនវិជ្ជា ៨ ប្រការនេះ នឹងសម្រេចបាន

១ — លុះតែជឿជាក់ថា មិននាំយកទៅប្រើក្នុងផ្លូវខុស មុននឹងឲ្យជឿនេះត្រូវធ្វើឲ្យបានសម្រេចវិបស្សនាញាណសិន ,

២ - ត្រូវមានចិត្តប្រាថ្នាឲ្យបានលុះអាសវក្ខយញាណជាទីបំផុត ពោលគឺត្រូវផ្ចង់ចិត្តរបស់ខ្លួនឲ្យផុតចាកគ្រឿងសៅហ្មងទាំងឡាយ ហេតុនេះហើយបានជាថាធម៌ពួកនេះ ត្រូវឲ្យមានវិបស្សនាញាណជាដំបូង ទើបអាសវក្ខយញាណជាបរិយោសាននោះទុកជាត្រូវណាស់ ។

## គ្រានេះមានបញ្ហា ២ ប្រការគឺ

១ - ពួកអសុរៈ ដែលមានចិត្តបាបអាក្រក់ ហេតុអ្វីក៏ហោះបាន ?

២ — បើចាំឲ្យសំរេចវិបស្សនាញាណជាមុន បានធ្វើវិជ្ជាឯទៀតបាន នោះ ធម៌ពួកនេះទើបមិនជាប្រយោជន៍អ្វី ដល់មនុស្សសម័យនេះទៀត ព្រោះក្នុងសម័យនេះរកអ្នកដែលបានសម្រេចវិបស្សនាញាណនោះពិបាកណាស់ ។

## សូមតបបញ្ហា ២ ខនេះដូច្នេះ

១ — ពីរឿងអសុរហោះបាននោះមិនខុសពីសត្វស្លាបហើយទេ ក្នុងរឿងនេះព្រះពុទ្ធឃោសាចារ្យ ដែលជាអ្នករចនាគម្ពីរវិសុទ្ធិមគ្គ កាលលោករៀនគម្ពីរក៏បានរកដល់បញ្ហានេះដែរ បានជាលោកចារិកទុកថា ការហោះនោះមិនមែនតែបានសម្រេចក្នុងវិជ្ជា ៨ ប្រការទើបហោះបាននោះទេ នៅមានផ្សេងឲ្យហោះបានទៀត ពោលគឺឫទ្ធិដែលកើតដោយផលកម្ម ដូចជាសត្វស្លាបឬយក្សដែលជាពួកអសុរ ឫទ្ធិដែលកើតដោយ



www.elibraryofcambodia.org

វិជ្ជាការ ដូចជាគ្រឿងសព្វាយុធនេះប្រៀបនឹងឫទ្ធិហោះ ឯអស្សហោះបាន នោះព្រះពុទ្ធឃោសាចារ្យ ពោលថាជាអំណាចនៃកម្ម ។

១២ — នោះយើងត្រូវយកវិជ្ជា ៨ ប្រការនេះ ប្រដូចនឹងគ្រឿងយន្តដែលប្រើប្រេងសាំង អ្នកដែលមានគ្រឿងបែបនេះបើគ្មានប្រេងសាំងនឹងយកប្រេងកាតប្រើក៏បាន តែម៉ាស៊ីនដើរមិនលឿនដូចប្រេងសាំង បើប្រសិនជាយកទឹកទៅប្រើវិញ ម៉ាស៊ីននោះក៏ដើរពុំបានឡើយ ឬបើមានខ្សាច់លាយផងប្រេងផង ក៏រឹតតែនាំឲ្យខូចម៉ាស៊ីនថែមទៀត វិបស្សនា-ញាណប្រៀបដូចប្រេងសាំង សម្រាប់ប្រើចំពោះតែគ្រឿងយន្តគឺវិជ្ជា ៨ ប្រ-ការនេះ អ្នកដែលមានវិបស្សនាញាណប្រាកដនោះ ដូចមានប្រេងសាំងទើបអាចធ្វើវិជ្ជា ៨ ប្រការ ដែលប្រៀបដូចគ្រឿងយន្តឲ្យដើរបានយ៉ាងស្រួលជាទីបំផុត បើប្រសិនជារកប្រេងសាំងមិនបាន ឬមិនចេះប្រើយកប្រេងកាតមកប្រើជំនួសគ្រឿងយន្តក៏គង់ដើរបានខ្លះ ដូចជាអ្នកដែលមិនចេះស្គាល់វិបស្សនាញាណ ឬមិនអាចប្រើវិបស្សនាញាណបាន ទើបយកធម៌ឯទៀតដែលមានកំឡាំងតិចជាង ដូចជាមេត្តា ករុណា ឬធម៌ណាដែលជាកុសល ក៏អាចនឹងធ្វើវិជ្ជា ៨ ប្រការនេះឲ្យសម្រេចបានខ្លះដែរ តែមិនអាចធ្វើឲ្យបានដូចវិបស្សនាញាណទេ ។

វិជ្ជា ៨ ប្រការជាធម៌ដែលបែកជាមែកជាធាង ចេញមកពីអភិញ្ញា

www.elibraryofcambodia.org

អភិញ្ញានោះ តាមគម្ពីររបស់ព្រះពុទ្ធឃោសាចារ្យជាមាន៥គឺ ឥទ្ធិវិធិ សំ-ដែងឫទ្ធិបាន ទិព្វសោត ត្រចៀកទិព្វ ចេតោបរិយញ្ញាណ ដឹងចិត្តអ្នកដទៃ បុព្វេនិវាសានុស្សតិញ្ញាណ រលឹកជាតិបាន ទិព្វចក្ខុ ភ្នែកទិព្វ បើតាមព្រះនិពន្ធរបស់សម្តេចមហាសមណៈ ជាមាន៦គឺបញ្ចូលអាសវក្ខយញ្ញាណ ចេះធ្វើអាសវៈឲ្យអស់ទៅ តាមសេចក្តីក្នុងព្រះនិពន្ធព្រះបឋមសម្ពោធិកថារបស់សម្តេចព្រះបរមានុជិតជិនោរស មានសេចក្តីធ្វើឲ្យចូលចិត្តថា អភិញ្ញាទាំងនេះ កាលក្នុងសម័យមុនព្រះពុទ្ធជាម្ចាស់ ក៏មានអ្នកបានសម្រេចខ្លះហើយ ដូចជាតាបសទាំងឡាយក្នុងគ្រានោះក៏អាចហោះហើរដើរលើអាកាសបាន តែមិនធ្វើឲ្យបានល្អស្មើនឹងព្រះពុទ្ធជាម្ចាស់នោះគ្មាន ទុកជាធ្វើប្រការឯទៀតបាន ក៏គង់នៅជាប់ត្រឹមប្រ-ការ៦គឺ អាសវក្ខយញ្ញាណ គិតធ្វើទៅពុំរួច បានជាគិតជាការវែល ទីងធ្វើកេសវៈឲ្យអស់ទៅជាប្រាកដនោះ គេធ្វើកងកាយប្រៀលប្រាក ដីរេកភ្លើងមកធ្វើកាយ អត់អាហារទាល់តែស្លាប់ លេងអគ្គិលជាកុហោក ក៏កើតមានឡើងដោយប្រការដូច្នេះ ដល់មកសម័យព្រះពុទ្ធជាម្ចាស់ ទ្រង់បានរកឃើញវិបស្សនាញាណ ដែលជាក្បួនសោធសំខាន់ ហើយបានទាំងមនោមយិទ្ធិមកមួយទៀត ទើបបង្កើតជាវិជ្ជា ៨ ប្រការឡើង ធ្វើឲ្យអភិញ្ញាផ្សេងៗមានចំនួនច្រើនថែមទៀត ពួកតាបសដែលចំរើន

អកិញ្ញា ក្នុងសម័យមុនព្រះពុទ្ធជាម្ចាស់ ក៏មានតាំងចិត្តបដិបត្តិតាមគោល វិបស្សនាញាណមកហើយដែរ តែគេឲ្យឃើញជាប្រាកដនោះពុំបាន ក៏ដូចជាគ្រឿងម៉ាស៊ីនប្រើទឹងប្រេងកាត តែងតែមានសេចក្ដីពិបាក ឬក៏សម្រេចបានយ៉ាងផ្លិះ ៗ ។

កាលល្អរបស់យោគី គេគ្មានគោលជាប្រាកដ ដូចវិបស្សនាញាណរបស់យើងទេ តែគេក៏មានរបៀបច្បាប់ដ៏សំខាន់ជាដើមថា ការរៀនវិជ្ជាគេអំណាចសម្រាប់ខ្លួនឯងនេះគោរពមានសេចក្ដីចំណាំដោយស្មោះត្រង់ (honnêteté dans les intentions) ហើយត្រូវទុកចិត្តឲ្យប្រាកដ ជាមិនយកវិជ្ជាទាំងនេះទៅប្រើក្នុងផ្លូវខុស ក្នុងសៀវភៅរបស់យោគីរាមៈចរកៈ គោលថា ទុកជាមនុស្សធម្មតា ក៏អាចលុះវិជ្ជាផ្សេង ៗ ទាំងនេះបាន តែថាបើលុះបាននោះទាល់តែចិត្តរបស់មនុស្សនោះខ្ពស់ហួសធម្មជាតិតាមទៅហើយ ហើយមានច្បាប់របស់ធម្មជាតិមួយថា "បើយើងមិនត្រូវការប្រើអំណាច ជាប្រយោជន៍ផ្ទាល់ខ្លួនរបស់យើងទេ ទើបអំណាចនោះនឹងកើតឡើងដល់យើង ហេតុនេះបានជាគេប្រដៅថា ការរៀនវិជ្ជាទាំងនេះ ក្នុងជាក់ដំបូងឲ្យមានសេចក្ដីទុកចិត្តថា បើយើងបានរៀនសម្រេចហើយ នឹងប្រើវិជ្ជាទាំងនេះជាប្រយោជន៍ដល់មនុស្សដូចគ្នា ប្រយោជន៍ដែលយើងនឹងធ្វើឲ្យមនុស្សម្នាក់នោះ ក៏ត្រូវតែគិតមើលថាប្រយោជន៍នោះនឹងធ្វើឲ្យក្ដៅក្រហាយដល់មនុស្សឯទៀតដែរឬទេ ។

www.elibraryofcambodia.org

ឯវិបស្សនាញាណនេះ បើអ្នកណាមិនសិក្សាដោយចិត្តជាកុសល-ធម៌ទេ ពិតជាពុំអាចធ្វើវិជ្ជាផ្សេងៗឲ្យសម្រេចបានឡើយ បើរៀនដោយចិត្តមិនបរិសុទ្ធគិតយកទៅប្រើការជាប្រយោជន៍របស់ខ្លួនតែមួយហើយនឹងធ្វើឲ្យខូចប្រយោជន៍របស់ទ្រព្យអ្នកដទៃ ដូចជាប្រើសម្រាប់បំបាត់ប្រពៃល្អទ្រព្យឬធ្វើទុក្ខគេដោយប្រការផ្សេង ដូចមានពោលមកនេះ គឺនឹងបានតែផល ២ ប្រការគឺ ១- រៀនវិជ្ជានេះមិនសម្រេច ។ ២- នឹងមានទោសផលខ្លួនឯង ដូចជាមនុស្សដែលរៀនធ្វើស្នេហ៍ អំពើពិធីគុណវិសេសផ្សេងៗនោះ ពុំឃើញប្រាកដជាធ្វើអ្វីឲ្យបានសម្រេចជាពិតនោះឡើយ បុគ្គលនឹងបានទទួលនូវសេចក្តីចំរើន សេចក្តីសុខអ្វីក៏ទេ អំពីការធ្វើស្នេហ៍ធ្វើមេមត់ ធ្វើគុណវិសេសផ្សេងៗនេះបាក់ដ៏ក៏មាននេះជឿជាច្រើន ក្រៃលែងគេស៊ុំកាមធុរនេះក៏មាន តែមនុស្សអស់នេះមិនត្រូវតែសរុបគឺទៅជាធ្មិនលេលាទៅឯងៗ ព្រោះធម្មជាតិក៏តែងតែមានច្បាប់ដូចគេដាក់ស្រុកដែរ (Loi de la nature) ហើយមានច្បាប់របស់ធម្មជាតិនេះទោសធ្ងន់ជាងច្បាប់សម្រាប់ស្រុកទៀត ។

សេចក្តីបរិយាយមកទាំងនេះ នឹងសំដែងឲ្យលោកអ្នកមើលស្គាល់យល់ច្បាស់ថា វិបស្សនាញាណ កាលដើមលោកគិតថា មិនបាច់មានក៏បានដែរនោះពុំត្រូវទេ ធម៌នេះពិតជាត្រូវការប្រកបតែវិជ្ជា ៨

ប្រការ ជាក្រាលដណាស់ ព្រោះវិបស្សនាញាណ ជាគ្រូនោះដ៏សំខាន់ ដែលនាំឲ្យយើងចូលចិត្តលក្ខណៈរបស់វិជ្ជាទាំង ៨ ហើយជាឧបករណ៍ ជួយឲ្យសម្រេចវិជ្ជាផ្សេងៗទាំងអស់នោះផង ។

## វិជ្ជាប្រការទី ២

យើងបានដឹងសេចក្តីអធិប្បាយមកច្រើនហើយថា ចិត្តមនុស្សមានអំណាចលើកាយទាំងមូល ពោលគឺរូបកាយនឹងកម្រើកបាន ដោយប្រការដូចម្តេច ឬមនុស្សយើងនឹងប្រព្រឹត្តល្អ ឬអាក្រក់យ៉ាងណា ក៏សម្រេចនូវដួងចិត្តទាំងអស់ ព្រោះចិត្តមានអំណាចបង្គាប់កាយគនៈខាងក្នុងគ្រប់យ៉ាង ពាក្យនេះជាពាក្យប្រដៅ ដែលយើងបានទទួលរៀនចាប់ពីថ្នាក់ដំបូង តែគ្រានេះយើងល្បងពិចារណាថា ក្រៅពីការកម្រើកកាយប្រក្រតីហើយ តើចិត្តយើងអាចធ្វើអ្វីបានខ្លះ តាមពុទ្ធភាសិតដែលថា "មនោសេដ្ឋា មនោមយា" នោះតើសំដៅសេចក្តីត្រឹមណា ?

ការវិជ្ជាពេទ្យសាស្ត្ររបស់បារាំង គេថាមានធម្មជាតិម្យ៉ាង ហៅថា ស៊ុបកុងស្យ៉ង់ (subconscience) នឹងមិនឃើញថា ត្រូវនឹងពាក្យអ្វីក្នុងភាសាយើង ទើបសូមប្រែជាបណ្តោះអាសន្ន ចុះសិនថា "កាយគនៈខាងក្រោម" ដែលបារាំងអធិប្បាយថា មនុស្សយើងប្រៀបដូចដុំទឹកកកអណ្តែតក្នុងទឹកសមុទ្រ យើងមើលឃើញតែត្រឹមភាគខាងលើទឹក ឯភាគ

www.elibraryofcambodia.org

នៅខាងក្រោមទឹកដែល យើងមើលពុំឃើញនោះ ទៅជាកន្លែងជាច្រើន ភាគជាងភាគដែលនៅលើទឹក មនុស្សក៏ដូចគ្នា យើងឃើញមនុស្សជា ធ្វើការអ្វីៗអាចធ្វើបានតែត្រឹមណោះ ដែលជាប្រាកដនោះ នៅធ្វើបាន ច្រើនជាអនេកទៀត ។ ឧទាហរណ៍ដែលនឹងនាំបកពិសោធក្នុងរឿងនេះនៅ មានច្រើន ដូចដែលបាននិយាយតៗមកថា វេលាដែលមានភ្លើងឆេះ ផ្ទះនោះ មនុស្សម្នាក់លើកទូដែកដាក់ប្រាក់ដែលធ្ងន់ណាស់រួច ដល់ភ្លើង រលត់វិញនឹងលើកតែម្នាក់ឯងពុំរួច គាត់តែហៅគេឯងឲ្យជួយទើបបានរួច កិច្ចការនេះយើងគិតថាហួសវិស័យនឹងធ្វើបាន តែបើមានអំណាចអ្វីមក បង្គាប់ឲ្យយើងធ្វើ យើងក៏ធ្វើបានសម្រេច មនុស្សដែលដើរក្នុងព្រៃអស់ កំឡាំងណាស់ពុំអាចនឹងដើរទៅទៀតបាន តែបើឃើញខ្លាឬសត្វសាហាវ វាដើរមកចំមុខ ក៏អាចរត់បានឆ្ងាយតទៅទៀត ។ មានរឿងក្នុងសៀវភៅ អ្នកប្រាជ្ញបារាំង ខ្លះជឿថាគេជាអ្នកប្រាជ្ញ គេនិទានរឿង គោលថា មានកេងល្ងាចសត្វមួយកន្លែង ទ្រុងដែលដាក់សិង្ហនោះ សិង្ហក៏ហក់ ចេញទៅ ដើរហើលប៉ាលទៅតាមផ្លូវ រួចក៏ចូលទៅក្នុងផ្ទះផ្សេងៗ ហើយបានចូលទៅក្នុងផ្ទះមួយមានមនុស្សទើបតែកំណើតក្មេងកើតពុំរួច លុះ ឃើញសិង្ហមក ក៏ក្រោករត់បានដូចមនុស្សជា ដល់សិង្ហចេញទៅវិញក៏ ត្រឡប់ខ្វិនដូចដែល រឿងនេះបានអធិប្បាយថា ព្រោះភ័យគនខាង

ក្រោម " ស៊ុបកុងស៊ីយ៉ង់ស៍ " ដែលជ្រែកចូលទៅក្នុងខួរមនុស្សនោះ ទៀត មកធ្វើប្រយោជន៍ឲ្យក្នុងវេលាកំពុងត្រូវការជាប្រាកដ តែសេចក្ដីត្រូវការនេះ លុះតែខ្លាំងលើសលុបជាងការតាំងចូល លើសពីមនុស្សដែលត្រូវការជាធម្មតា បានជាបាក់ង់យកហេតុនេះទុកជាគោលប្រដៅថា បើចង់ធ្វើឲ្យសម្រេចការអ្វីមួយៗ ត្រូវយកចិត្តទុកដាក់ក្នុងការដែលត្រូវការនោះឲ្យខ្លាំងជាបំផុត ពួកជាតិអង់គ្លេសតាំងជាសុភាសិតថា "បើមានសេចក្ដីត្រូវការត្រង់ណា គង់មានផ្លូវទៅត្រង់នោះ" (avec de la volonté on atteint le but)

យើងគង់តែប្រទះឃើញ អ្នកដែលបានរៀនសិក្សាដូចយើង ប្រឡងក៏បានដូចយើង ចំណេះចេះដឹងក៏ស្មើនឹងយើង តែគេធ្វើការបានល្អជាងយើង របស់អ្វីដែលយើងធ្វើសម្រេចក្នុង ៣ ម៉ោង គេធ្វើតែ ១ ម៉ោងសម្រេច ឬក៏កាលសម្រេចបានល្អជាងយើងដែលធ្វើតាំង ៣ ម៉ោងនោះផង ហើយរបស់អ្វីដែលយើងធ្វើមិនកើតសោះ តែគេធ្វើសម្រេចបានយ៉ាងងាយៗ មនុស្សបែបនេះហើយដែលគេចេះនាំយកអាយតនខាងក្រោមទៀតមកជួយបាន បាក់ង់យកចិត្តទុកដាក់ជាបំផុតក្នុងការប្រដៅថ្នាបណ្ដុះគំនិតរបស់មនុស្ស (éducation mentale)

ឧទាហរណ៍ផ្សេងៗ ដែលបាននិយាយមកខាងដើមនេះ ក៏គឺមនោ.

www.elibraryofcambodia.org

មហិទ្ធិរបស់ហេតុនេះឯង មិនមែនយ៉ាងឯទៀតឡើយ ពាក្យថាមហិទ្ធិនោះ ឃើញថាត្រង់នឹងភាសាដែលបារាំងហៅថា ( volonté ) ការពិតអធ្យាស្រ័យខ្ញុំឃើញថា ឫទ្ធិនេះ ជាសំខាន់បំផុត ដែលនឹងបណ្តុះចិត្តឲ្យមានអំណាច គឺហាត់ឲ្យចេះយកកាយគនទាំងក្រោមទៀងបរបើបានខ្លះ វិធីបណ្តុះចិត្តបែបយ៉ាងណានោះ បារាំងគេបានជ្រើសរើសទុកយ៉ាងពិស្តារ ហើយពីសេចក្តីដែលគេបកក្នុងសៀវភៅនេះ ។

បើយើងពិនិត្យ ប្រវត្តិរបស់មនុស្ស ដែលលុះរស់ជាងគេក្តី ឬមនុស្សដែលបានលុះដល់ផលគ្រប់ៗ យ៉ាង ដែលត្រូវការហើយនោះ នឹងឃើញថាមនុស្សទាំងនោះ មានចំណង់យ៉ាងខ្លាំងលើផលនោះ ហើយធ្វើការគ្រប់ៗ យ៉ាង ដើម្បីឲ្យបានសម្រេចនូវផលនោះជាប្រាកដ ឯមនុស្សដែលត្រូវធ្វើការឲ្យអស់តែកំឡាំង មិនបានផលសោះឡើយក្នុងមួយជីវិតរកសេចក្តីចំរើនមិនបាន មកពីធ្វើការកាយកាយខ្លួនរបស់ខ្លួន មិនដឹងជាគាប់ធ្វើការអ្វីឲ្យប្រាកដ ដូច្នេះតើមហិទ្ធិនឹងកើតឡើងដូចម្តេចបាន យ៉ាងដូចជាព្រះពុទ្ធជាម្ចាស់ ទ្រង់មានលក្ខណៈ តាមហោរាទាយទុកថា នឹងបានត្រាស់ជាព្រះពុទ្ធ ឬនឹងបានជាស្តេចចក្រពត្តិ ដែលព្រះអង្គបានត្រាស់ជាព្រះពុទ្ធ ព្រោះព្រះអង្គមានព្រះទ័យបំណងចង់បានត្រាស់ជាព្រះពុទ្ធពិតប្រាកដណាស់ ព្រះអង្គមិនបោះបង់ពេល


www.elibraryofcambodia.org

គួរព្យាយាមរកៈ បានជាបានត្រាស់ជាព្រះពុទ្ធ បើប្រសិនជាព្រះអង្គញែក ឬព្រះអង្គពេលព្រះហឫទ័យចង់បានសម្រេចយ៉ាងសង់ខាងនោះ ប្រហែលជាមិនបានសម្រេចជាអ្វីសោះឡើយ ។

បើយើងសង្កេតមើលឲ្យល្អ នឹងឃើញមានមនុស្សខ្លះដែលយកចិត្តព្យាយាមក្នុងការដែលមានប្រាថ្នាជាពិតប្រាកដនោះ ឃើញថាបានសម្រេចដូចប្រាថ្នាមែន របស់ដែលគិតថាមិនបាន ត្រឡប់ជាបានវិញ នេះហើយឲ្យឃើញថាជាគោលរបស់មនោមយិទ្ធិយ៉ាងជាន់ពាប ។

## គ្រានេះល្បងពិចារណាឲ្យខ្ពស់ឡើងបន្តិចទៅទៀត

អ្នកប្រាជ្ញអព្យាក្រឹត្យរបស់បារាំង នឹងពួកយោគីក្នុងឥណ្ឌៀយល់ឃើញដូចគ្នាថា គំនិតរបស់មនុស្សយើង បែកខ្ចាយចេញមកពីក្នុងខ្លួន ដូចក្រសែភ្លើងអគ្គិសនី មនុស្សដែលមានសេចក្តីគិតយ៉ាងខ្លាំង ដែលបារាំងហៅថា (homme-énergique) មនុស្សមាំមួនមានស្មារតីនោះ ក្រសែនោះឯងមានកំឡាំងខ្លាំងចេញទៅប៉ះប្រទះរបស់អ្វីៗ ក៏ជាប់នៅ ដែលអណ្តែតនៅក្នុងអាកាសក៏មាន បើប្រសិនជាមនុស្សច្រើនគ្នានៅក្នុងកន្លែងតែមួយគ្នា មានគំនិតដូចគ្នា ក្រសែនោះក៏កាន់តែខ្លាំងឡើងទៅទៀត គួយ៉ាងរឿងនេះមានច្រើន ដូចយើងទៅនៅជាមួយនឹងមនុស្សដែលមានសេចក្តីសោកជាពេកក្រៃ គឺនឹងធ្វើឲ្យយើងសោកក្រៀមក្រៅ

ជាមួយផង យើងនៅជាមួយនឹងមនុស្សដែលមានសេចក្តីព្រួយ យើង ក៏ដឹងថាខ្លួនយើងមានសេចក្តីប្រែប្រួលចង់ធ្វើការអ្វីម្យ៉ាងៗ ទៀត យើង ចូលទៅរកអ្នកមានបុណ្យស័ក្តិធំ យើងច្រើនតែមានសេចក្តីខ្លាច ទុកជាយើង ជាលោកមិនបានធ្វើអ្វីខ្ញុំទេ លោកនឹងទទួលយើងដោយស្រួលមានមេត្តា ករុណាក្តី ក៏មិនបាត់នូវសេចក្តីខ្លាចនោះ ក្នុងផ្ទះឬបន្ទប់ដែលមានមនុស្ស ស្លាប់នៅមកមុន ហើយលះបង់ចោលចេញទៅយូរ គង់ចោលក្រែស គំនិតទុក កាលណាយើងចូលទៅក្នុងផ្ទះឬបន្ទប់នោះ យើងក៏ដឹងនឹងខ្លួនថា មានចិត្តសោកឬក៏សប្បាយក៏ពេក ស្រេចទៅផ្ទះឬបន្ទប់ដែលអ្នកនៅមុន នោះ មានសេចក្តីសោកឬសប្បាយយ៉ាងណា គេប្រៀបសេចក្តីនេះប្រ-ដូចយើងបង្កក់ភ្លើងទុកចោលក្នុងបន្ទប់មួយ ទុកជាភ្លើងរលត់យូរហើយ បន្ទប់នោះក៏គង់ចោលចំហាយទុកដែរ អ្នកប្រាជ្ញការសាស្រ្តអាចស្រាយ កទៅថា ផ្កាយដែលយើងមើលឃើញនៅលើមេឃនោះ មានផ្កាយ ខ្លះបានធ្លាក់បាត់ទៅយូរៗ ហើយ តែពន្លឺគង់មានទៅជាប់ជាកន្លែងផ្កាយ នោះជាច្រើនឆ្នាំ យើងចូលទៅក្នុងផ្ទះដែលមានមនុស្សស្លាប់ថ្មីៗ ទុកជា យើងមិនដឹងជាមុននោះ យើងគង់ដឹងជាក្នុងចិត្តយើង មានចិត្តស្ញុកស្ញប់ ខុសពីប្រក្រតី រឿងទាំងនេះសំដែងឲ្យឃើញថា ក្រែសផ្លូវចិត្តមនុស្ស ក្លាយទៅគ្រប់អន្លើ បើយើងទៅប៉ះក្រែសណា យើងក៏គង់ដឹងខ្លួនតាម ដំណើរនោះជាដរាប ក្រែងតែយើងមិនបានសង្កេតឲ្យល្អ ៗ



www.elibraryofcambodia.org

មានរឿងរបស់បាក់ងមួយរឿងគួរឲ្យស្តាប់ ជាគ្រឿងសំដែងឲ្យឃើញថា ក្តៅសង្ហរចិត្តរបស់មនុស្សមានអំណាចត្រឹមណា រឿងនេះកើតក្នុងប្រទេសអាល្លឺម៉ាញ ជាយូរឆ្នាំមកហើយ ថាមានអ្នកមានម្នាក់បានជួលជាងដែកមកធ្វើការក្នុងផ្ទះខ្លួន តែដោយសេចក្តីកំណាញ់ចិត្តខ្លាំងពេក មិនព្រមឲ្យឈ្នួលដែលនៅសល់ជំពាក់ ជាងដែកបានទារជាច្រើនដងមិនបាន ដល់ក្រោយបំផុតបដិសេធថាពុំបានជំពាក់អ្វីសោះ ៗ ជាងដែកក៏អស់ផ្លូវនឹងទៅប្តឹងក៏ពុំកើត ព្រោះគ្មានអ្វីជាសំគាល់តាមច្បាប់ ដល់យប់បន្តិច អ្នកមាននោះកើតកេតដេកមិនលក់ ដល់តែយប់ វេលាយាម ២ ពាក់កណ្តាលអធ្រាត្របានឮតែសូរដំដែកដឹងតាំងគងរំពង ផ្ទះជាងដែកជិតផ្ទះអ្នកមាននោះ នៅឆ្ងាយពីគ្នាស្មានជា ៣ គីឡូម៉ែត្រ អ្នកមាននោះកាលពីដើមមកក៏ពុំដែលឮដូច្នេះទេ ទើបជាត្រចៀកខ្លួនពិការកើតទេ ហេតុអ្វីពេលមុនពាក់កណ្តាលអធ្រាត្រក៏មិនឮសូរ ទើបអញឮពេញមកត្រូវពេលនោះ ចួបចួនជាប្រទះទៅលើពេលនេះដឹងរឿងក្តៅសង្ហរចិត្ត ពេលនោះក៏សួរថា រឿលមានហេតុចាស់ហែងអ្វីទឹងអ្នកណាដែរឬទេ ។ អ្នកមាននោះក៏ពុំរកឃើញ ប្រាប់ពេលថា មានចាស់ទឹងជាងដែកម្នាក់នៅចម្ងាយពីផ្ទះខ្លួនទៅស្ពាន ៣ គីឡូម៉ែត្រ ពេលបានដឹងហើយ ដល់យប់ពាក់កណ្តាលអធ្រាត្រ ក៏ទៅផ្ទះជាងដែកនោះ ប្រទះឃើញជាងដែកកំពុង

www.elibraryofcambodia.org

ដំដែករងទឹងញញួរ ជាប់ញាក់ៗ ទឹងបានដំដែកធ្វើការអ្វីកើតទេ ពេទ្យក៏ចូលទៅសួរថាហេតុអ្វី ក៏បានជាធ្វើដូច្នេះ ជាងដែកក៏តបថា មានមនុស្សម្នាក់គេចប្រាក់ឈ្នួលរបស់ខ្ញុំ កាលយប់វេលាម៉ោង ១ កណ្ដាលអធ្រាត្រខ្ញុំដំដែកនេះ តាំងចិត្តឲ្យពុះដល់ទៅអ្នកនោះ ដើម្បីកុំឲ្យគេដេកបាន ទាល់តែអ្នកនោះសងឈ្នួលដែលជំពាក់ខ្ញុំនោះរួចហើយខ្ញុំឈប់ ។ ពេទ្យបានដឹងការច្បាស់ក៏ត្រឡប់មកណែនាំឲ្យអ្នកជម្ងឺនោះសងឈ្នួលព្រាក់ឲ្យជាងដែក តាំងពីបានសងរួចហើយមក ក៏ដេកលក់ដកប មិនពុស្សប់វែកទៀត ។

រឿងនេះជាគួយ៉ាងមួយទៀតក្នុងក្រែសដួងចិត្ត ជាគោលប្រើសម្រាប់អធិប្បាយលក្ខណៈ របស់មនោមយិទ្ធិ ។

ក្នុងក្រែសដួងចិត្តនេះ គេអធិប្បាយថា គាប់មានជា ២ ថ្នាក់ ថ្នាក់ដំបូងមនុស្សយើងបញ្ជូនក្រែសដួងចិត្ត ដូចរឿងដែលនិយាយមកនេះ ថ្នាក់ទី២ បើដួងចិត្តមានកំឡាំងខ្លាំង ដោយការហ្វឹកហ្វឺនឬដោយមានពីកំណើតមកក្រែសនោះក៏នឹងផ្សាយចេញទៅឯង មិនបាច់តាំងចិត្តបញ្ជូនទៅទេ ។

គួយ៉ាងដូចជាមនុស្សដែលមានលក្ខណៈម៉ាំមួន ទុកជាមិនតាំងចិត្តឲ្យមនុស្សខ្លាច ក៏គង់តែមនុស្សខ្លាចដែរ ឬមនុស្សដែលមានលក្ខណៈសំដីផ្អែមដោយធម្មជាតិមកនោះ តែងតែមានក្រែសដួងចិត្ត ស្រូបយកដួងចិត្តមនុស្សដទៃមករកខ្លួន បើអ្នកណាបានប្រទះហើយមានចិត្តស្រឡាញ់


www.elibraryofcambodia.org

ទុកជាមនុស្សនោះមិនបានគាប់ចិត្តឲ្យគេស្រឡាញ់ក៏ដោយ បើមនុស្សទាំងពីរនាក់នោះមកជិតគ្នា ក្រសែនិងក្រសែក៏ចូលគ្នា ក្រសែរបស់អ្នកណាខ្លាំងជាង ក៏សង្កត់ទៅលើអ្នកដែលមានក្រសែតិច ប្រៀបដូចយើងយកគោបពណ៌ខៀវនិងពណ៌ក្រហម ទៅដាក់នៅក្នុងចានទឹកជាមួយគ្នា ទៅទឹកនោះនឹងមានពន្លឺជាពណ៌ខៀវឬពណ៌ក្រហម ស្រេចនៅតាមពណ៌ណាមានពន្លឺខ្លាំងជាង ហេតុដូចនេះបានជា បើយើងយកក្មេងដែលឧស្សាហ៍នឹងក្មេងខ្ជិលទៅឲ្យនៅជាមួយគ្នា ក៏នឹងធ្វើឲ្យក្មេងខ្ជិលនោះទៅជាឧស្សាហ៍ទាំង ២ នាក់ ឬធ្វើឲ្យខ្ជិលទាំង២ នាក់ ស្រេចនូវក្រសែគំនិតរបស់ក្មេងខាងណា ខ្លាំងជាងក៏ធ្វើឲ្យក្រសែខាងម្ខាងដែលតិច មកតាមក្រសែគំនិតរបស់ខ្លួន ។

សម្តេចព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់មានបរមពុទ្ធិខ្លាំងណាស់ ក្រសែគំនិតរបស់ព្រះអង្គពេញទៅដោយធម៌ព្រហ្មវិហារ ហើយមានព្រះហឫទ័យស្រឡាញ់ប្រព្រឹត្តតែក្នុងសេចក្តីល្អ ព្រោះហេតុនេះឯង បើមនុស្សណាដែលបានចូលមកជិតព្រះអង្គហើយ ទុកជាមានចិត្តកាចយ៉ាងណាណាស់ក៏កែប្រែក្រសែដ៏ល្អរបស់ព្រះអង្គ សង្កត់ឲ្យត្រឡប់ទៅជាល្អវិញបានដោយបរមពុទ្ធិនេះ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់ទូន្មានមនុស្សដែលពាលកាចបំផុតឲ្យត្រឡប់ជាមនុស្សល្អបំផុតបានយ៉ាងអស្ចារ្យ បានជាទ្រង់



www.elibraryofcambodia.org

ព្រះនាមថា "អនុត្តរោ បុរិសទម្មសារថិ" ខនេះហើយដែលយើងដោះស្រាយប្រស្នាក្នុងរឿងព្រះអង្គុលិមាលបានសម្រេច ។

សេចក្តីដែលពោលមកនេះ ជាគោលនៃមនោមយិទ្ធិយ៉ាងខ្ពស់បំផុត ព្រោះនេះ យើងល្មមពិចារណាឲ្យខ្ពស់ឡើងទៅទៀត ពោលគឺក្នុងបរិ-ភាគបរិច្ឆេទទី ២ ថា មនោមយិទ្ធិនោះមាននិទ្ទេសថា និម្មិតកាយក្រៅពីកាយនេះបានប្រដូចហូតដាវចេញពីស្រោម សម្តេចព្រះមហាកោសបកក គ្រូបរិញ្ញាណកោស ទ្រង់ប្រៀបប្រដូចនឹងមនុស្សដែលគិតគូររបស់ផ្សេងៗ បានសម្រេច យើងល្មមយកស្រោមដាវកេប៊ិល យើងនិតគិតប្រៀប ដូច្នេះតើ មនុស្សយើងនឹងអាចនិម្មិតកាយក្រៅពីកាយនេះប្រដូចហូតដាវចេញពីស្រោម បានពិតឬទេ សេចក្តីនេះព្រះគន្ថរចនាចារ្យរបស់យើង បានបរិយាយរឿងនេះទុកប្រការដូចម្តេចខ្លះនោះពុំដឹង ហេតុនេះបានជាសាទៅរកពាក្យរបស់អ្នកប្រាជ្ញខាងផ្លូវអធ្យាត្មវិទ្យារបស់បារាំង នឹងលទ្ធិរបស់យោគីក្នុងឥណ្ឌាវិញ ។

អ្នកប្រាជ្ញនឹងយោគីទាំងនោះ ប្រកាន់ថាកាយរបស់មនុស្សយើង មានកាយ ២ គឺ Corps physique ១ នឹង Corps astral ១ ឯ corps physique បាននឹងរូបកាយ ដែលប្រកបឡើងដោយធាតុទាំង ៤ ដែលយើងឃើញនេះ ក្រៅនឹង corps astral នោះ គេអធិប្បាយទុកប្រហែលនឹងចេតសិករបស់

យើង ហេតុដូច្នេះសូមប្រែពាក្យនេះថា ចេតក្កូត ដូចបានពោលមកក្នុងសេចក្ដីដើម ត្រង់អធិប្បាយគោលចារិកលទ្ធិយោគីនោះហើយ ។

កាលបុរាណ ចេតក្កូតចេញពីខ្លួនមនុស្សលោកកំពុងដេកលក់ ក្នុងវេលាដែលចិត្តមនុស្សកំពុងតាំងសមាធិយ៉ាងមាំមួន ដែលថាចេតក្កូតចេញពីខ្លួនកំពុងដេកលក់នោះចូលចិត្តឆ្ងាយ គឺគេអធិប្បាយថា របស់រឿងផ្សេងៗ ដែលខ្លួនឃើញក្នុងយល់សប្ដិនោះ សុទ្ធតែចេតក្កូតបានប្រទះឃើញទាំងអស់ បាក់ទីដែលយកចិត្តទុកដាក់ក្នុងវិជ្ជានេះ ហើយទីពួកយោគីទាំងឡាយ បានព្យាយាមស្រាវជ្រាវរកផ្លូវដែលនឹងបញ្ជាប់ចេតក្កូតឲ្យទៅក្នុងទីឯទៀតៗ បានតាមចិត្តបំណង វិធីបញ្ជាប់ទីងដូយ៉ាងណានោះ គេធ្វើគោលចារិកសឹងឃើញបានជាក់ច្បាស់ថា គេចាំយកទៅពីព្រះពុទ្ធជាម្ចាស់ដ៏ប្រាកដ គោលចារិកដែលគេធ្វើទុកនោះមាន ៣ ប្រការគឺ:

១ Volonté ដែលត្រូវគ្នានឹងមនោមយិទ្ធិរបស់យើង

២ Vision ដែលត្រូវគ្នានឹងឧគ្គហនិមិត្តរបស់យើង

៣ Concentration ដែលត្រូវនឹងសមាធិ ។

ក្នុងសៀវភៅរបស់នាយ អែនដ្រឺឡេង ជាតិអង់គ្លេស ដែលជាអ្នកស្រាវជ្រាវរកសេចក្ដីពិតក្នុងវិជ្ជានេះ ពោលទុកមួយៗជាឧទាហរណ៍ យ៉ាងល្អពិតការផតកាយ ដូចមានសេចក្ដីប្រែទុកតទៅនេះ ។

www.elibraryofcambodia.org

នាងម៉ារីជាភរិយាសង់គូហ្វ មានផ្ទះឈើកែររបងរឹងរៃជាទាំង ទៅនៅក្បែខ្លួនឯផ្ទះក្បែរឆ្ម ចម្ងាយពីផ្ទះប្រហែលជាង ១៤ គីឡូម៉ែត្រ មុខទីនិអទិច្ចកម្ម មានមួយថ្ងៃស្ត្រីនោះមានចិត្តព្រួយយ៉ាងខ្លាំង ចង់ឃើញកូនរបស់ខ្លួនពីនាក់ដែលនៅផ្ទះ តែពេលរប៉ុនព្រួយឲ្យជួប ព្រោះផ្ទះស្ត្រីនោះកែចន្លង់ទៅកូនបាន ដល់វេលាម៉ោង ២ ជាងពាក់កណ្តាលអធ្រាត្រកន្លះយប់នោះ ស្ត្រីនោះមានអាការដូចមនុស្សស្លាប់ ហាក់ហា តែក្រើកបាត់ដង្ហើមចេញចូល ៗ ពេលដែលនៅប្រចាំការ ក៏ពុំកេចរើកញ្ញសជាជាស្ត្រីនោះស្លាប់ហើយឬទៅទៀយ ៗ លុះព្រឹកឡើងស្ត្រីនោះបើងខ្លួនឡើងជាមនុស្សទើបភ្ញាក់ពីដេក ក៏ប្រាប់ម្តាយខ្លួនថា "យប់មិញខ្ញុំទៅទីនកូនទើបមក" ស្ត្រីនោះក៏ស្តាប់កន្លះវេលាព្រឹកនោះទៅ ៗ

ចំណែកខាងផ្ទះស្ត្រីដែលកូននៅនោះ វេលាម៉ោង ២ ជាងពាក់កណ្តាលអធ្រាត្រកន្លះយប់ដែលស្ត្រីនោះខ្លុក ស្ត្រីដែលជាអ្នកក្បែចាំកូននៅផ្ទះនោះភ្ញាក់ឡើង ក្រឡេកទៅឯគ្រែកូនក្មេងដេកនោះ ឃើញម្តាយក្មេងនោះឈរនៅជិតគ្រែក្មេងដេក តែក្រវិលវល់ ហាក់គិតចង់និយាយតែមិននិយាយថាអ្វី ខ្លួនក៏ស្រែកសួរថា អ្នកណាមកឈរនៅនោះ ក៏ពុំឆ្លើយតបមកវិញ ក៏ក្រោកចុះពីគ្រែដើរទៅជិតឃើញម្តាយក្មេងនោះដើរចេញពីគ្រែទៅតាមទ្វារ ស្ត្រីដែលក្បែក្មេងនោះក៏ស្រែកទោឡាឡើង

អ្នកផ្ទះជិតខាងក៏ដើរមកសួរ ស្ត្រីនោះនិយាយប្រាប់តាមដំណើរ អ្នកផ្ទះជិតខាងថាស្ត្រីនោះយល់សប្តិមមើរហើយទេ តែស្ត្រីចិញ្ចឹមក្មេងនោះប្រកាន់មុឺងម៉ាត់ថា មិនមែនយល់សប្តិទេ គឺឃើញនឹងភ្នែកប្រាកដ ។

អ្នកប្រាជ្ញដែលពោលរឿងនេះ សន្និដ្ឋានថាប្រាកដជាចេតភូតរបស់ស្ត្រីនោះ ដែលជិតនឹងស្លាប់នោះគឺ ១ មានប្រាថ្នាចង់ឃើញកូនខ្លាំងពេក ជាហេតុឲ្យកើតមានឫទ្ធិ ២ ឃើញរូបកូនជាប់នៅនឹងភ្នែកដែលជាវត្ថុហរិបិត្ត ៣ មានសមាធិជាខ្លាំងបំផុតទាល់តែប្រាកដដូចមនុស្សស្លាប់ សេចក្ដីទាំងនេះចូលក្នុងគោល ៣ ប្រការ ដែលបានពោលមកខាងដើម ។

ចំណែកខាងផ្លូវព្រះពុទ្ធសាសនារបស់យើង ដែលពោលអំពីការឆកកាយនេះ បានអធិប្បាយតាមគម្ពីរវិសុទ្ធិមគ្គ ទុកនៅក្នុងចំពូកឥទ្ធិវិធ ព្រោះជាពួកឫទ្ធិដូចគ្នា បានជាពោលទុកក្នុងចំពូកនោះឃើញថានឹងចូលចិត្តងាយជាង ។

មានបញ្ហាសល់មួយទៀតថា ការដែលនឹងធ្វើឲ្យក្រសែជួនចិត្តរបស់យើងមានកំលាំងខ្លាំងឡើងនោះ តើយើងនឹងគិតធ្វើដោយវិធីណា ?

អ្នកតែងសៀវភៅនេះ ជាខ្ញុំពុំបានហាត់ឲ្យបានចេះដឹងអំពីក្នុងផ្លូវក្រសែជួនចិត្តនោះឡើយ ដែលបានតែងជារឿងទុកនេះ ក៏ដោយសារបានឃើញ

www.elibraryofcambodia.org

ក្នុងសៀវភៅឯទៀតៗ ហើយនឹងបានរៀនធ្វើល្បងឲ្យឃើញផលបែបនោះ ក៏ទេ ។

ឯក្រសែជួនចិត្ត ដែលនឹងធ្វើឲ្យមានកំលាំងខ្លាំងនោះ ក្នុងជាក់ជប្យុន គេនាំស្គាល់ទុកថា មនុស្សគ្រប់រូបតែងតែមានក្រសែជួនចិត្តមានកំលាំង ម្យ៉ាងៗ តែកំលាំងក្រសែជួនចិត្តនោះ ខ្លះក៏គួរប្រាថ្នាយកទុក ខ្លះក៏មិនគួរ យកទុក បើយើងចែកយ៉ាងសង្ខេប ក្រសែចិត្តមានពីរចំពូកគឺ ចំពូក ១ ដែលស្រូបចូលមក ចំពូក ២ ដែលបានចេញទៅ តាំងពីចំពូកនេះ មានតាំងល្អមានតាំងអាក្រក់ ប្លែកគ្នា បើយើងចែកឲ្យក្បិតចេញទៅ ទៀតដូច្នេះ :

ក - ចំពូកស្រូបយកមកយ៉ាងល្អ គឺក្រសែដែលទាញយកជួនចិត្ត របស់មនុស្សមកឲ្យស្រឡាញ់ខ្លួន មនុស្សដែលមានក្រសែចិត្តបែបនេះ អ្នកណាឃើញក៏នឹងចប់ចិត្ត កុំឲ្យស្រឡាញ់ពោះពុំបានឡើយ ទុក ជាមនុស្សនោះ រូបឆោមមិនល្អស្អាតក្តី ឬមិនបានសំដែងគុណអ្វីល្អ ឲ្យ ឃើញប្រាកដក្តី ក៏នៅតែមានចិត្តស្រឡាញ់ ។

ខ - ចំពូកស្រូបយកមកដែលមិនគួរគប្បីប្រាថ្នាទុក គឺក្រសែចិត្ត ដែលទាញយកចិត្តរបស់មនុស្សដូចគ្នា គង់តែបានយកមកឲ្យស្រឡាញ់ ឬក៏បកឲ្យស្អប់ក៏ទេ ទាញយកមកធ្វើឲ្យតែមានខ្លួនឯង មនុស្សដែល



www.elibraryofcambodia.org

ពួកក្រៅសចិត្តបែបនេះ ច្រើនមានមនុស្សចូលចិត្តជួបនិយាយជាមួយ តែមិនចង់និយាយរាយរាប់ពាក្យល្អក៏ទេ ជួបចង់តែចំអកចំអន់ដន្លងដំនេញ ឲ្យតែរំខាន ជួនកាលកំហែងថែមទៀត ក្នុងសាលាបង្រៀនយើងគង់តែងប្រទះឃើញរឿយៗ ពួកកូនសិស្សខ្លះ ប្រព្រឹត្តខុសមើលមិនចាស់ចែននឹងអ្នកណា ជួនកាលមិនចូលចិត្តគប់សមាគមនឹងអ្នកណា គ្មានអ្នកណាស្អប់ គ្មានអ្នកណាស្រឡាញ់ តែមានមនុស្សចូលចិត្តដន្លងដំនេញលេងឲ្យតែរំខាន ខ្លួនយើងបើបានប្រទះមនុស្សបែបនេះក៏មានចិត្តចង់កំហែងធ្វើឲ្យបំបែក ព្រោះដែលសត្វនឹងបាននឹងខ្លួនជាមកពីហេតុអ្វី បានជាចូលចិត្តដល់បុគ្គលនោះ ឯមនុស្សដែលត្រូវគេដន្លងដំនេញទៀត ក៏មិនដឹងខ្លួនថាហេតុអ្វីក៏គេរួចបង្កដន្លងខ្លួន បើយើងដឹងស្គាល់លក្ខណៈរបស់ក្រៅសដួងចិត្តដូច្នេះហើយ យើងនឹងអស់សង្ស័យហើយនឹងចូលចិត្តជាមនុស្សបែបនេះពួកក្រៅសចិត្តដែលស្របចាញយកដួងចិត្តមនុស្សមក ដើម្បីធ្វើឲ្យរំខានតែខ្លួនឯង ក្រៅសដួងចិត្តបែបនេះ មិនមានចំពោះតែក្មេងៗទេ សឹងមាននៅលើបុគ្គលដែលមានអាយុច្រើនៗផង ហេតុដូច្នេះបានជាមានមនុស្សខ្លះចាស់ជិតតែនឹងស្លាប់ហើយក៏នៅមានមនុស្សចូលចិត្តដន្លងលេងដែរ ។

ត - ចំពួកដែលក្រៅកក្រៅសចិត្តចេញទៅយ៉ាងល្អនោះ គឺដួងចិត្តដែលហាងណាបអ្នកណាចូលមកជិត តែងតែមានចិត្តគោតខ្លាច ជួន



www.elibraryofcambodia.org

កាលមិនសូវមានមនុស្សហ៊ានចូលជិតផង ព្រោះសេចក្ដីខ្លាចមិនមែនមក អំពីស្អប់ទេ អ្នកដែលមានអំណាចក៏សងា តែងតែមានក្រសែចិត្តបែបនេះ ជាប្រិនក្នុងខ្លួន មនុស្សបែបនេះ ទុកជាយើងដឹងច្បាស់ថា គេមិនប្រើ អំណាចធ្វើឲ្យយើងខ្លាចទេ ក៏គង់នៅមានចិត្តកោតខ្លាច ទុកជាគេស្រ-ឡាញ់រាប់អានយើងយ៉ាងណាក្ដី ក៏នៅតែមិនហ៊ានចូលទៅជិតដែរ ។

ង – ចំពូកដែលព្រាយក្រសែចិត្តចេញទៅ ដែលមិនគួរប្រាថ្នានោះ គឺក្រសែដួងចិត្តដែលមិនអាចចូលទៅរញ្ជួនជាមួយនឹងក្រសែចិត្តរបស់ អ្នកដទៃ មនុស្សដែលមានក្រសែចិត្តបែបនេះទុកជាមិនបានធ្វើអ្វីឲ្យគេការ ស្អប់ ក៏គ្មានអ្នកណាចូលចិត្ត ក្រសែចិត្តយ៉ាងនេះធ្វើឲ្យមនុស្សស្អប់ តាំងពីបានឃើញមុខជាដំបូង ។

ច – ក្រសែដួងចិត្តដែលរាប់ថាល្អជាទីបំផុត ហើយគួរប្រាថ្នាយ៉ាង បំផុតនោះ គឺក្រសែចិត្តបែប ក. និង គ. ផ្សំចូលគ្នាជាក្រសែចិត្ត ធ្វើឲ្យមនុស្ស ស្រឡាញ់ហើយកោតខ្លាចផង បានហៅថាក្រសែចិត្តដ៏ល្អ ដួងចិត្តទាំង នេះកើតមកពីហេតុអ្វីបានជាធ្វើឲ្យមនុស្សមានក្រសែចិត្តខុសពីគ្នាដូច្នេះ ? ដំណើរដួងចិត្តនេះត្រូវយើងសំគាល់ទុកថា ដួងចិត្តប្រៀបដូចជាដួងភ្លើង ពណ៌បរិសុទ្ធ ក្រសែដួងចិត្ត ប្រៀបដូចពន្លឺភ្លើងដែលចុះពន្លឺនោះជាពណ៌ អ្វី មានពន្លឺទាំងអម្បាលម៉ានស្រេចតែនឹងយើងយកកញ្ចក់ពណ៌ណាចុះ



www.elibraryofcambodia.org

កញ្ចក់ដែលសម្រាប់ឆ្លុះក្នុងនោះ គឺដួងចិត្តរបស់យើងមានដូច្នេះ ។ ដើមដម្បូងយើងមានកញ្ចក់ពីរផ្ទាំងសម្រាប់នឹងធ្វើឲ្យក្រៃសចិត្តទន់ឬខ្លាំង តាមត្រូវការ កញ្ចក់ទាំងពីរផ្ទាំងនេះគឺ ១ សេចក្តីព្យាយាម សម្រាប់ជួយឲ្យក្រៃសចិត្តខ្លាំង. ២ សេចក្តីញញើតធ្វើឲ្យក្រៃសចិត្តទន់ កញ្ចក់ទាំងពីរនេះនឹងធ្វើឲ្យក្រៃសចិត្តខ្លាំង ឬធ្វើឲ្យទន់ក៏បានទាំងពីរផ្លូវ គឺផ្លូវល្អនិងផ្លូវអាក្រក់ មនុស្សដែលមានព្យាយាម បើជាព្យាយាមខាងផ្លូវល្អក៏ល្អណាស់ បើព្យាយាមខាងផ្លូវអាក្រក់ក៏អាក្រក់ណាស់ មនុស្សដែលមានសេចក្តីញញើត បើញើតល្អក៏មិនល្អណាស់ បើទុកជាធ្វើអាក្រក់ក៏មិនខ្លាំងលើសលុប ។

ទាំងពីរផ្ទាំងនេះជាកញ្ចក់ជាន់ដើម ។

ឯកញ្ចក់ដែលមិនផ្លាស់ប្តូរពណ៌ ក្រៃសរបស់ដួងចិត្តឲ្យទៅជា ៥ យ៉ាង គឺ ព.ក. ខ.ប. ដូចបានពោលមកខាងដើមនោះ មាន ៦ ផ្ទាំងដែលរៀបទុកជាគូៗដូចមានតទៅនេះ:

គូទី ១ — សេចក្តីមេត្តា — សេចក្តីឫស្យា

គូទី ២ — សេចក្តីក្លាហាន — សេចក្តីខ្លាច

គូទី ៣ — សេចក្តីរឹងប៉ឹង — សេចក្តីទន់ ។

សេចក្តីមេត្តា ជាកញ្ចក់ឆ្លុះឲ្យកើតផលក្នុង ១ ក. ពោលគឺមនុស្សដែលមានសេចក្តីមេត្តា ជាប់ជាប្រក្រតី តែងតែមានមនុស្សទាំងឡាយ

www.elibraryofcambodia.org

ស្រឡាញ់មិនថាផ្លូវព្រះពុទ្ធសាសនាឥស្លាមគ្រិស្ទ ឬលទ្ធិណាៗ ក៏មាន
គោលសំខាន់ដូចគ្នាថា បើយើងចង់ឲ្យគេស្រឡាញ់យើងត្រូវយើងស្រ-
ឡាញ់គេមុន អំពីផ្លូវ "មេត្តា" ដែលមនុស្សជាច្រើនចូលចិត្តប្រើគាថា
ក្រមួន. ប្រេងម្ររបស់អ្វីផ្សេងៗនោះសុទ្ធតែជារបស់បញ្ឆោតមនុស្សលោក
គោលដែលជាប្រាកដនឹងធ្វើឲ្យសម្រេចផលបានពិតនោះគឺថា "យើងត្រូវ
តាំងចិត្តឲ្យមាំ ឲ្យមានមេត្តាដល់បុគ្គលដែលយើងត្រូវការឲ្យគេមេត្តាយើង
នោះ" នេះជាគោលដ៏ពិតប្រាកដរបស់ "ផ្លូវមេត្តា" ក្នុងផ្លូវព្រះពុទ្ធសាសនា
របស់យើង ប្រកាន់ថាធ្វើបុណ្យហើយត្រូវផ្សាយមេត្តាឲ្យទៅមនុស្សទាំង
គ្នា ទុកជាមនុស្សដែលជាសត្រូវរបស់ខ្លួនក៏ដោយ តាមផ្លូវសាសនាគ្រិស្ត
គេក៏មានគោលដូចនេះដែរ គេមានពាក្យប្រដៅរបស់គេមួយ១.គួរយើងស្តាប់
សេចក្តីថា "ចូរអ្នកស្រឡាញ់មនុស្សដែលគេស្រឡាញ់អ្នក សេចក្តីពិតក៏
មិនជាការប្លែកអ្វីទេ អ្នកណាៗក៏ធ្វើបាន តែបកចំផ្លែកពិតពាក់ធ្វើឲ្យ
បានជាផលល្អបំផុតនោះ គឺត្រូវស្រឡាញ់កប់អានមនុស្សដែលគេស្អប់អ្នក
ផង" សេចក្តីនេះជាផលរបស់មេត្តា ដែលយើងកែប្រែបានក្នុងខ្លួនយើង
មិនបាច់តែរកគាថាណាប្រដៅឡើយ ។

សេចក្តីខ្លាចនឹងចិត្តខ្ទន់ ជាកញ្ចក់ឆ្លុះឲ្យកើតផលក្នុង ១. ដូចដែល
យើងឃើញថាមនុស្សត្រូវផ្ទួនផ្ទេញជាប្រក្រតីនោះ ព្រោះមនុស្សនោះ
មានលក្ខណៈជាមនុស្សខ្លាចហើយចិត្តខ្ទន់ ។



www.elibraryofcambodia.org

សេចក្ដីក្លាហានជាមនុស្សចិត្តវែងប៉ុន្តែជាកញ្ចក់ឆ្លុះឲ្យកើតផលកម្ម ១ គ.

សេចក្ដីមុស្សា ជាកញ្ចក់ឆ្លុះឲ្យកើតផលកម្ម ១ ង

សូមលោកអ្នកមើលសៀវភៅនេះសូររត្តិគិតល្បងមើល មនុស្សដែលគ្មានអ្នកណាចូលចិត្តហើយត្រូវគេស្អប់ជាច្រើននោះ តើមកពីហេតុអ្វី គន់ឃើញជាមនុស្សបែបនេះកុងចិត្តច្រើនមានសេចក្ដីមុស្សាជាប្រក្រតី ជាមនុស្សមិនចង់ឲ្យអ្នកណាបានចំចេញជាងខ្លួន ទុកជាមនុស្សនោះលាក់បំបិទបំបាំងបំណងរបស់ខ្លួនយ៉ាងណាក៏មិនសម្រេច ព្រោះគ្រាប់ពូជចិត្តមុស្សានោះខ្លាំងជាងគ្រាប់ចិត្តឯទៀត អ្នកដែលមានគ្រាប់ចិត្តយ៉ាងនេះ តែងតែត្រូវគេស្អប់តាំងពីបានឃើញមុខជាដំបូង គឺយកជាផ្សេងៗ យើងអាចលាក់បាំងបានខ្លះ តែគ្រាប់ពូជចិត្តនេះមិនលាក់បាំងទុកពុំបានឡើយ ។

គុណគុណសម្បត្តិទាំងមូលដែលជាទីបំផុតនោះ គឺសេចក្ដីមេត្តា, ក្លាហាន, កំរូម ទាំង ៣ ប្រការនេះផ្សំគ្នាឡើងកើតជាផលកម្ម ១ ប. ដែលជាគ្រាប់យ៉ាងល្អត្រូវប្រាជ្ញា បើយក សេចក្ដីព្យាយាមបញ្ចូលថែមទៀតក៏នឹងជួយឲ្យគ្រាប់ពូជចិត្តកាន់តែមានកំលាំងខ្លាំងឡើង ជាការប្រសើរណាស់ ៗ

កាលណាយើងពិចារណាមកដល់ត្រឹមនេះហើយ ក៏នឹងពិចារណាតទៅដល់បញ្ហាដែលថាធ្វើដូចម្ដេច ទើបបានគ្រាប់ពូជចិត្តរបស់យើងមានកំលាំងខ្លាំង ច្រើនឡើងដោយឆ្ងាយតទៅទៀត រឿងនេះគេបានសរសេរជាគោលមុតស្ដួច:

www.elibraryofcambodia.org

១ ព្យាយាមលះបង់ចោលកង្វក់ដែលមិនល្អទាំង៤ ផ្គុំពេញ គឺ សេចក្ដីក្រោធ សេចក្ដីឫស្យា សេចក្ដីខ្លាចនិងចិត្តទន់ខ្សោយ ទុកតែ ៤ផ្លូវ គឺសេចក្ដីព្យាយាម សេចក្ដីមេត្តា សេចក្ដីក្លាហាននិងសេចក្ដីរឹងប៉ឹង ។

២ វេលានិយាយនឹងអ្នកណា ឲ្យសំឡឹងមើលភ្នែកអ្នកនោះ ឬអ្នក ដែលស្ដាប់យើងនិយាយផងណា ភ្នែកយើងមិនទាន់ងើបល្មមនឹងសំឡឹង ភ្នែកគេត្រង់បានទេ នឹងធ្វើឲ្យក្រសែដួងចិត្តរបស់យើងឲ្យបានខ្លាំងមាំមួន ពុំបានឡើយ ។

៣ ណែនាំខ្លួនឯង (Auto-suggestion) នោះរឿងនេះជាបញ្ហាធំបំ-ផុតក្នុងផ្លូវអព្យាក្រិត ហើយជាវិធីដែលអ្នកប្រាជ្ញក្នុងសម័យនេះ យល់ឃើញព្រមគ្នាថា ជាកាំជណ្ដើរដ៏ពិតប្រាកដសម្រាប់នឹងឲ្យបុគ្គលណា ១ ឡើងទៅកាន់សេចក្ដីសម្រេចបាន រឿងនេះអ្នកតែងសៀវភៅនេះ បានបរិ-យាយពីការហ្វឹកហ្វឺនខ្លួនឯង ទុកក្នុងសៀវភៅបង្ហាត់បុរស(ស្ត្រីលក្ខណ) ដែលបានបោះពុម្ពលើកទី ២ នោះហើយ ក្នុងសៀវភៅនេះគ្រាន់តែពោល យ៉ាងខ្លី ៗ ពីការហ្វឹកហ្វឺនខ្លួនឯង ដែលមានគោលទុកថា ឲ្យយើងនឹក ឬនិយាយខ្លួនឯង ថាយើងជានេះជានោះតាមដែលយើងត្រូវការ ក្នុងការ បណ្ដុះកំលាំងដួងចិត្ត ក៏ត្រូវនឹកឬនិយាយ ( ម្នាក់ឯង ) ថាដួងចិត្តរបស់ យើងមានកំលាំង ការនឹកឬនិយាយដូច្នេះជា ឧបករណ៍ដ៏សំខាន់ដែលនឹង

ធ្វើក្រសែដួងចិត្តឲ្យមានកំលាំងឡើង នឹងនាំឲ្យបានសេចក្ដីសម្រេចដល់ការតាំងខ្លួនផង ។

សេចក្ដីដែលពោលមកហើយនេះ នឹងជួយឲ្យលោកអ្នកមើលយល់នូវប្រើ វិធីបណ្ដុះក្រសែដួងចិត្ត បើចូលចិត្តយល់ឃើញតាមវិធីទាំងនេះ នឹងធ្វើល្បងមើលខ្លះក៏គួរ ព្រោះមានតែផ្លូវល្អ គ្មានផ្លូវឲ្យអន្តរាយឡើយ ។

តពីនេះ នឹងនាំយកសេចក្ដីអធិប្បាយរបស់យោគីពីការរក្សារោគដោយអំណាចដួងចិត្ត មកចុះក្នុងទីនេះ ដើម្បីឲ្យលោកអ្នកមើលប្រកបនឹងសេចក្ដីត្រិះរិះរបស់ខ្លួនក៏នឹងឃើញថា ក្នុងសម័យណា ៗ ប្រទេសណាក្ដី តែងតែមានមនុស្សចេះដឹងប្រើវិធីរក្សារោគដោយអំណាចដួងចិត្តជាដ-រាប តែគេប្រកាន់ថាជាអំណាចស្ងាត់កំបាំង Pouvoir occulte សម្រាប់ខ្លួនមនុស្សដែលបានមកពីព្រះឬទេវតាអង្គណាក៏ដោយ ដែលជាប្រាកដនោះ ពួកដែលមានវិជ្ជាបែបនេះ គង់មានខ្លះដឹងថាមិនមែនមកពីណាទេ គឺអំណាចមកពីដួងចិត្ត Pouvoir de l'esprit របស់ខ្លួនដែលនិយាយថាបានអំណាចមកពីព្រះឬមកពីអ្វី ៗ នោះ ដើម្បីឲ្យមនុស្សជឿច្រើនឡើង ព្រោះសេចក្ដីជឿជាឧបករណ៍ដ៏សំខាន់របស់វិជ្ជានេះ តែគោលដែលពិតប្រាកដនោះដូចមានពោលតទៅ ។

លោកអ្នកមើលសៀវភៅនេះ ក៏បានឃើញថា លទ្ធិរបស់យោគីដែលគេប្រកាន់ថា មនុស្សយើងមានចំណែកធំ បែងចេញជា ៧ ភាគ

www.elibraryofcambodia.org

ក្នុង ៧ កាលនេះ ភាគដែលត្រូវការជាពិតប្រាកដ សម្រាប់ធ្វើអោយមនុស្សទទួលទាន់កាយទៅបានក្នុងលោកគឺ "ព្រាណ" កាលបណាព្រាណអស់ទៅហើយ កាយក៏បែកធ្លាយ ដែលយើងហៅថាស្លាប់ ហេតុនេះបានជាគេប្រកាន់ថាមនុស្សដែលឈឺ ព្រោះព្រាណរបស់មនុស្សនោះ ដំណើរមិនគ្រប់គ្រាន់ដោយមានខ្វះខាតកំលាំងតិច ព្រាណជាធម្មជាតិមួយដែលអាចផ្ទេរចេញពីគ្នាបាន ឬយកទៅជួយគ្នាបាន ដូចពេទ្យសម័យនេះស្រូបយកឈាមពីមនុស្សដែលមានកំលាំងពេញបូន បញ្ចូលទៅក្នុងមនុស្សដម្ងឺ ជួយឲ្យមានកំលាំងច្រើនឡើង ត្រង់ការរក្សាកេតដោយដួងចិត្តនោះ គេយក ព្រាណគឺកំលាំងសរសៃប្រសាទ ទីងកំលាំងខ្យល់ដង្ហើមចេញចូលទៅជួយ ជាជំនួសឈាមបញ្ចូលទៅជួយនោះវិញ វិធីបែបនេះមានក្រឹមប្រការគឺ :

១ - ផ្ទេរព្រាណតាមខ្លួនពេទ្យ ចូលត្រង់ទៅមនុស្សដម្ងឺតែម្តង វិធីនេះធ្វើបានពីរយ៉ាង យ៉ាងប្រើ "ផ្លុំ" ដែលមិនបញ្ចូលខ្យល់ដង្ហើមព្រមទាំងកំលាំងព្រាណឲ្យផ្សាយចូលទៅ ដូចគ្រោះប្រើត្រង់កន្លែងដែលឈឺនោះ យ៉ាងទៀតប្រើប្រាប់ដៃស្ទាប ដោយប្រកាន់ថាព្រាណឬគ្រោះដួងចិត្តនោះផ្សាយចេញតាមចុងម្រាមដៃរបស់មនុស្សជាច្រើន ហេតុនេះឯងបានជាធម្មជាតិធ្វើឲ្យមនុស្សគ្រប់ជាតិគ្រប់សាសនា នេះដឹងប្រើម្រាមដៃ

បង្កើតគំនិតពិឃាតការរៀង ឲ្យមនុស្សស្លាប់ បើជាការសំខាន់ ដែល ចង់បង្ហាញឲ្យមនុស្សជឿ ដូចជាអ្នកមានអំណាចលើអ្នកដែលនៅក្រោម បង្គាប់នោះ កាលណាបង្គាប់ការជាមុន ច្រើនប្រើម្រាមដៃចង្អុលទៅ អកចូលបង្គាប់ជាដើម ពោលគឺត្រូវតែបង្គាប់ដោយសំដីហើយ ថែម បង្គាប់ដោយក្រសែដួងចិត្តទៀត មនុស្សដែលមិនស្គាល់ក្រសែដួងចិត្ត នោះ ក៏អាចធ្វើបានដែរ ព្រោះជាកំណើតរបស់ធម្មជាតិ ។

២– មានវិធីម៉្យាងទៀត សម្រាប់មនុស្សរក្សាជម្ងឺ ដែលមិនអាចទៅ ដល់ខ្លួនមនុស្សជម្ងឺឬប៉ះពាល់ដល់ខ្លួនមនុស្សជម្ងឺនោះ គឺផ្ញើព្រាណចូល ទៅរបស់អ្វីមួយ រួចបានផ្ញើតែរបស់នោះចូលទៅខ្លួនមនុស្សជម្ងឺ របស់ ដែលងាយនឹងទទួលព្រាណទុកនោះមានច្រើនយ៉ាង ដែលល្អបំផុតគឺទឹក ការ ផ្ញើព្រាណឲ្យចូលទៅក្នុងទឹកនោះ ទំនងប្រើដៃត្រាំទឹក ឬផ្លុំឲ្យខ្យល់ដក ដង្ហើមចូលទៅក្នុងទឹកក៏បាន រួចយកទឹកនោះទៅស្រោចមនុស្សជម្ងឺ វិធី នេះគឺវិធីធ្វើទឹកមន្តដែលយើងដឹងស្គាល់គ្រប់គ្នា ។

៣ – សម្រាប់អ្នកដែលមានកំលាំង ដួងចិត្តខ្លាំងណាស់នោះ មិន បាច់ផ្ញើព្រាណផ្លូវនេះទេ គេអាចប្រើកំលាំងដួងចិត្ត បង្គាប់ព្រាណឲ្យចេញ ទៅឆ្ងាយៗ ចូលទៅក្នុងខ្លួនមនុស្សជម្ងឺបាន ។ ដែលនឹងធ្វើឲ្យសម្រេច តាមវិធីនេះ អ្នករក្សាជម្ងឺនិងមនុស្សជម្ងឺត្រូវប្រតិបត្តិតាមរបៀប គឺ

www.elibraryofcambodia.org

ប្រការ ១ អ្នកសេក្យត្រូវតាំងចិត្តឲ្យមាំបន្ទាប់ពីការរបស់ខ្លួន ឲ្យពេញពីខ្លួនចូលទៅខ្លួនមនុស្សដទៃ ៗ ប្រការ ២ ត្រូវឲ្យមានបរោគតិ មើលឲ្យឃើញជា មនុស្សដទៃនោះទទួលសះជាការកេត ដោយកំលាំងដួងចិត្តរបស់ខ្លួនជាប្រាកដ ៗ ខាងមនុស្សដទៃវិញ ប្រការ ១ ត្រូវមានសេចក្តីជឿជាប្រាកដថា ខ្លួនទទួលជាដោយការសេក្យបែបនេះ ប្រការ ២ ត្រូវឲ្យនឹកថា ខ្លួនពេញចិត្តជាសេកដោយគ្រូនេះជាប្រាកដ បែបនេះហើយដែលជាការសេក្យកេតដោយអំណាចដួងចិត្ត ៗ

សេចក្តីនេះគ្រាន់តែកាត់ស្រង់យកមកប្រាប់ជូនលោកអ្នកមើលសៀវភៅនេះស្តាប់អំពីការសេក្យកេតបែបនេះល្អត្រឹមណា តោះ ទុកប្រើលោកអ្នកមើលវិច័យចុះ ទុកជាដូចម្តេចក៏ ពោះយើងដឹងយល់គោលនេះប្រាកដហើយ យើងក៏មិនត្រូវដៀលមនុស្សដែលមានទុច្ចរិតបោកលន់នាំយកវិជ្ជាអំណាចដួងចិត្តមកប្រើ ជាគ្រឿងប្រដាប់សម្រាប់បញ្ឆោតមនុស្សនោះទេ ៗ

## វិជ្ជាប្រការទី ៣

### ឥទ្ធិវិធិ

រឿងឥទ្ធិវិធិនេះ តាមគម្ពីរសៀវភៅធម្មវិភាគ បរិច្ឆេទទី ២ ពោលជាទំនួសទុកថា "សំដែងឫទ្ធិបានផ្សេង ៗ គឺមនុស្សម្នាក់និមិត្តឲ្យឃើញមានជាមនុស្សច្រើននាក់ក៏បាន មនុស្សច្រើននាក់ត្រឡប់ធ្វើឲ្យទៅតែម្នាក់វិញក៏បាន បំបាំងខ្លួនចេញចូលតាមវត្ថុផ្សេង ៗ ដែលខាំងកំពែង ដូចជាជញ្ជាំងកំផែង



www.elibraryofcambodia.org

ឬក៏បាន ផែនដីទៅផុះក្នុងទីឯណាៗក៏បាន ដើរលើទឹកក៏បាន ហោះហើរដើរអណ្ដែតលើអាកាសក៏បាន យកដៃទៅស្ទាបព្រះចន្ទនិងព្រះអាទិត្យក៏បាន ប្រើអំណាចកាយទៅដល់ព្រហ្មលោកក៏បាន ។

សម្ដេចព្រះមហាសមណ ក្រុមវិញ្ញាណវិសេស បានប្រទានព្រះដំរិះថា "ការបង់ទេសមើលទៅ ជារបស់ហួសធម្មតាមនុស្ស តែនៅមានកិច្ចការរបស់មនុស្សយកមករៀបប្រដូចបានច្រើនយ៉ាង គឺមនុស្សម្នាក់ធ្វើឲ្យឃើញហនជាច្រើននាក់ ប្រដូចនឹងមនុស្សម្នាក់ធ្វើការបានច្រើនមុខ ប្រៀបដូចជាព្រះរាជាមួយព្រះអង្គគ្រងអាណាចក្រជាច្រើន មនុស្សច្រើនឲ្យឃើញតែម្នាក់នោះ ប្រៀបនឹងការរួមសាមគ្គីរបស់ឯកជនជាមួយគណៈ ដូចយ៉ាងព្រះសង្ឃ ប៉ុន្មាននឹងដែនដី ប្រៀបនឹងការដាក់ទម្ងន់ ដើរលើទឹកប្រៀបនឹងមនុស្សទៅប្រទេសត្រជាក់ដើរលើទឹកកក ហោះ ប្រៀបនឹងអា-កាសយាន ស្ទាបព្រះអាទិត្យនិងព្រះចន្ទដោយដៃបាន ប្រៀបដូចការស្ទង់ដំណើរព្រះចន្ទនិងព្រះអាទិត្យរហូតដល់ចេះចំងាយចាយចន្ទត្រាស់ស្គាល់ត្រាស់បាន ប្រើអំណាចដោយកាយទៅដល់ព្រហ្មលោកបាននោះ ប្រៀបដូចការចេះចំងាយចាយផ្កាយនពគ្រោះនិងស្ថានរបស់ផ្កាយឫក្សបាន" តាមសេចក្ដីប្រៀបនេះ មើលទៅសម្ដេចព្រះមហាសមណៈទ្រង់មិនជឿឥទ្ធិឫទ្ធិសោះក៏ទេ តាមដែលបរិយាយទុកក្នុងទេសនោះ

www.elibraryofcambodia.org

ឃើញថាខ្ញុំគង់ជឿខ្លះ ឬក៏ជឿទាំងអស់ តែខ្ញុំជាព្រះពុទ្ធមាមកៈ ក្នុងប្រទេសស្យាម ក្នុងសម័យដែលខ្ញុំគង់ព្រះជន្មនៅឡើយ បើគង់មានព្រះបន្ទូលការអ្វីចេញទៅ ខ្ញុំប្រយ័ត្នមិនពោលពីរបស់អ្វីដែលពិចារណាពិសោធបាននោះទេ ដើម្បីបង្ការមិនឲ្យមានសេចក្ដីអែកពីមនុស្សទាំងឡាយនោះផង ប្រការមួយទៀត ខ្ញុំឃើញថាក្នុងសម័យនោះ ការសិក្សាធម៌របស់ព្រះពុទ្ធជាម្ចាស់សំដៅទៅតែក្នុងផ្នែកគន្ថធុរៈជាច្រើន ព្រមទាំងវិបស្សនាធុរៈ មានអ្នកសិក្សាតិច បានជាខ្ញុំរកពាក្យ អធិប្បាយឲ្យចូលចិត្តងាយ សៀវភៅដែលខ្ញុំតែងទុក ក៏ជាបែបសម្រាប់រៀនជាក់ស្ដែង ៗ បើប្រសិនជាខ្ញុំមិនប្រៀបប្រដូចខ្លះអ្នកដែលចាប់រៀនពិបាកនឹងញែកឃើញជាការសិក្សា ផ្លូវព្រះពុទ្ធសាសនាជារបស់ពិបាកលើសវិស័យមនុស្ស ហេតុនេះគួរឃើញគួរយល់ថាការប្រៀបប្រដូចនោះ ជាការបង្ខំ មិនមែនជាខ្ញុំមិនជឿសទ្ធិវិធីដូចជាអធិប្បាយរបស់ខ្ញុំ ទុកក្នុងចិត្តខុសនោះទេ ។

សៀវភៅនេះ មិនជាគោលសម្រាប់ឲ្យអ្នករៀនសូត្រគ្រប់គ្នាត្រូវតាមទេ គ្រាន់តែជាសេចក្ដីយល់ឃើញ របស់បុគ្គលពោលតាមគំនិតដែលពិតឃើញ ដោយមិនភ្ជាប់ក្នុងសេចក្ដីបំពក់បំពង បើលោកអ្នកឯណាយល់ឃើញថានៅមានសេចក្ដីគក់ភ្ជាក់ជាច្រើនឬខុសទាំងអស់ក្ដី ក៏ប្រែតែង

សេចក្ដីជាសៀវភៅមួយ ក្នុងរឿងដូចគ្នានេះ មកពីយាគលបណាន់សេចក្ដីយល់ឃើញរបស់សៀវភៅនេះឲ្យរលំរលាយទៅ របៀបដូចគេកាប់ក្រ-វែលដើមចេកដោយដាវមុតដូច្នោះចុះ ។

កាលសេចក្ដីយល់ឃើញថា ឥទ្ធិវិធី មានសេចក្ដីប៉ុនប៉ងត្រង់ការមិនខុសគ្រប់ប្រការមិនចាំបាច់គិតរបៀបធៀបទេ ព្រោះឥទ្ធិវិធីជារបស់ខ្ពស់លើសវិស័យមនុស្សសាមញ្ញជាប្រាកដ. បើប្រកាន់ថាចិនដែលដើរលើទឹកកក្កុងកេងត្បើកកកតាម ឬជាតិសាសន៍អស្ដុម្ប ដើរលើទឹកកកកេតាប់ផ្ទាំងទឹក អ៊ីចឹងក៏កើតសុំណូលដើម្បីបូជា ត្រូវជាមុះតើងចាំងនោះ ទុកជាតួអ្នកបួកកលលប្រពន្ធឥទ្ធិវិធីពិតមែនហើយ ក៏គួរកេណាកគាស្នូវវិជ្ជា ៨ ប្រការតែគកណាស់ បកក្ដាក់ចុះដល់ថ្នាក់តាមបំផុតហួសគេនេះ មើលទៅសម្ដេចព្រះមហាសមណៈប្រាកដជាទ្រង់មិនប្រកាន់ជឿដូច្នោះទេ ដែលទ្រង់របៀបទុកដូចបានពោលមកហើយនោះ គ្រាន់តែជាសេចក្ដីប្រដូចប៉ុណ្ណោះ ។

ឥទ្ធិវិធីនេះ មានលក្ខណៈជិតមនោមយិទ្ធិជាច្រើន បើនឹងហៅថាមនោ-មយិទ្ធិវិធីមានកំណាំងក៏បាន ការនឹងអធិប្បាយវិជ្ជានេះ ត្រូវតែអធិប្បាយជាដំណាក់ៗ ដូចបានអធិប្បាយមកហើយក្នុងមនោមយិទ្ធិ គឺថ្នាក់ទាប ថ្នាក់កណ្ដាល និងថ្នាក់ខ្ពស់បំផុត ។



www.elibraryofcambodia.org

ជាឧទាហរណ៍ដែលបានឃើញជាច្រើន មនុស្សខ្លះរកស៊ីការបោកប្រាក់បន្តិច ៗ ឲ្យដែលយើងហៅថាល្បិចកល ហេតុអ្នកលេងល្បែងនោះគង់ញញឹមចំអកចំអន់ថា មិនគួរនាំយករឿងល្បិចកល ជារបស់គេតាមច្បាប់កុសលអកុសលសៀវភៅដែលពោលពីវិធីប្រើ របស់ព្រះពុទ្ធជាម្ចាស់នោះ ហេតុដែលយកមកពុះពារនេះត្រង់តែសំគាល់ដល់កំណត់នូវចិត្តរបស់បុគ្គល មិនបានសំគាល់ដល់ការដែលលេងបញ្ឆោតអ្នកមនុស្ស យ៉ាងដែលចាប់បានរាយ ៗ នោះទេ ល្បែងល្បិចកលនេះបានឃើញមកជាច្រើន ហាងល្បិចប៉ុន្មាន ៗ ជាកិច្ចធ្វើឲ្យខូចណាស់ដល់ការមនុស្សជាច្រើន ច្រើននិយាយគ្នាថា លេងត្រង់នេះជាការបញ្ឆោត ត្រង់នោះជាការបំបាំងខ្លួន ហាក់ដូចជាថាខ្លួនដឹងត្រឹមនេះក៏ល្មមស្គាល់បានហើយដែលជាពិតប្រាកដនោះមិនទាន់ស្គាល់ល្អប្រពៃត្រង់ទេ នៅមានរបស់ដែលគួរឲ្យដឹងស្គាល់គេទៅទៀត គឺជាការដែលគេលេងបញ្ឆោតបំបាំងខ្លួននោះតើគេធ្វើដោយវិធីណា ?

ការបំបាំងខ្លួននេះ បានស្រាវជ្រាវរកសេចក្ដីអធិប្បាយ ព្រោះឃើញក្នុងសៀវភៅរបស់ពួកសណ្ដែង ឈ្មោះស្តាំបន្ទាស់ ដែលទុកជាគោលដ៏សំខាន់ជាគំនិតរបស់មនុស្សយើងនោះ គេបង្ហាញកើតជាប្រាកដទៀងទាត់ ទុកដែលការណាគំនិតនោះទាំងណាស់ ហើយត្រូវបញ្ចូលគំនិត

គឺនេះឲ្យបានយល់ច្បាស់ថារូបភាពនៅក្នុងនឹកដែលនឹងធ្វើឲ្យគេឃើញនោះបាន គំនិតដែលធ្វើឲ្យកើតជារូបភាពនេះ ភាសាបារាំងហៅថា (Forme de la pensée) មនុស្សដែលគេនឹកគេឃើញអំណាចដួងចិត្តរបស់ខ្លួនជាពិតប្រាកដនោះ គឺធ្វើគំនិតឲ្យបានជារូបភាពឡើង ដោយវិធីបែបជាមួយនឹងមនោធម្មោះ ដែលបានពន្យល់មកហើយ, គោលគឺ (១) ចក្ខុនិមិត្ត (Vision) ពន្យល់បង្ហាញឲ្យឃើញនូវរបស់ ដែលត្រូវការនឹងធ្វើឲ្យកើតមានឡើងនោះ ពាល់តែជាប់នៅនឹងនឹក; (២) មនោមយិទ្ធិ (Volonté) គឺឲ្យមានសេចក្តីប្រាថ្នាយ៉ាងខ្លាំង ចង់ឲ្យរបស់នោះកើតមានឡើង; (៣) ឲ្យបានសមាធិ (Concentration) បែបយ៉ាងដែលនឹងធ្វើនោះ គឺបើបានដបមួយទទេស្អាត ហើយនឹងធ្វើឲ្យមនុស្សឃើញបានជាផ្កាកុលាបនៅក្នុងដបនោះ (១) ត្រូវតាំងរូបភាពលក្ខណៈផ្កាកុលាបឲ្យជាប់នៅនឹងនឹកដែលជាចក្ខុនិមិត្ត របស់នេះមិនបែរធ្វើដោយងាយបាននោះទេ គេនឹងហាត់ធ្វើយូរឆ្នាំ ដូចជាអង្គុយសំឡឹងកសិណ ដែលបានពោលមកហើយនោះ ការដែលពិបាកធ្វើនោះ គឺមកពីនឹកមនុស្សឃើញ កាលណាបានបិទភ្នែកយករូបដែលបានឃើញមកជាប់នៅនឹងនឹកបានត្រឹមតែភ្លែតៗ បានជាការរៀនចក្ខុនិមិត្តហើយ ពន្យល់ឲ្យធ្វើរូបជាប់នៅនឹងនឹក ឲ្យបានយូរតាមត្រូវការនោះជារបស់ពិបាកធ្វើណាស់ (២) គេនឹងមានសេចក្តីប្រាថ្នាយ៉ាងខ្លាំង ដែលនឹងធ្វើ



www.elibraryofcambodia.org

បញ្ចាំងរូបផ្កាកុលាបឲ្យទៅមាននៅក្នុងផែនបនោះ (៣) គេអាចមានសមត្ថិ ដាក់លេចឲ្យនឹងនៅក្នុងផ្កាកុលាបនោះតែម្យ៉ាង ។

តាមគោលដែលបានមកនេះ បើលោកជឿឬមិនជឿក៏តាមចិត្តចុះ តែមនុស្សដែលគេជឿ គេចាំយកវិធីនោះមកប្រើ ក្នុងការល្អរបស់ផ្សេងៗ បានសម្រេច ដូចជាគ្រឿងថតរូប ភាពយន្ត (កុនស្រមោល) នឹងគ្រឿងបញ្ចាំងស្រមោលរូបតាមវាំង សុទ្ធតែយកជ្រាប់តាមវិធីនេះ គ្រាន់តែប្រើក្នុងខ្លួនមនុស្សប៉ុណ្ណោះ គ្រឿងថតរូបមានកញ្ចក់យ៉ាងក្រាស់ភ្ជាប់មុខបំពង់គ្រឿងថត ប្រៀបដូចភ្នែកមនុស្ស សម្រាប់ទុះយករូបទៅមុខគ្រឿងចូលទៅជាប់ហ្វីល ឯក្នុងដែលមានថ្នាំភ្ជាប់សម្រាប់ទទួលស្រមោលរូបទុក ប្រៀបដូចដួងចិត្តរបស់មនុស្ស ដូចមានពោលមកហើយ ជាភ្នែកមនុស្សកេចទុះយករូបដែលឃើញមកភ្ជាប់ទុកទៅនឹងភ្នែកបានក្នុងវិញ្ញាណ ព្រោះគេបានប្រទះវិធីមួយនេះហើយ បានជាគេគិតធ្វើភាពយន្តឲ្យសម្រេចបាន គឺផ្លាស់រូបកល់ក្នុងវិញ្ញាណ ឲ្យមនុស្សមើលឃើញរូប កម្រើកដៃជើងដើរទៅមកបាន តែបើយើងទៅពិនិត្យ ពិចារណាមើលរូបក្នុងហ្វីលឲ្យច្បាស់ប្រាកដហើយ ក៏នឹងឃើញរូបទាំងនោះផ្សេងៗ ពីគ្នា ជាមួយៗ កប់ ពាក់ភ្ជាប់រូប ។

ភាពយន្តក៏ ឬគ្រឿងទុះរូប (Appareil projecteur) ក៏ សុទ្ធតែគិតបង្កើតតាមគោល ៣ ប្រការនេះជាពិត គឺភ្នែកហាចិត្តបង្កើតឡើងដូចជា



www.elibraryofcambodia.org

រូបភ្ជាប់ទៅហ្វីល្មកញ្ចក់ដែលមានរូបជាប់នៅនោះ មានរាងយ៉ាង ដូចគ្រឿងចក្ខុរូបទៅឃើញខ្លួនសំតក់តាំង សម្រាប់ដូចតាំងដំកល់គ្រឿងចក្ខុឲ្យនឹងបិទប្រដាក់កៅកញ្ចក់ ដើម្បីឲ្យឃើញរូបច្បាស់ (Foyer) ងារគ្រឿងចក្ខុរូបការវិប្រោះ ក៏យកការគោលនេះដូចជា គ្រាន់តែចូរគ្រឿងតាំង ៣ នោះឲ្យទាំងឡើង ។

គ្រានេះយើងពិនិត្យលំបួសគល់ថា ការលេងកល ។ ពាយល្បែង ៗ ដែលគួរឲ្យចូលចិត្តនោះបង្កើតពីក្រុកទឹងដួងចិត្តរបស់មនុស្សនោះឯង ពីព្រោះរូបតាំងនោះគ្រាន់តែជាស្រមោល មិនមែនខ្លួនប្រាកដនោះទេ បានជាឃើញកែក្នុងវេលាកំពុងដួងចិត្តមានសំណាចបន្ទាប់ ឲ្យមានជារូបឡើងឲ្យមនុស្សឃើញបានមួយស្របក់ បានជាថតរូបមិនជាប់ បានក៏ដែលបានឃើញពួកយោគី ធ្វើរបស់ផ្សេងៗ ឲ្យកើតបានក្នុងវេលាមួយរំពេចនោះ គេបានព្យាយាមថតយករូបទុក តែដល់លាងហ្វីល្មទៅ មិនឃើញមានរូបជាប់នៅនឹងហ្វីល្មសោះ ។

សេចក្ដីដែលពោលមកនេះ ជាវត្ថុវិធីយ៉ាងទាប តទៅនេះយើងនឹងល្បងពិចារណាដល់យ៉ាងកណ្ដាល ។

តាមពាក្យអធិប្បាយរបស់ព្រះយោគីប្រការមួយថា ដួងចិត្តរបស់យើងកាចសាហាវៈឲ្យយើងបានមួយបែបទៀត ដែលក្នុងភាសាបារាំង


www.elibraryofcambodia.org

ហៅថា ព្រាកស្ត្រូស៍ (Bras astraux) បើប្រែតាមពាក្យថា "ដៃដែលជាប់គនឹងដួងផ្កាយ" គេអធិប្បាយថា យើងអាចប្រើដៃបែបនេះ ទៅធ្វើការយ៉ាងណា ៗ បានតាមត្រូវការ ដោយខ្លួនយើងមិនបាច់កម្រើកពីទីកន្លែង ដៃបែបនេះនឹងចង់ឲ្យមានកំឡាំងប៉ុណ្ណា ៗ ក៏សម្រេចបានតាមចិត្តអ្នកដែលមានអំណាចប្រើដៃបែបនេះ អាចធ្វើឲ្យកម្រើករបស់ដែលមានទម្ងន់ធ្ងន់លើសកំលាំងមនុស្ស ឲ្យឃ្លាតចេញពីទីកន្លែង មិនបាច់ពាល់ដោយដៃក៏បាន ហើយនឹងធ្វើការផ្សេង ៗ បានច្រើនជាអនេកគណទៀត សេចក្តីនេះត្រូវនឹងនិទ្ទេស ក្នុងឥទ្ធិវិធីរបស់យើងថា "ពាល់អង្អែលព្រះអាទិត្យនឹងព្រះចន្ទដោយដៃបាន" ។

ព្រាកស្ត្រូស៍ ឬដៃដែលជាប់គនឹងដួងផ្កាយនេះជាសេចក្តីប្រាជ្ញាយ៉ាងខ្ពស់បំផុត របស់ពួកយោគីក្នុងឥណ្ឌា ដល់ធ្វើឲ្យកើតមានឡើង បានជានាំគ្នាទៅព្យាយាមធ្វើ អស់បាយក្រហាយចិត្ត ទៅតាមភ្នំហិមាល័យកប់ជាឆ្នាំ ៗ ខ្លះក៏របួតអស់មួយជីវិតក៏មាន តាមដែលបានឃើញកាសែតអង់. គេនិយាយរៀបរាប់ ពីពួកយោគីដែលទៅប្រកាសព្រះពុទ្ធសាសនាក្នុងស្រុកបារាំងនោះ យោគីដែលជាមេគណ បានអធិប្បាយបំភ្លឺសេចក្តីឲ្យអ្នកតែងកាសែតថា ផលដែលពួកយោគីត្រូវការលុះនោះ គឺត្រូវការឲ្យមានឫទ្ធិកើតក្នុង ខ្លួនបន្ទាប់ពាក្យទាំង ៤ បាន (គឺសំដៅសេចក្តីថានឹងធ្វើឲ្យក្រៀន



www.elibraryofcambodia.org

ព្រាត់ចុះបកមកឲ្យវិញបានតាមសេចក្ដីត្រេកអរ) តាំងពីនោះមកដល់សព្វថ្ងៃនេះ ពួកយោគីណាធ្វើបាន ទុកជាដូចម្ដេច ក៏គង់តាំងព្យាយាមករៀនបកស្រាយជឿជាក់ថា ព្រះពុទ្ធជាម្ចាស់ព្រះអង្គធ្វើបានសម្រេចជាប្រាកដ ។

វិធីធ្វើឲ្យកើតដំបែបនេះ តាមគំនិតរបស់ពួកយោគីនោះឃើញថា មិនហួសពីគោលតាំង ៣ ដែលពោលមកនោះទេ គ្រាន់តែថែមមនោគតិ (Imagination) ឡើងមួយទៀត ដើម្បីជួយឲ្យមនោមយិទ្ធិមានកំលាំងខ្លាំងឡើង ប៉ុន្តែសម្រាប់ជួយឲ្យមានចិត្តជឿខ្ជាប់ខ្ជួនថាការសម្រេចរបស់ខ្លួន ព្រោះមនុស្សយើងនឹងធ្វើការអ្វី បើមិនជឿថាការនោះនឹងសម្រេចបានទេ ក៏គ្មានផ្លូវសម្រេចបានឡើយ ដែលពោលមកនេះជាយ៉ាងកណ្ដាល ត្រា-នេះនឹងពិចារណាដល់ជាន់ខ្ពស់បំផុត ។

ឯវិធីយ៉ាងខ្ពស់បំផុតនោះ តាមសេចក្ដីអធិប្បាយដែលបានប្រទះមក គឺការប្រើ (១) រូបកាយ (Corps astral) ដែលពោលមកហើយក្នុងមនោមយិទ្ធិ (២) សេចក្ដីគិតបង្កើតឲ្យជារូបរាង (Formo de la penséo) (៣) ដៃដែលជាប់តពីកាយ (Bras astraux) ទាំង ៣ ប្រការនេះរួមគ្នាជាមួយ ពោលគឺប្រើទី ១ ជាខ្លួនរបស់យើង, ប្រើទី ២ ជាគ្រឿងបញ្ជូនខ្លួនយើងឲ្យទៅប្រាកដនៅកន្លែងណា ៗ បាន, ប្រើទី ៣ ជាកំលាំងធ្វើការគ្រប់យ៉ាងបានតាមចិត្ត តែរូបខ្លួនដែលជាអ្នកធ្វើនោះនៅ ។



www.elibraryofcambodia.org

ចិត្តខ្លួនដែល មិនបានគេប្រើការខ្លួនទៅណាឡើយ ព្រោះដែលបំបាំង ផែន
ដី ដើរលើទឹក ហោះហើរដើរលើអាកាសនោះ គឺបេតក្ខុតទាំងអស់ ដែល
មានបញ្ហាថា ហេតុអ្វីបានជាព្រះអង្គុលិមាលរត់តាមព្រះពុទ្ធជាម្ចាស់មិន
ទាន់ យើងអាចដោះស្រាយបានដោយងាយ ថាបានជាព្រះអង្គុលិមាល
រត់តាមមិនទាន់ ព្រោះមិនមែនរូបព្រះពុទ្ធដ៏ប្រាកដ គ្រាន់តែបេតក្ខុត
របស់ព្រះអង្គ ដែលព្រះអង្គធ្វើឲ្យកើតឡើងដោយឥទ្ធិពលយ៉ាងខ្ពស់បំផុត
ត្រង់ព្រះរូបព្រះអង្គដ៏ពិតមែននោះមិនចាំបាច់ស្តេចទៅក្នុងចិត្តខ្លួននោះ
ក៏បាន ។

កាលណារៀបរាប់ពណ៌នាមកដល់មនោមយិទ្ធិ និងឥទ្ធិពលទាំង
នេះហើយ ច្រើនមានមនុស្សចូលចិត្តគិតជាបែបយ៉ាង ហ៊ិបណូទិស៍
(Hypnotisme) វិធីសណ្តំដួងចិត្ត តាមសេចក្តីពិតប្រាកដនោះខុសពាក្យប្រែ
ពាក្យដែលហៅថា ហ៊ិបណូស៍ មកពីភាសាក្រិក (Hypnose) ប្រែថា
លក់ វិជ្ជាបែបនេះ ជាវិជ្ជាធ្វើឲ្យមនុស្សដេកលក់ ឬសតិអណ្តែតដោយ
មិនដេកភ្លឹក បែបដែលហៅថា (Hypnotismo on ótat do voillo) វិជ្ជានេះ
មនុស្សយើងរៀនមកអំពីសត្វតិរច្ឆាន ដូចជាសត្វពស់ដែលមានអំណាច
សម្លឹងសត្វផ្សេងៗ ឲ្យគក់ស្លុតជាអាហាររបស់វា បានជាមានពាក្យហៅ
ម្យ៉ាងទៀតថា (Magnétisme animal) ក្បួនស្រូបរបស់សត្វតិរច្ឆាន


www.elibraryofcambodia.org

វិបាកនេះហើយគឺការយល់ឃើញថា ខ្លួនកើតមកតាមអំពើពីអតីតជាតិជាច្រើន ព្រោះវិជ្ជា ២ ប្រការនេះ ព្រះពុទ្ធជាម្ចាស់មិនបានរៀនមកពីសត្ថាណាទេ ប្រការមួយទៀត ហ៊ីប៉ូតេស៊ី បើបានចាំផ្លូវណាខ្លះទៅក្រោយ ព្រលឹងជាបានមនុស្សជាច្រើននាំយកទៅប្រើក្នុងផ្លូវដើរណាមកក្រោយ ដូចជាប្រើជារឿងនិទានកាប់ឲ្យស្ដាប់ស្រួលចិត្ត ឲ្យព្រមរួមប្រពៃណីជាដើម ឯមាត្រាមយ៉ាង ពីអំពើពីមុននោះ នឹងនាំយកទៅប្រើក្នុងផ្លូវណាមកអនាគតពុំបានឡើយ តែអ្នកណាកាន់សេចក្ដីថាជាយកទៅប្រើដូចពោលមកនេះនឹងធ្វើវិជ្ជា ២ ប្រការដោយគ្មានបែបសាស្ត្រញាណពុំបានឡើយ ការដែលមានមនុស្សខ្លះពោលថា ព្រះពុទ្ធជាម្ចាស់ទ្រង់ប្រើហ៊ីប៉ូតេស៊ីនោះ ជាសេចក្ដីយល់ខុសខ្លាំងណាស់ ហើយជាការមើលងាយព្រះពុទ្ធជាម្ចាស់ដោយមិនរិះគិត ។

គោលផ្សេងៗដែលបានបរិយាយមកនេះ ជាគំនិតរបស់បាត់ព្រីន យោគី ឯចំណែកគោលក្នុងគម្ពីរព្រះពុទ្ធសាសនា តាមដែលព្រះពុទ្ធ- បរមសាស្ដា បរិយាយទុកនោះដូចមានសេចក្ដីតទៅនេះ

គ្រាជាដំបូង ទ្រង់ធ្វើកសិណ ៨ ពីបឋវីកសិណដល់ឱទាត- កសិណ មិនបាច់ប្រើអាលោកកសិណ នឹងបរិច្ឆិន្នាកាសកសិណនោះទេ ប្រើតែឈាន ៨ ដោយអនុលោម (តាមលំដាប់) នឹងបដិលោម (ច្រាស ឡើង) ដោយអាការ ១៤ យ៉ាងដូចមានតទៅនេះ



www.elibraryofcambodia.org

១ ធ្វើវៀនតាមលំដាប់កសិណ គឺតាំងពីបឋវីកសិណ ទៅឱទាត-សិណ វៀនកបត់ទៅដល់ ឧទាតកសិណ បានមួយរយមួយពាន់ដង ។

២ ធ្វើកសិណព្រាសទៀន ពីឧទាតកសិណ, លោហិតកសិណ ចល់ដល់បឋវីកសិណ ធ្វើបែបនេះឲ្យបានច្រើនគ្រាដូចគ្នា ។

៣ ធ្វើតាមលំដាប់កសិណ វៀនទៅពាល់តែរស់ រួចធ្វើព្រាសទៀនវិញឲ្យពាល់តែដល់ដើមវិញ ។

៤ ចូលរូបជ្ឈាន ពីបឋមជ្ឈានដល់ចតុត្ថជ្ឈាន រួចចូលអរូបជ្ឈាន ពីវិញ្ញាណញ្ចាយតនជ្ឈាន តាមលំដាប់ពាល់តែដល់នេវសញ្ញានាសញ្ញា-យតនជ្ឈាន ឲ្យបានច្រើនគ្រា ។

៥ ចូលឈានព្រាសទៀន ពីនេវសញ្ញានាសញ្ញាយតនជ្ឈាន ទៅដល់បឋមជ្ឈាន ។

៦ ចូលឈានតាមលំដាប់រួចហើយ ចូលព្រាសទៀនវិញ ផ្លាស់ប្តូរបែបនេះជាផកបទៅ ។

៧ ធ្វើវៀនតាមលំដាប់កសិណ តែរំលងលំដាប់ឈាន គឺចូលបឋវី-កសិណរួចហើយ ចូលបឋមជ្ឈាន ។ រួចហើយ ត្រឡប់ចូលបឋវីក-សិណវិញ រួចចូលតតិយជ្ឈាន (រំលងទុតិយជ្ឈាន) រួចហើយ ផ្លាស់ពីបឋវីកសិណទៅចូលអាបោកសិណរួចហើយ ចូលឈានរំលងតាមលំ-ដាប់ផ្លាក់ឈាន ទីផ្លាស់កសិណឲ្យវៀនក្តាដកបតទៅ ទាល់តែគ្រប់ ៨ ។



www.elibraryofcambodia.org

៨ ធ្វើរៀងតាមលំដាប់ឈាន តែរំលងលំដាប់កសិណ គឺចូលបឋមជ្ឈានហើយ ចូលបឋវីកសិណ រួចត្រឡប់ទៅចូលបឋមជ្ឈានវិញ រួចចូលតេជោកសិណ ( រំលងអាបោកសិណ ) ធ្វើតាមលំដាប់នេះរួចហើយ ផ្លាស់ពីបឋមជ្ឈាន ទៅចូលទុតិយជ្ឈាន រួចចូលកសិណរំលងតាមលំដាប់ ផ្លាស់កសិណ នឹងផ្លាស់ឈានឲ្យរៀងគ្នាទាល់តែគ្រប់ទាំង ៨ ។

៩ រំលងទាំងឈាននឹងកសិណ ពោលគឺចូលបឋមជ្ឈាននឹងបឋវីកសិណហើយ ចូលតតិយជ្ឈាននឹងតេជោកសិណ ធ្វើដូច្នេះជាដរាបតទៅ ។

១០ រួមអង្គ សំដៅសេចក្ដីថា ចូលបឋមជ្ឈាននឹងបឋវីកសិណ ចូលទុតិយជ្ឈាននឹងបឋវីកសិណ, ចូលតតិយជ្ឈាននឹងបឋវីកសិណ ធ្វើតាមលំដាប់នេះទៅទាល់តែអស់ ។

១១ រួមអារម្មណ៍ សំដៅសេចក្ដីថា ចូលបឋមជ្ឈានហើយ ចូលបឋវីកសិណ រួចវិលទៅចូលបឋមជ្ឈានវិញ រួចចូលតេជោកសិណ ធ្វើយ៉ាងនេះទាល់តែអស់កសិណ ហើយសឹមផ្លាស់ឈានថ្មី ។

១២ រួមអង្គនឹងអារម្មណ៍ សំដៅសេចក្ដីថា ចូលឈាននឹងផ្លែកកសិណជាលំដាប់ទៅ ពោលគឺបឋមជ្ឈាននឹងបឋវីកសិណ រួចចូលទុតិយជ្ឈាននឹងអាបោកសិណ រួចចូលតតិយជ្ឈាននឹងតេជោកសិណ ។ល។

១៣ កំណត់អង្គ គឺមិនបានចូលឈាន ត្រូវតែកំណត់ថាឈាន ណា មានអង្គប៉ុន្មាន ដូចជាបឋមជ្ឈាន មានអង្គ ៥ ទុតិយជ្ឈានមានអង្គ ៣ (ដូចមានរបៀបបញ្ជាក់ទុកក្នុងទំព័រ ៣៨) ។

១៤ កំណត់អារម្មណ៍ គឺមិនបានចូលកសិណ ត្រូវតែពិតដល់ កសិណថាមានរបស់នោះៗ ជាអារម្មណ៍ ដូចបឋវីកសិណ មានដីជាអា· រម្មណ៍ អាបោកសិណ មានទឹកជាអារម្មណ៍ ។ល។

តាមវិធីដែលពណ៌នាមកតាំងពីទី ១ ដល់ទី ១៤ នេះ ត្រូវតែរបៀប គំនិតខ្លួនជាទៀយហត់ទៅហើយ បើប្រសិនជាធ្វើពិតមែន ពិនឹងកំបាក យ៉ាងណាក៏ដោយ ប្រសិនជាសទ្ធាវិធីជារបស់ធ្វើបានដោយងាយពិតមែន ហើយ តែគួរអោយគ្មានអ្នកឯណាធ្វើតាមដល់ទេ បុំងជាធាំត្នាហោះ អស់ហើយ ។ បើធ្វើបានសម្រេចតាមវិធីដូចបញ្ជាក់ទុកទាំង ១៤ ប្រការ នេះហើយ ដួងចិត្តនឹងទន់ភ្លន់គួរដល់ការងារ ជាដួងចិត្តបរិសុទ្ធផូរផង់ល្អម៉ា ម៉ួនប្រាសចាកគ្រឿងសៅហ្មង ជាចិត្តគួរដល់អភិធម៌ដែលអាចសំផែង ឫទ្ធិបានតាមវិធីរបស់លោកដែលពន្យល់ទុកមក ដូចមានតទៅនេះ ៖

១ បើត្រូវការបំបាំងខ្លួន ដើរចេញចូលទៅមកតាមជញ្ជាំង កំពែង ឬទីកន្លែងដែលមានអ្វីខាទាំងកំងកផ្សេងៗនោះ លោកឲ្យចូលអាកាសក· សិណស្រេចហើយរំពឹងដល់ជញ្ជាំងឬកំពែងនោះ រួចអធិដ្ឋានថា របស់

ទាំងនោះឲ្យក្លាយទៅជាអាកាស ផ្ទាំងថ្មកំពែងនោះក៏ទន់ទៅជាចន្លោះមួយរំពេច បើប្រសិនជាទៅទាស់ ត្រូវអធិដ្ឋានជាថ្មីទៀតវិញ ។

២ បើត្រូវការដើរលើដី ឲ្យចូលអាបោកសិណ រួចអធិដ្ឋានឲ្យដីត្រឡប់ទៅជាទឹក ។

៣ បើនឹងដើរលើទឹក ឲ្យចូលបឋវីកសិណ អធិដ្ឋានឲ្យទឹកទៅជាដី ។

៤ បើនឹងហោះហើរដើរលើអាកាស ឲ្យចូលបឋវីកសិណ អធិដ្ឋានឲ្យអាកាសទៅជាដី ។

៥ អំពីការលូកស្ទាបព្រះអាទិត្យព្រះចន្ទនោះ តាមគម្ពីរវិសុទ្ធិមគ្គ គឺឲ្យអធិដ្ឋានដូចគ្នា កាលណាអធិដ្ឋានហើយ ព្រះចន្ទព្រះអាទិត្យក៏នឹងធ្លាក់ចុះមកដូចជាផ្លែត្នោតជ្រុះពីធ្លាយមកនៅក្នុងដៃ តែដួងព្រះចន្ទព្រះអាទិត្យពិតនៅតែនៅទីកន្លែងដើមដដែល ឯដួងព្រះចន្ទព្រះអាទិត្យដែលគេឃើញនៅដៃនោះ គឺរូបនិម្មិត មិនមែនដួងព្រះចន្ទព្រះអាទិត្យមែនៗនោះទេ ។

តាមសេចក្ដីនេះឃើញថា ឥទ្ធិវិធិគ្រប់យ៉ាង សម្រេចដោយការអធិដ្ឋាន គឺការដែលនិម្មិតមនុស្សម្នាក់ឲ្យឃើញមានជាមនុស្សច្រើនឬនិម្មិតមនុស្សច្រើនឲ្យឃើញមានតែម្នាក់វិញ ឬក៏ការដកហូតកាយដូចជាដកដាវចេញពីស្រោម ដូចបានពោលមកហើយក្នុងមនោមយិទ្ធិនោះ ក៏សម្រេចដោយការអធិដ្ឋានទាំងអស់ ។

# វិជ្ជាប្រការទី ៤

## ទិព្វសោត

ក្នុងសៀវភៅធម្មវិភាគបរិច្ឆេទទី ២ ពោលជាទំនេសពីទិព្វសោតទុកជាមានត្រចៀកទិព្វលើសមនុស្សសាមញ្ញ ស្តាប់សំឡេងបាន ២ យ៉ាង គឺសំឡេងទិព្វនិងសំឡេងមនុស្ស នៅឆ្ងាយឬជិតបាន សម្តេចព្រះមហាសមណក្រុមដ៏ញាណវិសេស ទ្រង់ប្រៀបទុកជា មានការប្រដូចនូវមនុស្សខិនភ្នែក សន្និដ្ឋានយ៉ាងមនុស្សដែលបានទទួលពាក្យប្រាប់ ស្តាប់សំឡេងអំពីចម្ងាយបាន ធៀបដូចឮដំណឹងពីស្រុកឆ្ងាយដែលហៅថាត្រចៀកវៃ ឥឡូវមានទោរស័ព្ទជាគ្រឿងធៀបផង ។

ឯទិព្វសោតនេះ គ្មានសេចក្តីអ្វីនឹងពោលឲ្យច្រើនណាស់ទេ ព្រោះមិនបានប្រទះពាក្យអធិប្បាយដ៏ពេញចិត្តពិតៗ សោះសោះ ដែលបានប្រទះខ្លះ ក៏ឃើញមានអធិប្បាយតែផ្លូវអំណាចខាងលើ គឺជាអ្នកដែលបានទិព្វសោតនោះ ដោយបានព្យាយាមបំពេញកិច្ច ទាល់តែកេចស្តាប់ព្រះទេព្ដា នឹងសន្ទនាជាមួយព្រះម្ចាស់សួគ៌បាន ពាក្យអធិប្បាយនេះខ្ញុំមិនស្រឡាញ់សោះ ប្រការមួយទៀត គោលរឿងនេះ ប្រហែលនឹងរឿងទិព្វចក្ខុដែលនឹងមានអធិប្បាយទុកដោយពិស្តារនៅនេះ រឿងទិព្វសោតនេះ ដោយឃើញថាត្រចៀកជាភាគមួយ របស់កាយគន្ធៈខាងក្នុង បានជាពោលអំពីកាយគន្ធៈនោះផង ដើម្បីជាប្រយោជន៍ ២ ប្រការ គឺ:



www.elibraryofcambodia.org

១. នឹងនាំយកបញ្ហាដែលនឹងពោលមកនេះ ទៀងកាត់សេចក្តីពិ-ចារណារបស់លោកអ្នកធម៌ ។

២ នឹងដើម្បីជាពាក្យអធិប្បាយអំពីទុក្ខលោកនេះផង ។

ឯទុក្ខលោកនេះ មានមនុស្សជាច្រើនក្នុងលោកនេះ មិនអាចហ៊ាន ប្រើគំនិតគិតព្យាយាមស្រាវជ្រាវ ឲ្យឃើញសេចក្តីពិតដោយខ្លួនឯង នោះ ប្រើតែចុះចិត្តជឿតាមលទ្ធិម្យ៉ាងៗ ដែលមានអ្នកប្រដៅលំអៀង ដោយអគតិ, បានជាសេចក្តីជឿតាមនោះក៏ច្រើនខុសប្រាសចាកពីផ្លូវល្អ បើមនុស្សដែលត្រិះរិះរកហេតុផលដោយខ្លួនឯង ឲ្យឃើញពិតប្រាកដខ្លួន សិនចុះចិត្តជឿ ប្រតិបត្តិតាមសេចក្តីដែលខ្លួនឃើញនោះ ទើបឈ្មោះជា មានដំណើរតាមផ្លូវត្រង់ ហើយជាប្រយោជន៍ដល់ជាតិមនុស្សផង យើង គប្បីដែលបាននឹងឃើញក្នុងពង្សាវតារហេតុជា ក្នុងស្រុកប្រទេសណា ៗ បុគ្គលៈណា ដែលកាន់តែចំរើនឡើងនោះ ក៏មកពីមានមនុស្សត្រិះរិះរក ហេតុ មិនមែនដោយមានមនុស្សជឿហើយផ្តេសផ្តាសតាមលទ្ធិផ្សេង ៗ ដោយប្រាសចាកសេចក្តីពិនិត្យពិចារណានោះទេ ។

អំពីសេចក្តីសន្តោស ជារបស់គួរមាន បើអ្នកណាមានហើយ ក៏ទុកជា មានទ្រព្យដ៏ប្រសើរ ដូចពុទ្ធភាសិតថា «សន្តុដ្ឋី បរមំ ធនំ» មិនចាំបាច់កកេះ កកាយដោយអំណាចតណ្ហា ដែលនឹងដឹកនាំឲ្យធ្វើការទុច្ចរិតបាននោះទេ

សេចក្ដីសន្ដោសនេះសំដៅតែត្រឹមទ្រព្យសម្បត្តិឬយសលាភផ្សេងៗ មិនបានសំដៅដល់សេចក្ដីចេះដឹងទេ ព្រោះចំណេះចេះដឹងជារបស់ដែលយើងគួរស្វែងរកឲ្យខ្ពស់ៗឡើងតទៅ មិនគួរចូលចិត្តនៅត្រឹមចំណេះដែលចេះប៉ុណ្ណោះនោះទេ បើយើងមិនគិតស្រាវជ្រាវរកចំណេះតទៅទៀត រួចថែមទាំងមិនត្រិះរិះគិតរកហេតុផលរបស់ខ្លួនឯងខ្លះផងហើយ លោកក៏មិនបានផុតសភាព ពីព្រៃមកជារមណីយស្អាត បែបយ៉ាងដែលយើងឃើញក្នុងសម័យនេះឡើយ ដូចមានពាក្យរបស់នាយក្រេនវីលក្លៃសែរ ជាតិអាមេរិកាំង ដែលជាអ្នកមានវោហារយ៉ាងឯក សរសេរទុកក្នុងសៀវភៅ "វិធីបណ្ដុះកំលាំងដួងចិត្ត"[១] ថា ការដែលយើងសិក្សាវិជ្ជាដើម្បីជាផ្ទុកចាំឲ្យយើងប្រើគំនិតរបស់យើងឲ្យផុះមានឡើងតទៅទៀត មិនបានយកគំនិតរបស់អ្នកដទៃ មកផ្ទុកនៅក្នុងខួរក្បាលយើងតែម្យ៉ាងនោះទេ ។

ការដែលបានពួកមកដោយវិធីនេះ ដើម្បីជាការដោះខ្លួនទុកជាមុន ក្រែងមានពាក្យនិន្ទាថា ជាមនុស្សឥតត្រូវដោយហេតុដែលចង់ពណ៌នា ដល់រឿងអាយតនៈតទៅនោះ ។

យើងធ្លាប់ទទួលពាក្យប្រដៅមកថា អាយតនៈខាងក្នុងរបស់យើងមាន ៦ យ៉ាងគឺភ្នែក, ត្រចៀក, ច្រមុះ, អណ្ដាត, កាយនិងចិត្ត ហើយយើងធ្លាប់ទទួលពាក្យអធិប្បាយតទៅថា ចិត្តនឹងដឹងរឿងមុនក្រៅពីភ្នែក, ត្រចៀក,

---

១ សៀវភៅ How to bild Mental Powar របស់ Grenvill Kloiser ។



www.elibraryofcambodia.org

ច្រមុះ អណ្តាតនឹងកាយភាយការឲ្យផ្សាបនោះពុំបានឡើយ តែយើងនេះ ដឹងត្រឹមនេះយើងគួរល្មមពេញចិត្តហើយឬនៅ?

គួរយើងល្បងស្រាវជ្រាវមើល ក្រៅអំពីអាយតនៈទាំង ៦ ដែលចេញឈ្មោះមកហើយនោះ តើនៅមានអាយតនៈអ្វីទៅទៀតខ្លះ ដែលនឹងអាចចាំចិត្តឲ្យផ្សាបបាននោះ?

អំពីការដែលនឹងពិចារណាដល់វាទាំងនេះ យើងល្បងគិតគកកាយគេ ហេតុតាំងពីដើមរៀង, សត្វព្រៃ ដល់មនុស្ស អ្នកដែលបានសង្កេត គង់ដែលឃើញដើមឈើតូចៗ ដែលដុះជិតដើមឈើធំ ឬជិតវត្ថុអ្វីមួយច្រើន ធ្លាក់ចេញពីដើមឈើធំៗ ឬវត្ថុទាំងនោះ មិនល្អគួរសងល់នឹងដើមឈើធំៗ ឬវត្ថុដែលដុះនៅក្រោមនោះឡើយ ជាតិលតាវល្លិផ្សេងៗ ដែលដុះនៅទៀងតាមកំពែងព្រៃក៏ច្រើនបោះពួយវង្វេងទៅទីណា ដែលមានកន្លែងកោង ព្រោះត្រូវតែល្អកទៅចាប់តែកោងបាន ដើមឈើនឹងលតាវល្លិទាំងនោះគ្មានភ្នែកទេ ហេតុអ្វីក៏បានជាកើតនិកចេញសក់ពីដើមឈើធំ ហើយត្រូវកាពោះពួយវង្វេងទៅរកទីសម្រាប់កោងនោះបាន?

សត្វព្រៃខ្លះ ដូចជាខ្លាឬសេះ យើងពប់អានថាជាសត្វមានច្រមុះត្រចៀកភ្នែកវៃ កាចពួសំឡេងពីស្រែងក៏ឲបានពីចម្ងាយ ឬមើលឃើញពីចម្ងាយបាន តែដែលត្រាក់ផ្លូវផ្លូសក់នៅតាមផ្លូវ គួរចំណាំមនុស្ស

ដើរទៅមកជាច្រើន ក៏អាចតាមរកម្ចាស់ក៏ដែលនៅឆ្ងាយឃើញ មកពីហេតុស្គាល់ក្លិន មុនដែលនឹងជឿសំដីនេះ យើងគួរតាំងបញ្ហាក្នុងចិត្ត បាន មួយៗ ជាក្លិននេះជារបស់ចុះច្រាសខ្យល់ពុំបាន ហេតុអ្វីក៏តាមរកម្ចាស់ក៏ដែលនៅលើខ្យល់ឃើញ?

រឿងដែលសត្វដឹងនេះ មានក្នុងពង្សាវតារក្រុងកេម ជាកាលក្នុងសម័យបុរាណគប់អានពពែថាជាសត្វប្រសើរ ព្រោះមានសម័យមួយក្នុងវេលាយប់សត្រូវរបស់ពួកកេមរ៉ង់ លើកទ័ពជិតមកក្រុងកេម ដោយអ្នកស្រុកក្នុងក្រុងកេមមិនបានដឹង អ្នកចាំយាមនៅលើប៉មបន្ទាយក៏មើលមិនឃើញ តែក្នុងវេលានោះមានពពែមួយហ្វូង ក៏ស្រែកកញ្ជ្រោលឡើងខុសពីប្រក្រតី មនុស្សនៅក្នុងបន្ទាយចាំងប៉ុន្មាន ក៏បានដឹងភ្ញាក់ឡើង រៀបខ្លួនចាំតទល់រក្សាក្រុងកេម ឲ្យរួចពីសត្រូវបានៗ ជាពួកកេមរ៉ង់ឆ្ងល់ណាស់ថា ក្នុងវេលាដែលពពែស្រែកឡើងនោះ សត្រូវនៅឆ្ងាយណាស់ តែបន្ទឹកជើងដើរក៏មិនឮផង ហើយនៅក្រោមខ្យល់មិនអាចនឹងស្រង់ក្លិនបានទេ ហេតុអ្វីបានជាពពែមានអាការដើរខុសពីប្រក្រតីយ៉ាងនេះ បានជាពួកកេមរ៉ង់នាំគ្នាជឿថា សត្វពពែជាសត្វដែលព្រះម្ចាស់សួគ៌ឲ្យមកកើត សម្រាប់ជួយការពារក្រុងកេម សេចក្ដីនេះតើយើងគួរវិនិច្ឆ័យយ៉ាងណា? សេចក្ដីដឹងបែបនេះ ដែលខ្ពស់ជាងសត្វឯទៀត គឺបក្សាត្រៃ (ពង) ក្នុង



www.elibraryofcambodia.org

ស្រុកអាហ្វ្រិកបានដំណឹងថា ពួកនេះដឹងខ្លួនហើយជាប់ជុក ក្នុងវេលាដែល មានខ្មាឬសិទ្ធ កំពុងដើរមកក្នុងទីដែលខ្លួននៅ ចាក់ដែលនៅបញ្ចាញ់ សត្វក្នុងស្រុកអាហ្វ្រិក គោងតែមានមនុស្សបែបនេះនៅជាមួយដែរ តើ បកពីហេតុអ្វីបានជាមនុស្សទាំងនោះដឹង កាបហេតុដែលបណ្តាលឲ្យដឹង បុគ្គលនេះ យើងនឹកល់គ្នាគង់ដែលបានពួកពួកខ្លួនក្រុងនិយាយអ្វីផ្សេង ៗ ប្អូកពី ប្រក្រតី ដែលយើងហៅថា វិចារ ក្រាប់ហេតុដោយក្រុងនោះទើបបានដឹង ព្រោះយើញបកពុំងកាកគឺទេ ដូចកាលពីព្រៃកាបសំដីដែលពនិយាយនោះ តែ គ្មានអ្នកណាចាប់ក្តី យកចិត្តទុកដាក់ជាមិនមានហេតុនោះគឺទេ មនុស្ស ចាស់គឺមានជាដកបដែរ ដែលជាចៃដន្យក្នុងចិត្ត ដូចមានគេមកខ្សឹបប្រាប់ ដូនកាលពីព្រៃតាបដែលខ្លួនពួកខ្សឹបនោះ តែហើនចៃដន្យប្រផលទាំងនេះ ច្រើនតែមិនយកចិត្តទុកដាក់ទៀ ស្រាវជ្រាវរកហេតុ យកមកពិចារណា: ពិចារណាគេឲ្យឃើញសេចក្តីពិត ច្រើនទុកឲ្យកន្លងហួសទៅ សម្អក សម័យជំនឿនេះក៏ការនៃគណៈសំនៀងទៀត សុទ្ធតែជាមិនគួរនៅប្រកាន់ ជឿតាមចៃដន្យ ឬប្រផលដែលជាការគួរព្រលនោះទេ តែកាលណា មានហេតុពិតត្រូវតាមនិមិត្តនោះហើយ ទើបទឹកឃើញដល់បុព្វហេតុ និមិត្តដែលបណ្តាលឲ្យដឹងមុនកើតហេតុនោះ ដូចជាហេតុដែលមនុស្សត្រូវ គេសម្លាប់ប្រុសក្រុមខ្លួនឯងក្នុងផ្ទះណាមួយ មនុស្សដែលនៅក្នុងផ្ទះនោះ



www.elibraryofcambodia.org

សឹងគ្រប់គ្នានិយាយថា មុនកើតហេតុ បានឃើញបុព្វនិមិត្តប្លែកៗ យ៉ាងនេះយ៉ាងនោះ ខ្លះក៏ថាបានយល់សប្តិឃើញយ៉ាងនេះយ៉ាងនោះ ។ល។ តាមដែលមនុស្សទាំងនោះនិយាយ គង់មានមនុស្សខ្លះបានឃើញ បានឮអ្វីម្យ៉ាងៗ ឲ្យជាបុព្វហេតុ មុននឹងកើតហេតុជាប្រាកដតែមិនយកចិត្តទុកដាក់ពេលឲ្យគន្លងហួសទៅ មិនប្រកាន់ជឿថាជាការសំខាន់ ដល់មានហេតុឡើង ទើបភ្ញាក់ឃើញ ។

បើយើងយកហេតុ ដែលបានពោលមកខាងលើនេះ មកត្រិះរិះគិតមើលឲ្យល្អិតហើយ ក៏ចង់សន្និដ្ឋានបានពីរយ៉ាងគឺ:

១. យើងមានកាយគតមួយប្រភេទដែលហៅថាប្រព័ន្ធពុំបឹង ធ្វើឲ្យចិ-ញ្ចយការឲ្យចិត្ត ទៅនឹងការដែលភ្លូក, ត្រជៀក, ប្រែះ, ផ្អាក, កាយនឹងកយការឲ្យចិត្តពុំបាននោះ ។

២. កាយគតខាងក្នុងទាំង៥របស់យើង មានត្រាខ្លះកាចកយការឲ្យលើសជាងប្រក្រតី ។

លោកអ្នកមើលគង់គិតថា សេចក្តីទាំង២ផ្លូវនេះបើជាពិតដោយផ្លូវណាមួយ ហេតុដូចម្តេចវែងដន់ទាំងនោះ មិនបណ្តាលឲ្យឃើញត្រូវប្រាកដជាដកបទៅ តបថា បានជាមានខុសជាច្រើន ព្រោះរបស់ដែលធ្វើឲ្យយើងមានវែងដន់ប្រាប់បុព្វហេតុឲ្យយើងដឹងនោះ នៅឆ្ងាយហួស ដូចជាការដែលនិយាយដោយពោសេពួ មេឃស្រុកឬប្រទេសឆ្ងាយ

តែនៅតែកើតធ្វើឲ្យចូលបក្ខុសត្វជារឿយៗ មិនដាច់ពេលដល់ថ្ងៃដន់ ដែលគ្មានអ្វីជាទីកំណត់នោះទេ គ្រាន់តែយើងឮអ្វីៗ នៅជិតត្រចៀកយើង ក៏នៅមានខុសជាដកបដែរ ។

ឯទស្សនិកជន តាមផ្លូវទាំងពីរនេះ ទំនងវិនិច្ឆ័យថា ផ្លូវណាជាត្រូវ ក៏មិនទាន់បាន (ព្រោះពួកយោគីក្នុងឥណ្ឌា) ច្រើនជឿតាមផ្លូវទី ១ ដោយថ្លឹងសេចក្តីយល់ឃើញថា មនុស្សមានកាយតទៅច្រើនជាង ៦ ហើយ នៅមានជំនឿតទៅទៀតថា បើក្នុងលោកដទៃ ១ ដូចជាលោកព្រះអង្គារ ជាដើម មានមនុស្សនៅហើយ មនុស្សទាំងនោះអាចមានកាយតទៈទាំង ៨-៩ ឬ ១០ ក៏បាន ដោយជំនឿនេះបានជាលទ្ធិរបស់យោគី វិលទៅ រកផ្លូវដែលនឹងបណ្តុះកាយតទៈមួយជាថ្មី ឲ្យកើតមានឡើងក្នុងខ្លួនដូចជា បណ្តុះដៃឲ្យជាប់នឹងផ្កាយ (bras astral) ទំនងប្រើកាយឲ្យជាប់គនឹងផ្កាយ (corps astral) ដែលបានពោលមកហើយក្នុងមោមយុទ្ធទីនឹងវិធី តាមឧទាហរណ៍ដែលបានពោលមកហើយនោះគេឲ្យឈ្មោះថា សេចក្តីដឹងខ្លួន ដែលជាប់គនឹងដួងផ្កាយ (perception astrale) ដែលឲ្យឈ្មោះថា "ជាប់គនឹងដួងផ្កាយ" នេះ ក៏ព្រោះមិនទាន់ដឹងជានឹងឲ្យហៅជាឈ្មោះអ្វីនោះឯង ត្រង់វិធីដែលគេនឹងបណ្តុះឲ្យកើតឡើងបានយ៉ាងណានោះ គេអធិប្បាយទុកយ៉ាងពិស្តារ បើនឹងប្រែយកមកចុះក្នុងសៀវភៅនេះផង ឃើញថាគ្មានទីកាលនឹងបញ្ចប់បាន បានជាមិនយកមកចុះស្រាយ ។

តាមមើលទៅបាក់ង ប្រហែលជាកទៅតង់ស្ទើរតែ គឺជាយើងគ្មានអាយតនអ្វីថែមទៀតទេ មានតែអាយតនមានក្នុង ៥ គឺភ្នែក, ត្រចៀក, ច្រមុះ អណ្តាតនឹងកាយ របស់យើងនេះ បើហាត់ឲ្យល្អហើយក៏អាចទទួលអាយតនខាងក្រៅទាំង ៥ គឺ: រូប សំឡេង, ក្លិន, រសនឹងផោដ្ឋព្វ ឆ្ងាយលើសពីប្រក្រតីបាន ដោយជំនឿនេះហើយ បានជាបាក់ងចាំគ្រាតែងសៀវភៅជាច្រើន និយាយពីវិធីហាត់ធ្វើឲ្យភ្នែកវៃ, ត្រចៀកវៃ, ច្រមុះចាំក្លិនបាន ។ ល ។

ជំនឿទាំងពីរយ៉ាងនេះ យ៉ាងទី ១ ដែលជាសេចក្តីជឿរបស់ពួកយោគីថា មនុស្សយើងអាចមានអាយតនច្រើនជាង ៦ នោះ គឺមិនទាន់ឃើញមានពាក្យអធិប្បាយ ឲ្យបានក្បោះក្បាយ គួរឲ្យជឿប្រាកដនោះសោះ នៅតែក្នុងពិគ្រោះពិចារណាតទៅទៀត អំពីស្ទើរតែ ដែលជាជំនឿរបស់បាក់ងនោះល្មមស្តាប់បាន ព្រោះថាអវយវៈគ្រប់យ៉ាងរបស់យើងនោះ បើហាត់ហើយក៏អាចប្រើការបានយ៉ាងល្អផកប ឯត្រចៀកនេះ ក៏ដោយត្រូវការទំលាប់ឲ្យធ្លាប់ បើមិនដូច្នោះទេ យើងនឹងញែកខ្សែសំឡេងពេញពុំបាន អ្នកដែលមិនចេះភាសាក្លឹងគិតថាភាសាក្លឹងនិយាយមានសំឡេងឡល់ "រ" ទាំងអស់ តែបើបានស្តាប់ទាល់តែធ្លាប់ត្រចៀកទៅហើយ ក៏នឹងញែកអក្សរតាមសំឡេងចេញបាន បើយើងឲ្យបាក់ងដែលទើបមកពី


www.elibraryofcambodia.org

ស្រុកចុះរួមមកស្តាប់ទេសនាមហាជាតក៍  គេមិនថាឮតែសំឡេងមួយតាំង ពេញគ្នាសំឡេងខ្ពស់ទាប តែពួកឃើញធ្លាប់ស្តាប់នោះមិនថាមានសំឡេង ខ្ពស់ទាប ពិរោះមិនពិរោះ អ្នកដែលធ្លាប់ស្តាប់ញឹកញយ ក៏កាន់តែចេះ មើលឃើញសំឡេងស្រួលសំឡេងមិនស្រួល ទាល់តែគេថាមានពាក្យសរសើរ បណ្តុះថាទេសនេសពិរោះឬមិនពិរោះណា៎ ឯការស្តាប់ភ្លេងពាក់ព័ន្ធដូចគ្នា ភ្លេង យ៉ាងឯកទៅអ្នកប៉េក៉ន្ត្រ ក្រុងពាក់ព័ន្ធសែស  បើឃើញទៅដល់ជម្រើសហើយ ពួលទៅស្តាប់ គង់ព្រភ្លេងនោះដូចគ្នោះគោះអ្នកលេងជាតែល្បែង  តែបើបាន ស្តាប់ញយ ៗ ទាល់តែចាប់តាំងពីភ្លេងជាច់ចាប់ដែលលេងតាមកេងណ្ហូនតូច ៗ ទៅរួចទៅស្តាប់ភ្លេងគង់អ្នកប៉ាក់  ទើបដឹងថាភ្លេងដែលគេលេងនោះពិរោះ យ៉ាងប្រសើរពិតប្រាកដមែន  មិនមែនដូចឃើញឮថាដូចគ្នាភ្លេងគោះជា ល្បែងនោះទេ ហេតុនេះបានជាអ្នកស្រុកបែលស្រុកដែលជាអ្នកមាន ស៊ូជ៊ះ រេចះភ្លេងពីក្រុងប្រិកសែល  តាំងចិត្តក្រង់មកស្តាប់ភ្លេងអ្នកប៉ាក់នៅក្រុង បារីស ដល់ពាក់កណ្តាលអធ្រាត្រទើបត្រឡប់ទៅស្រុកវិញ ។

ចំណែកអ្នកប្រាជ្ញខាងក្បួនគន្ថ  គេយល់ចូលចិត្តជ្រៅជ្រះជាងអ្នក ស្តាប់ គង់ប៉េកកំពុងលេងភ្លេង គេគ្រាន់តែស្តាប់ពីចម្ងាយ មិនឃើញ រូបអ្នកលេងភ្លេងផង  គេតែចជាយប្រាប់ថាគង់ភ្លេងនេះនោះ  មានចំ-នួនបុរសអ្នកលេងប៉ុន្មាននាក់ មានគ្រឿងបែបណា ខ្លះគេដឹងទាំងអស់

ក្រកូនដែលគេស្គាល់ គេអាចបន្តុលមនុស្សអ្នកលេងដែលកូកបុផ្តុំរួសតែ បន្តិចបន្តួច ក្នុងពេលកំពុងតែលេងនោះបានមួយរំពេច ។

ការដែលនាំយករឿងក្បួនក្លែ បកពោលក្នុងឥតបំភេរ ត្រង់តែជាឧទាហរណ៍ ឲ្យឃើញពិតថា ត្រចៀកមនុស្ស បើព្យាយាមហាត់ហ្វឹកហ្វឺនឲ្យល្អហើយ ក៏គង់ស្គាល់បានខ្លះ ព្រោះរូបកាយរបស់មនុស្ស ដែលធម្មជាតិកសាងមកនោះ ជារបស់អស្ចារ្យលើសលុប ជាងរបស់ដែលមនុស្សបង្កើតនោះទៀត ពោលគឺមានវិទ្យុក្តី ឥតវិទ្យុក្តី ដែលឃើញចូលចិត្តថាជារបស់ប្រសើរ ប្រើនិយាយជជែងសំដីគ្នាបាន ដោយរហ័សឆាប់មិនខ្ចូចពេលវេលាឆ្ងាយនោះ ព្រោះជាយកបែបតាមអាយតនៈក្នុងកាយរបស់មនុស្ស មកគិតប្រឌិតសាងគ្រឿងពោលសព្ទនេះឡើង យើងគង់ដឹងថា សំឡេងផ្សេងៗ អណ្តែតតាមអាកាសមកប៉ះនឹងគ្រឿងទទួលដែលនៅក្នុងត្រចៀកយើង បានជាដឹងសេចក្តី បានជាគេយកបែបនេះមកគិតធ្វើជាគ្រឿងពោលសព្ទ ត្រង់តែបន្ថែមឲ្យមានកំលាំងខ្លាំងឡើង វិទ្យុពោល-សព្ទដែលបញ្ជូនសំឡេង ទៅឆ្ងាយមួងខ្ទីបបាន ក៏ព្រោះមានកំលាំងខ្លាំងជាបំផុត បើប្រសិនជាយើងមានវិធីហាត់ ឲ្យត្រចៀកយើងមានកំលាំងខ្លាំងតើយើងនឹងស្តាប់សំឡេង ពីចម្ងាយមិនបានដែរឬអ្វី មនុស្សក្នុងខ្ញាក់ហេតុអ្វីបានជាត្រចៀកវៃខុសពីប្រក្រតី ព្រោះហេតុមកពីដឹងខ្លួនថាត្រូវតែ


www.elibraryofcambodia.org

ប្រើត្រចៀកជំនួសភ្នែក ព្រោះជាញាណបញ្ជាក់ឲ្យត្រចៀកបានឮសំឡេង របស់អ្វីក៏ដោយ សុទ្ធតែមកពីពាក្យដែលបញ្ជាក់ឲ្យស្គាល់ទាំងអស់ ។

តាមគម្ពីរព្រះពុទ្ធសាសនាព្រាហ្មណ៍នោះ ក៏ឲ្យបង្ហាត់ត្រចៀកឲ្យឮសំឡេងវែង តែត្រូវធ្វើចិត្តឲ្យស្ងប់ផង ដែលធ្វើជាមុនសិន តាមគន្ថគម្ពីរវិសុទ្ធិមគ្គថា ត្រូវចូលឈានជាមុន ព្រោះពលជាសំរេចដល់គ្រប់ ៗ ឈាន ព្រោះមិនឃើញច្បាប់ឲ្យចូលស់ជាឈានណា កាលណាចេញពីឈាន ហើយកុំដាក់ផ្សំ ឲ្យនឹកដល់សំឡេងខ្លាំង ៗ ជាមុន ដូចជាសំឡេងផ្គរ ស្គរម្ហោរី រួចហើយក៏នឹកដល់សំឡេងដែលល្អិតទៅ ទាល់ដល់ទីបំផុតឲ្យនឹកដល់ចិត្តសោត ៗ ក៏នឹងកើតឡើង បើត្រូវការចង់ស្ដាប់សំ-ឡេងអ្វី ៗ ក៏ឲ្យកំណត់ក្នុងចិត្ត ពេលនឹកដល់ទិសខ្លួនដែលត្រូវការនឹងស្ដាប់នោះ ទុកជាមានសូរអ្វីទេហឹងអឺកេប ក៏គង់នៅឮសំឡេងដែលត្រូវការជាដរាបបាន ។

## វិជ្ជាប្រការទី ៥

### ចេតោបរិយញ្ញាណ

ចេតោបរិយញ្ញាណនោះ មានវិសេសពោលទុក ក្នុងធម្មវិភាគ បរិច្ឆេទទី ២ ថា កំណត់ដោយចិត្តរបស់ខ្លួនឯងរួចហើយ ដឹងចិត្តរបស់បុគ្គលដទៃជាបរិសុទ្ធឬសៅហ្មងយ៉ាងណា សម្ដេចព្រះមហាសមណក្រុមវជិ-

ញ្ញាណវិសេស ទ្រង់ប្រៀបប្រដូចការទាយចិត្តដែលកំណត់សំគាល់នូវ អធ្យាស្រ័យរបស់មនុស្ស ។

តាមគម្ពីរទិព្វសត្ត ក្នុងអត្ថាធិប្បាយរបស់សម្តេចព្រះមហាសមណភក្តិ ចេតោបរិយញ្ញាណ មើលទៅមិនជារបស់ហួសវិស័យមនុស្សទេ ពួកយើងធម្មតាច្រើនគង់មើលឃើញថាជារបស់ងាយ ព្រោះដោយការស្រ័យបនិកា-ណរបស់ខ្លួន សង្កេតមុខមាត់នឹងពាក្យនិយាយរបស់មនុស្ស ក៏អាចស្គាល់នូវចិត្តមិនបានច្រើនក៏តិច ឬដោយយើងដឹងនិស្ស័យចិត្តជុំមនឹងសេចក្តីប្រព្រឹត្តិរបស់បុគ្គលនោះពីអតីតមកយ៉ាងណាក៏អាចទាយតាយបានថា បុគ្គលនោះ ក្នុងកាលឥឡូវនេះកំពុងគិតអ្វី ឬនឹងដឹងថាកំពុងគិតអ្វីទៅមុខទៀត ក៏ទាយត្រូវទាំងអស់ ។

តាមគម្ពីរចិត្តវិទ្យារបស់បារាំងក្តី លទ្ធិរបស់យោគីឥណ្ឌាក្តី ចេតោបរិយញ្ញាណ ដែលត្រូវនឹងពាក្យថា (Lecture de la pensée) ក្តី ក៏គេប្រកាន់ថាជារបស់ងាយដូចគ្នាដែរ ហើយជាដើមនៃវិជ្ជាដ៏ជ្រាលជ្រៅ (Sciences occultes) ទាំងឡាយជាវិជ្ជាខាងដើមរបស់ទិព្វចក្ខុ បើតាមតាមគោលរបស់គេហើយ មនុស្សយើងនឹងធ្វើទិព្វចក្ខុឲ្យកើតឡើងបាន លុះតែធ្វើចេតោបរិយញ្ញាណឲ្យកើតឡើងជាមុនសិន ។

www.elibraryofcambodia.org

ឯវិជ្ជាមួយទៀត គួរ ក្រាផ្ទាក់និងចិត្តទៅ គេចែកជាពីរប្រការគឺ ប្រភេទទី ១ គេចេះដឹងគំនិតរបស់អ្នកដទៃ (Lecture de la pensée) ប្រភេទទី ២ គេចេះផ្ញើអ្នកដទៃដឹងគំនិតរបស់ខ្លួន (Transmission de la pensée) ប្រភេទទី ១ ត្រូវពឹងទៅតាមបរិញ្ញាណរបស់យើង ត្រង់ប្រភេទទី ២. មិនមែនជាត្រូវពឹងអ្វី ក្នុងព្រះពុទ្ធសាសនា មើលទៅប្រហែលជាគ្មានទៅក្នុងវិជ្ជា ៨ ប្រការនោះទេ តែទុកជាដូចម្ដេច ក៏មិនជាការផុតប្រយោជន៍ទេ ព្រោះជាជាងយកទាំងពីរនេះមកពណ៌នាទុកដើម្បីបង្ហាញបុគ្គលដែលរៀនតាម-វិញ្ញាណពេលឲ្យបានល្អទៀង ។

សេចក្ដីនេះបានបរិយាយមក គឺ "មនោបវេជ្ជ" ជាចិត្តឬគំនិតរបស់មនុស្ស តែងតែមានក្រសែផ្សាយចេញពីខ្លួន ហើយក្ដៅត្រសែតទៅតាមអាកាសធាតុ មានខ្លះក៏ជាប់នៅក្នុងទីផ្សេងៗ ហេតុនេះឯងបានជាបើប្រសិនជាមានចិត្តមួយទៀតជាគ្រឿងទទួលក្រសែនោះ ក៏អាចនឹងដឹងនូវគំនិតរបស់គ្នាទៅវិញទៅមកបាន ដូចជាវិទ្យុតេលេសព្ទ សឹងមានគ្រឿងសំរាប់បញ្ជូនសំឡេង តែសំឡេងដែលចេញទៅតាមអាកាសនោះគ្មានអ្នកណាឮទេ លុះតែកាលណាសំឡេងនោះមកប៉ះពាល់គ្រឿងដែលទទួលគ្នា ទើបឮសូរសំឡេងមួយរំពេច តេលេសព្ទដែលមានខ្សែក៏ដូចគ្នាដែរ តាមដែលយើងគិតថា សំឡេងរត់ទៅមកតាមខ្សែលួស តែបើយើងយកខ្សែលួសមកដាក់ភ្ជាប់ត្រចៀកយើងៗ ក៏មិនបានឮអ្វីសោះឡើយ



www.elibraryofcambodia.org

ព្រោះសំឡេងដែលកើតមកពីខ្យល់ស្រូសនោះ ក្នុងគ្រឿងទទួលបានជាប់ៗ កាលណាមានគ្រឿងភ្ជាប់នឹងខ្យល់សក់ចូល សំឡេងក៏កើតមកប៉ះ គ្រឿងនោះបានចេញឮសូរសំឡេងឡើង ហេតុនេះឯង បានជាអ្នកប្រាជ្ញ ចាក់ននទឹងសណ្ឋា ចែកវិជ្ជានេះជា ២ ប្រភេទ គឺអាចធ្វើឲ្យមនុស្សឯទៀត ដឹងគំនិតរបស់ខ្លួនដែលជាគ្រឿងបញ្ចេញ នឹងចេះគោរពវិញ្ញាណជាគ្រឿង ទទួល ហេតុដែលបានជានាំយកវិធីបង្ហាត់ចេះគោរពវិញ្ញាណរបស់ចាក់ង ទឹងរបស់លោកគី មកបរិយាយទុកនេះ ដើម្បីជាគ្រឿងប្រាប់សតិបញ្ញា ឲ្យអ្នករៀនធម៌របស់យើង ប្រៀបធៀបមើលនឹងវិធីដែលមាននៅក្នុងកប្រ ព្រះពុទ្ធសាសនា ។

ឯវិធីបង្ហាត់វិជ្ជាប្រភេទនេះ តាមក្នុងសៀវភៅរបស់លោក អធិប្បាយ ថា ក្នុងជាន់ដំបូង ត្រូវមានគ្នាពីរនាក់ គឺរកអ្នកដែលមានចិត្តជឿក្នុង វិជ្ជានេះ ហើយឲ្យអ្នកនោះមានចិត្តប្រាថ្នា ចង់ចេះវិជ្ជានេះ ពិតប្រាកដ បើកបានហើយ ឲ្យម្នាក់ជាអ្នកហាត់បញ្ចេញ ម្នាក់ជាអ្នកហាត់ទទួល ផ្លាស់ ប្តូរគ្នា អ្នកហាត់ទទួលត្រូវយកសំពត់ចងបិទភ្នែក ឲ្យមាននៅដៃមួយទង់ ក្រដាសសំកប់កត់ ឯអ្នកបញ្ចេញត្រូវយកដៃខ្ទប់ជាសអ្នកទទួល ឲ្យមាននៅ ដៃនឹងក្រដាសសំកប់កត់ដូចគ្នា ស្រេចហើយត្រូវសញ្ញាយល់ព្រមគ្នាថា វិធីដែលត្រូវធ្វើ គឺចាប់ធ្វើពីលេខណាមួយក្នុងរវាងពីមួយដល់៥ អ្នកបញ្ចេញ



www.elibraryofcambodia.org

ត្រូវការឲ្យអ្នកទទួលសរសេរលេខណា ត្រូវតាំងចិត្តជាសមាធិដំកល់ឲ្យមាំ នឹកដល់លេខដែលខ្លួនទើបនឹងឲ្យទទួលសរសេរនោះ ខាងចំណែកអ្នកទទួលក៏ត្រូវដំកល់ចិត្តជាសមាធិឲ្យមាំដូចគ្នា នឹកតែក្នុងរវាងលេខ ១ ដល់លេខ ៥ រួចសរសេរតែ ១ លេខក្នុងក្រដាសរបស់ខ្លួន តាមតែចិត្តដែលគិតឃើញថាអ្នកបញ្ជូនត្រូវការលេខណា ក្នុងថ្ងៃដំបូងគេឲ្យធ្វើបាន ២០ ដង គឺសរសេរលេខឲ្យបាន ២០ ដង រួចស្រាយសំពត់ពីភ្នែកអ្នកទទួលចេញ យកក្រដាសទាំងពីរសន្លឹកមកផ្ទៀងគ្នាមើល ឃើញមានខុសប៉ុន្មាន ត្រូវប៉ុន្មានកត់ទុក ដល់ថ្ងៃក្រោយទៀតធ្វើដូច្នោះទៀត គេឲ្យធ្វើតែរាល់ថ្ងៃរាល់តែលេខទាំង ៥ នូវត្រូវគ្នាទាំងអស់ឬក៏ទៅមានខុសខ្លះតែយ៉ាងតិចបំផុត តាមក្រមាពោលថា បើអ្នកទាំង ២ មានសមាធិមាំស្មើគ្នាហើយ លេខដែលកត់នោះក៏កាន់តែខុសតិចៗទៅជារាល់ថ្ងៃ ទាល់តែត្រូវគ្រប់លេខ រួចបានបន្ថែមចំនួនលេខឲ្យច្រើនឡើងពី ១ ដល់ ១០ រហូតដល់ពាន់ នេះបាត់ជាថ្នាក់ទី ១ គ្រប់តែក្នុងថ្នាក់ទី ១ នេះ គេចអស់វេលាហាក់បីខែ ក្នុងថ្នាក់ទី ២ វិធីហាត់ពេលចំនួនដូចគ្នាដែរ តែឲ្យប្រើអក្សរជំនួសលេខ ដាក់ដំបូងឲ្យព្រមព្រៀងគ្នា ធ្វើពីអក្សរតិច រួចបន្ថែមទៅជាដកបទាល់តែអស់ស្រៈនិងព្យញ្ជនៈ រួចបានផ្សំគ្នាជាពាក្យឡើង បើធ្វើបានទាំងពីរថ្នាក់នេះហើយឲ្យចោលការដែលយកដៃខ្ទប់ក្រដាសចេញ គ្រាន់តែយកដៃរុងទាប់ត្រាទុក រួចធ្វើដូចយ៉ាង



www.elibraryofcambodia.org

ពេលមកនោះ នេះជាថ្នាក់ទី ៣ ដល់ថ្នាក់ទី ៤ មិនបាច់ពាល់ដល់វេយ្យាករណ៍ ក៏កាយឡើយ ត្រាន់តែឲ្យជាប់គន្លងវត្ថុអ្វីមួយ ដូចជាសំពត់ឬវេយ្យាករណ៍ វិធីធ្វើតាមបែបក្នុងថ្នាក់ទី ១ និងទី ២ ។

តាមបែបដែលបានពណ៌នាមកហើយនេះ ជាវិធីធ្វើតាមបែបគោល-សព្ទឬគោលលេខដែលមានខ្សែ បើមានសេចក្ដីព្យាយាមហាត់ហ្វឹកហ្វឺនជាថ្នាក់ៗ បានល្អឡើងជាដរាបតទៅហើយ តពីនេះទៅទៀត ត្រូវហាត់តាមបែបគោលសព្ទគ្មានខ្សែ គឺមិនឲ្យរាងកាយប៉ះពាល់គ្នាដោយវត្ថុអ្វីឡើយ ដូចមានពេលតទៅនេះ គឺថ្នាក់ទី ៥ ឲ្យនៅក្នុងបន្ទប់ជាមួយគ្នា មិនបាច់ចងភ្នែក អង្គុយឃ្លាតពីគ្នា ឲ្យអ្នកបញ្ជូនគិតក្នុងចិត្តត្រង់ពាក្យណាមួយឲ្យអ្នកទទួលសរសេរ ។ បើឃើញថាសរសេរត្រូវតាមសេចក្ដីគិតរបស់អ្នកបញ្ជូនត្រឹមត្រូវច្រើនជាប់ផុតហើយ ក៏ឲ្យចេញពីទីកន្លែង ឲ្យឃ្លាតបន្តិចៗ ប្ដូររួចទៅអង្គុយនៅបន្ទប់មួយដោយឡែកពីគ្នា ធ្វើបានហើយត្រូវទៅអង្គុយផ្ទះដោយឡែក បេះតែឃ្លាតចេញពីគ្នាឲ្យបានឆ្ងាយជាដរាបទៅ ។

វិធីផ្សេងៗដែលពណ៌នាមកនេះ នឹងឲ្យបានសម្រេចត្រឹមណានោះ ពុំបានដឹងទេ ព្រោះមិនដែលបានហាត់ធ្វើ តែបានប្រទះគម្រោងជាច្រើន ហេតុ អធិប្បាយដូចៗគ្នាថា មនុស្សយើងអាចធ្វើឲ្យសម្រេចបានលើសពីសេចក្ដីដែលយើងស្មាននោះទៀត តែគេត្រូវមានសេចក្ដីព្យាយាមហាត់ធ្វើរឿងរាប


www.elibraryofcambodia.org

ការផ្ចង់ការផ្ចាន់ កុំរម្ងង់ពេលផ្ចង់ទី១ ទៅធ្វើផ្ចង់ទី២ តែម្ដងនោះពុំបាន ទេ ហើយត្រូវហាត់ធ្វើកិច្ចផ្ចង់មួយៗឲ្យបានល្អសិន គន្លឹះវិធីធ្វើនេះដែល សំខាន់បំផុត គឺសមាធិ (Concentration) បើផ្គង់ចិត្តមិនដល់នឹងជាសមាធិ ទេ នឹងធ្វើឲ្យសម្រេចពុំបានឡើយ ។

វិធីនេះបើយើងចូលចិត្តជឿតាម ដែលមានពណ៌នាមកនោះហើយ ៗ បានបង្ហាត់ហ្វឹកហ្វឺន តាមសេចក្ដីអធិប្បាយរបស់គេ ក៏នឹងឲ្យយើងបាន សម្រេចគ្រប់បែបដែលយើងត្រូវការ ហើយក៏អាចទាយចិត្តមនុស្សដទៃ បាន ឬធ្វើឲ្យមនុស្សដទៃជឿគំនិតរបស់យើងបាន អ្នកតែងសៀវភៅពី វិជ្ជានេះពោលថា បើអ្នកដែលហាត់ធ្វើមិនសម្រេចមានចិត្តធុញថប់ថយ សេចក្ដីព្យាយាមគិតបោះបង់ពេលលែងធ្វើតទៅទៀត ក៏ស្រាប់តែសម្រេច ឡើងៗ ពេលក៏មាន គេប្រកាន់ថា កាលមនុស្សខំធ្វើបានសម្រេចអាចឲ្យ អំណាចជាប់គំនិតមនុស្សទៅញៀនប្រែសត្វក៏បាន បើពិតប្រាកដដូច្នោះ មែនហើយ គួរតែប្រយោជន៍ក្រៃលែងណាស់ ព្រោះសំរាប់ប្រើក្នុងវេលា មានការក្រីក្រ ឬពេលទោរទាប់មកខ្លួនទៅណាក៏ដោយក៏អាចឲ្យជំនឿនៅគ្នា បាន កាលធ្លាក់ក្លួងមកហើយ មានសាស្ត្រាចារ្យស្រុកអូទ្រីសម្នាក់ ចូល មកសំដែងវិជ្ជានេះ នៅក្រុងសាញ្ញូន នៅទីកន្លែងក្រុមតម្រួត (ប៉ូលិស) ដើម្បីឲ្យឃើញថា វិជ្ជានេះមានប្រយោជន៍ត្រឹមណា ក្នុងការស៊ើបអង្កេត ចោរកំណាចនោះ ។

វិធីដែលពណ៌នាមកនេះ ជាវិជ្ជាជាន់បឋមដម្បូង សឹងមើលទៅអ្នកណាក៏អាចហាត់ធ្វើបាន តែតាមបំណងរបស់ចេតោបរិយញ្ញាណក្នុងវិជ្ជា ៨ ឬការដឹងពិតប្រាកដនោះ ជាវិជ្ជាខ្ពស់ជាងនេះទៅទៀត ពោលគឺដួងចិត្តរបស់អ្នកមានញាណបែបនេះ ប្រៀបដូចគ្រឿងទទួលវិទ្យុមានកំលាំងច្រើន អាចទទួលខ្សែគំនិតរបស់មនុស្សណាមួយមកឲ្យដឹងបានទាំងអស់ ទុកជាមនុស្សនោះព្យាយាមលាក់គំនិតរបស់ខ្លួនទុកដូចម្ដេចក្ដី ក៏យើងអាចដឹងឮគំនិតនោះដែរ ដូចជាគ្រឿងវិទ្យុដែលគេកែតំឡើងខ្លាំង អាចស្ដាប់ឮដំណឹងផ្សេង ៗ ដែលបញ្ជូនមកតាមវិទ្យុប្រទេសនានា ដោយមិនចំពោះជាដំណឹងនោះ គេជូនទៅដល់តែគ្រឿងរបស់គេមួយទេ ឬយើងបានដឹងឮកាលក្នុងគ្រាមហាសង្គ្រាមលោកលើកហើយនោះ ជាកងទ័ពហ្វាំងកោប្រៀង ពោរសត្រូវ លួចស្ដាប់ទទួលដំណឹងរបស់ពួកម្ខាងទៀតបានជាដរាប បើយើងឃើញថា ការធ្វើចិត្តរបស់យើងឲ្យបានជាគ្រឿងសំរាប់ទទួលខ្សែគំនិតរបស់មនុស្សបានហើយ ៗ ការនេះត្រឹមតែមនុស្សសាមញ្ញជនក៏អាចហាត់ធ្វើបានដែរ ចុះហេតុអ្វីក៏ព្រះពុទ្ធជាម្ចាស់របស់យើងធ្វើមិនបាន តាមក្នុងពុទ្ធប្រវត្តិ ឬអនុពុទ្ធប្រវត្តិ ដែលយើងបានរៀនមកហើយនោះ ទើងឃើញថាព្រះពុទ្ធជាម្ចាស់របស់យើង ព្រះអង្គប្រើចេតោបរិយញ្ញាណជាដម្បូង ក្នុងកាលដែលទ្រង់ទូន្មានសាវកឲ្យបានលុះមគ្គផល បានជាថា



www.elibraryofcambodia.org

ការដែលនឹងប្រៀបធៀបមនុស្ស ដោយមិនដឹងគំនិតរបស់គេនោះជាការ ពិបាកនឹងប្រៀបធៀបណាស់ ។

តាមក្នុងគម្ពីរវិសុទ្ធិមគ្គ ត្រង់ដែលនិយាយអំពីចេតោបរិយញ្ញាណ ដែលព្រះពុទ្ធឃោសាចារ្យបានសំដែងទុកនោះ ឃើញផ្សេងពីរបស់លោកគី ឆ័ង់របស់អ្នកប្រាជ្ញអឺរ៉ុប ដែលបានពោលមកខាងដើមនោះជាច្រើន គឺព្រះពុទ្ធឃោសាចារ្យ ត្រូវការឲ្យចេះដឹងស្គាល់ដួងចិត្តមនុស្សដទៃតែត្រឹម សេចក្ដីទោមនស្សឬសោមនស្ស ឬដង់ល្អអាក្រក់ជាដើម មិនត្រូវការឲ្យ ដឹងស្គាល់ដល់ចិត្តមនុស្សនោះទេ ហើយលោកបានពោលជាគោលទុកថា ត្រូវតែប្រើចិត្តតែជាមុនសិន មុននឹងបានប្រើចេតោបរិយញ្ញាណ នេះ ព្រោះត្រូវតែស្រ័យក្នុងចិត្តឲ្យមើលធ្លុះឃើញពណ៌បេះដូងរបស់ មនុស្សកើតកពណ៌យ៉ាងណា ពេលគឺថាបើចិត្តសោមនស្ស បេះដូង ក្រហមប្រឿកប្រឿងដែរ បើចិត្តទោមនស្ស បេះដូងខ្មៅ បើចិត្តជាឧបេក្ខា បេះដូងព្រឿងប្រែល្អ ឃើញខុសពីគោលរបស់លោកគី ដែលជាចេតោ បរិយញ្ញាណ ជាជាក់ស្ដែងរបស់ចិត្តចក្ខុ សេចក្ដីនេះសូមលោកអ្នកមើល វិនិច្ឆ័យចុះ ។

## វិជ្ជាប្រការទី ៦

### បុព្វេនិវាសានុស្សតិញ្ញាណ

តាមធម្មវិភាគ បរិច្ឆេទទី ៦ ពោលជានិទ្ទេសទុកថា អនេកជាតិដែល



www.elibraryofcambodia.org

កន្លងមកហើយបាន រាប់ពីជាតិ ១ ជាតិ ២ រហូតដល់ទៅច្រើនៗកល្ប ដឹងថាក្នុងកាលជាតិនោះៗមានឈ្មោះគោត្រត្រកូលយ៉ាងនោះ មានសម្បុរពណ៌ មានអាហារបែបនោះៗ បានសោយសុខឬសោយទុក្ខមានអាយុប៉ុន្មានៗក៏ដឹង ច្យុតពីជាតិនោះមក កើតក្នុងជាតិណាខ្លះ បានធ្វើជារឿងៗរូបបានមកកើតក្នុងជាតិនេះ រឿងនេះសម្តេចព្រះមហាសមណទ្រង់ប្រៀបប្រដូចនឹងការដើរចាកពីស្រុករបស់ខ្លួន ហើយទ្រង់ត្រឡប់ទៅទៀតអជា សេចក្តីរឭកជាតិបាន ដូចមានសំដែងមកនោះ ចាត់ជាអង្គនៃព្រះសម្មា-សម្ពោធិញាណ បានដោយបែបយ៉ាងណា គួរពិចារណាមើលថា បើរឭកជាតិបានដូច្នោះហើ ទើបបាត់ក្អក់ផ្តិលផ្លូវសេចក្តីវិលកើតវិលស្លាប់ ដែលជាគតិនៃធម្មតានាំឲ្យកើតជាអនត្តានុបស្សនាញាណដោយឯកឯងដូច្នេះនេះ ក៏គួរឲ្យទទួលដែរ ព្រោះញាណនេះពេលក្រោយជាកំចាត់នូវមោហៈដែលកំបាំងក្នុងខន្ធសន្តាន ឲ្យឃើញជាអនត្តានុបស្សនាញាណ ហើយរាប់ជាអង្គនៃព្រះសម្មាសម្ពោធិញាណ ។

បុព្វេនិវាសានុស្សតិញ្ញាណនេះ ជាបញ្ហាដែលអ្នកចេះធម៌បានជជែកគ្នាមកជាច្រើន មិនមែនតែសាសនារបស់យើងនេះទេ សាសនាឯទៀតក៏ដូចគ្នា គឺពួកដែលប្រកាន់ថា វិញ្ញាណជាធម្មជាតិមិនចេះរលត់សូន្យ (Spiritualiste) នោះក៏ប្រកាន់តាមនិទ្ទេស ដែលពោលមកហើយនោះ ចំណែកខាងពួកដែលប្រកាន់ថា វិញ្ញាណជាធម្មជាតិរលត់ទៅជាមួយនឹងខ្លួនវេលា



www.elibraryofcambodia.org

ស្លាប់ទៅនោះ គឺជាគ្មានអ្វីលើសពីភ្នែកឃើញ, ត្រចៀកឮ, ហិតក្លិនដោយច្រមុះ, ដឹងរសជាតិដោយអណ្តាត, សម្ផស្សដឹងដោយកាយនោះទេ (Matérialiste) ពួកនេះហើយដែលប្រៀបធៀបនឹងការដែលពុំឃើញកាលពីកើត, ពីព្រោះនឹងកាលពីទីតាំងណា ៗ បានផ្តើមខ្លះ បានប្រទះហេតុយ៉ាងណាខ្លះ ប្រយោជន៍ដែលបានប្រទះឃើញមកនោះ បានសេចក្តីសុខសេចក្តីទុក្ខសេចក្តីចំរើនឬមិនចំរើន ដោយហេតុផលជាប់គ្នាយ៉ាងណា ៗ នេះឯងកើតជាបញ្ហាដ៏គួរគិត តើខាងណាខុសខាងណាត្រូវ ៗ

មុននឹងដោះស្រាយបញ្ហានេះនៅមានខ្លួនមួយទៀតជាបញ្ហាសំខាន់ណាស់ ហើយជាបណ្តូលរបស់សាសនាគ្រប់សាសនាដែលបានដាក់ក្បួនច្បាប់ទាំងពាន់ៗ គ្នាហើយក៏មិនសម្រេច សព្វថ្ងៃនៅមានមនុស្សព្យាយាមស្រាវជ្រាវរកហេតុ ឲ្យបានឃើញពិតប្រាកដត្រឹមត្រូវនោះណាស់ ក៏ពុំបានប្រទះឃើញពាក្យតបឆ្លើយណាមួយ ដែលនឹងមិនឲ្យអ្នកណាហ៊ានជំទាស់ទៀតបានអំពីប្រស្នានេះថា "មនុស្សយើងស្លាប់ហើយកើតវិញឬទេ" បើប្រសិនជាវិនិច្ឆ័យថា មនុស្សស្លាប់ហើយសូន្យនោះមិនបាច់សង្ស័យទេ ត្រូវតែគិតប្រៀបធៀបឲ្យឃើញថាបុព្វនិវាសមនុស្សវិញ្ញាណមានចំនួនដូចម្តេច? បើវិនិច្ឆ័យថា មនុស្សស្លាប់ហើយកើតវិញទៀតនេះ គឺនឹងមានបញ្ហាតទៅថា គួរគិតរកអ្វីប្រៀបប្រដូចឲ្យនឹងអធិប្បាយទៅតាមវិទេស ៗ

ឯកំណើតកើតរបស់មនុស្សនោះ បានគឺមានសេចក្ដីយល់ឃើញផ្សេងពីគ្នាជាពីរពួក គឺចំណែកពួកដែលប្រកាន់យកតាមផ្លូវសាសនាថា ព្រះម្ចាស់សួគ៌សាងមនុស្សប្រុស១ ស្រី១ ឲ្យជាគូនៅរួមជាមួយគ្នា បង្កើតជាពូជតៗ មករាលដាលផ្សាយទូទៅក្នុងលោក ដូចមាននៅក្នុងបច្ចុប្បន្ននេះ ចំណែកខាងពួកអ្នកប្រាជ្ញវិទ្យាសាស្ត្រឃើញថា មនុស្សយើងកើតឯងដោយធម្មជាតិ គឺដើមឈើកើតមុនបានសត្វកើតពីដើមឈើ រួចកាន់តែចំរើនឡើងក្លាយទៅជាស្វា ទើបក្លាយទៅជាមនុស្ស បានជាថាមនុស្សយើងជាប់ពូជមកពីស្វា ត្រង់នេះឯង ដែលធ្វើឲ្យពួកលោកសង្ឃបាក់ទឹកក្នុងស្រុកអាមេរិក នាំគ្នាប្ដឹងតុលាការសុំឲ្យហាមឃាត់ កុំឲ្យប្រដៅកូនសិស្សក្នុងសាលារៀនថាមនុស្សកើតមកពីស្វាឬពីសត្វផ្សេងៗ ព្រោះថាបើប្រដៅដូច្នេះហើយ ក្នុងមួយរយឆ្នាំទៅមុខ គ្មានមនុស្សជឿព្រះម្ចាស់ក្នុងសាសនាគ្រិស្ដនោះឡើយ ។

អំពីសេចក្ដីយល់ឃើញរបស់មនុស្សទាំងឡាយ អំពីកំណើតកើតរបស់មនុស្សនោះ យើងល្មមយកមកសរុបជាបីពួកដូច្នេះ ៗ

ពួកទី ១ – យល់ឃើញថាមនុស្សយើងកើតមកឯងៗ ដោយបានវិញ្ញាណមកថ្មី មិនមែនវិញ្ញាណជាប់មកពីជាតិណាៗទេ តែកាលណាស្លាប់ វិញ្ញាណក៏រលត់ ៗ ផលនៃអំពើនេះ គឺថាមនុស្សនឹងបានទទួលផលល្អ

បុគ្គលកើតហើយប្រការដូចម្តេចៗ ក៏ទទួលផលក្នុងលោកនេះប៉ុណ្ណោះ ដល់ស្លាប់ទៅហើយគឺជាអហោសិកម្ម ។

ពួកទី ២– យល់ឃើញថាមនុស្សកើតមកតាមអាស្រ័យវិញ្ញាណ ដែលមានមកពីមុនហើយនោះទាំងរស់ កាលណាស្លាប់វិញ្ញាណមិនរលត់ នៅចាំទាល់តែប្រទះកាយសម្រាប់កើតជាថ្មីទៀត ។

ពួកទី ៣· យល់ឃើញជាកណ្តាលថា មនុស្សកើតថ្មីវិញ្ញាណក៏ថ្មី ដោយមិនបានយកវិញ្ញាណរបស់មនុស្សស្លាប់មកបញ្ចូលក៏មាន មនុស្សដែលកើតមក ដោយវិញ្ញាណចាស់ក៏មាន មនុស្សដែលស្លាប់ហើយដោយវិញ្ញាណរលត់ទៅក៏មាន មិនរលត់ក៏មាន ។

តាមសេចក្តីយល់ឃើញ ពួកទី ១ ជាសេចក្តីយល់ឃើញរបស់អ្នកប្រាជ្ញវិទ្យាសាស្ត្រដោយពិត ដែលជាពួកអ្នកអធិប្បាយថា មនុស្សកើតមកពីសត្វស្វានោះឯង, សេចក្តីយល់ឃើញរបស់ពួកនេះយើងអាចតាំងប្រស្នាដែលបានច្រើនខ គឺ:

១– បើមនុស្សយើង បានវិញ្ញាណថ្មីជាដរាបទៅ ដោយមិនជាប់មកពីជាតិណាៗទេ វិញ្ញាណនោះក៏នឹងដូចគ្នាទាំងអស់ តែហេតុអ្វីក៏មនុស្សយើង មិនដូចគ្នាទាំងអស់ ដូចម្តេចបានជាមានល្ងង់មានឈ្លាស មានឧស្សាហ៍ មានខ្ជិល មានចិត្តត្រង់មិនត្រង់សុចរិតមិនសុចរិត ដែលជាហេតុ

ឲ្យផ្ទុយគ្នាខុសគ្នាជាដរាប ដូចជាកូនដែលកើតពីមាតាបិតាជាមួយគ្នា មួយល្អជាបំផុត មួយទៀត អាក្រក់បំផុតក៏មាន មិនដូចគ្នានឹងដើមឈើ ដូចជាដើមកុលាប ដែលមានផ្កាច្រើន ទុកជាខុសគ្នាដោយផ្កាធំតូចក៏គង់គូនមិនខុសពីគ្នា ដោយផ្កាមួយក្រហម ផ្កាមួយស្វាយ ក៏ទេដែរ ប្រសិនបើហានពាក្យដោះស្រាយថា ព្រោះវិញ្ញាណដែលបានមកនោះផ្សេងពីគ្នា យើងក៏មានពាក្យសួរទៅថា តើជាហេតុអ្វីផ្សេងពីគ្នា ក្នុងសាសនាពុទ្ធណាៗក្តី តែងតែមានគោលដូចគ្នាថា ផលនឹងកើតបានតែតាមហេតុ ។

២— មនុស្សដែលបានរៀនសូត្រដូចគ្នា ធ្វើការដូចគ្នា ចិត្តហ៊ានដូចគ្នា តែម្នាក់បានល្អ, ម្នាក់មិនបានចំរើនល្អ ដូចជាមនុស្សដែលចិត្តត្រង់ខំស្វាហាប់ធ្វើការដោយសុចរិតអស់មួយជីវិត តែមិនបានសេចក្តីសុខ ឬឲ្យបានជាអ្នកមានសម្បត្តិទ្រព្យក៏ទេ ឯមនុស្សខ្លះដែលធ្លាប់តែកេងក្រៅ ចាំងព្រះកដទ្រព្យ បៀតបៀនមនុស្សដទៃ ធ្វើឲ្យមនុស្សក្តៅក្រហាយជានិច្ចនោះ ត្រឡប់ជាមានសេចក្តីចំរើន មានអំណាចវាសនា មានមនុស្សទាំងគួរញញើតខ្លាចក៏មាន ។

៣— បើយល់ឃើញពិតប្រាកដថា មនុស្សស្លាប់ទៅហើយវិញ្ញាណក៏រលត់ទៅជាមួយដែរ មិនមានបាបបុណ្យគុណទោសអ្វីជាប់ទៅលោកខាងមុខទេ ដូច្នេះនេះមនុស្សនោះក៏នឹងគិតថា ចាំបាច់ខ្វល់ខ្វាយប្រព្រឹត្តធ្វើឲ្យ

បានសេចក្តីល្អក៏ធ្វើអ្វី គ្រាន់តែកែខ្លួនចិត្តមិនពិតឲ្យត្រូវចំណំលក់ទៅក៏បានហើយ ។

ប្រការមួយវិញទៀត បើមនុស្សនោះ មានអំណាចធ្វើអ្វីបានតាមចិត្ត គឺនឹងប្រព្រឹត្តដោយផ្ទៃត្រង់ខ្លះ វៀចខ្លះ រកផលប្រយោជន៍ឲ្យខាងតែបាន ទុកជាមានពាក្យនិន្ទាជារឿងក៏ដោយ ស្តាប់ទៅហើយអ្នកណាចង់និយាយជាប្លែកប្លែក ៗ ក៏ជាទៅចុះ សុំឲ្យតែមានទ្រព្យចាយសប្បាយចិត្តក្នុងមួយជាតិគឺបានហើយ ។

បើគិតដល់បញ្ហាទាំង ៣ ខ ដែលមានមកនោះ គឺនឹងធ្វើឲ្យអ្នករៀនធម៌ អាចតាំងជាបញ្ហាបានច្រើនខកទៅទៀត ៗ តាមសេចក្តីយល់ឃើញក្នុងពួកទី ១ នោះ មិនខុសតែម្យ៉ាងទេ នៅមានសេចក្តីខុសតទៅទៀតជាបើជឿតាមសេចក្តីនោះហើយ គឺនឹងនាំឲ្យមនុស្សប្រាសចាកសីលធម៌ដែលល្អនោះផង ។ អ្នកដែលបានរៀនធម៌គង់ជឿថា ជាការពិបាកណាស់ដែលនឹងអធិប្បាយឲ្យមនុស្សក្នុងបច្ចុប្បន្ននេះ យល់មើលឃើញផលដែលបានទទួលដោយការសុចរិតក្រៅអំពីមនុស្សដែលប្រព្រឹត្តរកស៊ីដោយខុសផ្លូវធម៌នោះ មួយទៀត ការដែលនឹងសំដែងពន្យល់ឲ្យមនុស្សមើលឃើញផលក្នុងការរក្សាសីលថានឹងបានផលក្នុងបច្ចុប្បន្នយ៉ាងណានោះ គឺពិបាកពន្យល់ណាស់ដែរ ព្រោះក្នុងលោកនេះ មានមនុស្សដែលប្រព្រឹត្តតាមក្រឹត

ច្រើនជាងមនុស្សប្រព្រឹត្តល្អ មនុស្សបែបនេះ មានតាំងពីលោកកើតឡើង រហូតមកដល់ឥឡូវនេះ ក៏មិនឃើញមានអ្វីធ្វើទោសឲ្យបានតែមនុស្ស ដែលប្រព្រឹត្តខុស ឲ្យបានឃើញប្រាកដនៅក្នុងមនុស្សក្នុងបច្ចុប្បន្ននេះ ឃើញនៅតែមានមនុស្សប្រព្រឹត្តអាក្រក់នោះ មានអាយុយឺនវែង មានឱកាសរស់នៅបៀតបៀនមនុស្សឯទៀតឲ្យបានយូរទៅទៀត តែមនុស្ស ល្អច្រើនស្លាប់ឆាប់ ប្រហែលដូចពាក្យថា ទេវតាក្នុងស្ថានសួគ៌ ត្រូវការ យកខ្លួនឲ្យទៅនៅជាប់នោះទេដឹង?

វិធីដែលយើងប្រើជាធម្មតា ក្នុងជំនាន់ថ្មីនេះ យើងនិយាយថា មនុស្សធ្វើបាបអាក្រក់លាមកយ៉ាងណា ទុកជាគ្មានអ្នកណាដឹងឃើញ គ្មានអ្នកណាធ្វើទោសបាន ក៏គង់នៅមានសេចក្តីក្រហល់ក្រហាយក្នុងចិត្ត របស់ខ្លួនដែរ បែបនេះក៏មានច្រើន តែក៏គង់នៅមានបញ្ហាជាច្រើនទៀត ដែរ ព្រោះមនុស្សដែលធ្វើបាបជាប្រក្រតីរាល់តែថ្ងៃហើយ ត្រឡប់ជា មានសេចក្តីពេញចិត្ត ក្នុងការដែលខ្លួនមានឱកាសធ្វើបាបនោះៗ មនុស្ស ដែលគេស៊ីចិញ្ចឹមជីវិត ដោយផ្លូវកោងកាចក៏មានចិត្តត្រេកអរ យល់ឃើញ ថា ខ្លួនឆ្លាតចេះកោងគេបានសម្រេចដូចប្រាថ្នារបស់ខ្លួន មនុស្សដែល ប្រព្រឹត្តបៀតបៀន ធ្វើឲ្យមនុស្សឯទៀតក្តៅក្រហាយដោយមិនយុត្តិធម៌ ច្រើនមានចិត្តអំណរ យល់ឃើញថាខ្លួនមានជ័យជំនះក្នុងការដែលធ្វើបាន


www.elibraryofcambodia.org

សប្រែបដូចគំនិតរបស់ខ្លួន ៗ មនុស្សដូចបានពណ៌នាមកនេះ មាននៅក្នុងលោកជាច្រើន ៗ

អ្នកប្រាជ្ញទាំងឡាយ បានយល់ឃើញដូចគ្នាថា ដំណើរធម្មជាតិក៏តែងតែមានគោលច្បាប់ដូចជាការក្នុងស្រុកដែលគេហៅថា (Loi de la nature) ដូចបានពណ៌នាក្នុងដើមប្រការទី១ រួចមកហើយ ៗ បើធម្មជាតិសាងមនុស្សឡើងហើយ ធម្មជាតិក៏ត្រូវតែធ្វើទោសមនុស្សដែលប្រព្រឹត្តខុសហើយក៏ត្រូវឲ្យបំណាច់រង្វាន់មនុស្សដែលប្រព្រឹត្តល្អ ហេតុនេះយើងគួរជឿថាមនុស្សដែលប្រព្រឹត្តល្អឬអាក្រក់ បើប្រសិនជាមិនបានទទួលផលក្នុងជាតិនេះ ក៏គង់តែនឹងបានទទួលនៅក្នុងជាតិមុខ គិតបានដូច្នេះក៏នឹងធ្វើឲ្យមនុស្សដែលមានចិត្តអាក្រក់ខំចិត្តបានខ្លះ មុននឹងទៅធ្វើអំពើឲ្យមនុស្សដទៃ ហើយនឹងធ្វើឲ្យមនុស្សដែលប្រកបដោយសេចក្តីសុចរិតល្អមិនបានទទួលផលល្អក្នុងលោកនេះ ត្រូវឲ្យទទួលនូវផលអាក្រក់វិញនោះ នឹងបើបើឃើញក្នុងលោកនេះ ប្រាសចាកសេចក្តីយុត្តិធម៌ ហើយក៏នឹងលះបង់ចោលនូវសេចក្តីតូចចិត្តចេញបានខ្លះ ដោយមានចិត្តគិតទៅទទួលផលល្អ ក្នុងលោកខាងមុខ មនុស្សដែលកើតមកបានសេចក្តីសុខ ក៏នឹងបានប្រព្រឹត្តឲ្យល្អតទៅ ដើម្បីឲ្យបានទទួលសេចក្តីសុខក្នុងលោកខាងមុខតទៅទៀត ៗ មនុស្សដែលកើតមកបានសេចក្តីទុក្ខក៏នឹងបានគិតឃើញថា

www.elibraryofcambodia.org

ពីព្រោះប្រព្រឹត្តមិនល្អមកពីជាតិមុន គឺនឹងបានព្យាយាម ប្រព្រឹត្តឲ្យល្អក្នុងជាតិនេះតទៅ នឹងបានទទួលផលល្អក្នុងជាតិមុខ ៗ ហេតុនេះបានជាការដែលប្រដៅថា មនុស្សស្លាប់ហើយវិញ្ញាណលត់គ្មានអ្វីមកកើតទៀតនោះ ជាការមិនគួរប្រដៅសោះ បើប្រដៅតាមបែបនោះហើយ គឺនឹងនាំឲ្យមនុស្សប្រព្រឹត្តអាក្រក់ខុសពីធម៌ល្អ ហើយនឹងនាំឲ្យមានគំនិតធ្វើការអាក្រក់ឲ្យក្តៅក្រហាយដល់មនុស្សគ្នាឯងផង ដោយមិនគោរពខ្លាចអាជ្ញាក្នុងលោកនេះធ្វើទោស ព្រោះនឹងគិតថាក្នុងវេលាដែលធ្វើការអាក្រក់នោះ គ្មានអ្នកណាឃើញ ឬក៏គេចកើតរួចប្រាណ ថាខ្លួនមិនត្រូវទោសទេ គឺនឹងប្រព្រឹត្តតទៅ មិនគិតខ្លាចមានទោសទៅក្នុងលោកខាងមុខពីព្រោះយល់ឃើញថា ស្លាប់ហើយវិញ្ញាណលត់ទៅជាមួយផង ។

សេចក្តីយល់ឃើញពួកទី ២ មានហេតុផលសមច្រើនជាងពួកទី ១ តែនៅមានពាក្យជជែកថា បើមនុស្សយើងកាន់កើនឡើង វិញ្ញាណចាស់ទាំងនោះមកកើតជាមួយ តើវិញ្ញាណចាស់បានមកពីណា កាលដំបូងបង្អស់តាមព្រះគម្ពីរវេទាពាក្យក្នុងសាសនារបស់យើង សំដែងទុកថាអាយុរបស់លោកមានច្រើនកោដិឆ្នាំ (ខាងអ្នកប្រាជ្ញពង្សាវតារគេឃើញតាមសា-ការឃើញមានតែត្រឹមប្រាំពាន់ឆ្នាំជាយ៉ាងច្រើន) ទុកជាយូរយ៉ាងណាក៏ដោយ ក៏គង់នៅមានបញ្ហាថា វិញ្ញាណដើមបង្អស់នោះកើតមកពីណា ?

www.elibraryofcambodia.org

ហើយមនុស្សយើងទាំងអស់គ្នាប្រកាន់ថា ភ្ជាប់កើតមកហើយ ក៏ពិបាកថា ដែលកើតថ្មី វិញ្ញាណក៏ថ្មី គង់មានខ្លះៗ

តាមសេចក្ដីយល់ទាំង ៣ ពួក បើគិតទៅឃើញថា ពួកទី ៣ នោះត្រូវណាស់ យើងអាចយកសេចក្ដីយល់ឃើញរបស់អ្នកប្រាជ្ញវិទ្យាសាស្ត្រ និងអ្នកប្រាជ្ញខាងផ្លូវសាសនា មកប្រៀបគ្នាគង់ឃើញមិនខុសដល់ទៅផ្ទុយគ្នាបាននោះទេ ពោលគឺជាន់ដំបូង មនុស្សអាចកើតពីដើមឡើយជាមុន តែមិនបានកើតជាមនុស្សក្នុងវេលានោះទេ គឺបានកើតជាសត្វមុន តាំងដើមដំបូងកើតជាសត្វដែលល្អិតសិន រួចបានកើតជាសត្វតរៀងរាបដរាប តាល់តែដល់សត្វដែលឆ្លាតដូចជាស្វា រួចហើយបានក្លាយមកជាមនុស្ស ហេតុនេះបានជាក្នុងផ្លូវសាសនារបស់យើងកប់មនុស្សទុកជាសត្វ ១ពួក ដ៏ប្រសើរខ្ពង់ខ្ពស់ជាងសត្វទាំងពួង ។ កាលណាក្លាយមកជាមនុស្សហើយ ក៏អាចមានកូនទៅកើតជាមនុស្សតមក ដោយបានវិញ្ញាណមកថ្មី ឯវិញ្ញាណដែលបានកើតមកជាមួយនឹងរូបកាយនៅក្នុងលោកនេះហើយ ក៏ត្រូវតែទទួលខុសត្រូវ ក្នុងការដែលកាយប្រព្រឹត្ត បើកាយទៅប្រព្រឹត្តអាក្រក់ហើយមិនបានទទួលទោសក្នុងលោកនេះ វិញ្ញាណក៏នឹងត្រូវទៅទទួលទោសក្នុងកាលខាងមុខ វិញ្ញាណតើនឹងទៅតែមុខ ដោយមិនបានទទួលទោសដែលកាយធ្វើ ដូចជាកូនវាយក្បាលគេបែកហើយគេចាប់



www.elibraryofcambodia.org

មិនឲ្យចាប់បាននោះ ធម្មជាតិគង់តែមិនព្រមឲ្យគេរួចបាននោះទេ ។ បានជាថាហេតុដែលប្រកាន់ថាវិញ្ញាណរលត់ទៅជាមួយខ្លួនស្លាប់នោះ មិនគួរស្លាប់យកមកជាគតិសោះឡើយ ព្រោះតែមនុស្សទោសដែលត្រូវប្រហារជីវិតម្ដងគេទំនុកបំរុងរាំងរក្សាមិនឲ្យវាស្លាប់មុនប្រហារជីវិត ។ វិញ្ញាណរបស់មនុស្សក៏ដូចគ្នា បើធ្វើខុសអ្វីក្នុងលោកនេះនឹងតែរលត់ទៅនោះពុំបាន ត្រូវតែចាំទទួលទោសកំហុសរបស់ខ្លួនឲ្យអស់សិន បើចង់រលត់ក៏រលត់ទៅបាន ឯការដែលរលត់នោះឯង យើងហៅថា និព្វាន ។

តាមសាសនារបស់យើង ពោលថានឹងទៅដល់និព្វាននោះជារបស់ពិបាកណាស់ គេសាងបារមីច្រើនជាតិ ការសាងបារមីនេះគឺជាការដោះខ្លួនពីទោសដែលខ្លួនប្រព្រឹត្តខុសមកនោះ ហើយនឹងដោះបំណុលក្នុងលោកដែលខ្លួនបានអាស្រ័យមកនោះផង បើបានធ្វើការដោះខ្លួនរួចពីទោសនឹងដោះបំណុលរបស់លោករួចបានហើយ ចង់ទៅកើតទៅឬចង់រលត់នោះមានគតិ២ ផ្លូវ មួយបើចង់ទៅកើត ក៏ទៅកើតក្នុងសុគតិដែលហៅថាស្ថានសួគ៌ មួយវិញទៀត បើមិនចុកចិត្ត ខ្លាចក្រែងទៅទៀតហើយប្រព្រឹត្តអាក្រក់ធ្វើបាបក៏នឹងនាំឲ្យមានទោសទុក្ខ ត្រូវចាំដោះទៀតរហូតទៅទៀត ឬក៏មានសេចក្ដីនឿយណាយ ជិនឆ្អន់នឹងកំណើតដែលវិលកើតវិលស្លាប់នោះ ក៏មានតែរលត់សូន្យទៅ ដែលហៅថាចូលព្រះនិព្វាន ។

មនុស្សដែលកើតមកក្នុងលោកជាមួយគ្នា ត្រូវប្រកាន់ដូចជាបានចូលហ៊ុនជាមួយគ្នា ហើយនៅក្រោមច្បាប់របស់ធម្មជាតិ ដូចជាអ្នកចូលហ៊ុនធ្វើជំនួញ ដែលត្រូវនៅក្នុងបន្ទាប់ច្បាប់សម្រាប់ស្រុក ដែលខ្លួនអាស្រ័យផែនដីនោះ ព្រោះខ្លួនបានផលប្រយោជន៍ ជាគ្រឿងចិញ្ចឹមជីវិត ប្រៀបប្រដូចនឹងប្រាក់ចំណេញ និងការប្រាក់ដែលចូលហ៊ុនបានមកតាំងពីមុននោះ ត្រូវតែកាត់សងបំណុលដែលហ៊ុនជំពាក់ឲ្យរួចសិន អ្នកចូលហ៊ុនមិនព្រមកាត់សងបំណុលនិងការបង់ខាត ដែលហ៊ុនធ្វើនោះទេ គិតតែចូលហ៊ុនហើយ ទារយកតែចំណេញនោះ ច្បាប់ក្នុងស្រុកក៏គង់តែមិនយល់ព្រមឲ្យធ្វើដូច្នោះបានឡើយ ។

រួមសេចក្តីដែលពោលមកនេះ គួរតែជឿថា មនុស្សស្លាប់ហើយត្រូវតែមកកើតជាថ្មីទៀត ពាល់តែសងបំណុលដែលជំពាក់ក្នុងលោកឲ្យអស់ ដែលហៅថាបំណុលនោះ គឺសំដៅដល់កំហុសរបស់ខ្លួន ដែលបានប្រព្រឹត្តបទពេក្រក់មកពីជាតិមុនៗ ដែលជាសងបំណុលនោះ គឺត្រូវប្រព្រឹត្តសេចក្តីល្អដោះសេចក្តីអាក្រក់របស់ធម្មជាតិ ដែលខ្លួនបានប្រព្រឹត្តមកហើយនោះ ។ មនុស្សដែលកើតមកហើយនៅស្ងៀម មិនបានប្រព្រឹត្តធ្វើនូវការល្អឬការអាក្រក់សោះ គឺពុំទៅជាទានពុំបានដែរ ព្រោះនៅមានជាប់បំណុលរបស់ធម្មជាតិ ដូចជាកំណើតមនុស្សធ្វើសេចក្តីល្អបានដល់មនុស្សពួកខ្លះដូចមាតាជាដើម គេនឹងតែសងគុណលោកឲ្យរួចស្រេច ទើបចូល



www.elibraryofcambodia.org

ទៅនិព្វានបាន ។ ហេតុដូច្នេះបានជាការដែលនឹងទៅនិព្វានបាននោះលុះ
តែធ្វើសេចក្ដីល្អឲ្យច្រើនណាស់ ដូចដែលហៅថាសន្សំបារមីមកកប់ហ្មឺន
សែនជាតិនោះ តាមន័យដែលអធិប្បាយមកនេះ ។

បើលោកអ្នកមើល មានសេចក្ដីយល់ឃើញថា មនុស្សស្លាប់ហើយ
កើតទៀតនោះ បញ្ហាក៏នឹងមានតទៅថា បុព្វេនិវាសានុស្សតិញ្ញាណណានោះ
កើតនឹងសំដៅតែត្រឹមជាតិនេះតែមួយ ឬក៏សំដៅដល់ទៅជាតិដែលកន្លងមក
ហើយនោះផង ។

បើសំដៅតែត្រឹមក្នុងជាតិនេះ ក៏តោងអធិប្បាយថាតាំងពីដឹងសេចក្ដី
មក ទល់ឥឡូវនេះ អាចដឹងថាបានជាកាលក្នុងអាយុបានប៉ុណ្ណោះៗ បាន
ធ្វើការឬបានប្រទះហេតុយ៉ាងនោះៗ ដែរឬទេ រឿងនេះមិនជាពិបាកទេ
បើមនុស្សយើងគ្រប់គ្នាគ្មានសតិវិបល្លាសហើយ ក៏អាចចាំហេតុការណ៍
ដែលខ្លួនបានប្រទះមកហើយនោះបាន ។ បើយើងយកសេចក្ដីចាំ ក្នុងជាតិ
នេះថា ជាបុព្វេនិវាសានុស្សតិញ្ញាណហើយ គឺនឹងធ្វើឲ្យកិត្តិគុណ របស់
ព្រះពុទ្ធជាម្ចាស់ ថោកថយទាបពេកណាស់ ។ ព្រោះថាព្រះពុទ្ធជាម្ចាស់
ដែលនឹងបានលុះញាណ ១ នេះ តោងធ្វើទុក្ករកិរិយាដល់ទៅ ៦ ឆ្នាំ
ហាក់ដូចជាព្រះអង្គល្ងង់ ជាងសាមញ្ញជន ព្រោះការធ្វើបានដោយងាយ
មិនបាច់ព្យាយាម ក៏ធ្វើបានដែរ ព្រះអង្គទៅព្យាយាមធ្វើជាយូរឆ្នាំ ឲ្យ
អស់តែកំឡាំងឥតអំពើ ។ ហេតុនេះគួរឲ្យជឿថា បុព្វេនិវាសានុស្ស-


www.elibraryofcambodia.org

វិញ្ញាណនោះ ពិតប្រាកដជាទីករពួកយើងដល់ជាតិ ដែលកន្លងមក ហើយបាន មិនមែនទើបកើតតែក្នុងជាតិនេះទេ ។

ឯបុព្វេនិវាសានុស្សតិញ្ញាណនេះ ពុំដែលប្រែងះសេចក្ដីអធិប្បាយរបស់ប្រាជ្ញរបស់លោកណាមួយក្នុងលោក ជាជាអ្នកឲ្យប្រាកដនោះឡើយ តាមសេចក្ដីដែលយល់ឃើញ គឺបានទូកានាំយករបស់ធ្លាប់ដឹងឃើញចំណាំចាំបានមកហើយនោះ ចូលមកការទុកចិត្តជាថ្មីវិញបាន ដូចក្នុងការសាបាក់ហៅថា (Faculté de la mémoire) ប្រៀបដូចយើងធ្លាប់នៅក្នុងស្រុក ស្គាល់ផែនផ្លូវទាំងប៉ុន្មាន ហើយចេញចោលស្រុកទៅបាន ៣០ ឆ្នាំ បានត្រឡប់វិលមកស្រុកវិញ គំនិតអ្វីដែលយើងធ្លាប់ដើរពីមុននោះពុំឃើញឡើយ ព្រោះចេញចោលទៅយូរឆ្នាំ ស្រុកប្រទេសដែលយើងធ្លាប់នៅពីដើមនោះ ក៏ជាការផ្លាស់ប្ដូរផែនរៀបចំជាថ្មី ប៉ុន្តែគំនិតចាស់សេចក្ដីចំណាំរបស់ខ្លួនមិនប្រាកដក៏មាន ម្យ៉ាងទៀត យើងធ្លាប់រៀនមកថា មនុស្សយើងស្លាប់ហើយវិញ្ញាណចេញទៅរស់នៅក្នុងទីណាមួយកប់ហ៊ឹកៗឆ្នាំ ទើបបានមកកើតជាថ្មីទៀត ហេតុនេះបានជាចាំអ្វីមិនបាន ព្រោះក្នុងលោកបានផ្លាស់ប្ដូរទៅជាច្រើន វិញ្ញាណក៏ភ្លេចអស់ ។ យើងតែក្រឡេកគិតមើលទៀតថា បើមនុស្សស្លាប់ហើយមកកើតមួយរំពេចវិញ តែមនុស្សនោះមុននឹងស្លាប់មានស្មារតីល្អចាំសេចក្ដីបាន ប្រហែលជារឭកជាតិបានខ្លះម្ដេច រឿងនេះយើងគង់



www.elibraryofcambodia.org

ដែលបានពុ លោកចាស់ៗនិយាយដំណាលមកជាច្រើន ថាមានក្មេងខ្លះ
កើតមកដល់ធំដឹងសេចក្តី ក៏និយាយប្រាប់ថាខ្លួនធ្លាប់កើតមកហើយបានចាំ
របស់ទ្រព្យនោះៗប្រាប់ដំណើររបស់តាំងនោះក៏ត្រូវទៀត តែរឿងនេះមាន
តិចណាស់ បានជាបណ្តាយឲ្យថាជារឿងមិនពិត ហើយមិនយកចិត្តទុក
ដាក់គតមក ៗ មានរឿងគេនិយាយថា មានស្ត្រីម្នាក់មានប្តី កាលប្តីឈឺជាប់
ខ្សល់ស្លាប់ បានយកកំបោរលាបកជើងសំគាល់ ដើម្បីចង់ដឹងថាមកកើត
វិញឬទេ ដល់ស្ត្រីនោះមានប្តីថ្មីកូនដំបូងកើតមកឃើញមានជាំខ្មៅនៅ
កជើង ជាស្នាមកំបោរដែលគូសសំគាល់ ដល់កូននោះធំឡើងដឹងសេចក្តី
មិនព្រមហៅស្ត្រីនោះថាម្តាយ ក៏ហៅថាប្រពន្ធវិញ ពួកអ្នកប្រាជ្ញសម័យ
ថ្មីរើសយកមកអធិប្បាយថា ការដែលក្មេងមានជាំខ្មៅនៅកជើងនោះ
ព្រោះម្តាយមានចេតសិករឭកជារឿយៗ ដល់ស្នាមកំបោរដែលខ្លួនគូស
នៅកជើងរបស់ប្តី ឯក្មេងដែលហៅម្តាយថាជាប្រពន្ធវិញនោះប្រហែល
ជាមានអ្នកណាទៅបញ្ចុះឲ្យហៅ ៗ ការរលឹកជាតិនេះ លោកការ៉សែលដេ-
លីមេក្មេងក្រុងខេត ចុះដំណឹងការបាវែរ្យស៊ូសថា មានរឿងវិបូកកើតឡើងក្នុង
(ស្រុកវណ្ណា) គឺក្មេងស្រីម្នាក់អាយុបាន៣ឆ្នាំ ប្រាប់ពុកថាជាកំណើត
ទីពីរដែលខ្លួនមកកើតក្នុងលោកនេះកាលមុនកើតនៅទីនោះ ៗ ឪពុកក៏មិន
យកចិត្តទុកដាក់ គិតថាបុត្រខ្លួននិយាយទៅតាមភាសាក្មេង តែកូននោះ



www.elibraryofcambodia.org

នៅតែនិយាយជាដរាប ហើយរំលឹកឲ្យឪពុកវានាំទៅទី ដែលខ្លួនបានកើតមុននោះ ទាល់តែក្មេងនោះអាយុ ៧ ឆ្នាំ ឪពុកឃើញវានិយាយញយៗខុសនឹងប្រក្រតី ក៏នាំកូននោះទៅតាមពាក្យវាថា ទីកន្លែងភូមិដែលវាកើតមុននោះ ដេកផ្លូវមួយយប់បានដល់ ទៅដល់ភូមិនោះហើយវាប្រាប់ផ្លូវឲ្យទៅទីកន្លែងផ្ទះដែលវាកើត នឹងប្រាប់ឈ្មោះមនុស្សដែលនៅក្នុងភូមិនោះត្រូវ រួចវាក៏ទៅរកបុរសពីនាក់ថាជាកូនរបស់វា ដល់វេលាឪពុកវានឹងនាំត្រឡប់វិលមកស្រុកវិញ វាយំមិនព្រមវិលវិញ ទាល់តែបង្ខំបានវាមក រឿងនេះគឺជាហេតុនាំឲ្យយើងគួរស្រាវជ្រាវរកសេចក្តីពិតឲ្យឃើញថាមកពីហេតុដូចម្តេច[១]? កាលដែលព្រះពុទ្ធជាម្ចាស់របស់យើងទ្រង់អាចរំឭក

---

១ កាលខ្ញុំនៅធ្វើជាចៅហ្វាយស្រុកកៀនស្វាយ មានស្ត្រីឈ្មោះពាង់ផ្លុំជាប្រពន្ធឈ្មោះផ្លូនៅភូមិស្តុកកំពង់ខ្នុល ខណ្ឌកណ្តាលស្ទឹង កើតកូនមកភ្លោះប្រុសទាំង ២ មួយមិនដឹងជាតិ កូនមួយទៀតដឹងជាតិ ឪពុកម្តាយឲ្យឈ្មោះរ៉ូច ចៅរ៉ូចអាយុបាន ៦ ខួបលេងនៅមុខផ្ទះបៀតចិញ្ចើមថ្នល់ស្រាប់តែឃើញតាងកេតតុំងឈ្មោះតេត មកពីស្រុកភ្នំស្រួច ដើរមកដល់មុខផ្ទះចៅរ៉ូចក៏ស្រែកប្រាប់ឪពុកម្តាយថា ឪពុកម្តាយខ្ញុំមកហើយ ឪពុកម្តាយក៏ចូលទៅសួរចៅរ៉ូចថាកាលជាតិមុនខ្ញុំឈ្មោះអ៊ីមប្រពន្ធឈ្មោះពក់ នៅឃុំព្រែកឫស្សីកៀនស្វាយ ទៅសួរឪពុកម្តាយនៅភ្នំស្រួចទទួលពិតស្រាប់ ខ្លួនខ្ញុំដើរមកបា ២ នាក់ ដល់ភូមិស្តុកកំពង់ខ្នុលទទួលភ្ញៀវធំខ្ញុំក៏នាំគ្នាចូលទៅសុំផ្ទះតាងផ្លូនៅ ឪពុកម្តាយបានដឹងហើយចៅរ៉ូចប្រាប់ផ្លូវនោះ ក៏នាំចៅរ៉ូចមកឃុំព្រែកឫស្សីស្រុកកៀនស្វាយ ចៅរ៉ូចចង្អុលឈ្មោះនាងណាប់ថាជាប្រពន្ធរបស់ខ្លួន ហើយស្គាល់ឈ្មោះបងប្អូនខាងប្រពន្ធសឹងគ្រប់ឈ្មោះ ឯរបស់ទ្រព្យរបស់ចៅរ៉ូចក៏ស្គាល់ ដល់អាយុពេញបួសជាសាមណេរ ឪពុកម្តាយចង់ឲ្យបួសនៅវត្តកោះក្របី ចៅរ៉ូចមិនព្រម រត់ទៅបួសជាសាមណេរនៅវត្តពោធិ៍ល្បើ កណ្តាលស្ទឹង រឿងនេះខ្ញុំបានយកខ្លួនក្មេងនោះតាំងពីអាយុ ៨ ខួបមកសួរបញ្ជាក់ហើយបានសួរបងប្អូនខាងនាងណាប់ក៏ទទួលថាពិតមែន (ន័យលក្ខណៈរបស់អ្នកប្រែ) ។

ដែលជាប់ប្រព្រឹត្តសេចក្ដីទុច្ចរិត វេលានឹងស្លាប់ពុំបានស្លាប់ដោយសេចក្ដីសុខទេ ។

ព្រះពុទ្ធជាម្ចាស់ កាលកំពុងសាងព្រះបារមី ក្នុងជាតិក្រោយៗមក នោះ ព្រះអង្គបានប្រព្រឹត្តធ្វើតែសេចក្ដីល្អជាបមក មិនដែលឃើញមាន ក្នុងគម្ពីរថា ព្រះអង្គធ្វើឲ្យអ្នកណា បានក្ដៅក្រហាយនោះឡើយ ហេតុនេះឯង បានជាវេលាដែលព្រះអង្គនឹងលះលោកមួយទៅ សាងសន្សំព្រះបារមីក្នុងលោកឯទៀតនោះ ព្រះអង្គតែងតែមានសតិជួនជុំ គ្មានអ្វីប៉ះពាល់ធ្វើឲ្យខ្វល់ក្នុងព្រះទ័យបាន បានជាព្រះអង្គមានសេចក្ដីចាំម៉ាំមួនបានដោយងាយ ហេតុនេះបានជាថា មិនគួរទៅសង្ស័យ ក្នុងរឿងដែលថាព្រះពុទ្ធជាម្ចាស់មិនអាចរំឭកជាតិជាច្រើនបាននោះសោះ គួរតែជឿថាព្រះអង្គរំឭកជាតិបានជាពិតប្រាកដណាស់ ។

តាមសេចក្ដីអធិប្បាយ របស់ព្រះពុទ្ធឃោសាចារ្យថា បុព្វេនិវាសានុស្សតិញ្ញាណ លោកសំដៅដល់សេចក្ដីរំឭកជាតិដ៏កន្លងមកជាច្រើនជាតិ មុននឹងមកកើតក្នុងជាតិនេះ ។ ឯវិធីដែលលោកអធិប្បាយទុកនោះគួរឲ្យជ្រះថ្លា ព្រោះជាការបង្ហាត់សេចក្ដីចាំថយក្រោយជាជាន់ៗ តទៅ ។ លោកអធិប្បាយទុកថា ក្នុងជាន់ដំបូង ត្រូវចូលឈាន ៤ ដោយលំដាប់ កាលណាចេញពីឈានទាំង ៤ ហើយ ឲ្យរំឭកនឹកដល់ការដែលបានធ្វើ

មកហើយនោះ នឹកថយក្រោយទៅទាល់តែដល់ការដែលបានកើតក្នុងវេលាព្រឹកព្រហាម រួចនឹកតទៅការផ្សេងៗដែលបានកើតក្នុងបច្ឆិមយាម ក្នុងមជ្ឈិមយាម ហូតទៅដល់ ២ ថ្ងៃ ៤ ថ្ងៃ ១០ ថ្ងៃ រួចដល់ ១ ខែ ១ ឆ្នាំ ១០ ឆ្នាំ ២០ ឆ្នាំ ទាល់តែដល់វេលាកើត បើជាប់ត្រង់ណា ត្រូវចូលឈានទៀតវិញ (ដើម្បីធ្វើឲ្យចិត្តជាថ្មីផង សម្រាប់ឲ្យរំឭកបាន) រួចនឹករំឭកៗទៅ ទាល់តែដល់គតិដែលកន្លងមកហើយ ។

## វិជ្ជាប្រការទី ៣

### ទិព្វចក្ខុ

ទិព្វចក្ខុនេះជាវិជ្ជាធំបំផុត ហើយជាទីសំគាល់ដ៏សំខាន់ក្នុងសៀវភៅនេះ បានជារៀបរាប់ឲ្យពិស្ដារជាងវិជ្ជាឯទៀតបន្តិច ។

កាលសម្បាតបរិច្ឆេទទី ២ ពោលជានិទ្ទេសទុកក្នុងវិជ្ជាទី ៣ ឲ្យឈ្មោះជាចុតូបបាតញាណ គឺមានចក្ខុទិព្វបរិសុទ្ធលើសចក្ខុមនុស្សសាមញ្ញ មើលឃើញពពួកសត្វកំពុងចុតិ កំពុងកើត ជាសត្វថោកទាប ឧត្តម មានពណ៌សម្បុរស្រស់ មិនស្រស់ ទីដ៏មានសេចក្ដីសុខឬទុក្ខក៏មិនមាន ហើយដឹងឃើញច្បាស់នូវពួកទាំងនោះអន្ទោលទៅតាមកម្ម ។ សម្ដេចព្រះមហាសមណៈ ទ្រង់ប្រៀបប្រដូចនូវការដឹងសាតាររបស់មនុស្សនេះ រួចទ្រង់អធិប្បាយតទៅថា "ដែលប្រាកដដល់សត្វលោកើត



www.elibraryofcambodia.org

វិលស្លាប់នោះ ដូចគ្នានឹងបុព្វេនិវាសានុស្សតិញ្ញាណ ព្រោះពួខកាប និទ្ទេស ដែលព្រោះពួខ្លួនគតិនៃសត្វទាំងនោះផង មើលទៅសំដែងនោះ មិនមែនតែត្រឹមវិលកើតវិលស្លាប់ដែលជាគតិធម្មតានោះទេ សេចក្តីជា ប្រព្រឹត្តទៅដោយអំណាចកម្ម ក៏ជាគតិនៃធម្មតាដូចគ្នាដែរ ៗ ញាណ នេះលោកពោលថា កំចាត់មោហៈដែលកំបាំងកម្មស្សកតា ទីងពោល ថាកំចាត់នូវមោហៈ ដែលជាហេតុជឿប្រកាន់ដោយគ្មានហេតុ ដូចជា សីលព្វតបរាមាសនឹងមិច្ឆាទិដ្ឋិក៏បាន ចាត់ជាអត្ថនៃព្រះសព្វញ្ញុត-ញាណក៏គួរដែរ ៗ

បណ្តាអវយវៈទាំងអស់ ភ្នែកជារបស់សំខាន់ជាងអវយវៈឯទៀត គឺ ប្រើបានជាប្រយោជន៍ច្រើនជាងអវយវៈដែលមាននៅក្នុងកាយយើងហើយ ជារបស់សំរាប់សំដែងឲ្យឃើញនិស្ស័យ ចិត្តថ្លើមនិងសេចក្តីប្រព្រឹត្តរបស់ មនុស្សជាគ្រឿងដ៏ប្រសើរ ដែលមនុស្សត្រូវការប្រើបាន មិនត្រឹម តែកិច្ចការដែលប្រចាំថ្ងៃនោះទេ ជាគ្រឿងជួយឲ្យសំរេចសេចក្តីបំណង ក្នុងការផ្សេង ៗ បានច្រើនយ៉ាងទៀត ៗ

យើងដឹងថាភ្នែករបស់យើងកល្លាមាន ៣ ពណ៌ ៗ សនៅជុំវិញ ខាងក្រៅរួចពណ៌ស្ករ ឬពណ៌ស្ទើរខ្មៅ ភ្នែកបាក់ងជាពណ៌ស្ករខ្ចី ឬពណ៌ ផ្ទៃមេឃក៏ថាបាន ដែលជាប្រយោជន៍ហើយជាសំខាន់បំផុត គឺចុចខ្មៅ



www.elibraryofcambodia.org

ទៅកណ្ដាលប្រស្រីភ្នែកដែលយើងហៅថាកែវភ្នែក ឯត្រង់ដុំវិញនោះទុក
ជាត្រូវប្រួសផល់ចេញឈាមក៏មិនខ្វាក់ បើត្រូវប្រួសបន្តិចបន្តួចត្រង់កែវ
ភ្នែកហើយក៏អាចខ្វាក់បាន បានជាធម្មជាតិបង្កើតឲ្យមានរោមភ្នែកមក
ជាមួយសម្រាប់ការពារវេលាមានអ្វីមកប៉ះពាល់ ទើបប៉ះរោមភ្នែកជាមុន
ភ្នែកក៏ដឹងបិទប្រិចឲ្យរួចពីត្រូវប្រួសបាន ក៏ដោយសាររោមភ្នែកជួយការពារ
ដែលថាភ្នែកជាប្រយោជន៍របស់កាយជាច្រើនបំផុតនោះ គឺព្រោះភ្នែក
ជាគ្រឿងសំរាប់មើល គេចចំពោះរបស់ដែលទាំងពួងមកការពារខ្លួនបាន
មនុស្សរួចផុតពីការព្រោះក្ដីជាមនុស្សភ្នែកជាច្រើន ។ បើដូចមនុស្ស
ភ្នែកខ្វាក់ពីកំណើត មិនស្គាល់រូបអ្វីមួយមកតាំងពីកើតនោះដូច
ម្ដេចនោះ គ្រាន់តែដឹងសណ្ឋានដូចជាដឹងរូបសណ្ឋាន គោ, ក្របី, ដំរី
សេះ, ដោយមានមនុស្សប្រាប់ឲ្យស្ដាប់ មិនអាចដឹងដល់ពណ៌ទៀត ស
ក្រហមរបស់សត្វទាំងនោះដូចម្ដេចឡើយ ព្រោះគ្មានអ្នកប្រាជ្ញណាមួយ
ក្នុងលោកនេះដឹងអធិប្បាយឲ្យមនុស្សភ្នែកខ្វាក់ពីកំណើត ស្គាល់លក្ខណៈ
ពណ៌ទាំងនោះបាន ហេតុដូច្នេះមនុស្សខ្វាក់នោះក៏នឹងចូលចិត្តថា សម្បុរ
ពណ៌ក៏ដូចជារូបសត្វទាំងនោះដែរ ឬមួយវិញទៀត គ្រាន់តែដឹងថាភ្លើង
ជារបស់ក្ដៅ, ដីជារបស់រឹង, ទឹកជារបស់ត្រជាក់ តែមិនស្គាល់រូបសម្បុរ
របស់ធាតុទាំងនោះជាយ៉ាងណា ពុំបានឡើយ ហេតុនេះឯងបានជាថា

មនុស្សខ្វាក់ពីកំណើត ទុកជាមនុស្សមានគ្រោះធ្ងន់បំផុត ព្រោះខាតផ្លូវចេះដឹងក្នុងលោកនេះពាក់កណ្ដាល ឬក៏ច្រើនជាងពាក់កណ្ដាលក៏មាន ។

ដែលជាភ្នែកជាគ្រឿងសំដែងឲ្យស្គាល់ឃើញនិស្ស័យ ចិត្តថ្លើមនិងសេចក្ដីប្រព្រឹត្តនិងលក្ខណៈផ្សេងៗរបស់មនុស្សនោះ គឺថាបើយើងសង្កេតមើលឲ្យល្អហើយ នឹងឃើញថាភ្នែកមនុស្សម្នាក់ៗខុសគ្នាជាច្រើន ដែលជាសំខាន់បំផុតគឺចុចកណ្ដាលដែលហៅថាកែវភ្នែក មនុស្សខ្លះច្រើនមានកែវភ្នែកធំ មនុស្សល្ងង់កែវភ្នែកច្រើនតូច មនុស្សដែលអាចពង្រីកកែវភ្នែកឲ្យធំ ឬក៏ឲ្យតូចបាននោះ ជាអ្នកមានលក្ខណៈអត់ធ្មត់មាំមួន ជាមនុស្សមានសេចក្ដីព្យាយាមឧស្សាហ៍ មិនញញើតខ្លាចសេចក្ដីលំបាក ហើយមិនខ្លាចក្រែងអ្នកណា ។ អាចប្រើមនោមយិទ្ធិយ៉ាងងាយ ឬយ៉ាងកណ្ដាល ជាគ្រឿងបង្គាប់មនុស្សដែលនៅក្នុងអំណាច ឲ្យជឿស្ដាប់បានដោយងាយ ៗ មនុស្សដែលមិនហ៊ានមើលភ្នែកគេត្រង់ៗ កំពុងនិយាយនោះ ជាមនុស្សមាននិស្ស័យទន់ខ្លាច ធ្វើអ្វីមិនប្រាកដ បើមិនដូច្នោះទេ ក៏ជាមនុស្សស្លូតតែចិត្តវៀច គង់មានសេចក្ដីខុសអ្វីជាប់នឹងខ្លួន ។

ហេតុនេះ បានជាបារាំងគេប្រកាន់យ៉ាងមាំមួន ថាកាលណាចាប់ដៃគ្នា ឬធ្វើសេចក្ដីគោរពគ្នាទៅវិញទៅមក ត្រូវតែមើលភ្នែកគ្នាផងកប បើមិនធ្វើដូច្នេះទេ គេប្រកាន់ថាជាកិរិយាថោកទាបបំផុត ។ វេលានិយាយនឹង



www.elibraryofcambodia.org

អ្នកមានបណ្ណាស័ក្តិធំ ឬស្តាប់លោកនិយាយត្រូវមើលភ្នែកលោក បើដាក់ភ្នែកសញ្ចប់សញ្ចឹងមើលខាងក្រោម មិនសំឡឹងមើលមាត់លោកនិយាយ ឬក៏មើលទៅឯទៀត ក៏ចាត់ជាអគារវៈ មិនជាទីគោរព ។ បើជាទាហាន ទទួលបញ្ជាបង្គាប់ទុកជាស្រេចជា ក្នុងវេលាធ្វើការគោរពត្រូវមើលភ្នែកអ្នកធំជាងខ្លួន អ្នកណាដែលក្រឡេកមើលនេះមើលណោះ ទុកជាមនុស្សមិនមាំមួន គង់មានរឿងអ្វីៗ ដែលប្រព្រឹត្តមិនល្អលាក់ទុកក្នុងខ្លួន ព្រោះហេតុនេះឯងភ្នែកជាគ្រឿងសំដែងឲ្យឃើញចិត្តរបស់មនុស្ស ដែលធ្វើខុសចង់លាក់ជាស្ងៀម ៗ ។ កាលណាយើងចូលទៅរកលោកអ្នកមានបណ្ណាស័ក្តិធំ ៗ យើងគង់ឃើញភ្នែកលោកសំឡឹងមើលត្រង់មកភ្នែកយើង យើងត្រូវឲ្យដឹងថាដែលលោកសំឡឹងមកយើងនោះ លោកមិនសំឡឹងមើលដោយឥតប្រយោជន៍ទេ លោកព្យាយាមមើលនិស្ស័យចិត្តឬមួយទឹកសេចក្តីចំណង់របស់យើងក្នុងវេលានោះផង ។ ព្រោះហេតុនេះឯង បានជាក្នុងវេលាកំពុងនិយាយការអ្វីៗ នឹងលោក លោកអាចស្គាល់និយាយប្រាប់ឲ្យត្រូវទីនចិត្តយើង ដែលយើងបំរុងនឹងនិយាយតទៅទៀតនោះ មកតែពីភ្នែកយើង ជាគ្រឿងសំដែងឲ្យលោកឃើញពីសេចក្តីនិយាយល្អអាក្រក់ ពិតឬមិនពិត ល្ងង់ខ្លៅឆ្លាតមិនឆ្លាត យ៉ាងណាៗបាន ។ សេចក្តីខុសត្រូវអាចលាក់ទុកក្នុងចិត្តយ៉ាងជ្រៅៗ បាន តែភ្នែកនោះ



www.elibraryofcambodia.org

នឹងនាំយកសេចក្ដីដែលលាក់ទុកនោះមកបង្ហាញឲ្យគេដឹង ៗ ដូច្នេះបាន ជាមនុស្សបរិសុទ្ធប្រាសចាកមន្ទិលក្នុងខ្លួន មិនខ្វល់ញាប់ញ័រខ្លាច ក្នុងការ ដែលនឹងសំឡឹងមើលភ្នែកមនុស្សដោយត្រង់នោះសោះ ។

តាមសេចក្ដីអធិប្បាយ ក្នុងមនោមយិទ្ធិ ដែលមានមកហើយខាង ដើមនោះ ជាក្រសែគំនិតរបស់មនុស្ស ផ្សាយចេញចាកមនុស្សទៅបាន ច្រើនផង បានជាអ្នកប្រាជ្ញក្នុងវិជ្ជានេះប្រកាន់ដូចគ្នាថា ក្រសែទាំងនោះ ចេញតាមភ្នែកជាច្រើនបំផុត បានជាមនុស្សយើងប្រើភ្នែកជាគ្រឿងដ៏ សំខាន់ ក្នុងការផ្សាយមនោមយិទ្ធិរបស់ខ្លួន តាមដែលបានសង្កេតមើល ក្នុងទីប្រជុំធំៗ ដែលនានាប្រទេសក្នុងលោក បញ្ជូនបន្ទូរទៅនិយាយការ ជំនួសនោះ ឃើញបណ្ដាលោកដែលមានកេរ្តិ៍ឈ្មោះជាបន្ទូរខ្លាំងបំផុត ក្នុងលោកវេលានិយាយក្នុងទីប្រជុំ ភ្នែកលោកមិនមើលទៅទីណាឡើយ សំឡឹងមើលទៅតែអ្នកស្ដាប់ដូចជាគេខ្វេះយកទូវដួងចិត្តរបស់អ្នកស្ដាប់មក ញាំញីបង្គាប់ឲ្យជឿតាមដែលលោកនិយាយនោះ ឯពួកដែលគ្មានឈ្មោះ ល្បីល្បាញខាងនិយាយការអ្វីឲ្យល្អជាវិសេសនោះ វេលានិយាយច្រើន ងើយមើលពិតានមើលសំបុត្រឬមើលបាតដៃរបស់ខ្លួន សំដីរបស់ពួកនេះ ទុកជានិយាយខ្លាំងបំផុត ក៏គ្មានទំងន់ល្មមធ្វើឲ្យមនុស្សជឿបានជាច្រើន ដែរ បើយើងព្យាយាមសង្កេតមើលភ្នែករបស់លោកដែលមានអំណាច ក៏សមា នឹងឃើញចុចកណ្ដាលប្រស្រីភ្នែករបស់លោក ធ្វើឲ្យធំឬតូចបាន

តាមហេតុការណ៍ដែលនិយាយនោះ បើគ្មានពេលនិយាយសប្បាយពីកាយ ទិដ្ឋភាពលោកទើបឃើញចំណុចគន្លងលោកតូច តែដល់និយាយការប្រមាទ បន្ទាប់ពីអស់ការទីដ៏ឃើញចំណុចនោះរីកធំឡើង បើកំពុងវិលផងទៀត ចំណុចនោះក៏កាន់តែរីកធំបំផុតទៅទៀត ដល់តែពណ៌តែប្លែកមែនជុំវិញនោះតិចទៅ ៗ ពួកសត្វក៏ដែលល្បើកកោះកូនចុះរូប ដែលមានរង្វង់ខ្មៅកណ្ដាល ពណ៌ផ្សេងរបស់វត្ថុទាំងនោះ ដល់ពេលនិយាយអធិប្បាយរឿងក៏សំខាន់ៗ ពិតឃើញតែប្លែកខ្មៅទាំងអស់ពណ៌ផ្សេងដែលនៅជុំវិញនោះគឺបាត់ទៅ នៅសល់តែពណ៌ខ្មៅកណ្ដាលទីងសជុំវិញ ៗ ហេតុទាំងនេះបានពីរតួនេសចក្តីប្រាជ្ញាទាំង ក្រោយបោយយកមុំនោះផ្សាយចេញបកកាយតែកម្លាំងខ្លាំងបំផុត ដោយនិយាយអធិប្បាយសេចក្តី ចង់ឲ្យកុលាការជឿជាក់របស់ខ្លួនហាក់ត្រូវកញ្ចក់ល្អជាងគួរតែ អ្នកដែលអំណានការនេះ ពេលដែលត្រូវការនិយាយឲ្យពួកសហជីព កុំវង្វេងការតាំងពេល ឲ្យយល់ឃើញត្រឹមតាមសេចក្តីគិតរបស់ខ្លួននោះ ត្រូវប្រើអណ្ដាតរបស់ខ្លួនជាដាវយ៉ាងមុត កាប់ត្បិតសេចក្តីយល់របស់អ្នកស្ដាប់ ឲ្យរលំដួលព្រមយល់តាមខ្លួននិយាយ ដែលជាការបានប្រយោជន៍ ហើយឲ្យមានរបៀបដល់ប្រទេសរបស់ខ្លួនផងនោះក៏ ៗ អ្នកដែលគ្រប់គ្រងមនុស្សច្រើន ដូចជាបេក្ខជនដែលព្យាយាមបញ្ចុះបញ្ចូលឲ្យមនុស្សបោះឆ្នោតជាមាន

ចំនួនកប់ការ កំពុងពោះបង់ពេលការទៅនោះ ឲ្យត្រឡប់ចូលមកធ្វើការវិញក្តី ពួកទាំងនេះបានប្រើភ្នែក ជាគ្រឿងដ៏ប្រសើរសំខាន់ក្រៃលែងជាងសព្វគ្រប់ទៀត តាមដែលពួកនិយាយថា មនុស្សដែលប្រទះនឹងទុក្ខពាល់ប្រកកក់ទៅណាពុំបាន បានសំឡឹងមើលភ្នែកក៏មិនបើប្រើភ្នែកអាចធ្វើឲ្យខ្វាក់ទៀសចេញ មិនហ៊ានធ្វើអ្វីបាននោះ គួរជឿថាបានប្រាកដមែន ។

តាមដែលពណ៌នាមកនេះ គឺពោលអំពីលក្ខណៈនឹងគុណប្រយោជន៍របស់ភ្នែកមនុស្សប្រក្រតី មិនទាន់ចូលក្នុងគោលទិព្វចក្ខុ ការណាយពិតនោះ រឿងនេះគួរពណ៌នាទុកក្នុងបរោបរម្យ ព្រោះជាគោលទុកក្នុងនេះ សង្ឃនេះនឹងបានបរិយាយរបស់លក្ខណៈភ្នែកចិត្ត ដែលបានឈ្មោះហៅថា "ទិព្វចក្ខុ" ជាក្រសំខាន់ក្នុងសៀវភៅនេះតទៅ ។

ទិព្វចក្ខុនេះត្រូវនឹងបារាំងហៅថា (Clairvoyance) តែបារាំងរួមយកញាណទាំង ៣ គឺអតីតំសញ្ញាណ ញាណក្នុងចំណែកអតីត អនាគតំ-សញ្ញាណ ញាណក្នុងអនាគតនឹងបច្ចុប្បន្នំសញ្ញាណ ញាណក្នុងបច្ចុប្បន្នទាំង ៣ ប្រការនេះនៅក្នុងចំណោមទិព្វចក្ខុ បើតាមទិដ្ឋិរបស់បារាំងមើលទៅសំដៅដល់ការ ឃើញក្នុងហួសចក្ខុរបស់មនុស្សធម្មតា ដូចដែលមានពោលមកពីដើម ជាមើលធ្លុះកំផែងធ្លុះដី ។ល។ (Clairvoyance) បើបារាំងយកមកប្រៀបគ្នាហើយ ក៏នឹងធ្លុះតាមគន្លងជាមួយបាន គឺថាបើ



www.elibraryofcambodia.org

ការមើលឃើញ សត្វក៏ពុំពិតបានហើយ មិនគួរសង្ស័យនឹងការដែលជាការមើលឃើញ អតីត អនាគត បានយ៉ាងច្បាស់ល្អនោះឡើយ ដោយហេតុនេះបានជាជាការដែលទទឹងអធិប្បាយដល់ចិត្តចក្ខុនោះ នឹងបានពាំយកគំនិតរបស់បាកុង នឹងគោលគំនិតទេសរបស់យើងមករួមគ្នា ឲ្យលោកអ្នកមើលវិនិច្ឆ័យប្រៀបធៀបតាំងពីផ្ទើមមើល ៗ

វិទ្យាសម្រាប់ដឹងអតីតនិងទំនាយទៅអនាគតបាននោះ ជារបស់បានផ្សាយមកក្នុងលោក មនុស្សបានចេះដឹងមកក្នុងលោកជាច្រើនបំផុត គឺហោរាសាស្ត្រ គោលគឺលទ្ធិដែលប្រកាន់ថា មនុស្សយើងកើតមកនៅក្រោមអានុភាពរបស់ផ្កាយតាំងឡាយ នឹងបានល្អឬអាក្រក់ដោយប្រការយ៉ាងណាក៏ស្រេចហើយតែផ្កាយជាដើមហេតុ ៗ មានន័យមួយទៀតប្រកាន់ថា មនុស្សយើងកើតមកមានបការិតរបស់ព្រះនៅខាងលើបំផុត ត្រាទំនាយទុកមកហើយនឹងបានល្អ អាក្រក់យ៉ាងណា តែងទៅតាមបកាសិតនោះ ៗ លទ្ធិដែលពណ៌នាមកខាងដើមនោះ មានមូលជាសេចក្ដីពិតប្រាកដជាច្រើន បានជាមានអ្នករៀន ចំឡងជាតម្រាក្បួនផ្សាយចេញទៅគ្រប់ប្រទេស ព្រោះសេចក្ដីនិយមមិនទាន់សាបសូន្យ បានជាមានបករល់ផ្សេងៗនេះ ៗ រឿងនេះយើងល្បងពិចារណាមើលលទ្ធិនេះមានខ្លះដែលមិនស្រួល គួរឲ្យសង្ស័យពេកដោយហេតុបញ្ហាយ៉ាងណាខ្លះ ៗ តាមសេចក្ដីបកពេញពោះប្រុះណ៎;

១— មានខែដែលមិនស្រួលច្រើន គឺត្រូវឲ្យបានថ្ងៃខែឆ្នាំនិងពេលវេលា ដែលកើតឲ្យត្រឹមត្រូវប្រាកដជាបំផុត ទើបគន់គូរទំនាយត្រឹមត្រូវបាន ហេតុនេះបានជាមនុស្សក្នុងលោកនេះ មួយសែននាក់មានប្រហែលមួយនាក់ ដែលអាចដឹងច្បាស់ពេលវេលាកំណើតរបស់ខ្លួនជាប្រាកដបាន នោះ បើមនុស្សដែលនៅឆ្ងាយ ផុតពីស្រុកកំណើតបាត់ញាតិញាប ហើយគ្មានទាំងនាឡិកាដែលដើរត្រឹមត្រូវទៀត ក៏មិនអាចដឹងពេលវេលាដែលខ្លួនកើតឲ្យបានត្រឹមត្រូវឡើយ បានជាអ្នកចេះវិជ្ជាហោរាសាស្ត្រ ជាការដែលទាយខុសនោះមកពីពេលវេលាកើតមិនទៀងត្រឹមត្រូវប្រាកដ(១) ។

២— គួរសង្ស័យនោះ គឺមនុស្សដែលកើតមក បានជាស្តេចសោយរាជសម្បត្តិ ឬជាមហាសេដ្ឋី ហើយមានមនុស្សដែលកើតក្នុងពេលវេលា ឆ្នាំ ខែ ថ្ងៃ ដូចគ្នា ឬក៏ពេលវេលានាទីប្រកិតគ្នា ល្មមនៅក្នុងពេលចំណាយជាមួយគ្នាបាន តើមនុស្សនោះនឹងបានជាស្តេចសោយរាជ្យ ឬជាមហាសេដ្ឋីទៅទាំងអស់បានឬទេ(២) ។

---

១ មានគេអធិប្បាយថា អាចយករូបពណ៌សម្បុររបស់បុគ្គលមកជាគ្រឿងត្រួតមើលឲ្យដឹងវេលាកើតខុសឬត្រូវបាន ។ ២ មានអ្នកដែលបានមើលសៀវភៅវិជ្ជា ៨ ប្រការដែលលោះពុទ្ធគ្រាមុនអធិប្បាយថាថ្ងៃកំណើតតែប៉ុណ្ណោះ នឹងធ្វើឲ្យមនុស្សល្អប្លែកពុំបាន ពោលយកហ៊ឹងរបៀងមកប្រកបជាមួយប្រផ្លិតនូវស្មៅដុះលើភ្នំ ទុកជាប្លែកមេត្តា កំពស់ខ្ពស់ជាងដើមត្នោត ដែលដុះតាមជើងភ្នំដែរ ។

៣ — មនុស្សដែលមានអំណាចស័ក្តិធំខ្ពស់បំផុត ដែលមានឈ្មោះក្នុងកិត្តិការរបស់លោក ដូចជា ណាប៉ូឡេអុង, សេសារ, ការឡូក-សត្រីមហាកាដ ទាំងនេះ ជួនជាល្អប្រសើរឬទេ?

៤ — មនុស្សដែលថាជា ជួនជាការរបស់ខ្លួនអាក្រក់ហើយព្យាយាមប្រព្រឹត្តតែសេចក្ដីល្អ មិនព្រមធ្វើអំពើសេចក្ដីអាក្រក់ ដូច្នេះគេនឹងមានទុក្ខសោកពុំល្អខ្លះដែរឬទេ? ឬមនុស្សដែលជឿច្បាស់ថា ជួនជាការរបស់ខ្លួនល្អ តែប្រហែសខ្លួនមិនធ្វើការល្អសោះ ប្រព្រឹត្តជាមនុស្សពាលទៅនោះ តើនឹងបានល្អដូចជួនជាការនោះដែរឬទេ?

៥ — លទ្ធិដែលប្រកាន់ថា មនុស្សយើងកើតមក មានបកាសិតរបស់ព្រះអាទិទេពបំផុត ព្រោះទំនាយទុកមកនោះ នឹងថាត្រូវខុសក៏តាមចុះ តែលទ្ធិបែបនេះមើលទៅមិនសូវល្អ ព្រោះនឹងនាំឲ្យមនុស្សខ្ជិលមិនចង់ធ្វើការងារ ដោយគិតឃើញថាទុកជាធ្វើទៅក៏មិនបានជាល្អ ព្រោះជួនជាទំនាយថាអាក្រក់ ឬក៏នឹងទៀត ហោរទាយថាល្អ ក៏ទុកជាលាភផលទាំងពួងនឹងមកឯង ៗ មិនចាំបាច់ធ្វើការអ្វីទៀយ ៗ ក្នុងលោកនេះ យើងគន់ប្រទះឃើញ មានមនុស្សជាច្រើនដែលខ្ជិលជាប្រក្រតីមិនធ្វើការគេស៊ីអ្វី ដើរតែបន់ស្រន់អ្នកតា នឹងគេហោរទាយឲ្យ បើព្រំទំនាយទាយថានឹងមានបុណ្យធ្មនឹងមានលាភ ក៏ត្រឡប់បកផ្ទះចាំតែឃ្លានចាំបុណ្យនឹងលាភ មិនធ្វើការអ្វី បើឃ្លានណាស់យកទ្រព្យគេនោះ រង់ចាំពេល

វេលាដោតលាភ តាមទំនាយដែលជាមឹងហោមកនោះ ចាំទៅមិនឃើញមានបានអ្វី ក៏ជេរប្រទេចផ្ដាសាអ្នកតាំងហោរជាកុហក ឬក៏ខឹងកើតកាយ ឃើញទៅជាមានមនុស្សឈ្នះមិន បានជាប៉ុនបានលោក ក៏កើតចិត្តវិបល្លាស គិតស្ទួនគេលោកអោយប៉ិនប្រែកបមិនធម៌បំពៃ អកុសលក៏តាមបង្កើតឲ្យផលទៅជាកក្រោកទុក្ខមិនចំណាយ ។

តាមដែលពណ៌នាមកទាំង ៤ ប្រការនេះ មិនមែនបើសង្ស័យដោយមិនចង់ជឿលទ្ធិហោរដែលមនុស្សគ្រងលោកបានកាប់កេនមកយូរហើយនោះទេ វិជ្ជាហោរគួរជឿណាស់ ព្រោះមានខ្លះទំនាយតាមត្រូវជាច្រើន តែតាមប្រក្រតីត្រូវលើមនុស្សយ៉ាងកណ្ដាល គឺមនុស្សដែលមានព្យាយាមធម្មតា មានសេចក្ដីប្រព្រឹត្តល្អគួរសម គ្មានចិត្តទុច្ចរិតកង់ខ្ទង់ មិនបានធ្វើសេចក្ដីល្អដ៏វិសេសអ្វីឲ្យបានច្រើនផង ទំនាយច្រើនត្រូវមនុស្សបែបនេះ ព្រោះមនុស្សយើង. គង់មានថ្ងៃខណាមួយដែលប្រែប្រួលនិស្ស័យចិត្ត ប្រព្រឹត្តឲ្យល្អឡើង ឬក៏អាក្រក់ទៅក៏មានជាច្រើន ៗ បានជាបកាសិតរបស់ព្រះទាំងលើបំផុតនោះ បើមានពិតប្រាកដមែន គេនឹងប្រែប្រួលបានទៅខ្លះដែរឬទេ (១)។

---

១ មានលោកម្នាក់ថា ហោរាសាស្ត្រ មិនមែនជាលទ្ធិដែលប្រកាន់បកាសិតខាងលើនោះទេ ការដែលហោរទាយនោះ ជាការចង្អុលផ្លូវឲ្យដើរតាមផ្លូវ ស្រេចនៅម្ចាស់របស់ដួងជាតា រើសដើរតាមផ្លូវល្អឬអាក្រក់ ស្រេចនៅតែនឹងខ្លួនគិតចុះ ។

វិជ្ជានឹងគិតទំនាយទាយទៅអនាគតនេះ ជាវិជ្ជាគួរឲ្យយមណាស់ បើបុគ្គលយើងចេះប្រើនូវវិជ្ជាមួយនេះ ដល់ទៅប្រើការបានជាពិតប្រាកដហើយ គឺកេពចិត្តផ្ញើប្រយោជន៍ឲ្យលោកបានជាច្រើនណាស់ ដោយហេតុនេះខ្ញុំព្យាយាមអធិប្បាយតាមគោលរបស់ទិព្វចក្ខុលក្ខណ៍មើល ដើម្បីបើកផ្លូវជូនលោកអ្នកមើលសៀវភៅ ត្រិះរិះគិតស្រាវជ្រាវតទៅ សេចក្តីដែលខ្ញុំអធិប្បាយនេះ មិនបានគិតសង្កត់សង្កិនវិជ្ជាហោរាសាស្ត្រឬក៏ខ្ញុំគិតលើកយកមួយសេចក្តីដែលខ្ញុំពោលតទៅនេះ ថាខ្ពង់ខ្ពស់លើសវិជ្ជាហោរាទេ ត្រាន់តែអធិប្បាយទុកជូនលោកអ្នកមើលពិនិត្យកាត់សេចក្តីដោយខ្លួនឯងតែប៉ុណ្ណោះ ។

តាមគន្លងវិជ្ជាទិព្វចក្ខុ (clairvoyance) របស់ពាក់ឥន្ទយោគីគេមានគោលថា:

១) របស់អ្វីដែលបានមកពីអតីតហើយនោះ គង់មានពេលស្នាមលំអានទុកឲ្យគន្លងបច្ចុប្បន្ននេះដឹងបានជាដរាប ។

២) របស់អ្វីដែលនឹងមានមកក្នុងកាលខាងមុខ ច្រើនមានជាស្រមោលមកឲ្យឃើញជាមុន ឬមានក្រសែមកឲ្យដឹងជាមុន ។

៣) របស់អ្វីកំពុងកើត ច្រើនមានជាស្រមោលឲ្យឃើញមានការក្នុងមួយអន្លើទៀត ។

ហេតុនេះឯង បានជាមានសេចក្ដីអធិប្បាយពីគោលតាំង ៣ ប្រការទុក ដូចមានតទៅ:

១ — ដែលថារបស់អ្វីបានមានពីអតីតមកហើយ គង់ហោលស្លាបទុកឲ្យក្នុងបច្ចុប្បន្នដឹងបាននោះ គឺថាមនុស្សពីបុរាណគ្រប់គ្នាដែលបានប្រុង របស់ចាស់ៗ ហើយមានបរោគតិ ឃើញហេតុការណ៍ដែលកើតមកក្នុងគ្រានោះៗ យើងមើលបុគ្គលណាក្នុងគ្រួចាស់ៗ ដែលកោលមកនៅក្នុងផ្ទះ ហើយនោះ យើងគង់មានបេកសិកពេកឃើញឬបោះពុម្ព ពីជីវិតឧទិការ ដែលកន្លងទៅហើយរបស់មនុស្សក្នុងសម័យនោះ អ្នកដែលគេបេះស្លឹក ក្នុងវិជ្ជានេះគេត្រូវតែរើសយកដុំគ្រួសឬដុំថ្មមួយដុំពីស្ពានបុគ្គល មក កាប់ទុកក្នុងដៃ ហើយអាចប្រាប់ថារបស់ទាំងនោះ មានមកហើយក្នុងសម័យនោះៗបាន ដោយគ្រួសដែលជាប់នូវគុណនោះមកប៉ះពាល់ដៃមនុស្សដែលរេះវិជ្ជានេះ ឲ្យមានជាសម្ពស្សផលកាយៗ អាចកយការគេ ទៅចិត្តឲ្យដឹងជារឿងទៀងបានមួយពេលៗ

២ — ត្រង់ថារបស់អ្វីដែលនឹងមានមកដល់អនាគត ទើបមានជាស្រមោលមកមុន ឬមានជាគ្រួសមកឲ្យដឹងជាមុននោះ គេប្រៀបសេចក្ដីដូចជាកញ្ចាល់ធំៗដែលកំពុងបើកទៅ តែងតែមានលេកក្នុងទឹកជាត់ទៅមុនមុខកញ្ចាល់ដកប ពួកដែលគេស៊ីចាប់ត្រីក្នុងសមុទ្រតែងតែដឹងហេតុជាមុន



www.elibraryofcambodia.org

ប្រឹងខ្ទាត់ ឬប្រើកដៃឲ្យទាត់ កូនសេណាដែលមានក្រិតមក ដោយឃើញលោកបាក់ខុសពីប្រក្រតី ហេតុការណ៍ទាំងឡាយកូនសេណាកនេះ កែងកែមានកំឡាំងពីធម្មតាចំរាស់ ច្រើនជាងក្រទីងគប៉ាល់ទាំងនោះ តាមប្រក្រតីក្នុងសេរីងបើលមិនឃើញថា កូនកាកាសដែលស្រឡះ ទូកកំយត្តាយល្បីងល្បើយហួសក្នុងសេរីងនោះមានអ្វីទៅវុះ បើប្រសិនជាសេរីងមានក្នុងបែបប្លួចជាចិត្តបក្សហើយ សើងក៏ទីងមើលឃើញហេតុការណ៍ឬរបស់ផ្សេងៗ ដែលកណ្ដាលហួសទៅក្នុងចក្រវាឡ ដែលមានរបស់សុទ្ធតែគួរអោយដឹងអោយស្គាល់ណាស់ ៗ

តាមគម្ពីរព្រះពុទ្ធសាសនាយើង ដែលព្រះគន្ធវប្បតាចារ្យលោកពោលទុក ជាទៅតាមគន្លងប់ធម៌ទេសនា របស់ព្រះពុទ្ធជាម្ចាស់ជាច្រើនណាស់ ចាល់តែបញ្ចៀតណែនភ្ជាប់ គេកំបូងឥទ្ធិយស្តាប់គ្មាន ពោធិមិត្តខ្ទង់ឲ្យរួមបុណ្ណូល ប្រជៀតស្តាប់ព្រះធម៌ទេសនា ៗ បើជាសេចក្ដីដែលលោកពារកុសមកនោះ មិនបានពោលតែត្រឹមប៉ុនោះតត់ទេ ហើយបានឃើញក្លួរទៅតាមទាំងនោះ ប្រហែលឃើញដោយផលនៃរឿងចិត្តបក្សមួយនេះដែរឬទេ ?

៣— ត្រង់ដែលជារបស់អ្វីកំពុងធ្វើ តាចមានជាស្រមោលឲ្យឃើញត្រាកដមួយអន្ទុំទៀតបាននោះ បាត់ឲ្យឈ្មោះថា (Deuxième vue)

សេចក្ដីអធិប្បាយរឿងនេះបែបដូចគ្នានឹងរឿងប្រផ្នូលថៃដំ ដែលបានពោលមកហើយខាងដើម បានជាមិនបាច់អធិប្បាយក្នុងរឿងនេះតទៅទៀត ។

រឿងនេះសមាគមស្វែងរកចំណេះវិជ្ជាផ្លូវចិត្ត (Société des recherches psychiques) ដែលតាំងនៅក្រុងឡុនដុន បានឲ្យបែបចុកតាយ៉ាង សម្រាប់ពិសោធត្រង់ប្រការ២ និងប្រការ៣ ដែលយើងខ្ញុំយកមកពិគ្រោះពិចារណាមើល ឲ្យឃើញសេចក្ដីពិតនោះតើកើតត្រឹមណា សុំឲ្យលោកអ្នកមើលជ្រាបជាមុនថា សមាគមនេះបានតាំងមកជាយូរឆ្នាំហើយ សមាជិកនិងកម្មការសុទ្ធតែអ្នកប្រាជ្ញដែលមានកេរ្តិ៍ឈ្មោះក្នុងលោក ៗ ពួកសេដ្ឋីគហបតីឃើញនូវគុណប្រយោជន៍របស់សមាគមនេះ បានជួយចេញប្រាក់ឲ្យជាច្រើន សម្រាប់ទំនុកបំរុងក្នុងការស្រាវជ្រាវវិជ្ជានេះ ដើម្បីផ្សាយក្នុងលោកឲ្យចេះដឹងច្រើនឡើង ដោយហេតុនេះបានជាមុខការរបស់សមាគមនេះ ត្រូវរក្សាកេរ្តិ៍ឈ្មោះ មិនចាំយករឿងផ្ដេសផ្ដាស ប្រាសចាកមូលនៃសេចក្ដីពិត មកពោលបញ្ឆោតមហាជនឡើយ បែបយ៉ាងដែលគេទុកសម្រាប់ឲ្យពិសោធត្រង់ប្រការ ២ នោះមានដូច្នេះថា :

ក្នុងស្រុកអង់គ្លេស មានស្ត្រីម្នាក់ឈ្មោះហ័ខណាហ៍គ្រិន នៅតំបន់ឧកសហ្វ័តឈា ក្នុងប្រទេសអង់គ្លេស មានរបរជាអ្នកស៊ីឈ្នួលបំរើនៅផ្ទះ១ មានយប់មួយដេកយល់សប្តិឃើញថា ខ្លួននៅក្នុងផ្ទះតែម្នាក់ឯង



www.elibraryofcambodia.org

ក្នុងថ្ងៃកេចិត្រ វេលាយប់ បានឮសូរមនុស្សគោះទ្វារ ក៏បើកចេញទៅមើល ហានទោរ ៣ - ៤ ពាក់តែឡូលបកក្នុងផ្ទះ ខ្លួនក៏បានព្យាយាមគោះ ១ មិនល្បះ ក៏ត្រូវរបួសរបស់ចោរដល់សន្លប់ ហើយចោរក៏យកទ្រព្យដែលមានដំឡៃបានទៅជាច្រើន ដល់ព្រឹកឡើងក៏ទៅនិយាយប្រាប់ឲ្យផ្ទះជិតខាងស្ដាប់ តាមហេតុដែលខ្លួនយល់សប្ដិឃើញនោះ ជាខ្លួនបានចាំលក្ខណៈបុរសចាស់រូបកាយចោរទាំងនោះជាប្រាកដផង រួចពីនោះមកជាយូរថ្ងៃក៏ពុំឃើញមានហេតុអ្វី ដល់មកថ្ងៃ ១ ជាថ្ងៃកេចិត្រ ម្ចាស់ផ្ទះនឹងកូនឈ្នួលចេញទៅរស់នៅតែស្ត្រីនោះចាំផ្ទះតែម្នាក់ឯង វេលាពាក់កណ្ដាលអធ្រាត្រ បានឮសូរគោះទ្វារ ស្ត្រីនោះក៏នឹកឃើញដល់សេចក្ដីដែលខ្លួនយល់សប្ដិនោះ ក៏មិនបើកទ្វារ គ្រាន់តែបើលទៅតាមបង្អួច ក៏ឃើញចោរមានចំនួនពីរលក្ខណៈរូបកាយ ត្រូវនឹងសេចក្ដីយល់សប្ដិរបស់ខ្លួនជាទីបំផុត ក៏ស្រែកចោទឡើងឲ្យអ្នកស្រុកជួយ ចោរទាំងនោះក៏រត់ទៅវិញអស់ ។

មានរឿងមួយទៀត ជារឿងល្បីល្បាញ គឺរឿងលោកស្មៀនសើពិយ័រសេហ្វ៊ល ជាសេនាបតីក្រសួងឃ្លាំងប្រទេសអង់គ្លេស ត្រូវមនុស្សលួចសម្លាប់ ។ មុននឹងកើតហេតុជាយូរថ្ងៃ មានមនុស្សម្នាក់ឈ្មោះសន់វីលលើយ៉េម៉្យ ចំលំនៅ ១ ឆ្ងាយពីក្រុងឡុងដង បានឃើញនឹងភ្នែកខ្លួនស្រស់ៗ ដល់ ៣ ដង ដោយមិនបានយល់សប្ដិ ជាឃើញមានមនុស្ស


www.elibraryofcambodia.org

ពាក់អាវពណ៌ខៀវចាស់ អាវកាក់ក្នុងស ចូលទៅសម្លាប់លោកពិរៃយសេ-ក៏ល់ ក្នុងទីបរិវេណប្រជុំសភាកស្ត្រ ក្រុងឡុងដង ។ សង៉ីវិលលើយ៉ម្ស ឃើញបុព្វនិមិត្តគាត់ក្រេកយ៉ាងរបេះរបល់ ៣ ដងជាប់គ្នា ហើយខ្ញុំមិនហ៊ាន សតិ្ឋគេកើតយ៉ាងនេះទេ គឺឃើញមិនត្រូវស្រស់ៗ ជាហេតុឲ្យគប់ផុត ក្នុងលោក ក៏ហាក់ចិត្តមិនសប្បាយ ទៅប្រាប់ក្រុមមិត្រសម្លាញ់ជាច្រើន គិតចូលទៅក្រុងឡុងដង ជំរាបលោកពិរៃយសេក៏ល់ឲ្យជ្រាប មិនបាន រាំងខ្លួន ក៏ត្រូវសម្លាញ់ទាំងនោះ ជាមនុស្សសម័យថ្មី នាំគ្នាសើចចំអក ឲ្យវិលលើយ៉ម្ស ថាទៅជឿតាមនិមិត្តផ្តេសផ្តាសដែលឃើញនោះធ្វើអ្វី ក៏ ឃាត់មិនឲ្យវិលលើយ៉ម្សទៅជំរាបលោកសេក៏ល់ វិលលើយ៉ម្សក៏ខានចូល ទៅក្នុងក្រុងឡុងដង ។ គម្រប់បាន ៧ ថ្ងៃ លោកពិរៃយសេក៏ល់ ក៏ត្រូវមនុស្ស ពាក់អាវពណ៌ខៀវចាស់ អាវកាក់ស បាញ់លោកស្លាប់នៅទីបរិវេណ សភាកស្ត្រក្នុងក្រុងឡុងដង ត្រូវដូចវិលលើយ៉ម្សបានឃើញមុនថ្ងៃកើត ហេតុនោះមែន បើប្រសិនជាគ្នាពួកសម្លាញ់សម័យថ្មី ឃាត់ទាំងហើយ លោកពិរៃយសេក៏ល់ប្រហែលជាមិនស្លាប់ដោយហេតុនេះទេ ទាំងពីររឿង នេះជាបែបយ៉ាងឲ្យឃើញថា ហេតុការណ៍អ្វីដែលនឹងមានឡើង កេចហាន ស្រមោលមកឲ្យឃើញមុន ឯបែបយ៉ាងក្នុងប្រការទី ៣ ដែលជាបេសអ្វី កំពុងធ្វើ អាចមានស្រមោលឲ្យឃើញក្រោកដទៅទីមួយទៀតបាននោះ

ពីហេតុសេចក្ដីដំណាលថា កាលកន្លងមកជាង ៧០ ឆ្នាំហើយនោះ មានអ្នកប្រាជ្ញជាតិស្វីដម្នាក់ឈ្មោះស្វ៊ីដេនបើគ៍ នៅក្នុងក្រុងកោតេនបើគ៍ក្នុងប្រទេសស្វ៊ីដ អ្នកប្រាជ្ញនេះមានផ្ទះមួយកន្លែងទៀត នៅក្រុងស្តុកហុល ពេលមួយថ្ងៃទៅស៊ីលៀងឯផ្ទះសំឡាញ់ជាមួយនឹងគ្នា ១៥ នាក់ កំពុងស៊ីលៀងស្វ៊ីដេនបើគ៍ ចេះតែក្រវល់ក្រវាយ ក្រោកចេញទៅក្រៅបន្ទប់លៀង រួចត្រឡប់ចូលមក មុខស្លុត ស្រែកប្រាប់សំឡាញ់ទាំងនោះថា ភ្លើងកំពុងឆេះផ្ទះក្នុងក្រុងស្តុកហុល ជិតដល់ផ្ទះរបស់ខ្លួនហើយ រួចក៏ត្រឡប់ចេញទៅក្រៅវិញ យូរបន្តិចក៏ត្រឡប់ចូលមកវិញប្រាប់ថា ភ្លើងរលត់ហើយ នៅតែផ្ទះ ៣ ទៀតពីឆេះដល់ផ្ទះរបស់ខ្លួន មនុស្សដែលកំពុងស៊ីលៀងទាំងប៉ុន្មាន ក្នុងវេលានោះក៏ភ្ញាក់ផ្អើល រឿងនេះក៏ខ្ចរខ្ចាយទៅឮយ៉ាងលឿនជារឿងចំឡែក អ្នកជាការក្រុងស្រុកក៏អញ្ជើញស្វ៊ីដេនបើគ៍ទៅពិចារណាសួរតាមហេតុទុក លុះបានពីរថ្ងៃមានដំណឹងតាមកាសែតពីក្រុងស្តុកហុល បរិយាយពីរឿងភ្លើងឆេះដោយពិស្ដារត្រូវតាមហេតុដែលស្វ៊ីដេនបើគ៍ ធ្វើឲ្យការទុកនៅសាលាស្រុកគ្រប់ប្រការ ។

ការដែលនាំយករឿងទាំងនេះមកសំដែងទុកក្នុងនេះ មិនមែនបំណងឲ្យលោកអ្នកមើលជឿថាជាការប្រាកដនោះទេ ទុកត្រាន់តែជាផ្លូវពិចារណាគិតដល់បែបយ៉ាង ដែលមាននៅក្នុងស្រុកយើង លោកគង់



www.elibraryofcambodia.org

បានឃើញឬបានស្ដាប់មកខ្លះ បើលោកមើលមកដល់ត្រង់នេះ លោកគង់ចង់ជ្រាបថា ទិនមើលរបស់ទាំងនោះ ដោយប្រការដូចម្ដេចនោះ ដូចមានពោលតទៅ:

វិធីដែលបាក់ងងឹងយោគ្គីក្នុងអណ្ដៀ) ប្រើសំរាប់ធ្វើឲ្យគេគង់ពួក្ដ មើលឃើញរបស់ផ្សេងៗ ក្នុងអត្ថាគមខាតគន្ធងបបុប្ផានោះមាន ៣ វិធី:

វិធីទី ១ - ដោយប៉ះពាល់គ្រឿងណាមួយ ដែលជាប់ទាក់ទងនឹង បុគ្គល ទីស្ថាន ឬហេតុការណ៍ដែលត្រូវការទិនជ្រាបនោះ ។

វិធីទី ២ - ដោយសម្លឹងមើលកែវឬពែងទឹក ។

វិធីទី ៣ - ដោយសណ្ដំខ្លួនឲ្យលក់ បែបចូលឈានរបស់យ៉េន ។

ឯវិធីទាំង ៣ នេះខ្ញុំនាំយកវិធីទី ១ និងទី ២ មកបរិយាយទុក ដើម្បីជាគ្រឿងសម្រាប់ប្រកបសេចក្ដីត្រិះរិះរបស់អ្នកដែលយកចិត្តទុកដាក់ក្នុងវិជ្ជានេះខ្លះ តែត្រង់វិធីទី ៣ នោះ មិនបាននាំយកសេចក្ដីមកបរិយាយទុក ព្រោះជាសេចក្ដីពិស្ដារណាស់ គង់ធ្វើជាសៀវភៅមួយផ្សេងទៀតបាន បើនឹងកាត់ប្រញាប់យកតែសេចក្ដីឲ្យបានខ្លីមកចុះក្នុងសៀវភៅនេះ ខ្លាចក្រែងនាំឲ្យលោកអ្នកមើលមិនយល់សេចក្ដីច្បាស់ យកទៅធ្វើតាមមិនបាន ឲ្យអន្តរាយដល់ខ្លួន ព្រោះមានដំណើរថា មានអ្នករៀនវិជ្ជាសណ្ដំម្នងចិត្ត ដោយមិនយល់ច្បាស់ ហាត់ធ្វើជិតតែម៉ង់ខ្វាក់ភ្នែកជាប្រើម សមតាមសុភា-សិតដែលថា "ចំណេះតិចពើបតែអន្តរាយ" ។



www.elibraryofcambodia.org

ឯវិធីទី ១ ទីទី ២ នោះ បើទុកជាយកទៅហាត់ធ្វើតាមក៏គ្មានអន្តរាយ មានតែគុណប្រយោជន៍ ជាគ្រឿងហាត់ឲ្យចាំ ហើយមនោគតិរបស់យើងក៏នឹងល្អឡើង សមាធិទៀតក៏កាន់តែមាំមួនឡើង ព្រោះសេចក្តីចាំ ១ មនោគតិ ១ សមាធិ ១ ទាំង ៣ ប្រការនេះ ជាប្រយោជន៍សំខាន់ធ្វើការគ្រប់យ៉ាងបាន ៗ ឯវិធីផ្សេង ៗ ដែលមានអធិប្បាយមកនេះ សូមកុំឲ្យលោកអ្នកមើលគិតថា អ្នកតែងសៀវភៅនេះ បានសម្រេចផ្តាច់តាំងនេះឡើយ វិធីទាំងប៉ុន្មានស្រង់យកតាមតែក្រហរបស់គេដែលបានប្រទះឃើញ គឺនាំយកមករួបរួមទុកចែកគ្នាមើលតែប៉ុណ្ណោះ ៗ

ផាត់វេប្បធីរបស់វិធីទី ១ នោះ គេឲ្យចាប់ធ្វើពីរបស់ដែលងាយជាមុន គឺឲ្យយកពុតបញ្ហាយចាស់ ៗ ដែលគេបានទេសរសេរមកដល់យើងជាយូរមកហើយនោះ មកក្តាប់ទុកក្នុងបាតដៃរួចព្យាយាមទាយដល់អ្នកដែលសរសេរនោះ ទាយរួបកថិរក្ខណៈបុរសហាក់ចិត្តស្រួយចិត្តស្ងួតស្ងួតខ្លះ វិធីនេះត្រូវព្យាយាមទាយដល់មនុស្សសរសេរ ដែលយើងស្គាល់ជិតដិតច្បាស់នោះជាមុនរួចសិមទាយដល់មនុស្សដែលយើងស្គាល់ស្រពេចស្រពិលជាក្រោយ ៗ

ផាទី ២ — កាលណាយើងទៅលេងទីកន្លែងណា ៗ មួយ តាមវត្តក្រៅ ដល់វិលមកវិញរើសយកដីមួយដុំ មកកាន់ក្តាប់ទុកក្នុងបាតដៃព្យាយាមគិតទាយដល់ទីកន្លែងនោះ ទាល់តែឃើញរូបភាពទីកន្លែងនោះជាប់ចំពីភ្នែក ស្មើតែទៅជាគុហានិមិត្ត ៗ



www.elibraryofcambodia.org

ជាទី ៣ — យករបស់អ្វីមួយ ដែលជារបស់បកតីឯទៀត ដែលយើងមិនធ្លាប់ឃើញសោះ ត្រាន់តែឮរឿងខ្លះ ឧបមាដូចខ្សែរដូកប៉ុ មួយបានមកពីស្រុកអង់គ្លេស ដែលយើងពុំស្គាល់ស្រុកនោះសោះ ត្រាន់តែដឹងតាមសៀវភៅ ឬដឹងដោយគេនិយាយឲ្យស្ដាប់ គេឲ្យយកខ្សែរនោះមកកាន់ទុកនៅដៃ រួចព្យាយាមនឹកដល់ប្រទេសអង់គ្លេសនោះ ទាល់តែប្រើមនោគតិសង់ឡើងមើលទៅឃើញដូចជាខ្លួននៅក្នុងស្រុកនោះ ៗ

ជាទី ៤ — យករបស់អ្វីដែលបានបកតីទីកន្លែង ដែលយើងមិនស្គាល់មិនដែលឮនិយាយសោះនោះ មកកាន់ទុករួចព្យាយាមនឹកថារបស់នេះមកពីទីកន្លែងណា ៗ

ជាទី ៥ — បើកេចនឹងធ្វើបាន ល្បងមើលយករបស់ដែលគេចោលដោយយើងមិនស្គាល់ឬក៏ឈ្មោះម្ចាស់របស់នោះសោះ ដូចជាកន្ទុយបារីសំបកឈើគូសឬកាសែតក្ដី យកមកកាន់ទុករួចព្យាយាមនឹកគេម្ចាស់របស់នោះ តើមាននិស្ស័យចិត្តថ្លើមយ៉ាងណា មានរបរកស៊ីធ្វើការអ្វី ក្នុងវេលានេះកំពុងធ្វើអ្វី ៗល ៗ

តាមវិធីដូចអធិប្បាយមកនេះ ទើបឃើញថាមនោគតិជាគ្រឿងជួយយ៉ាងសំខាន់ បើយើងហាត់ហ្វឹកហ្វឺនឲ្យញឹកញាប់ហើយ ក្រៅដែលជាប់នៅនឹងរបស់នោះឯង ទើបធ្វើឲ្យមនោគតិរបស់យើងដឹងឃើញច្បាស់ឡើង

www.elibraryofcambodia.org

ទាល់តែត្រូវតាមសេចក្ដីពិតប្រាកដជាប់ផុតនោះ បាក់នឹងបានប្រើវិធីនេះ ចាប់ចោរបានខ្លះ ក្នុងករណីយហេតុដែលហួសវិស័យនឹងស្គាល់ខ្លួនចោរនោះបាន ដោយរបស់ដែលចោរលួចនោះកំពោលនៅទីណាមួយៗ គេយករបស់នោះមកឲ្យអ្នកនេះស្គាល់ក្នុងវិធីនេះធ្វើល្បងមើល បើអ្នកនោះប្រាប់ចំពោះឈ្មោះណា គេហៅឈ្មោះនោះមកពិចារណាសួរ តែដោយសេចក្ដីប្រាកដរបស់អ្នកសួរយកចម្លើយផងទើបបាន ដូចកាលក៏ត្រូវដោយចោរឆ្លើយទទួលសារភាព ឬក៏ឲ្យមានចលាចិត្តប្រែប្រួល ចូលក្នុងផ្លូវច្បាប់ណាឲ្យជ្រះតែការទៅទៀតបាន ។

ក្នុងវិធីទី ២ ការដែលឲ្យសំឡឹងមើលតែនោះ គឺពេលប្រាកដណារបស់យើងនេះឯង តាមមុខណាគេប្រើសំឡឹងមើលទឹក ត្រង់តែនេះជាវិធីដោយបានទទួលគិតឡើងជាន់ក្រោយ ដែលជាប្រាកដនោះ របស់អ្វីដែលធ្លុះមើលឃើញស្រមោលបាន ក៏ប្រើបានទាំងអស់ តាមប្រទេសដែលធ្លាប់ប្រើក្នុងសម្ស៊ីនេះ ពួកអេស៊ីប និងឥណ្ឌានៅប្រើទឹកដាក់ក្នុងកែវ ពួកអារ៉ាប់ប្រើមើលទឹកក្នុងអណ្ដូង ពួកនូវែលសេឡង់ប្រើមើលឈាមសត្វ ឯពួកយុរ៉ុបយល់ឃើញថា ហាក់សំឡឹងមើលកែវហើសជាប់ផុត ។ វិធីហាត់តាមក្បួនផ្លូវមានតទៅ:

១ – ត្រូវតែចូលក្នុងបន្ទប់ដែលស្ងាត់ គ្មានមនុស្សទៅធ្វើឲ្យរំខានបាន ក្នុងបន្ទប់នោះកុំឲ្យមានរូបភាពអ្វីៗឲ្យសោះ ហើយកុំឲ្យក្ដៅស្អុះពេក



www.elibraryofcambodia.org

កុំឲ្យមានពន្លឺខ្លាំង កុំឲ្យងងឹតពេក ពន្លឺនោះឲ្យមានពីខាងក្រោយ កុំឲ្យមានទៅខាងមុខ ។

២ - របស់ដែលនឹងសំឡឹងមើលនោះ ជាដុំកែវឬកែវឆ្នាមាន ទឹកក្នុងនោះក៏បាន តែត្រូវឲ្យមានកំណាត់សំពត់ឬក្រដាសពណ៌ខ្មៅនៅខាងក្រោម ។

៣ - ហាមមិនឲ្យហាត់ធ្វើក្នុងវេលាដែលទើបបរិភោគអាហាររួច ត្រូវបន្ទន់ឲ្យអាហាររលាយសិន ។

៤ - ឲ្យអង្គុយតាមសម្រួលដែលស្រួលបំផុត រួចហើយសំឡឹងមើលក្នុងដុំកែវពែងទឹកនោះ កុំមើលខាងក្រៅរបស់នោះ កុំសំឡឹងមើលឲ្យហួសកំឡាំងភ្នែក មើលតាមតែប្រក្រតីដែលយើងធ្លាប់មើល ដែលជាសំខាន់បំផុត គឺសមាធិផ្ចង់ចិត្តឲ្យនឹងនៅក្នុងដុំកែវឬក្នុងពែងទឹកនោះ កុំឲ្យនឹកដល់របស់អ្វីឲ្យសោះ ។

៥ - ក្នុងគ្រាដំបូងឲ្យអង្គុយសំឡឹងត្រឹម ១៥ នាទី រួចទុកកែវពែងនោះក្នុងទីងងឹត កុំឲ្យមានមនុស្សទៅប៉ះពាល់ ដល់ថ្ងៃស្អែកឡើងឲ្យអង្គុយក្នុងវេលាពេលដូចថ្ងៃមុន ត្រូវថែមវេលាបាន ៥ នាទីឡើងទៀត ជារាល់ថ្ងៃ ទាល់តែដល់ ១ ម៉ោង កុំឲ្យហួសពី ១ ម៉ោងឡើយ ។ ដែលធ្វើនេះក្នុង ១០ ដងដំបូង មុខជាមិនបានឃើញអ្វីទេ បើមានអ្នកណាធ្វើហើយបានឃើញក្នុងគ្រាទីពីរ ទុកជាអ្នកនោះធ្វើបានហើសណាស់ហើយ ។

៦– បើកាលណាមើលឃើញក្នុងផ្ទៃកែវប្លុងក្នុងតែងមានជាផ្សែងពពក ហើយមានចំណុចមូលប៉ុនចុងម្ជុលជាពណ៌សរលីរលោក្នុងកណ្ដាលពពកនោះ ក៏ទុកជាបានសម្រេចដូចប្រាថ្នាហើយ ក្នុងវេលាដែលបានសម្រេចនោះ ត្រូវយកទុកចិត្តទាំងអស់រវល់នៅតែរឿងមួយ ដែលត្រូវការចង់ដឹងនោះ ដូចជាចង់ដឹងថាបងប្អូនមិត្តសម្លាញ់យើងដែលនៅឆ្ងាយ កំពុងតែធ្វើអ្វីនៅពេលនេះ ការចង់ពុំដឹងមើលឃើញមួយរំពេច រួចពីនេះគេទៅគឺហេតុដល់នៅមើលមនុស្សផ្សេងៗ រហូតដល់នៅមើលឲ្យដឹងថាខ្លួនឯងទៅថ្ងៃខាងមុខនោះ នឹងមានហេតុការណ៍ដូចម្ដេចៗ ក៏បាន ឬមិនមើលហេតុការណ៍ក្រោយៗ ទីនឹងដឹងដោយផ្ទៃកែវនេះជាដរាប ។

វិធីហាត់រៀនបានពោលមកនេះ ទីនឲ្យសម្រេចបានអម្បាលម៉ាណនោះ ពុំគេចខ្លួនខុសគ្រូទេ ព្រោះមិនដែលហាត់ធ្វើ គ្រាន់តែសរសេរតាមក្រមាដែលគួរជឿ គម្រាមមួយៗមានវិធីប្រែប្រួលខុសគ្នា តែចេញមកពីគោលដ៏សំខាន់តែមួយ គឺឲ្យមានជំនឿចិត្តជាសមាធិ បើលោកអ្នកមើលសៀវភៅនេះ ឃើញមានហេតុផល គួរធ្វើល្បងមើលក៏ធ្វើបាន ឥតមានសេចក្ដីអន្តរាយអ្វីដល់ខ្លួនឡើយ ។

តាមសេចក្ដីដែលពណ៌នាមកហើយខាងដើមនោះ ជាវិធីបង្ហាត់ចិត្តឲ្យដឹង ឃើញ តែមនុស្សយើងជួនកាលបានឃើញដោយអស្ចារ្យ



www.elibraryofcambodia.org

ដូចជា ២ . ៣ រឿងដែលបានមកនោះ ៗ សេចក្ដីដែលបរិយាយមកនេះ ជាវិធីដឹងនូវអតីតទំនាយ នូវអនាគតបាន ក្រៅពីរបៀបពិចារណាតាម និទ្ទេសដែលពោលទុកថា ចក្ខុមើលឃើញហួសវិស័យរបស់សាមញ្ញជន(១) តទៅ ៗ

ក្នុងក្រុងប៉ារីស មានស្ត្រីម្នាក់ឈ្មោះអេល្យូនដឺស៊ី: គ្រាន់តែឈ្មោះក៏ដឹងថាមានជាប់ពូជមកពីកុគ្គ មានរបរជាអ្នកទាយ ស្ត្រីនេះ បានទទួលសេចក្ដីកប់អាចពីសភាអ្នកប្រាជ្ញវិទ្យាសាស្ត្រក្នុងក្រុងប៉ារីស ៗ បានឲ្យប្រកាសនីយប័ត្រទុកជាសំគាល់ ដោយស្ត្រីនុ៎ះឯងអាចទាយទុក កាលក្នុងមហាសង្គ្រាម យ៉ាងល្អិតពិស្ដារថា មហាសង្គ្រាមនឹងសម្រេច លើកលែងចប់ឆ្នាំនៅថ្ងៃនោះ ៗ បារាំងសែសនឹងបានស៊ីញេសញ្ញាស្ងប់សឹក ជាមួយអូទ្រីសនឹងអាល្លឺម៉ង់នៅថ្ងៃនោះ ៗ ផលនៃការសង្គ្រាមនឹងមានជា ប្រការដូចម្ដេច ៗ នោះ ឃើញត្រូវតាមទំនាយទាយ អ្នកតែងសៀវភៅនេះ បានតាំងប្រស្នាសួរស្ត្រីនេះថា មនុស្សយើងអាចមើលធ្លុះកំផែងឬជញ្ជាំង ឬគ្រឿងបិទបាំងផ្សេង ៗ បានឬទេ ? ស្ត្រីនោះក៏ឆ្លើយថា មនុស្សយើងអាច មើលធ្លុះបានដោយពិត សូម្បីសត្វចំពូកខ្លះ ដូចជាស្រមោចក៏មានភ្នែក មើលឃើញធ្លុះដូចគ្នា ៗ ឯភ្នែកស្រមោចមើលឃើញធ្លុះនោះ បានល្បង យកស្លាកខ្ចប់ រួចទុកនៅទីកន្លែងមួយ ដែលប្រមុះស្រមោចស្រង់ក្លិនមិន



www.elibraryofcambodia.org

បាន ក្នុងវេលាមួយហើយស្ករគ្រាប់នោះពេញស្ងួតកៃស្រមោច បានត្រូវមើលតាមផ្លូវដែលវាមក ឃើញទៀងតាមជញ្ជាំងពីក្រោមដុះមករកស្ករនោះ ដល់ព្រឹកឡើងល្បងមើលទៀត បានយកគ្រាប់ស្ករដាក់ក្នុងពែងរួចយកទឹកដាក់ក្នុងចានទ្រពែង ហើយចាំមើលដើមផ្លូវដែលវាមកពីមុនតើវាចេះរកទៀតឬទេ ក្រោយពេលយូរហើយ ក៏មិនឃើញវាមក ចាំមើលទៅក្នុងថូស្ករពីរហើយទៀត ក៏មិនឃើញមានស្រមោចដល់មួយមកជិតចានស្ករនោះសោះ ។

ហេតុនេះ គួរគិតបើយើងប្រកាន់ថា ស្រមោចមានច្រមុះល្អ ស្រង់ក្លិនបាន បានជាថ្ងៃដំបូងវាមករកស៊ីស្ករបាន លុះដល់ថ្ងៃទី ២ ដែលយកស្ករទៅបណ្ដែតលើទឹកនោះ ហេតុអ្វីក៏វាមិនមករកទៀត ក្លិនស្ករដែលបណ្ដែតទឹកនោះ នឹងបាត់ក្លិនក៏ទេ គួរតែវាស្រង់ក្លិនតាមមករកបាននោះទៀត ហេតុអ្វីក៏មិនឃើញមកដល់មួយសោះ បានជាថាបើរឿងនោះមិនសន្និដ្ឋានថាស្រមោចមានភ្នែកមើលធ្លុះទីកំបាំងផ្សេង ៗ បានទេ ក៏គ្មានអ្វីនឹងអធិប្បាយទៅទៀតហើយ ។

ក្នុងសម័យនេះ មានកែវដែលមនុស្សសាងឡើង សម្រាប់ធ្លុះមើលក្នុងខ្លួនមនុស្សផង ដូចជាមនុស្សដែលត្រូវគ្រាប់កាំភ្លើង ឬកើតវណរោគ (រោគរបេង) ក្នុងខ្លួន គេយកកែវនោះធ្លុះមើលឃើញ ដឹងថាមានគ្រាប់

ឬជម្រៅនៅទីកន្លែងត្រង់ណាៗបាន ហើយគេអាចផ្ទេរផលយករូបភាពនោះ មកពិនិត្យមើលបានទៀត ។

ឯភ្នែករបស់មនុស្ស ដែលពីរមើលឃើញផ្ទះបាតនោះ តាមកប្រែ ដែលបានប្រែមក ឃើញពេលថា ដាប្លាក់ខ្ពស់ជាងការសណ្តំខ្លួនឯង ឲ្យលក់នោះទៀត គឺគោងសណ្តំខ្លួនឯងឲ្យបានស្ទាក់សិន ក្នុងវេលាដែលលក់ដោយសណ្តំនោះ ឲ្យមើលឃើញរបស់ផ្សេងៗបាន ដូចជាយល់សប្តិ តែខុសនឹងសេចក្តីយល់សប្តិ ហេតុដែលឃើញដោយសណ្តំជារបស់ពិត ព្រោះអាចមើលឃើញរបស់គ្រប់យ៉ាងតាមត្រូវការបាន មិនដូចសេចក្តីយល់សប្តិ ដែលឃើញបន្ទាប់បានដោយពិបាកនោះទេ បើស្ទាក់ដល់ទីនេះហើយ គ្រាក្រោយមិនបាច់សណ្តំខ្លួនឲ្យលក់ទេ អាចមើលឃើញដោយភ្នែកស្រស់ៗបាន ដូចគ្នានឹងសណ្តំចិត្តមនុស្សដទៃឲ្យលក់ហើយ ឲ្យស្តីនិយាយប្រាប់រឿងអ្វីបានគ្រប់យ៉ាង កាលណារៀនស្ទាត់ប្រាកដហើយ ដល់ក្រោយមិនបាច់សណ្តំឲ្យលក់ទេ អាចបង្គាប់មនុស្សនៅកំពុងភ្ញាក់ ឲ្យធ្វើអ្វីៗបានទាំងអស់ ។

ដែលពិតនោះ ការដែលនឹងឲ្យមានចិត្តបកបានដល់ថ្នាក់នេះ ជារបស់ពិបាកណាស់ ក្នុងសម័យនេះមិនដែលប្រទះឃើញមនុស្សណាមាន ចិត្តបក្ខដល់ថ្នាក់នេះសោះ ព្រោះមនុស្សក្នុងសម័យនេះមិនហានរៀនស្រ-

នាញាណឲ្យពេញបរិបូណ៌ពុំបាននោះឯង ឯព្រះពុទ្ធជាម្ចាស់ ឬសាវករបស់ព្រះអង្គដែលបានសម្រេចវិបស្សនាញាណពេញបរិបូណ៌ ឆ្ងាយចាកកិលេសហើយនោះ ក៏ដឹងចិត្តបុគ្គលជាប្រាកដពុំសង្ស័យឡើយ ។

តាមចំណែកក្នុងគម្ពីរវិសុទ្ធិមគ្គនោះ លោកបញ្ញត្តឲ្យប្រើអាលោក-កសិណជាសំខាន់ ពោលគឺឲ្យចំរើនឲ្យកើតពន្លឺក្នុងចំណោមទិព្វសោតក៏បាន ពន្លឺរបស់កសិណមាំនឹងភ្លឺចេញ ឲ្យភ្នែកអាចមើលឃើញចុះហេតុដល់សត្វកំពុងចុតិ កំពុងកើតបាន ។

ឯលទ្ធិរបស់យោគី គេក៏មានដូច្នេះដែរ គេពោលទុកថាអ្នកដែលបានលុះទិព្វចក្ខុ ក៏បានមើលឃើញប្រេតភូត កំពុងតែទៀលធ្លាក់ចុះទៀងក្នុងលោក បើតាមន័យអត្ថាធិប្បាយរបស់ព្រះពុទ្ធឃោសាចារ្យនោះ មិនឃើញប្រាកដថា ប្រើចិត្តបុគ្គលជាគ្រឿងធ្វើឲ្យដឹងអតីត អនាគតបាន ដូចយ៉ាងលទ្ធិរបស់យោគីទាំងពាក់ព័ន្ធនោះឡើយ ។

## វិជ្ជាប្រការទី ៨

### អាសវក្ខយញាណ

តាមលំនាំក្នុងវិជ្ជាប្រការទី ៨ នេះ មានសេចក្តីក្នុងធម្មវិភាគបរិច្ឆេទទី ២ ថា "ដឹងច្បាស់តាមពិតប្រាកដថា នេះជាទុក្ខ នេះជាទុក្ខសមុទយ នេះជាទុក្ខនិរោធ នេះជាទុក្ខនិរោធគាមិនីបដិបទា ទាំងនេះជាអាសវៈ



www.elibraryofcambodia.org

នេះជាហេតុកើតនៃអាសវៈ នេះជាហេតុរលត់នៃអាសវៈ នេះជាផ្លូវទៅដល់សេចក្ដីរលត់អាសវៈ កាលណាយើងដឹងឃើញដូច្នេះហើយ ចិត្តក៏ផុតចាកកាមាសវៈ ភវាសវៈ អវិជ្ជាសវៈ ដឹងច្បាស់ថាជាតិអស់ហើយ ព្រហ្មចរិយៈបាននៅរួចហើយ ករណីយកិច្ចបានធ្វើស្រេចហើយ កិច្ចការផ្សេងៗ ដែលនឹងត្រូវធ្វើដូច្នេះតទៅទៀតនោះគ្មានឡើយ " ។

វិជ្ជាទី ៨ នេះមិនបានអធិប្បាយទៀតទេ ព្រោះថាបើនឹងអធិប្បាយ គង់វិលទៅរកចតុរារិយសច្ច ដែលមានសេចក្ដីអធិប្បាយយ៉ាងប្រសើរ ដល់ ២ សៀវភៅហើយនោះ គឺសៀវភៅពុទ្ធប្បវត្តិរបស់សម្ដេចព្រះមហា· សមណៈ ទាំងសៀវភៅ "ព្រះពុទ្ធត្រាស់ដឹងអ្វី" ដែលជាព្រះរាជនិពន្ធរបស់ព្រះបាទសម្ដេចព្រះរាមាធិបតីទី ៦ តែងទុកមកហើយនោះ ។

ហេតុនេះនឹងអធិប្បាយឲ្យល្អជាងសៀវភៅនោះតទៅទៀតពុំបាន ។ ប្រការមួយទៀត អរិយសច្ច ៤ ជាធម៌ដែលពុទ្ធសាសនិកជនយល់ចូលចិត្តរាល់គ្នាហើយ នឹងនាំយកមកអធិប្បាយទៀតក៏ពុំគួរ ។

ដើម្បីនឹងរួបរួម ឲ្យបានចូលចិត្តលក្ខណៈរបស់វិជ្ជា ៨ ប្រការនេះឲ្យច្បាស់លាស់ឡើងតទៅនោះ សូមឲ្យលោកអ្នកមើលរំពឹងដល់សេចក្ដីដែលបានពោលមកហើយខាងដើម ព្រោះវិជ្ជា ៨ ប្រការនេះបានរៀបរៀងតាមលំដាប់ទុកត្រឹមត្រូវណាស់ គឺមានវិបស្សនាញាណជាខាងដើម



www.elibraryofcambodia.org

គឺនឹកសង្គ្រោះព្យញ្ញាណជាបរិយោសាន ៗ ថាបើបុគ្គលណាចង់រៀនវិជ្ជា ប្រការឲ្យសប្បុរសប្រាកដពិតជាក្រោយពីចង់ចេះវិជ្ជានោះ ដើម្បីចង់ធ្វើឲ្យកសាងផលអស់ទៅ មិនបានចង់ធ្វើតែនឹងជាគ្រឿងប្រដាប់សម្រាប់ជំនួយជួយឲ្យកសាងគំរើកទៅវិញដោយឡើយ ៗ

កាលដែលសម្ដេចព្រះមហាសមណ ទ្រង់ប្រទានអធិប្បាយទុកថា “មិនធ្វើតែត្រឹមកិច្ចចេះដឹងប៉ុណ្ណោះទេ ត្រូវយោលយកសេចក្ដីដែលចេះនោះមកជាឧបការៈ ធ្វើកសាងឲ្យអស់ទៅជាមួយផង ទើបបានជាគុណព្រះសម្រេចសម្ដេចពិញ្ញាណជាគួរណាស់” សេចក្ដីនេះឃើញថាជាសេចក្ដីត្រឹមត្រូវ គេមិនតិះដៀលជាដូចម្ដេចបានឡើយ ព្រោះសេចក្ដីចេះដឹងរបស់មនុស្សគ្រប់គ្នាតែចេះនឹងគេបាន តែនឹងអាស្រ័យសេចក្ដីចេះដឹងតែប៉ុណ្ណឹង ធ្វើឲ្យបានល្អនោះពុំបានឡើយ គេនឹងយកសេចក្ដីចេះនោះមកប្រើតាមផ្លូវត្រឹមត្រូវផង បើអ្នកណាយកសេចក្ដីដែលចេះនោះ ទៅប្រើដើម្បីឃើញតែប្រយោជន៍របស់ខ្លួន ធ្វើឲ្យខូចប្រយោជន៍របស់អ្នកដទៃនោះ ក៏ជាបាបកម្មណាស់ គង់មានមួយថ្ងៃនឹងទទួលទោស ជាពិតប្រាកដពុំខាន ព្រោះធម៌របស់ព្រះពុទ្ធជាម្ចាស់គ្រប់ៗ ប្រដៅឲ្យមនុស្សប្រព្រឹត្តខ្លួនឲ្យល្អ ឲ្យមានប្រយោជន៍ដល់ខ្លួន ហើយឲ្យមានដល់អ្នកដទៃផង យើងគ្រប់គ្នាគង់បានដឹងថា ព្រះពុទ្ធជាម្ចាស់ ព្រះអង្គយកព្រះទ័យទុកដាក់ក្នុងសេចក្ដី

នេះណាស់ បានជាមានព្រះពុទ្ធពាក្យដែលជាខាងក្រោយបំផុតមុនស្តេចរំលត់ខន្ធចូលកាន់ព្រះនិព្វានថាៈ "អ្នកទាំងឡាយ ចូរញ៉ាំងកិច្ចការទាំងពួង ឲ្យបានជាប្រយោជន៍ដល់ខ្លួន ហើយឲ្យបានជាប្រយោជន៍ដល់អ្នកដទៃ ឲ្យបានបរិបូណ៌ដោយសេចក្តីមិនប្រមាទនេះចុះ" ព្រះពុទ្ធ-ពាក្យនេះ ជាទីបញ្ចប់ចិត្តនៃយើងដែលជាពុទ្ធសាសនិកជនត្រប់គ្នា ។

## អវសានកថា

អំពីរឿងប្រាំបីប្រការនេះ លោកអ្នកមើលក៏បានមើលហើយ តាំងពីដើមដល់ចប់ចុង ដូច្នេះសូមលោករំពឹកឡើងវិញ ដល់សេចក្តីដែលបានមើលមកហើយទាំងប៉ុន្មាននោះ រួចស្វែងរកវិនិច្ឆ័យរបស់លោក តើមានសេចក្តីយល់ឃើញដូចម្តេច សៀវភៅនេះមិនបានបំណងបង្ខំចិត្តលោកអ្នកមើល ឲ្យជឿក្នុងវត្ថុបដិហារិយ៍នោះទេ ការដែលលោកនឹងជឿឬមិនជឿក៏មិនខូចប្រយោជន៍ឬបានប្រយោជន៍អ្វី ដល់អ្នកតែងនោះឡើយ បំណងដ៏ពិតប្រាកដក្នុងការតែងសៀវភៅនេះ គ្រាន់តែរើសយកគំនិតរបស់លោកអ្នកប្រាជ្ញមករួបរួមទុកហើយនឹងបំពេញថែមសេចក្តីដែលអ្នកតែងបានគិតឃើញនោះផង ទុកសម្រាប់ជាផ្លូវជួយលោកអ្នកចេះធម៌ត្រិះរិះវិនិច្ឆ័យតទៅ ។

ឯវិជ្ជាការក្នុងលោកនេះ តែងតែមានច្រើនប្រកែក អ្នកណាសិក្សាផ្លូវណា គឺសរសើរថាផ្លូវនោះល្អជាធម្មតារបស់លោកមិនជាខុសអ្វីទេ



www.elibraryofcambodia.org

តែបើយើងមិនគួរយើងយកវិជ្ជាការ ប្រភេទដែលយើងសិក្សាទៅសង្កត់សង្កិនវិជ្ជាប្រភេទដទៃទៀតនោះឡើយ ។ ឧបមាដូចយើងរៀនផ្លូវពេទ្យ យើងក៏បានអំណាចសរសើរវិជ្ជាពេទ្យរបស់យើងថាល្អវិសេស សម្រាប់ជួយជីវិតមនុស្ស តែយើងមិនគួរនិយាយថាល្អជាងច្បាប់ ដែលជាវិជ្ជាសម្រាប់សម្រេចឲ្យកាត់ក្បាលមនុស្ស ឬល្អជាងវិជ្ជាធ្វើគ្រឿងយន្តដែកជាប្រដាប់សម្រាប់ធ្វើឲ្យមនុស្សដាច់ដៃជើងនោះឡើយ ។ ក្នុងសម័យនេះច្រើនសិក្សាខាងគន្ថធុរៈ យើងក៏សរសើរថាគន្ថធុរៈរបស់យើងវិសេសដូចម្ដេចក៏បាន តែកុំយកទៅនិយាយសង្កត់សង្កិនវិបស្សនាធុរៈថាជារបស់មិនពិតនោះឡើយ វិជ្ជាប្រភេទនីមួយៗតែងតែមានលក្ខណៈវិធីដែលរៀងខ្លួនគុណប្រយោជន៍ផ្សេងៗពីគ្នា ទីនេះយកមកប្រៀបប្រដូចគ្នាឲ្យឃើញថាប្រភេទណាល្អជាងណាពុំបានឡើយ ។

វិបស្សនាធុរៈ ជាវិជ្ជាបង្វឹកបង្វឺន ដុសខាត់ពត់ដួងចិត្ត បណ្ដុះសមត្ថភាពឲ្យល្អ ដូចលោកអ្នកមើល បានមើលដឹងមកហើយថា ផ្លូវព្រះពុទ្ធសាសនារបស់យើងក្ដី ផ្លូវអធ្យាត្មវិទ្យារបស់បារាំងក្ដី លទ្ធិរបស់យោគីក្ដី គេពោលត្រូវត្រង់ដូចគ្នាថា ដួងចិត្តរបស់មនុស្សដែលហាត់ហ្វឹកហ្វឺនល្អហើយ តែងតែមានអំណាច អាចធ្វើរបស់អ្វីៗដែលយើងមើលមិនឃើញដោយភ្នែកជាប្រក្រតីបាននោះឲ្យឃើញបាន ។ ពោលចំពោះតែព្រះពុទ្ធ-

ជាម្ចាស់របស់យើង យើងនេះដឹងមិនអស់ថា ព្រះអង្គជាឯកអគ្គមហាបុរស នោះតែព្រះអង្គបានធ្វើការបង្ហាត់ព្រះអង្គយ៉ាងណាខ្លះ បានជាព្រះអង្គលេចខ្ពង់ជាងមនុស្សដទៃបានយ៉ាងល្អដល់ម្ល៉េះ ហេតុនេះយើងមិនត្រូវសង្ស័យថា ព្រះអង្គមិនបានបង្ហាត់ព្រះអង្គឯងឲ្យបានយ៉ាងល្អបំផុត ឲ្យមានអំណាចដ៏វិសេសលើសជាងមនុស្សសាមញ្ញនោះឡើយ ។

ការប្រែប្រួលនៃកាលសម័យ តែងតែធ្វើឲ្យបុគ្គលផ្លាស់ប្តូរចិត្តនិយមវិជ្ជាផ្សេងៗ នៅជាមួយផង កាលក្នុងសម័យព្រះពុទ្ធជាម្ចាស់ សេចក្តីនេះដឹងក្នុងផ្លូវចិត្តសាស្ត្រចំរើនឡើងដល់ទីបំផុត រួចក៏ចុះថយបន្តិចៗមកដល់សម័យឥឡូវនេះ សេចក្តីនេះដឹងខាងផ្លូវវិទ្យាសាស្ត្រក៏ចំរើនឡើង ចឹងទុកជាដល់កំរិតបំផុតហើយក៏បាន ដោយមានអាកាសយានសំរាប់ហោះ មានកបាល់មុជទឹកសំរាប់មុជចុះទៅបាតសមុទ្រយ៉ាងជ្រៅបាន មានរទេះដើរក្នុងដី មានគ្រឿងវិទ្យុទូរលេខទូរសព្ទ គ្រឿងបំភ្លាយ គ្រឿងធ្វើទឹកកក យើងឃើញគ្រប់ចំពូកហើយ មើលទៅហាក់ដូចជាគ្មានឃើញអ្វីជាវិសេសទៅទៀតឡើយ សេចក្តីនេះដឹងក្នុងផ្លូវវិទ្យាសាស្ត្ររបស់មនុស្សចំរើនឡើងដល់ទីបំផុតហើយ សម័យនេះក៏ជិតនឹងផ្លាស់ប្តូរវិលទៅចំរើនខាងផ្លូវចិត្តសាស្ត្រវិញក៏បាន ដូច្នេះក្នុងវេលានេះ បានជាអ្នក-ពួកយកចិត្តទុកដាក់ស្រាវជ្រាវរកវិជ្ជាទាំងនេះឡើងវិញ ក្នុងដីដែនយើងក៏ប

ពឹងទាល់ឃើញវិជ្ជាចិត្តសាស្ត្រចម្រើនឡើងវិញ ដោយរកចំណែកម្តង ទៀតក៏បាន ដោយមនុស្សកំពុងបញ្ជាក់វិជ្ជា ៨ ប្រការនេះ ដូចកាលក្នុង សម័យរបស់ព្រះពុទ្ធជាម្ចាស់ទ្រង់ក៏សំដែងបានដែរ ។

សៀវភៅវិជ្ជា ៨ ប្រការនេះ ប្រដូចជាព្រះសូត្រតូចៗដែលសាងទុក ក្នុងព្រះពុទ្ធសាសនា ដោយដុំដង្រួចៗដែលបានព្យាយាមស្វែងរកមក ពីទីកន្លែងទាំងបួនទិសក្នុងលោកមកផ្គុំគ្នារួមទុកជាដុំមួយ ចាំកាំតែទឹង បានសម្រេចជាអត្ថព្រះសូត្រតូចនេះ អ្នកសាងបានយកកំឡាំងព្យាយាម ប្រាំប្រាំកសាងកប់ជាធ្លាំៗទើបបានសម្រេច តែកំឡាំងទាំងប៉ុន្មានដែល អស់ទៅនោះ បានអត្ថផលបាក់ទៅ ដោយដឹងច្បាស់ថាសៀវភៅ "វិជ្ជា ៨ ប្រការនេះ" ជាសៀវភៅមានឧបការៈ មូលចិត្តជាច្រើន ទុកជា កេរ្តិ៍សម្បត្តិដ៏ធំសម្រាប់អ្នកដែលបានទទួលបានដល់ខ្លួននេះ ។

ក្នុងទីបំផុតរបស់សៀវភៅវិជ្ជា ៨ ប្រការនេះ អ្នកនិពន្ធបានតាំងសេចក្តី ប្រាថ្នាហ៊ានតិចតួចក្រោមគុណបក្ខ ជូនលោកអ្នកស្តាប់ទាំងលោកអ្នកដែល មិនបានដើរ សូមឲ្យបានទទួលនូវសេចក្តីសុខ សេចក្តីចម្រើនគ្រប់ៗគ្នា ហើយសូមអនុញ្ញាតបញ្ចូលពាក្យរបស់ ស្វាមីបុត្រី ជាតិខណ្ឌៀ អ្នកនិពន្ធ សៀវភៅ បរលោកវិជ្ជា បកពោលទុកក្នុងទីនេះ មិនដូចជាពាក្យរបស់ អ្នកនិពន្ធសៀវភៅថា :

សូមឲ្យអ្នកដែលមានជម្ងឺឈឺចាប់ទាំងប៉ុន្មាន ឲ្យបានជាស្រឡះពីជម្ងឺទាំងនោះ ឲ្យមានកងកាយមាំមួនបរិបូណ៌ឡើងវិញ ។

សូមឲ្យមនុស្សដែលទន់គ្មានកំឡាំង ឲ្យមានកំឡាំងមាំមួនឡើង ។

សូមឲ្យមនុស្សដែលក្រខ្សត់ ឲ្យបានជាអ្នកមានសម្បត្តិមាំមួនឡើង ។

សូមឲ្យមនុស្សដែលមានសេចក្តីទុញថប់ ត្រឡប់ជាអ្នកមានក្សាយាមឡើង ។

សូមឲ្យមនុស្សដែលមានចិត្តអាក្រក់ ត្រឡប់ជាមនុស្សមានចិត្តមេត្តាយ៉ាងល្អឡើង ។

សូមឲ្យមនុស្សដែលត្រូវគេស្អប់ ត្រឡប់ជាមនុស្សមានគេស្រឡាញ់រាប់អានឡើង ។

សូមឲ្យមនុស្សដែលមានចិត្តប្រឡាក់ប្រឡូស ដោយមន្ទិលផ្សេងៗ លាងមន្ទិលក្នុងខ្លួន ឲ្យបានជាមនុស្សបរិសុទ្ធិឡើង ។

អវសាន

# បញ្ជីសៀវភៅដែលព្រះរាជបណ្ណាល័យបោះពុម្ពផ្សាយ

| | |
|---|---|
| អព្ភូកោសកថា . . . . . . . . . . . . . . . . . . . . . . . | ១ សៀវភៅថ្លៃ ០, ០៥ |
| អត្តានុសាសនី . . . . . . . . . . . . . . . . . . . . . | — ០, ១០ |
| អនត្តលក្ខណសូត្រ . . . . . . . . . . . . . . . . . . . | — ០, ១០ |
| អភិធម្មត្ថសង្គហ . . . . . . . . . . . . . . . . . . . | — ០, ៩០ |
| អំពីព្រះពុទ្ធសាសនា. . . . . . . . . . . . . . . . . . | — ១, ៥០ |
| អំពីក្រុកភាវនោរង្គ . . . . . . . . . . . . . . . . . . | — ០, ២៥ |
| កច្ចាយនូបត្ថម្ភ ក្បៀវ ១ . . . . . . . . . . . . . . . . | — ០, ៨០ |
| 〃 〃 ក្បៀវ ២ . . . . . . . . . . . . . . . . . . . | — ១, ៤០ |
| កាឡាមសូត្រនិងបរាភវសូត្រ . . . . . . . . . . . . . . | — ០, ១៥ |
| គតិលោក ក្បៀវ ១ . . . . . . . . . . . . . . . . . . . | — ០, ១៥ |
| គិរិមានន្ទសូត្រ . . . . . . . . . . . . . . . . . . . | — ០, ០៧ |
| គំហើបវិចក្ខិពិត្តារ . . . . . . . . . . . . . . . . . . | — ០, ៤៥ |
| ជយវរ្ម័ន ទី ៧ (អក្សរខ្មែរ) ក្រដាសស្តើង . . . . . . . . . . | — ០, ១០ |
| 〃 〃 ( 〃 ) ក្រដាសក្រាស់ . . . . . . . . . . . | — ០, ១០ |
| ជយវរ្ម័ន ទី ៧ (អក្សរបារាំង) . . . . . . . . . . . . . | — ០, ៣០ |
| ដំណាលពុទ្ធចេតិយ . . . . . . . . . . . . . . . . . . | — ០, ៨០ |
| ទសបារមីកថា . . . . . . . . . . . . . . . . . . . . | — ០, ៣០ |
| ទស្សនាវដ្តី (មួយឆ្នាំ) . . . . . . . . . . . . . . . . | — ៤, ០០ |
| ធម្មបទដ្ឋកថា. . . . . . . . . . . . . . . . . . . . | — ០, ៦៥ |
| ធម្មប្រទីប . . . . . . . . . . . . . . . . . . . . . | — ០, ៤០ |



www.elibraryofcambodia.org

| | | |
|---|---|---|
| នាគោបមាទិកថា | • សៀវភៅថ្លៃ | ០១, ០៨ |
| បាយាសិរាជញ្ញសូត្ត | — | ០, ០៨ |
| បុណ្ណោវាទសូត្ត | — | ០, ០២ |
| ព្រះត្រៃបិដក (បាលីនិងប្រែ) ១ ឈុំចំនួន ១០០ សៀវភៅ | — | ២៥០, ០០ |
| ព្រះចង្កូមកែវ | — | ០ ១០ |
| ពុទ្ធោវាទានុសាសនី | — | ០, ១៥ |
| ពាក្យកាព្យក្រមង៉ុយ | — | ០, ០៦ |
| បទោបុព្វកថា | — | ០, ១៤ |
| មរណានុស្សតិ | — | ០, ២០ |
| មាតាបិតុឧបដ្ឋានកថា | — | ០, ៣៤ |
| មិលិន្ទបញ្ហា ខ្សែ ១ | — | ០, ៥០ |
| ខ្សែ ២ | — | ០, ៦០ |
| ១០០ គាថា | — | ០, ១០ |
| រឿង ១ ពាន់ ១ យប់ | — | ០, ០២ |
| វិជ្ជាចរណកថា | — | ០, ៣០ |
| វត្តាទយ | — | ០, ២៥ |
| សប្បុរិសធម៌ | — | ០, ០៤ |
| សត្តបរិត្តនិងទ្វាទសបរិត្ត | — | ០, ៤០ |
| សាសនកិច្ចានុក្រម ១២ ខ្សែ | — | ០, ៥០ |
| សីមាវិនិច្ឆ័យ | — | ០, ១០ |
| សុរាទោសកថា | — | ០, ០៥ |
| សុរិយាត្រឡើងស័ក | — | ០, ៣០ |
| សុភាសិតច្បាប់កាសិនី | — | ០, ៤០ |



www.elibraryofcambodia.org

| | | |
|---|---|---|
| សេចក្ដីដាស់តឿន | • សៀវភៅរៀល | ០, ០៦ |
| គិហិបដិបត្តិសង្ខេប | — | ០, ១៥ |
| បច្ចគណនាវិធី និងបច្ចសម្រេច | — | ០, ៣០ |
| សព្ពញ្ញូមហណ | — | ១, ២៥ |
| សីលធិខ្មែរ | — | ០, ៥០ |
| គតិលោកភាគ ២ | — | ០, ១២ |
| សការទេសនា | — | ០, ០៣ |
| បទានុក្រមបារេក្តី | — | ០, ០៨ |
| អក្សរខ្មែរជាប់និងរូបសព្ទ | — | ០, ៣០ |
| ប្រស្នាវិនយបិដកសង្ខេប | — | ១, ០០ |
| គតិលោកភាគ ៣ | — | ០, ១២ |
| រតនប្បភា | — | ០, ៤០ |
| ភាពគ្រឿងលក្ខណ ១ ភាគ | — | ០, ១០ |
| " លក្ខណ ១៧ ភាគ | — | ១, ៥០ |
| វិធីបក្ការបោត | — | ០ ០៣ |
| ទាយទបាតិហេតុ | — | ០, ៦០ |
| គោលសារបរិក្ខារ | — | ០, ១៥ |
| វចនានុក្រមខ្មែរ ក្របរឹង | — | ៩, ៥០ |
| " ក្របទន់ | — | ៧, ០០ |
| ពុទ្ធកេបកវិធី (បែបធម្មយុត្តិ) | — | ០, ៤០ |
| សាមណេរវិន័យ | — | ០, ៣០ |
| បញ្ហាអភិណ្ហប្បច្ចវេក្ខណៈ | — | ០, ១០ |
| សង្កាលោកទសូត្រ | — | ០, ៣០ |



www.elibraryofcambodia.org

| | | |
|---|---|---|
| អនុមោទនាវិធី ........................ | ១ សៀវភៅថ្លៃ | ០រ, ៤០ |
| ព្រះត្រៃលក្ខណ៍ និងសង្វេគវត្ថុ ................ | — | ០, ១០ |
| ពាក្យកាព្យថ្លែងរឿងពុទ្ធប្រវត្តិ ................ | — | ០, ០៨ |
| វិសេសសូត្រ .................... | — | ០, ១៨ |
| នានាជាតក ...................... | — | ០, ៦០ |



www.elibraryofcambodia.org

# រូបផ្តិតពុម្ពផ្សេងៗ

| | | |
|---|---|---|
| ព្រះពុទ្ធរូបមហាអគ្គសាវករួម (រចនាលោក) . . . . . . . . . . | ១ សន្លឹកថ្លៃ | ០រ, ០៥ |
| " និព្វាន . . . . . . . . . . . . . . . . . . . . . . | — | ០, ០៥ |
| " ៣ ព្រះរត្ន . . . . . . . . . . . . . . . . . . . | — | ០, ០៥ |
| " ហែនព្រះឥន្ទ្រនឹងព្រះព្រហ្មឈររអប . . . . . . . . . . | -- | ០, ០៥ |
| ព្រះរូបព្រះបាទសម្ដេច ព្រះស៊ីសុវត្ថិមុនីវង្ស ក្រដាសរឹង . . . . | — | ០, ១៥ |
| " " ក្រដាសទន់ . . . | — | ០, ០៦ |
| " ព្រះស៊ីសុវត្ថិ . . . . . . . . . . . . | — | ០, ២០ |
| " ព្រះកៅក្រុងកម្ពុជា ៤ ព្រះអង្គ . . . . . | — | ០, ១០ |
| រូបព្រះពុទ្ធបាទ ១ សន្លឹក . . . . . . . . . . . . . . . . . . | — | ០, ០៣ |
| រូបព្រះវេត្តកាសំពត់រឿងពុទ្ធប្រវត្តិ . . . . . . . . . . . . . . . | — | ០, ០៣ |
| រូបវេស្សន្តរជាតក ១៣ សន្លឹក ១ សន្លឹក . . . . . . . . . . . . . | — | ០, ០៦ |
| រូបតំនួរតេមិយជាតក ១០ សន្លឹក . . . . . . . . . . . . . . | — | ០, ១៥ |
| " មហាជនកជាតក ១០ សន្លឹក . . . . . . . . . . . . . | — | ០, ១៥ |
| " សុវណ្ណសាមជាតក ១០ សន្លឹក . . . . . . . . . . . | — | ០, ១៥ |
| ប្រក្រតិទិនឆ្នាំថ្មី . . . . . . . . . . . . . . . . . . . . . . | — | ០, ១៧ |



www.elibraryofcambodia.org

With bad advisors forever left behind,
From paths of evil he departs for eternity,
Soon to see the Buddha of Limitless Light
And perfect Samantabhadra's Supreme Vows.

The supreme and endless blessings
of Samantabhadra's deeds,
I now universally transfer.
May every living being, drowning and adrift,
Soon return to the Pure Land of
Limitless Light!

~The Vows of Samantabhadra~

I vow that when my life approaches its end,
All obstructions will be swept away;
I will see Amitabha Buddha,
And be born in His Western Pure Land of
Ultimate Bliss and Peace.

When reborn in the Western Pure Land,
I will perfect and completely fulfill
Without exception these Great Vows,
To delight and benefit all beings.

~The Vows of Samantabhadra
Avatamsaka Sutra~

www.elibraryofcambodia.org

យើងខ្ញុំជាកូន ខ្ចៅ យុនសំរ៉េង ខ្ចៅ យ៉ាតណៃ ខ្ចៅសុខផល ខ្ចៅ វិសាល ខ្ចៅ វ៉ាមុន
ខ្ចៅ ភារាជា ខ្ចៅ ចំរើន ខ្ចៅ ភារី

បានឧបត្ថម្ភការផ្សាយសៀវភៅនេះជា eBook
ដើម្បីឧទ្ទិសកុសលដល់វិញ្ញាណក្ខន្ធ ឧបាសក ខ្ចៅ ពាញ និង ឧបាសិកា ឈរ យឿន

ការផ្សាយសៀវភៅនេះជា eBook បានបង្កើតឡើងដោយ

**មូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ**

ដើម្បីបម្រើប្រយោជន៍ជាសាធារណៈ ដោយមិនគិតកម្រៃ

ស្កេន ជា eBook ដោយ ប៉ៅ ភារម្យ

មិថុនា ឆ្នាំ ២០១៥


បើលោក-លោកស្រីចង់បានសៀវភៅនេះ ឬអានបន្តទៅទៀត សូមទិញ ឬជាវពីអ្នកនិពន្ធ

ឬបណ្ណាគារដោយផ្ទាល់ដើម្បីគោរព "រក្សាសិទ្ធិ" របស់អ្នកនិពន្ធ។

យើងខ្ញុំ ពុំមានការព្រាស្រ័យទាក់ទង ដោយប្រភេទណាមួយជាមួយអ្នកនិពន្ធ ឬបណ្ណាគារទេ។


សូមអរគុណ

ខ្ចៅ យុនសំរ៉េង

ប្រធាន

មូលនិធិខ្មែរសម្រាប់ការសិក្សា

www.elibraryofcambodia.org